# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ ចតុក្កនិបាត
# ចតុត្ថភាគ
# ៤៣



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## AṄGUTTARANIKĀYA

## CATUKKANIPĀTA

## CATUTTHABHĀGA

## 43

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមឆ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
**This book is strictly for free distribution, it is not for sale.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

### ឧទាហរណ៍

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្កឹកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## អង្គុត្តរនិកាយ ចតុក្កនិបាត

## ចតុត្ថភាគ

## ៤៣

ព. ស. ២៤៩៦

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

## ចតុត្ថោ ភាគោ

## ចតុត្ថបណ្ណាសកោ

## ឥន្ទ្រិយវគ្គោ បឋមោ

[១] ចត្តារីមានិ ភិក្ខវេ ឥន្ទ្រិយានិ ។ កាតមានិ ចត្តារិ ។ សទ្ធិន្ទ្រិយំ វិរិយិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ[១] ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ឥន្ទ្រិយានីតិ ។

[២] ចត្តារីមានិ ភិក្ខវេ ពលានិ ។ កាតមានិ ចត្តារិ ។ សទ្ធាពលំ វិរិយពលំ សមាធិពលំ បញ្ញាពលំ[២] ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានីតិ ។

[៣] ចត្តារីមានិ ភិក្ខវេ ពលានិ ។ កាតមានិ ចត្តារិ ។ បញ្ញាពលំ វិរិយពលំ អនវជ្ជពលំ សង្គាហកពលំ[៣] ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានីតិ ។

---

១ ឱ. ម. សតិន្ទ្រិយំ សមាធិន្ទ្រិយំ ។ ២ ឱ. ម. សតិពលំ សមាធិពលំ ។ ៣ ឱ. សង្គាហាពលំ ។ ម. សង្គហាពលំ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ចតុក្កនិបាត

# ចតុត្ថភាគ

## ចតុត្ថបណ្ណាសក

## ឥន្ទ្រិយវគ្គទី ១

[១] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៤ ។ ឥន្ទ្រិយ ៤ គឺអ្វីខ្លះ ។ ឥន្ទ្រិយគឺសទ្ធា ១ ឥន្ទ្រិយគឺវីរិយៈ ១ ឥន្ទ្រិយគឺសមាធិ ១ ឥន្ទ្រិយគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៤ នេះឯង ។

[២] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំងគឺសទ្ធា ១ កម្លាំងគឺវីរិយៈ ១ កម្លាំងគឺសមាធិ ១ កម្លាំងគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។

[៣] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំងគឺបញ្ញា ១ កម្លាំងគឺវីរិយៈ ១ កម្លាំងគឺកម្មដែលមិនមានទោស ១ កម្លាំងគឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។

[៤] ចត្តារីមានិ ភិក្ខវេ ពលានិ ។ កតមានិ ចត្តារិ ។ សតិពលំ សមាធិពលំ អនវជ្ជពលំ សង្គាហកពលំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានីតិ ។

[៥] ចត្តារីមានិ ភិក្ខវេ ពលានិ ។ កតមានិ ចត្តារិ ។ បដិសង្ខានពលំ ភាវនាពលំ អនវជ្ជពលំ សង្គាហកពលំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានីតិ ។

[៦] ចត្តារីមានិ ភិក្ខវេ កប្បស្ស អសង្ខេយ្យានិ ។ កតមានិ ចត្តារិ ។ យទា ភិក្ខវេ កប្បោ សំវដ្ដោ តិដ្ឋតិ[១] តំ ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានីតិ វា ឯត្តកានិ វស្សសតានីតិ វា ឯត្តកានិ វស្សសហស្សានីតិ វា ឯត្តកានិ វស្សសតសហស្សានីតិ វា ។ យទា ភិក្ខវេ កប្បោ សំវដ្ដដ្ឋាយី[២] តិដ្ឋតិ តំ ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានីតិ វា ឯត្តកានិ វស្សសតានីតិ វា ឯត្តកានិ វស្សសហស្សានីតិ វា ឯត្តកានិ វស្សសតសហស្សានីតិ វា ។

---

១ ឱ. ម. កប្បោ សំវដ្ដតីតិ ទិស្សតិ ។ ២ ឱ. ម. សំវដ្ដោ ។

[៤] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំងគឺសតិ ១ កម្លាំងគឺសមាធិ ១ កម្លាំងគឺកម្មដែលមិនមានទោស ១ កម្លាំងគឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។

[៥] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ ។ កម្លាំង ៤ គឺអ្វីខ្លះ ។ កម្លាំងគឺការពិចារណាមុនហើយទើបធ្វើ ១ កម្លាំងគឺការចម្រើនកុសលដែលមិនទាន់មាន ឲ្យមានឡើង ១ កម្លាំងគឺកម្មដែលមិនមានទោស ១ កម្លាំងគឺការសង្គ្រោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៤ យ៉ាងនេះឯង ។

[៦] ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ (កាលដែលយូររាប់មិនបាន) នៃកប្បនេះមាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បសូន្យទៅ តាំងមានឡើង កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះវិនាសទៅ តាំងមានឡើង ក៏កម្រនឹងរាប់ថា ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណេះសែនឆ្នាំ ១ ។

យថា ភិក្ខវេ កប្បោ វិវដ្ដោ តិដ្ឋតិ[១] តំ ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានីតិ វា ឯត្តកានិ វស្សសតានីតិ វា ឯត្តកានិ វស្សសហស្សានីតិ វា ឯត្តកានិ វស្សសតសហស្សានីតិ វា ។ យថា ភិក្ខវេ កប្បោ វិវដ្ដដ្ឋាយី[២] តិដ្ឋតិ តំ ន សុករំ សង្ខាតុំ ឯត្តកានិ វស្សានីតិ វា ឯត្តកានិ វស្ស-សតានីតិ វា ឯត្តកានិ វស្សសហស្សានីតិ វា ឯត្តកានិ វស្សសតសហស្សានីតិ វា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កប្បស្ស អសង្ខេយ្យានីតិ ។

[៧] ទ្វេមេ ភិក្ខវេ រោគា ។ កតមេ ទ្វេ ។ កាយិកោ ច រោគោ ចេតសិកោ ច រោគោ ។ ទិស្សន្តិ ភិក្ខវេ សត្តា កាយិកេន រោគេន ឯកំ-បិ វស្សំ អរោគំ[៣] បដិជានមានា ទ្វេបិ វស្សានិ អរោគំ បដិជានមានា តីណិបិ វស្សានិ អរោគំ បដិជានមានា ចត្តារិបិ វស្សានិ អរោគំ បដិជា-នមានា បញ្ចបិ វស្សានិ អរោគំ បដិជានមានា

១ ឱ. ម. កប្បោ វិវដ្ដតីតិ ទិស្សតិ ។ ២ ឱ. ម. វិវដ្ដោ ។ ៣ ឱ. ម. អារោគ្យំ ។

ម្នាលភិក្ខុទាំងឡាយ កាលកប្បត្រឡប់ចម្រើន តាំងមានឡើងវិញ ក៏កម្រនឹងរាប់ថា ប៉ុណ្ណោះឆ្នាំ ប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណោះពាន់ឆ្នាំ ឬប៉ុណ្ណោះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះចម្រើនតាំងមានឡើង ក៏កម្រនឹងរាប់ថា ប៉ុណ្ណោះឆ្នាំ ប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណោះពាន់ឆ្នាំ ឬប៉ុណ្ណោះសែនឆ្នាំ ១ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យនៃកប្បមាន ៤ យ៉ាងនេះឯង ។

[៧] ម្នាលភិក្ខុទាំងឡាយ រោគនេះមាន ២ យ៉ាង ។ រោគ ២ យ៉ាងគឺអ្វីខ្លះ ។ គឺកាយិករោគ (រោគកាយ) ១ ចេតសិករោគ (រោគចិត្ត) ១ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ រមែងប្រាកដដោយកាយិករោគតែងប្តេជ្ញាថា មិនមានរោគអស់ ១ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ២ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៣ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៤ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៥ ឆ្នាំក៏មាន

ទសបិ វស្សានិ អរោគំ បដិជានមានា វីសំបិ វស្សានិ អរោគំ បដិជានមានា តឹសំបិ វស្សានិ អរោគំ បដិជានមានា ចត្តាឡីសំបិ វស្សានិ អរោគំ បដិជានមានា បញ្ញាសំបិ វស្សានិ អរោគំ បដិជានមានា វស្សសតំបិ ភិយ្យោបិ[1] អរោគំ បដិជានមានា ។ តេ ភិក្ខវេ សត្តា ទុល្លភា[2] លោកស្មឹ យេ ចេតសិកេន រោគេន មុហុត្តម្បិ អរោគំ បដិជានន្តិ អញ្ញត្រ ខីណាសវេហិ ។ ចត្តារោមេ ភិក្ខវេ បព្វជិតស្ស រោគា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ មហិច្ឆោ ហោតិ វិឃាតវា អសន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ។ សោ មហិច្ឆោ សមានោ វិឃាតវា អសន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន បាបិកំ ឥច្ឆំ បណិទហតិ អនវញ្ញប្បដិលាភាយ លាភសក្ការសិលោកប្បដិលាភាយ ។ សោ ឧដ្ឋហតិ ឃដតិ វាយមតិ អនវញ្ញប្បដិលាភាយ

---

១ ឱ. ភិយ្យោបីតិ ន ទិស្សតិ ។ ២ ម. សុទុល្លភា ។

តែងប្តេជ្ញាថា មិនមានរោគអស់ ១០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ២០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៣០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៤០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគអស់ ៥០ ឆ្នាំក៏មាន តែងប្តេជ្ញាថា មិនមានរោគលើសជាង ១០០ ឆ្នាំក៏មាន ។ ម្នាលភិក្ខុទាំងឡាយ តែថាសត្វទាំងនោះ ដែលប្តេជ្ញាថា មិនមានរោគដោយចេតសិក សូម្បីត្រឹមតែវេលាមួយស្របក់ប៉ុណ្ណោះ ក៏រកបានដោយកម្រក្នុងលោក វៀរលែងតែព្រះខីណាស្រព ។ ម្នាលភិក្ខុទាំងឡាយ រោគរបស់បព្វជិតនេះមាន ៤ យ៉ាង ។ រោគ ៤ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ។ កាលភិក្ខុនោះ មានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជ-បរិក្ខារ តាមមានតាមបានហើយ រមែងតាំងសេចក្តីប្រាថ្នាលាមក ដើម្បីបាននូវសេចក្តីថ្កុំថ្កើង ដើម្បីបានលាភសក្ការៈ និងសេចក្តីសរសើរ ១ ។ ភិក្ខុនោះ តែងប្រឹងប្រែង ខ្នះខ្នែង ព្យាយាម ដើម្បីបាននូវសេចក្តីថ្កុំថ្កើង

លាភសក្ការសិលោកប្បដិលាភាយ ។ សោ សង្ខាយ កុលានិ ឧបសង្កមតិ សង្ខាយ និសីទតិ សង្ខាយ ធម្មំ ភាសតិ សង្ខាយ ឧច្ចារបស្សាវំ សណ្ឋាបេតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បព្ពជិតស្ស រោគា ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ន មហិច្ឆា[១] ភវិស្សាម វិឃាតចិត្តា អសន្តុដ្ឋា[២] ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន ន បាបិកំ ឥច្ឆំ បណិទហិស្សាម អនញ្ញប្បដិលាភាយ លាភសក្ការសិលោកប្បដិលាភាយ ន ឧដ្ឋហិស្សាម ន ឃដយិស្សាម[៣] ន វាយមិស្សាម អនញ្ញប្បដិលាភាយ លាភសក្ការសិលោកប្បដិលាភាយ ខមា ភវិស្សាម សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ

---

១ ម. អប្បិច្ឆា ។ ២ ឱ. វិឃាតវន្តោ អសន្តុដ្ឋា ។ ម. អវិឃាតវន្តោ សន្តុដ្ឋា ។ ៣ ឱ. ម. ន ឃដិស្សាម ។

ដើម្បីបាននូវលាភសក្ការៈ និងសេចក្តីសរសើរ ១ ។ ភិក្ខុនោះ តែង ចូលទៅត្រកូល ដើម្បីឲ្យគេរាប់អាន អង្គុយនៅ (ក្នុងត្រកូល) ដើម្បីឲ្យគេរាប់អាន ពោលធម៌ (ក្នុងត្រកូល) ដើម្បីឲ្យគេរាប់អាន អត់ទ្រាំឧច្ចារៈបស្សាវៈ (ក្នុងត្រកូល) ដើម្បីឲ្យគេរាប់អាន ១ ។ ម្នាលភិក្ខុទាំងឡាយ ពាគរបស់បព្វជិតមាន ៤ យ៉ាងនេះឯង ។ ម្នាល ភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងមិនជាអ្នកប្រាថ្នា ច្រើន មានសេចក្តីចង្អៀតចង្អល់ចិត្តនៅជានិច្ច មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន នឹងមិនតាំងសេចក្តីប្រាថ្នាលាមក ដើម្បីបាននូវសេចក្តី ថ្កុំថ្កើង ដើម្បីបាននូវលាភសក្ការៈ និងសេចក្តីសរសើរ នឹងមិន ប្រឹងប្រែង ខ្នះខ្នែង ព្យាយាម ដើម្បីបាននូវសេចក្តីថ្កុំថ្កើង ដើម្បី បានលាភសក្ការៈនិងសេចក្តីសរសើរ នឹងជាអ្នកចេះអត់ទ្រាំ ចំពោះត្រជាក់ ក្តៅ សេចក្តីឃ្លាន ស្រេក សម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្តី ដែលអាក្រក់ជួជាតិ ជាអ្នក អត់ធ្មត់ ចំពោះវេទនាដែលកើតឡើង ក្នុងសរីរៈរាងកាយ ដែលជាទុក្ខ ក្លៀវក្លា ក្រហល់ក្រហាយ ខ្លោចផ្សា មិនត្រជាក់ចិត្ត មិនគាប់ចិត្ត

តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកា ភវិស្សាមាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា ចត្តារោ ធម្មេ អត្តនិ សមនុបស្សតិ និដ្ឋមេត្ថ គន្តព្វំ បរិហាយាមិ កុសលេហិ ធម្មេហិ បរិហានមេតំ វុត្តំ ភគវតា ។ កតមេ ចត្តារោ ។ រាគវេបុល្លតំ ទោសវេបុល្លតំ មោហវេបុល្លតំ គម្ភីរេសុ ខោ បនស្ស ឋានាឋានេសុ បញ្ញាចក្ខុំ នក្កមតិ ។ យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា ឥមេ ចត្តារោ ធម្មេ អត្តនិ សមនុបស្សតិ និដ្ឋមេត្ថ គន្តព្វំ បរិហាយាមិ កុសលេហិ ធម្មេហិ បរិហានមេតំ វុត្តំ ភគវតា ។

ដែលអាចនឹងផ្តក់យកជីវិតទៅបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[៨] ក្នុងទីនោះ ព្រះសារីបុត្តមានអាយុ បានហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យព្រះសារីបុត្តមានអាយុថា ម្នាលអាវុសោ ។ ព្រះសារីបុត្តមានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ ៤ ប្រការដែលមាននៅក្នុងខ្លួន គប្បីចូលចិត្តបានថា អាត្មាអញសាបសូន្យ ចាកកុសលធម៌ទាំងឡាយ ព្រោះការដែលមានធម៌ ៤ ប្រការនេះ នៅក្នុងខ្លួនន៉ុះ ព្រះមានព្រះភាគត្រាស់ហៅថា ជាសេចក្តីសាបសូន្យ ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺការដុះដាលរាគៈ ១ ការដុះដាលទោសៈ ១ ការដុះដាលមោហៈ ១ និងមិនមានបញ្ញាចក្ខុប្រព្រឹត្តទៅក្នុងឋានៈ និងអដ្ឋានៈដ៏ជ្រាលជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចាណាឃើញធម៌ ៤ ប្រការនេះ មាននៅក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញសាបសូន្យ ចាកកុសលធម៌ ព្រោះការដែលមានធម៌ ៤ ប្រការនេះនៅក្នុងខ្លួនន៉ុះ ព្រះមានព្រះភាគត្រាស់ហៅថាជាសេចក្តីសាបសូន្យ ។

៧

ចតុត្ថបណ្ណាសកេ ឥន្ទ្រិយវគ្គោ បឋមោ

យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា ចត្តារោ ធម្មេ អត្តនិ សមនុបស្សតិ និដ្ឋមេត្ថ គន្តព្វំ ន បរិហាយាមិ កុសលេហិ ធម្មេហិ អបរិហានមេតំ វុត្តំ ភគវតា ។ កតមេ ចត្តារោ ។ រាគតនុត្តំ ទោសតនុត្តំ មោហតនុត្តំ គម្ភីរេសុ ខោ បនស្ស ឋានាឋានេសុ បញ្ញាចក្ខុំ កមតិ ។ យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា ឥមេ ចត្តារោ ធម្មេ អត្តនិ សមនុបស្សតិ និដ្ឋមេត្ថ គន្តព្វំ ន បរិហាយាមិ កុសលេហិ ធម្មេហិ អបរិ-ហានមេតំ វុត្តំ ភគវតាតិ ។

[៩] ឯកំ សមយំ អាយស្មា អានន្ទោ កោ-សម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អញ្ញតរា ភិក្ខុនី អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេន អយ្យោ អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា មម វចនេន អយ្យស្ស អានន្ទស្ស បាទេ សិរសា វន្ទ

ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ ៤ ប្រការដែលមានក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញមិនសាបសូន្យ ចាកកុសលធម៌ទាំងឡាយ ព្រោះការដែលមានធម៌ ៤ ប្រការនេះ នៅក្នុងខ្លួននុ៎ះ ព្រះមានព្រះភាគត្រាស់ហៅថាជាសេចក្តីមិនសាបសូន្យ ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺការស្រោលស្តើងរាគៈ ១ ការស្រោលស្តើងទោសៈ ១ ការស្រោលស្តើងមោហៈ ១ មានបញ្ញាចក្ខុ ប្រព្រឹត្តទៅក្នុងឋានៈនិងអដ្ឋានៈដ៏ជ្រាលជ្រៅ ១ ។ ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ពិចារណាឃើញធម៌ទាំង ៤ ប្រការនេះ ដែលមាននៅក្នុងខ្លួន គប្បីចូលចិត្តថា អាត្មាអញមិនសាបសូន្យ ចាកកុសលធម៌ទាំងឡាយឡើយ ព្រោះការដែលមានធម៌ ៤ ប្រការនេះ នៅក្នុងខ្លួននុ៎ះ ព្រះមានព្រះភាគត្រាស់ហៅថាជាសេចក្តីមិនសាបសូន្យ ។

[៩] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ភិក្ខុនី ១ រូប បានហៅបុរសម្នាក់ មកបង្គាប់ថា នែបុរសអើយ ចូរអ្នកមកអាយ ចូរអ្នកចូលរកព្រះអានន្ទជាម្ចាស់ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះបាទា ព្រះអានន្ទជាម្ចាស់ ដោយត្បូងតាមពាក្យរបស់យើងថា

ឥត្ថន្នាមា ភន្តេ ភិក្ខុនី អាពាធិកិនី ទុក្ខិតា ពាឡ្ហគិលានា សា អយ្យស្ស អានន្ទស្ស បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អយ្យោ អានន្ទោ យេន ភិក្ខុនុបស្សយោ យេន សា ភិក្ខុនី តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវំ អយ្យេតិ ខោ សោ បុរិសោ តស្សា ភិក្ខុនិយា បដិស្សុណិត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯក-មន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ អានន្ទំ ឯតទវោច ឥត្ថន្នាមា ភន្តេ ភិក្ខុនី អាពាធិកិនី ទុក្ខិតា ពាឡ្ហគិលានា សា អយ្យស្ស អានន្ទស្ស បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អយ្យោ[១] អានន្ទោ យេន ភិក្ខុនុបស្សយោ យេន សា ភិក្ខុនី តេនុប-សង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ អាយស្មា អានន្ទោ តុណ្ហីភាវេន ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ[២] និវាសេត្វា បត្តចីវរមាទាយ

១ ឱ. ម. អាយស្មា ។ ២ ឱ. ម. បុព្វណ្ហសមយន្តិ ន ទិស្សតិ ។

បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុនីឈ្មោះនេះ មានអាពាធ ទទួលទុក្ខវេទនា ឈឺធ្ងន់ នាងក្រាបថ្វាយបង្គំព្រះបាទា ព្រះអានន្ទជាម្ចាស់ដោយត្បូងដូច្នេះ ហើយចូរទូលយ៉ាងនេះថា សូមព្រះអានន្ទជាម្ចាស់ករុណាចូលទៅសួរភិក្ខុនីនោះ ក្នុងសំណាក់ភិក្ខុនី ដោយអាស្រ័យសេចក្តីអនុគ្រោះផងចុះ ។ បុរសនោះ ក៏ទទួលពាក្យនាងភិក្ខុនីនោះថា ព្រះករុណានាងម្ចាស់ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ ទើបថ្វាយបង្គំព្រះអានន្ទមានអាយុ រួចអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ទើបទូលព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រព្រះករុណាដ៏ចម្រើន ភិក្ខុនីឈ្មោះនេះមានអាពាធ ទទួលទុក្ខវេទនា ឈឺធ្ងន់ នាងក្រាបថ្វាយបង្គំព្រះបាទាព្រះអានន្ទជាម្ចាស់ដោយត្បូងរួច នាងពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះអានន្ទជាម្ចាស់ ករុណាចូលទៅសួរភិក្ខុនីនោះ ក្នុងសំណាក់ភិក្ខុនី ដោយអាស្រ័យសេចក្តីអនុគ្រោះផងចុះ ។ ព្រះអានន្ទមានអាយុ ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ

យេន ភិក្ខុនូបស្សយោ តេនុបសង្កមិ ។ អស្សសា ខោ សា ភិក្ខុនី អាយស្មន្តំ អានន្ទំ ទូរតោ វ អាគច្ឆន្តំ ទិស្វា សសីសំ ចារុបិត្វា មញ្ចកេ និបជ្ជិ ។ អថខោ អាយស្មា អានន្ទោ យេន សា ភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ អាយស្មា អានន្ទោ តំ ភិក្ខុនឹ ឯតទវោច អាហារសម្ភូតោ អយំ ភគិនិ កាយោ អាហារំ និស្សាយ អាហារោ បហាតព្វោ តណ្ហាសម្ភូតោ អយំ ភគិនិ កាយោ តណ្ហំ និស្សាយ តណ្ហា បហាតព្វា មានសម្ភូតោ អយំ ភគិនិ កាយោ មានំ និស្សាយ មានោ បហាតព្វោ មេថុនសម្ភូតោ អយំ ភគិនិ កាយោ មេថុនោ បហាតព្វោ មេថុនោ សេតុឃាតោ[1] វុត្តោ ភគវតា ។ អាហារសម្ភូតោ អយំ ភគិនិ កាយោ អាហារំ និស្សាយ អាហារោ បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភគិនិ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ

---

១ ឱ. ម. កាយោ មេថុនោ ច សេតុឃាតោតិ ទិស្សន្តិ ។

ហើយចូលទៅកាន់លំនៅនាងភិក្ខុនី ។ ឯភិក្ខុនីនោះ បានឃើញព្រះអានន្ទមានអាយុ និមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏សិងលើគ្រែដណ្តប់ទទូរទាំងក្បាល ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅត្រង់ទីដែលនាងភិក្ខុនីនោះនៅ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលទុក ។ លុះព្រះអានន្ទមានអាយុ គង់ហើយ ទើបនិយាយទៅនឹងនាងភិក្ខុនីនោះ ដូច្នេះថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញ ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យនូវតណ្ហាហើយ គប្បីលះតណ្ហាចេញ ម្នាលនាង កាយនេះ កើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះមានះចេញ ម្នាលនាង កាយនេះ កើតមកដោយមេថុន បុគ្គលត្រូវលះបង់នូវមេថុនចេញ ព្រោះថាមេថុននោះ ព្រះមានព្រះភាគត្រាស់ថា ជាទោសសម្លាប់នូវហេតុ ។ ក៏ពាក្យដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញ ដូច្នេះនេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បរិភោគនូវអាហារ ពិចារណាដោយឧបាយ មិនបរិភោគដើម្បីលេងទេ មិនបរិភោគដើម្បីស្រវឹងទេ

១០



ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ សោ អបរេន សមយេន អាហារំ និស្សាយ អាហារំ បជហតិ ។ អាហារសម្ភូតោ អយំ ភគិនិ កាយោ អាហារំ និស្សាយ អាហារោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ តណ្ហាសម្ភូតោ អយំ ភគិនិ កាយោ តណ្ហំ និស្សាយ តណ្ហា បហាតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភគិនិ ភិក្ខុ សុណាតិ ឥត្ថន្នាមោ កិរ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

មិនបរិភោគដើម្បីប្រដាប់ទេ មិនបរិភោគដើម្បីស្អិតស្អាងទេ បរិភោគគ្រាន់តែដើម្បីតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់សេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ គឺបរិភោគដោយគិតថា អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង ទាំងមិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តទៅនៃឥរិយាបថ ៤ ក្តី ការមិនមានទោសគឺមិនច្រអូសកាយ មិនច្រអូសចិត្តក្តី ការនៅជាសុខក្តី នឹងមានដល់អាត្មាអញ ។ លុះសម័យខាងក្រោយមក ភិក្ខុនោះក៏អាស្រ័យអាហារហើយ លះបង់អាហារចេញ ។ ពាក្យណាដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយអាហារ បុគ្គលអាស្រ័យនូវអាហារហើយ គប្បីលះអាហារចេញដូច្នេះ ពាក្យនុ៎ះដែលយើងពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ក៏ពាក្យថា ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យនូវតណ្ហាហើយ គប្បីលះតណ្ហាចេញដូច្នេះនេះ យើងបានពោលហើយ ពាក្យនុ៎ះដែលយើងពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ។

១១

## ចតុត្ថបណ្ណាសកេ ឥន្ទ្រិយវគ្គោ បឋមោ

តស្ស ឯវំ ហោតិ កទាស្សុ នាម អហំបិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សាមីតិ ។ សោ អបរេន សមយេន តណ្ហំ និស្សាយ តណ្ហំ បជហតិ ។ តណ្ហាសម្ភូតោ អយំ ភគិនិ កាយោ តណ្ហំ និស្សាយ តណ្ហា បហាតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ មានសម្ភូតោ អយំ ភគិនិ កាយោ មានំ និស្សាយ មានោ បហាតព្វោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភគិនិ ភិក្ខុ សុណាតិ ឥត្ថន្នាមោ កិរ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ តស្ស ឯវំ ហោតិ សោ ហិ នាម អាយស្មា

ភិក្ខុនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹង ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ទាំងឡាយ ។ លុះសម័យខាងក្រោយមក ភិក្ខុនោះក៏អាស្រ័យនូវ តណ្ហាហើយ លះបង់តណ្ហាបាន ។ ពាក្យណាដែលយើងពោល ហើយថា ម្នាលនាង កាយនេះ កើតមកដោយតណ្ហា បុគ្គលអាស្រ័យ នូវតណ្ហាហើយ គប្បីលះតណ្ហាចេញដូច្នេះ ពាក្យនុ៎ះយើងបានពោល ហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលថា ម្នាលនាង កាយនេះ កើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះ មានះចេញដូច្នេះនេះ យើងបានពោលហើយ ពាក្យនុ៎ះ ដែលយើងពោល ហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលនាង ភិក្ខុក្នុងសាសនានេះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយ បញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ។ ភិក្ខុនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្បាលយ៉ាងលោកមានអាយុនោះ

១២



អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ កិមង្គំ បនាហន្តិ ។ សោ អបរេន សមយេន មានំ និស្សាយ មានំ បជហតិ ។ មានសម្ភូតោ អយំ ភគិនិ កាយោ មានំ និស្សាយ មានោ បហាតព្វោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ មេថុនសម្ភូតោ អយំ ភគិនិ កាយោ មេថុនោ បហាតព្វោ មេថុនោ សេតុឃាតោ[១] វុត្តោ ភគវតាតិ ។ អថខោ សា ភិក្ខុនី មញ្ចកា វុដ្ឋហិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា អាយស្មតោ អានន្ទស្ស បាទេសុ សិរសា និបតិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យាហំ ឯវមកាសឹ តស្សា មេ ភន្តេ អយ្យោ អានន្ទោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

---

១ ឱ. ម. កាយោ មេថុនោ ច សេតុឃាតោតិ ទិស្សន្តិ ។

បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ចំណែកអាត្មាអញ ចាំបាច់និយាយធ្វើអ្វី ។ លុះសម័យខាងក្រោយមក ភិក្ខុនោះអាស្រ័យមានះ ហើយលះបង់មានះបាន ។ ពាក្យណាដែលយើងពោលហើយថា ម្នាលនាង កាយនេះ កើតមកដោយមានះ បុគ្គលអាស្រ័យនូវមានះហើយ គប្បីលះមានះចេញដូច្នេះ ពាក្យនុ៎ះយើងបានពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលនាង កាយនេះ កើតមកដោយមេថុន បុគ្គលត្រូវលះបង់នូវមេថុនចេញ ព្រោះមេថុននោះ ព្រះមានព្រះភាគត្រាស់ថាជាទោស តែងសម្រាប់នូវហេតុ ។ លំដាប់នោះ នាងភិក្ខុនីនោះ ក្រោកអំពីគ្រែហើយ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបចុះទៀបព្រះបាទានៃព្រះអានន្ទមានអាយុដោយសិរសា ហើយពោលខមាទោស នឹងព្រះអានន្ទមានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទោសកំហុសត្រូវនូវខ្ញុំម្ចាស់ហើយ ដោយខ្ញុំម្ចាស់ជាស្ត្រីល្ងង់ ជាស្ត្រីវង្វេង ជាស្ត្រីមិនឈ្លាសវៃយ៉ាងណា ខ្ញុំម្ចាស់ឯណាបានធ្វើអំពើយ៉ាងនេះ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះអានន្ទជាម្ចាស់ អត់នូវទោសកំហុស តាមទោសកំហុសដល់ខ្ញុំម្ចាស់នោះ ដើម្បីនឹងសង្រួមតទៅ ។

តត្ថ តំ ភគិនិ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យា ត្វំ ឯវមកាសិ យតោ ច ខោ ត្វំ ភគិនិ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិហេសា ភគិនិ អរិយស្ស វិនយេ យា(១) អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។

[១០] សុគតោ វា ភិក្ខវេ លោកេ តិដ្ឋមានោ សុគតវិនយោ វា តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ច ភិក្ខវេ សុគតោ ។ ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ

---

១ ឱ. ម. យោ ។

ព្រះអានន្ទតបថា អើនាង ទោសកំហុសត្រូវនាងហើយ ដោយសារនាងជាស្ត្រីល្ងង់ ជាស្ត្រីវង្វេង ជាស្ត្រីមិនឈ្លាសវៃយ៉ាងណា នាងបានធ្វើអំពើយ៉ាងនេះ ម្នាលនាង កាលណាបើនាងឃើញទោសកំហុសតាមទោសកំហុស ហើយសម្តែងឲ្យសមគួរតាមធម៌ យើងនឹងទទួលទោសកំហុសនោះរបស់នាង ម្នាលនាង ស្ត្រីឯណាបានឃើញទោសកំហុស តាមទោសកំហុស ហើយសម្តែងឲ្យសមគួរតាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នោះជាសេចក្តីចម្រើន របស់ស្ត្រីនោះ ក្នុងវិន័យរបស់ព្រះអរិយៈ ។

[១០] ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅក្នុងលោក ការនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រះសុគតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើង ក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន

សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ អយំ ភិក្ខវេ សុគតោ ។ កតមោ ច ភិក្ខវេ សុគតវិនយោ ។ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ អយំ ភិក្ខវេ សុគតវិនយោ ។ ឯវំ[១] សុគតោ វា ភិក្ខវេ លោកេ តិដ្ឋមានោ សុគតវិនយោ វា តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

ចត្តារោមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខូ ទុគ្គហិតំ សុត្តន្តំ បរិយាបុណន្តិ ទុន្និក្ខិត្តេហិ បទព្យញ្ជនេហិ ទុន្និក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ ។

១ ឱ. ឯវំសទ្ទោ នត្ថិ ។

ព្រះអង្គជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹង នូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ ចុះវិន័យព្រះសុគតដូចម្តេច ។ ព្រះសុគតនោះ ទ្រង់សម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវិន័យព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅ ក្នុងលោកយ៉ាងនេះ ការនោះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀនខុស ដោយបទនិងព្យញ្ជនៈដែលរៀបរៀងខុសលំដាប់ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងខុសលំដាប់ រមែងយល់សេចក្តីបានដោយលំបាក ។

១៨

ចតុត្ថបណ្ណាសកេ ឥន្ទ្រិយវគ្គោ បឋមោ

អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ ទុព្ពចា ហោន្តិ ទោវចស្សករណេហិ ធម្មេហិ សមន្នាគតា អក្ខមា អប្បទក្ខិណគ្គាហិនោ អនុសាសនឹ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ យេតេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ ន សក្កច្ចំ សុត្តន្តំ បរំ វាចេន្តិ តេសំ អច្ចយេន ឆិន្នមូលកោ សុត្តន្តោ ហោតិ អប្បដិស្សរណោ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ថេរា ភិក្ខូ ពាហុលិកា ហោន្តិ សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាមនុស្សដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ មិនញុំាងបុគ្គលដទៃឲ្យរៀនព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះ ក៏ដាច់មូលលែងប្រតិស្ឋាននៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយ ជាថេរៈជាអ្នកប្រតិបត្តិ ដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់

តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ពាហុល្លិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ ចត្តារោមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខូ សុគ្គហិតំ សុត្តន្តំ បរិយាបុណន្តិ សុនិក្ខិត្តេហិ បទព្យញ្ជនេហិ សុនិក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ សុនយោ ហោតិ ។ អយំ ភិក្ខវេ បឋមោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខូ សុវចា ហោន្តិ

ប្រជុំនៃជនដែលកើតខាងក្រោយគឺ សទ្ធិវិហារិក និងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំនៃជនទាំងនោះឯង ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេសដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ធម៌ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះរៀនព្រះសូត្រ ដែលខ្លួនរៀនត្រូវ ដោយបទនិងព្យញ្ជនៈ ដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈ ដែលរៀបរៀងត្រូវរមែងយល់សេចក្តីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅងាយ

១៧

ចតុត្ថបណ្ណាសកេ ឥន្ទ្រិយវគ្គោ បឋមោ

សោវចស្សករណេហិ ធម្មេហិ សមន្នាគតា ខមា បទក្ខិណគ្គាហិនោ អនុសាសនឹ ។ អយំ ភិក្ខវេ ទុតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ សក្កច្ចំ សុត្តន្តំ បរំ វាចេន្តិ តេសំ អច្ចយេន អច្ឆិន្នមូលកោ សុត្តន្តោ ហោតិ សប្បដិស្សរណោ ។ អយំ ភិក្ខវេ តតិយោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ថេរា ភិក្ខូ ន ពាហុល្លិកា ហោន្តិ ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ន ពាហុល្លិកា ន សាថលិកា

ប្រកបដោយធម៌ ធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលនូវពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ញុំាងបុគ្គលដទៃឲ្យរៀននូវព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះ មិនបានដាច់ឫស តាំងនៅតៗ គ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈ មិនប្រតិបត្តិ ដើម្បីឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតខាងក្រោយ គឺសទ្ធិ-វិហារិកនិងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុទាំងនោះ ប្រជុំជនទាំងនោះឯង ជាអ្នកមិនប្រតិបត្តិឲ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ

១៨



ឱក្កមនេ និក្ខិត្តធុរា បវិវេកោ បុព្វង្គមា វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ អយំ ភិក្ខវេ ចតុត្ថោ ធម្មោ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។

ឥន្ទ្រិយវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ឥន្ទ្រិយានិ តិពលានិ
បញ្ញាសតិសង្ខាតំ បញ្ចមំ
កប្បោ រោគោ បរិហានិ ភិក្ខុនី
សុគតវិនយេន តេ ទសាតិ ។

ជាអ្នកដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ទាបបន្ថយ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាស សាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឲ្យវិនាស សាបសូន្យទៅ ។

ចប់ ឥន្ទ្រិយវគ្គ ទី ១ ។

## ឧទ្ទាននៃឥន្ទ្រិយវគ្គនោះគឺ

និយាយអំពីឥន្ទ្រិយ ១ អំពីពលៈ ៣ គឺ សទ្ធាពលៈ ១ បញ្ញាពលៈ ១ សតិពលៈ ១ និងបដិសង្ខានពលៈ ១ ជាគម្រប់ ៥ អំពីកប្ប ១ អំពីរោគ ១ អំពីការសាបសូន្យ ១ អំពីនាងភិក្ខុនី ១ អំពីព្រះសុគតនិងវិន័យរបស់ព្រះសុគត ១ រួមត្រូវជា ១០ ។

# បដិបទាវគ្គោ ទុតិយោ

[១១] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

[១២] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ កតមា ច ភិក្ខវេ ទុក្ខា បដិបទា ទន្ធាភិញ្ញា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បកតិយាបិ តិព្វរាគជាតិកោ ហោតិ អភិក្ខណំ រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ តិព្វទោសជាតិកោ ហោតិ អភិក្ខណំ ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ តិព្វមោហជាតិកោ ហោតិ អភិក្ខណំ មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

# បដិបទាវគ្គ ទី ២

[១១] ម្នាលភិក្ខុទាំងឡាយ បដិបទា (ការប្រតិបត្តិ) នេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែងត្រាស់ដឹងឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

[១២] ម្នាលភិក្ខុទាំងឡាយ បដិបទា នេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិបត្តិលំបាក តែត្រាស់ដឹងឆាប់ ១ ប្រតិបត្តិស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិបត្តិស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិបត្តិលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី ជាអ្នកមានរាគៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានទោសៈក្លៀវក្លា តែងទទួលទុក្ខទោ-មនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានមោហៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយ ៗ ។

តស្សិមានិ បញ្ចិន្ទ្រិយានិ មុទូនិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ មុទុត្តា ទន្ធំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខា បដិបទា ទន្ធាភិញ្ញា ។ កតមា ច ភិក្ខវេ ទុក្ខា បដិបទា ខិប្បាភិញ្ញា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បកតិយាបិ តិព្វរាគជាតិកោ ហោតិ អភិក្ខណំ រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ តិព្វទោសជាតិកោ ហោតិ អភិក្ខណំ ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ តិព្វមោហជាតិកោ ហោតិ អភិក្ខណំ មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ តស្សិមានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ខិប្បំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខា បដិបទា ខិប្បាភិញ្ញា ។ កតមា ច ភិក្ខវេ សុខា បដិបទា ទន្ធាភិញ្ញា ។

ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ ទន់ខ្សោយ បុគ្គលនោះ រមែងសម្រេចអនន្តរិយគុណ (មគ្គសមាធិដែលឲ្យផលជាលំដាប់) ដើម្បីអស់អាសវៈទាំងឡាយបាន យឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទលំបាក តែត្រាស់ដឹងឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី ជាអ្នកមានរាគៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី ជាអ្នកមានទោសៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយ បើតាមប្រក្រតី ជាអ្នកមានមោហៈក្លៀវក្លា តែងទទួលទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះគឺ សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ របស់បុគ្គលនោះ ក្លៀវក្លា ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ បុគ្គលនោះ រមែងសម្រេចអនន្ត-រិយគុណ ដើម្បីអស់អាសវៈទាំងឡាយ បានឆាប់ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ប្រតិប័ទលំបាក តែត្រាស់ដឹងឆាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ តើដូចម្តេច ។

២១

ចតុត្ថបណ្ណាសកេ បដិបទាវគ្គោ ទុតិយោ

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បកតិយាបិ ន តិព្វរាគជាតិកោ ហោតិ ន អភិក្ខណំ រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ ន តិព្វទោស-ជាតិកោ ហោតិ ន អភិក្ខណំ ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ ន តិព្វមោ-ហជាតិកោ ហោតិ ន អភិក្ខណំ មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ តស្សិមានិ បញ្ចិន្ទ្រិយានិ មុទូនិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ មុទុត្តា ទន្ធំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ សុខា បដិបទា ទន្ធាភិញ្ញា ។ កតមា ច ភិក្ខវេ សុខា បដិបទា ខិប្បាភិញ្ញា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ បកតិយាបិ ន តិព្វរាគជាតិកោ ហោតិ ន អភិក្ខណំ រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ បកតិយាបិ ន តិព្វទោសជាតិកោ ហោតិ ន អភិក្ខណំ ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី មិនមែនជាអ្នកមានរាគៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានទោសៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានមោហៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់បុគ្គលនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ បុគ្គលនោះក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្រួល ទាំងត្រាស់ដឹងក៏ឆាប់តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បើតាមប្រក្រតី មិនមែនជាអ្នកមានរាគៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ បើតាមប្រក្រតី មិនមែនជាអ្នកមានទោសៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយ ៗ

បកតិយាបិ ន តិព្វមោហជាតិកោ ហោតិ ន អភិក្ខណំ មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ តស្សិមានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ខិប្បំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

[១៣] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ កតមា ច ភិក្ខវេ ទុក្ខា បដិបទា ទន្ធាភិញ្ញា ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សុបដ្ឋិតា[១] ហោតិ ។

១ ម. សុបតិដ្ឋិតា ។

បើតាមប្រក្រតី មិនមែនជាអ្នកមានមោហៈក្លៀវក្លា តែងមិនទទួលទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ ឥន្ទ្រិយទាំង ៥ នេះ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ក្លៀវក្លា រមែងកើតប្រាកដដល់បុគ្គលនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ បុគ្គលនោះ រមែងសម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

[១៣] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិប័ទលំបាក តែត្រាស់ដឹងឆាប់ ១ ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញគ្រឿងមិនស្អាត ក្នុងកាយ កំណត់សេចក្តីបដិកូល ក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរ ក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះកំណត់សេចក្តីស្លាប់ តម្កល់ទុកដោយប្រពៃចំពោះខាងក្នុង ។

២៣

## ចតុត្ថបណ្ណាសកេ  បដិបទាវគ្គោ  ទុតិយោ

សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិមានិ បញ្ចិន្ទ្រិយានិ មុទូនិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ មុទុត្តា ទន្ធំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខា បដិបទា ទន្ធាភិញ្ញា ។ កតមា ច ភិក្ខវេ ទុក្ខា បដិបទា ខិប្បាភិញ្ញា ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សុបដ្ឋិតា ហោតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិមានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ

ភិក្ខុនោះ តែងអាស្រ័យសេក្ខពល (ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ) ៥ នេះគឺ សទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះនៅទន់ខ្សោយដែរ ភិក្ខុនោះ ក៏សម្រេចអនន្តរិយ-គុណ ដើម្បីអស់អាសវៈទាំងឡាយ បានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាត ក្នុងកាយ កំណត់សេចក្ដីបដិកូល ក្នុងអាហារ កំណត់សេចក្ដីមិនត្រេកអរ ក្នុងលោកទាំងពួងឃើញនូវសេចក្ដីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្ដីស្លាប់ តម្កល់ទុកដោយប្រពៃញ្ជ័ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពល (ធម៌ជាកម្លាំងរបស់ព្រះសេក្ខៈ) ៥ នេះគឺ សទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះ

ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ខិប្បំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខា បដិបទា ខិប្បាភិញ្ញា ។ កតមា ច ភិក្ខវេ សុខា បដិបទា ទន្ធាភិញ្ញា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧប-សម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្ប-សាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ

ក៏សម្រេចនូវអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទលំបាក តែត្រាស់ដឹងឆាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់នោះ ភិក្ខុនោះ ព្រោះស្ងប់ស្ងាត់ចាកវិតក្កៈវិចារៈ ក៏បានដល់ទុតិយ-ជ្ឈាន ជាធម្មជាត កើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ភិក្ខុ ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតី ដឹងខ្លួនដោយប្រពៃផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្ស ក្នុងកាលមុន

អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិមានិ បញ្ចិន្ទ្រិយានិ មុទូនិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ មុទុត្តា ជន្តំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ សុខា បដិបទា ទន្ធាភិញ្ញា ។ កតមា ច ភិក្ខវេ សុខា បដិបទា ខិប្បាភិញ្ញា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធា-ពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ

កំបានដល់នូវចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ភិក្ខុនោះតែងអាស្រ័យនូវសេក្ខពល ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាធម្មជាតទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ នៅទន់ខ្សោយដែរ ភិក្ខុនោះ កំសម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយ បានយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្រួលទាំងត្រាស់ដឹងក៏បានឆាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈាន ព្រោះស្ងប់ស្ងាត់ វិតក្កៈនិងវិចារៈ ។ បេ ។ កំដល់នូវទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។ បេ ។ កំដល់នូវតតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។ បេ ។ កំដល់នូវចតុត្ថជ្ឈាន ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល

តស្សិមានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ បាតុភវន្តិ សទ្ធិន្ទ្រិយំ វិរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ខិប្បំ អនន្តរិយំ បាបុណាតិ អាសវានំ ខយាយ ។ អយំ វុច្ចតិ ភិក្ខវេ សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

[១៤] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ។ អក្ខមា បដិបទា ខមា បដិបទា ទមា បដិបទា សមា បដិបទា ។ កតមា ច ភិក្ខវេ អក្ខមា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អក្កោសន្តំ បច្ចក្កោសតិ រោសន្តំ បដិរោសតិ ភណ្ឌន្តំ បដិភណ្ឌតិ ។ អយំ វុច្ចតិ ភិក្ខវេ អក្ខមា បដិបទា ។ កតមា ច ភិក្ខវេ ខមា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អក្កោសន្តំ ន បច្ចក្កោសតិ រោសន្តំ ន បដិរោសតិ ភណ្ឌន្តំ ន បដិភណ្ឌតិ ។ អយំ វុច្ចតិ ភិក្ខវេ ខមា បដិបទា ។

ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះ ក៏សម្រេចអនន្តរិយគុណ ដើម្បីអស់អាសវៈទាំងឡាយបានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

[១៤] ម្នាលភិក្ខុទាំងឡាយ បដិបទានេះ មាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទមិនអត់ធន់ ១ ប្រតិប័ទអត់ធន់ ១ ប្រតិប័ទទូន្មាន (ឥន្ទ្រិយ) ១ ប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទមិនអត់ធន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជេរតបនឹងបុគ្គលដែលជេរ ខឹងតបនឹងបុគ្គលដែលខឹង ប្រកួតប្រកាន់តបនឹងបុគ្គលដែលប្រកួតប្រកាន់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទមិនអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទអត់ធន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនជេរតបនឹងបុគ្គលដែលជេរ មិនខឹងតបនឹងបុគ្គលដែលខឹង មិនប្រកួតប្រកាន់តបនឹងបុគ្គលដែលប្រកួតប្រកាន់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទអត់ធន់ ។

២៧



កាតមា ច ភិក្ខវេ ឆមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុ-សលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិ-បជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិ-ន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ឆមា បដិបទា ។ កាតមា ច ភិក្ខវេ សមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ

ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទទូន្មាន (នូវឥន្ទ្រិយ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមភិក្ខុ ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្ដាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងធម្មារម្មណ៍ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុ ដែលជាអ្នកមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទទូន្មាន (នូវឥន្ទ្រិយ) ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្ដោយឲ្យកាមវិតក្កៈដែលកើតឡើងហើយ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់

សមេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ... ឧប្បន្នំ វិហឹសាវិតក្កំ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ សមេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ អយំ វុច្ចតិ ភិក្ខវេ សមា បដិបទា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

[១៨] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ។ អក្ខមា បដិបទា ខមា បដិបទា ទមា បដិបទា សមា បដិបទា ។ កតមា ច ភិក្ខវេ អក្ខមា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អក្ខមា ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកោ ហោតិ ។

រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន មិនបណ្តោយឲ្យព្យាបាទវិតក្កៈ ដែលកើតឡើងហើយ... មិនបណ្តោយឲ្យវិហឹសាវិតក្កៈ ដែលកើតឡើងហើយ... មិនបណ្តោយឲ្យអកុសលធម៌ទាំងឡាយ ដ៏អាក្រក់ ដែលកើតឡើងហើយរឿយៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) ។ ម្នាលភិក្ខុទាំងឡាយ បដិបទា មាន ៤ យ៉ាងនេះឯង ។

[១៥] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទមិនអត់ធន់ ១ ប្រតិប័ទអត់ធន់ ១ ប្រតិប័ទទូន្មាន (នូវឥន្ទ្រិយ) ១ ប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទមិនអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនអត់ធន់ចំពោះត្រជាក់ ក្តៅ សេចក្តីឃ្លាន ស្រេក ចំពោះសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្តីដែលអាក្រក់ជួជាតិ ជាអ្នកមិនអត់ធ្មត់ ចំពោះវេទនាដែលកើតឡើងក្នុងសរីរៈរាងកាយ ដែលជាទុក្ខក្លៀវក្លា ក្រហល់ក្រហាយ ខ្លោចផ្សា មិនត្រជាក់ចិត្ត មិនគាប់ចិត្ត ដែលអាចនឹងឆក់យកជីវិតទៅបាន ។

២៩



អយំ វុច្ចតិ ភិក្ខវេ អក្ខមា បដិបទា ។ កតមា ច ភិក្ខវេ ខមា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបា-សាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទ-នានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ខមា បដិបទា ។ កតមា ច ភិក្ខវេ ទមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា-ទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្ស-វេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទមិនអត់ធន់ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះប្រតិប័ទអត់ធន់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ពួកខ្លះ ក្នុងលោកនេះ ជាអ្នកអត់ធន់ ចំពោះត្រជាក់ ក្ដៅ សេចក្ដីឃ្លាន ស្រេក ចំពោះសម្ផស្សនៃរបោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំ ចំពោះពាក្យសម្ដី ដែលអាក្រក់ ជូជាតិ ជាអ្នកអត់ធ្មត់ ចំពោះ វេទនាដែលកើតឡើងក្នុងសរីរៈរាងកាយ ដែលជាទុក្ខក្លៀវក្លា ក្រហល់ ក្រហាយ ខ្លោចផ្សា មិនត្រជាក់ចិត្ត មិនគាប់ចិត្ត ដែលអាចនឹងផ្ដាច់ យកជីវិតទៅបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទទូន្មាន (នូវឥន្ទ្រិយ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំង ឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុ ដែលមិន សង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមចក្ខុន្ទ្រិយឯណា ប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុង ចក្ខុន្ទ្រិយ ឮនូវសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួល រសដោយអណ្ដាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងធម្មារម្មណ៍ ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ

យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ខមា បដិបទា ។ កតមា ច ភិក្ខវេ សមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ សមេតិ ព្យន្តីករោតិ អនភាវំ គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ... ឧប្បន្នំ វិហឹសាវិតក្កំ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ សមេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ អយំ វុច្ចតិ ភិក្ខវេ សមា បដិបទា ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

[១៦] ចតស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។

អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុ ដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយឯណា ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទទូន្មាន (នូវឥន្ទ្រិយ) ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្តោយឲ្យកាមវិតក្កៈ ដែលកើតឡើងហើយអាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន មិនបណ្តោយឲ្យព្យាបាទ-វិតក្កៈ ដែលកើតឡើងហើយ... មិនបណ្តោយឲ្យវិហឹសាវិតក្កៈដែលកើតឡើងហើយ... មិនបណ្តោយឲ្យអកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលកើតឡើងហើយរឿយៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ រម្ងាប់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រតិប័ទស្ងប់រម្ងាប់ (វិតក្កៈ) ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

[១៦] ម្នាលភិក្ខុទាំងឡាយ បដិបទានេះមាន ៤ យ៉ាង ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាក ទាំងត្រាស់ដឹង ក៏យឺតយូរ ១ ប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួល ទាំងត្រាស់ដឹង ក៏បានឆាប់ ១ ។

៣១



តត្រ ភិក្ខវេ យាយំ បដិបទា ទុក្ខា ទន្ធាភិញ្ញា អយំ ភិក្ខវេ បដិបទា ឧភយេនេវ ហីនា អក្ខាយតិ យម្បាយំ បដិបទា ទុក្ខា ឥមិនាបាយំ ហីនា អក្ខាយតិ យម្បាយំ បដិបទា ទន្ធា ឥមិនាបាយំ ហីនា អក្ខាយតិ ។ អយំ ភិក្ខវេ បដិបទា ឧភយេនេវ ហីនា អក្ខាយតិ ។ តត្រ ភិក្ខវេ យាយំ បដិបទា ទុក្ខា ខិប្បាភិញ្ញា អយំ ភិក្ខវេ បដិបទា ទុក្ខត្តា ហីនា អក្ខាយតិ ។ តត្រ ភិក្ខវេ យាយំ បដិបទា សុខា ទន្ធាភិញ្ញា អយំ ភិក្ខវេ បដិបទា ទន្ធត្តា ហីនា អក្ខាយតិ ។ តត្រ ភិក្ខវេ យាយំ បដិបទា សុខា ខិប្បាភិញ្ញា អយំ ភិក្ខវេ បដិបទា ឧភយេនេវ បណីតា អក្ខាយតិ យម្បាយំ បដិបទា សុខា ឥមិនាបាយំ បណីតា អក្ខាយតិ យម្បាយំ បដិបទា ខិប្បា ឥមិនាបាយំ បណីតា អក្ខាយតិ ។ អយំ ភិក្ខវេ បដិបទា ឧភយេនេវ បណីតា អក្ខាយតិ ។ ឥមា ខោ ភិក្ខវេ ចតស្សោ បដិបទាតិ ។

ម្នាលភិក្ខុទាំងឡាយ បណ្ដាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណា ទាំងមានសេចក្ដីលំបាក ទាំងត្រាស់ដឹងបានក៏យឺតយូរ ម្នាលភិក្ខុទាំងឡាយ បដិបទានេះ ចាត់ជាថោកទាប ដោយហេតុ ២ ស្ថាន គឺថាប្រតិប័ទលំបាក ចាត់ជាថោកទាប ដោយប្រតិប័ទលំបាក ១ ប្រតិប័ទត្រាស់ដឹងបានយឺតយូរ ចាត់ជាថោកទាប ដោយសេចក្ដីយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះចាត់ជាបដិបទាថោកទាប ដោយហេតុ ២ ស្ថាន ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណាលំបាក ត្រាស់ដឹងបានឆាប់ ម្នាលភិក្ខុទាំងឡាយ បដិបទានេះ ចាត់ជាថោកទាប ព្រោះសេចក្ដីលំបាក ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបដិបទាទាំង ៤ យ៉ាងនោះ បដិបទាណាស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ម្នាលភិក្ខុទាំងឡាយ បដិបទានេះចាត់ជាថោកទាប ព្រោះត្រាស់ដឹងយឺតយូរ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបដិបទាទាំង ៤ នោះ បដិបទាណាស្រួល ទាំងត្រាស់ដឹងក៏ឆាប់ ម្នាលភិក្ខុទាំងឡាយ បដិបទានេះចាត់ជាថ្លៃថ្លា ដោយហេតុ ២ ស្ថាន គឺថាប្រតិប័ទស្រួល ចាត់ជាថ្លៃថ្លាដោយប្រតិប័ទ ១ បដិបទាណា ត្រាស់ដឹងបានឆាប់ ចាត់ជាថ្លៃថ្លាដោយការត្រាស់ដឹងបានឆាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះចាត់ជាបដិបទាថ្លៃថ្លា ដោយហេតុ ២ ស្ថាន ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៤ យ៉ាងនេះឯង ។

[១៧] អថខោ អាយស្មា សារីបុត្តោ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាមោគ្គល្លានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ចតស្សោ ឥមា អាវុសោ មោគ្គល្លាន បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ អាវុសោ ចតស្សោ បដិបទា ។ ឥមាសំ អាវុសោ ចតស្សន្នំ បដិបទានំ កតមំ តេ បដិបទំ អាគម្ម អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ ចតស្សោ ឥមា អាវុសោ សារីបុត្ត បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ អាវុសោ ចតស្សោ បដិបទា ។

[១៧] គ្រានោះ ព្រះសារីបុត្តមានអាយុ ចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាមោគ្គល្លានមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ក៏បានពោលនឹងព្រះមហាមោគ្គល្លានមានអាយុថា ម្នាលអាវុសោមោគ្គល្លាន បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាក ទាំងត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិប័ទស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួលទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្តាបដិបទាទាំង ៤ នេះ ចិត្តអ្នកអាស្រ័យនូវបដិបទាណា ទើបរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោសារីបុត្តបដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាកទាំងត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិប័ទស្រួល តែទាស់ត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួលទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ានេះឯង ។

ឥមាសំ អាវុសោ ចតស្សន្នំ បដិបទានំ យាយំ បដិបទា ទុក្ខា ខិប្បាភិញ្ញា ឥមំ មេ បដិបទំ អាគម្ម អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

[១៨] អថខោ អាយស្មា មហាមោគ្គល្លានោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ចតស្សោ ឥមា អាវុសោ សារីបុត្ត បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ អាវុសោ ចតស្សោ បដិបទា ។ ឥមាសំ អាវុសោ ចតស្សន្នំ បដិបទានំ កតមំ តេ បដិបទំ អាគម្ម អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ ចតស្សោ ឥមា អាវុសោ មោគ្គល្លាន បដិបទា ។ កតមា ចតស្សោ ។ ទុក្ខា បដិបទា ទន្ធាភិញ្ញា

ម្នាលអាវុសោ បណ្តាបដិបទាទាំង ៤ នេះ ចិត្តខ្ញុំអាស្រ័យនូវបដិបទា ដែលជាប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់នេះ ទើបរួចចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។

[១៨] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏គង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះសារីបុត្តមានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត បដិបទានេះ មាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១ ប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួល ទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្តាបដិបទាទាំង ៤ នេះ ចិត្តអ្នកអាស្រ័យនូវបដិបទា ដែលនាំឲ្យរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោមោគ្គល្លាន បដិបទានេះមាន ៤ ។ បដិបទា ៤ គឺអ្វីខ្លះ ។ គឺប្រតិប័ទលំបាក ទាំងត្រាស់ដឹងក៏យឺតយូរ ១

ទុក្ខា បដិបទា ទិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញា ។ ឥមា ខោ អាវុសោ ចតស្សោ បដិបទា ។ ឥមាសំ អាវុសោ ចតស្សន្នំ បដិបទានំ យាយំ បដិបទា សុខា ខិប្បាភិញ្ញា ឥមំ មេ បដិបទំ អាគម្ម អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

[១៩] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទិដ្ឋេវ ធម្មេ សសង្ខារបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ កាយស្ស ភេទា សសង្ខារបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ ទិដ្ឋេវ ធម្មេ អសង្ខារបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ កាយស្ស ភេទា អសង្ខារបរិ-និព្វាយី ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ[១] ទិដ្ឋេវ ធម្មេ សសង្ខារបរិនិព្វាយី ហោតិ ។

១ ម. ឯកច្ចោ បុគ្គលោ ។

ប្រតិប័ទលំបាក តែត្រាស់ដឹងបានឆាប់ ១ ប្រតិប័ទស្រួល តែត្រាស់ដឹងយឺតយូរ ១ ប្រតិប័ទស្រួលទាំងត្រាស់ដឹងក៏បានឆាប់ ១ ។ ម្នាលអាវុសោ បដិបទាមាន ៤ យ៉ាងនេះឯង ។ ម្នាលអាវុសោ បណ្ដាបដិបទាទាំង ៤ នេះ ចិត្តខ្ញុំអាស្រ័យនូវបដិបទា ដែលជាប្រតិប័ទស្រួលទាំងត្រាស់ដឹងបានឆាប់នេះ ទើបរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[១៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមានប្រាកដនៅក្នុងលោក ។ បុគ្គល ៤ ពួក ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសសង្ខារបរិនិព្វាយី[១] ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអសង្ខារបរិនិព្វាយី[២] ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាសសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន តើដូចម្ដេច ។

១ បុគ្គលដែលដល់ព្រះអរហត្តប្រកបដោយសេចក្ដីព្យាយាម ហៅថា សសង្ខារបរិនិព្វាយី ។
២ បុគ្គលដែលដល់ព្រះអរហត្ត មិនបាច់ប្រកបដោយសេចក្ដីព្យាយាម ហៅថា អសង្ខារបរិនិព្វាយី ។ អដ្ឋកថា ។

ចតុត្ថបណ្ណាសកេ បដិបទាវគ្គោ ទុតិយោ

ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វលោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សុបដ្ឋិតា ហោតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិ-មានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ ចាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ទិដ្ឋេវ ធម្មេ សសង្ខារបរិនិព្វាយី ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ ទិដ្ឋេវ ធម្មេ សសង្ខារបរិនិព្វាយី ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ កាយស្ស ភេទា សសង្ខារ-បរិនិព្វាយី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អសុភានុបស្សី កាយេ វិហរតិ អាហារេ បដិក្កូលសញ្ញី សព្វ-លោកេ អនភិរតសញ្ញី សព្វសង្ខារេសុ អនិច្ចានុបស្សី មរណសញ្ញា ខោ បនស្ស អជ្ឈត្តំ សុបដ្ឋិតា ហោតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរ ក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្តីស្លាប់ តម្កល់ទុកដោយប្រពៃពួដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពល (ធម៌ជាកម្លាំងព្រះសេក្ខៈ) ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដ៏ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះក្លៀវក្លាដែរ ភិក្ខុនោះក៏ជាសសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្នយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញគ្រឿងមិនស្អាតក្នុងកាយ កំណត់សេចក្តីបដិកូលក្នុងអាហារ កំណត់សេចក្តីមិនត្រេកអរ ក្នុងលោកទាំងពួង ឃើញនូវសេចក្តីមិនទៀង ក្នុងសង្ខារទាំងពួង មួយទៀត ភិក្ខុនោះ កំណត់សេចក្តីស្លាប់ តម្កល់ទុកដោយប្រពៃពួដ៏ខាងក្នុង ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ

សទ្ធាពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិមានិ បញ្ចិន្ទ្រិយានិ មុទូនិ ចាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ មុទុត្តា កាយស្ស ភេទា សសង្ខារបរិនិព្វាយី ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ កាយស្ស ភេទា សសង្ខារបរិ-និព្វាយី ហោតិ ។ កថញ្ច ភិក្ខវេ បុគ្គលោ ទិដ្ឋេវ ធម្មេ អសង្ខារបរិនិព្វាយី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមានិ បញ្ច សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធា-ពលំ ហិរិពលំ ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ

គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយ ៥ នេះគឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះ នៅទន់ខ្សោយដែរ ភិក្ខុនោះ លុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលុះបែកធ្លាយរាងកាយទៅ ទើបជាសសង្ខារបរិនិព្វាយីយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ននេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈ វិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ។ ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល

តស្សិមានិ បញ្ចិន្ទ្រិយានិ អធិមត្តានិ ចាតុភវន្តិ សទ្ធិ-
ន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ
សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ អធិមត្តត្តា ទិដ្ឋេវ ធម្មេ
អសង្ខារបរិនិព្វាយី ហោតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ
ទិដ្ឋេវ ធម្មេ អសង្ខារបរិនិព្វាយី ហោតិ ។ កថញ្ច
ភិក្ខវេ បុគ្គលោ កាយស្ស ភេទា អសង្ខារបរិនិព្វាយី
ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។
បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូប-
សមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា
ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ
សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។ បេ ។
ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមានិ បញ្ច
សេក្ខពលានិ ឧបនិស្សាយ វិហរតិ សទ្ធាពលំ ហិរិពលំ
ឱត្តប្បពលំ វីរិយពលំ បញ្ញាពលំ តស្សិមានិ បញ្ចិន្ទ្រិ-
យានិ មុទូនិ ចាតុភវន្តិ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ
សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ សោ ឥមេសំ បញ្ចន្នំ ឥន្ទ្រិយានំ
មុទុត្តា កាយស្ស ភេទា អសង្ខារបរិនិព្វាយី ហោតិ ។

ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ដ៏ក្លៀវក្លា រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះឥន្ទ្រិយទាំង ៥ នេះ ក្លៀវក្លាដែរ ភិក្ខុនោះ ទើបជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអសង្ខារបរិនិព្វាយី ក្នុងបច្ចុប្បន្ន យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គល លុះតែបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។ បេ ។ ក៏ចូលកាន់ចតុត្ថជ្ឈាន ភិក្ខុនោះ តែងអាស្រ័យនូវសេក្ខពលទាំង ៥ នេះ គឺសទ្ធាពល ហិរិពល ឱត្តប្បពល វីរិយពល បញ្ញាពល ឥន្ទ្រិយទាំង ៥ នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ នៅទន់ខ្សោយ រមែងកើតប្រាកដដល់ភិក្ខុនោះ ព្រោះតែឥន្ទ្រិយទាំង ៥ នេះ នៅទន់ខ្សោយដែរ ភិក្ខុនោះ លុះបែកធ្លាយរាងកាយទៅ ទើបជាអសង្ខារបរិនិព្វាយី ។

ឯវំ ខោ ភិក្ខវេ បុគ្គលោ កាយស្ស ភេទា អសង្ខារបរិនិព្វាយី ហោតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[២០] ឯកំ សមយំ អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តត្រ ខោ អាយស្មា អានន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា មម សន្តិកេ អរហត្តប្បត្តឹ ព្យាករោតិ សព្វសោ ចតូហិ មគ្គេហិ ឯតេសំ វា អញ្ញតរេន ។ កតមេហិ ចតូហិ ។ ឥធាវុសោ ភិក្ខុ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ តស្ស សមថបុព្វង្គមំ វិបស្សនំ ភាវយតោ មគ្គោ សញ្ជាយតិ[១] ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។

១ ម. បញ្ញាយតីតិ ទិស្សតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលលុះតែបែកធ្លាយរាងកាយទៅ ទើបជា អសង្ខារបរិនិព្វាយី យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ទាំង ៤ ពួកនេះ រមែងមានប្រាកដនៅក្នុងលោក ។

[២០] សម័យមួយ ព្រះអានន្ទមានអាយុ នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ក្នុងទីនោះ ព្រះអានន្ទមានអាយុ បានហៅ ភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតបថេរវាចានៃព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទមានអាយុ ក៏បានពោលពាក្យដូច្នេះថា ម្នាលអាវុសោ ទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ព្យាករនូវ ការដល់ព្រះអរហត្ត ក្នុងសំណាក់ខ្ញុំ ដោយមគ្គទាំង ៤ ឬបណ្តាមគ្គ ទាំង ៤ នុ៎ះ មគ្គណាមួយ ដោយអាការទាំងពួង ។ មគ្គទាំង ៤ គឺអ្វីខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើន វិបស្សនា មានសមថៈជាប្រធាន កាលលោកចម្រើនវិបស្សនា មានសមថៈ ជាប្រធាន មគ្គក៏កើតឡើង ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើន នូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើនឡើងនូវមគ្គនោះ លោក ក៏អាចលះបង់សញ្ញោជនៈទាំងឡាយបាន ទាំងអនុស័យក៏អស់ទៅ ។

បុន ចបរំ អាវុសោ ភិក្ខុ វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ តស្ស វិបស្សនាបុព្វង្គមំ សមថំ ភាវយតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។ បុន ចបរំ អាវុសោ ភិក្ខុ សមថវិបស្សនំ យុគនទ្ធំ ភាវេតិ តស្ស សមថវិបស្សនំ យុគនទ្ធំ ភាវយតោ មគ្គោ សញ្ជា-យតិ ។ សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលី-ករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ ។ បុន ចបរំ អាវុសោ ភិក្ខុនោ ធម្មុទ្ធច្ច-វិគ្គហិតំ មានសំ[១] ហោតិ សោ អាវុសោ សមយោ យន្តំ ចិត្តំ អជ្ឈត្តំយេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ តស្ស មគ្គោ សញ្ជាយតិ ។

១ ឱ. ធម្មុទ្ធច្ចវិគ្គហិតមានា ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនសមថៈ មានវិបស្សនា ជាប្រធាន កាលលោកចម្រើនសមថៈ មានវិបស្សនា ជាប្រធាន មគ្គក៏កើតឡើង ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោ-ជនៈបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនសមថៈនិងវិបស្សនា ជាគូនឹងគ្នា កាលលោកចម្រើសមថៈនិងវិបស្សនា ជាគូនឹងគ្នា មគ្គក៏កើតឡើង ។ លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោជនៈបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ចិត្តរបស់ភិក្ខុដែលឧទ្ធច្ចៈ (វិបស្ស-នូបក្កិលេស ១០) ក្នុងសមថៈនិងវិបស្សនាធម៌ក្តួចកាន់មាំ ម្នាលអាវុសោទាំងឡាយ ដល់សម័យដែលចិត្តឈប់នឹង ស្ងប់ស្ងៀម មានអារម្មណ៍ខ្ពស់ឯក នៅខាងក្នុង ជាសមាធិ មគ្គរមែងកើតឡើងដល់ភិក្ខុនោះ ។

សោ តំ មគ្គំ អាសេវតិ ភាវេតិ ពហុលីករោតិ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីក-រោតោ សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តី-ហោន្តិ ។ យោ ហិ កោចិ អាវុសោ ភិក្ខុ វា ភិក្ខុនី វា មម សន្តិកេ អរហត្តប្បត្តឹ ព្យាករោតិ សព្វសោ ឥមេហិ ចតូហិ មគ្គេហិ ឯតេសំ វា អញ្ញតរេនាតិ ។

បដិបទាវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

សង្ខិត្តំ វិត្ថតំ អសុតំ[១]
ទ្វេ ខមា ឧភយេន[២] ច
មោគ្គល្លានោ សារីបុត្តោ សង្ខារំ
យុគនទ្ធេន ចាតិ ។

១ ឱ. អសុទំ (អសុភន្តិ យុត្តតរំ) ។ ២ ឱ. ទុតិយេន ច (ឧភយេន ចាតិ យុត្តតរំ) ។

លោកក៏បន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលបើលោកបន្ទុំ ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ លោកក៏អាចលះបង់សញ្ញោជនៈទាំងឡាយបាន ទាំងអនុស័យក៏អស់ទៅ ។ ម្នាលអាវុសោទាំងឡាយ សហធម្មិកឯណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី ព្យាករនូវការដល់ព្រះអរហត្ត ក្នុងសំណាក់ខ្ញុំ ដោយមគ្គទាំង ៤ នេះ ឬក៏បណ្តាមគ្គទាំង ៤ នោះ ដោយមគ្គណាមួយ ដោយអាការទាំងពួងបាន ។

ចប់ បដិបទាវគ្គ ទី ២ ។

## ឧទ្ទាននៃបដិបទាវគ្គនោះគឺ

និយាយអំពីបដិបទា ៤ យ៉ាងដោយសង្ខេប ១ អំពីបដិបទា ៤ យ៉ាងដោយពិស្តារ ១ អំពីបដិបទា ៤ យ៉ាង មានភិក្ខុពិចារណាឃើញថា មិនស្អាតជាដើម ១ អំពីបដិបទា ៤ យ៉ាង មានសេចក្តីអត់ធន់ជាដើម ២ លើក អំពីបដិបទារួមគ្នាដោយចំណែកពីរ ១ អំពីរឿងព្រះមោគ្គល្លាន ១ អំពីព្រះសារីបុត្ត ១ អំពីសសង្ខារបរិនិព្វាយីជាដើម ១ អំពីការចម្រើនសមថៈនិងវិបស្សនាជាគូនឹងគ្នា ១ ។

# សញ្ចេតនិយវគ្គោ តតិយោ

[២១] កាយេ វា ភិក្ខវេ សតិ កាយសញ្ចេតនាហេតុ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ វាចាយ វា ភិក្ខវេ សតិ វចីសញ្ចេតនាហេតុ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ មនេ វា ភិក្ខវេ សតិ មនោសញ្ចេតនាហេតុ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ អវិជ្ជាបច្ចយា វា ។ សាមំ វា តំ ភិក្ខវេ កាយសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ បរេ វាស្ស តំ ភិក្ខវេ កាយសង្ខារំ អភិសង្ខរោន្តិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ សម្បជានោ វា តំ ភិក្ខវេ កាយសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ អសម្បជានោ វា តំ ភិក្ខវេ កាយសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។

# សញ្ចេតនិយវគ្គ ទី ៣

[៦១] ម្នាលភិក្ខុទាំងឡាយ កាលបើកាយទ្វារ[១] មាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះកាយសញ្ចេតនា[២] ជាហេតុ ម្នាលភិក្ខុទាំងឡាយ កាលបើវចីទ្វារមាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះវចីសញ្ចេតនាជាហេតុ ម្នាលភិក្ខុទាំងឡាយ កាលបើមនោទ្វារមាន សុខទុក្ខជាខាងក្នុង រមែងកើតឡើង ព្រោះមនោ-សញ្ចេតនាជាហេតុ ឬ ព្រោះអវិជ្ជាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងកាយសង្ខារដោយខ្លួនឯង ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងកាយសង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្ដីដឹងច្បាស់[៣] តាក់តែងកាយ-សង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនមានសេចក្ដីដឹងច្បាស់ តាក់តែងកាយ-សង្ខារ ដែលជាបច្ច័យ នាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។

---

១ នឹងហៅថាកាយវិញ្ញត្តិដូច្នេះវិញក៏បាន ។ ២ ការសម្រេចនៃចេតនាក្នុងកាយទ្វារហៅថាកាយសញ្ចេតនាៗ នោះមាន ២០ គឺជាកាមាវចរកុសល ៨ ជាអកុសល ១២ ។ វចីសញ្ចេតនា និងមនោសញ្ចេតនា ក៏ដូចគ្នានឹងកាយសញ្ចេតនាដែរ ។ ៣ គឺដឹងច្បាស់នូវកុសលថាកុសលមែន បើជាអកុសលថាអកុសលមែន ដូច្នេះជាដើម ។ អដ្ឋកថា ។

សាមំ វា តំ ភិក្ខវេ វចីសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ បរេ វាស្ស តំ ភិក្ខវេ វចីសង្ខារំ អភិសង្ខរោន្តិ យំបច្ច-យាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ សម្បជានោ វា តំ ភិក្ខវេ វចីសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ អសម្បជានោ វា តំ ភិក្ខវេ វចីសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ សាមំ វា តំ ភិក្ខវេ មនោសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ បរេ វាស្ស ភិក្ខវេ មនោសង្ខារំ អភិសង្ខរោន្តិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ សម្បជានោ វា តំ ភិក្ខវេ មនោសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ អសម្បជានោ វា តំ ភិក្ខវេ មនោសង្ខារំ អភិសង្ខរោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ ឥមេសុ ភិក្ខវេ ធម្មេសុ អវិជ្ជា អនុបតិតា អវិជ្ជាយត្វេវ អសេសវិរាគនិរោធា

ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងវចីសង្ខារដោយខ្លួនឯង ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងវចីសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្ដីដឹងច្បាស់ តាក់តែងវចីសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលតាក់តែងមនោសង្ខារដោយខ្លួនឯង ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃតាក់តែងមនោសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្ដីដឹងច្បាស់ តាក់តែងមនោសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនមានសេចក្ដីដឹងច្បាស់ តាក់តែងមនោសង្ខារ ដែលជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជាតែងជាប់តាមទៅក្នុងធម៌ទាំងនេះ ព្រោះអវិជ្ជាវិនាសរលត់មិនមានសេសសល់

សោ កាយោ ន ហោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ សា វាចា ន ហោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ សោ មនោ ន ហោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ខេត្តំ ន ហោតិ... វត្ថុំ ន ហោតិ... អាយតនំ ន ហោតិ... អធិករណំ ន ហោតិ យំបច្ចយាស្ស តំ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។ ចត្តារោមេ ភិក្ខវេ អត្តភាវប្បដិលាភា ។ កតមេ ចត្តារោ ។ អត្ថិ ភិក្ខវេ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្តសញ្ចេតនា កមតិ នោ បរសញ្ចេតនា ។ អត្ថិ ភិក្ខវេ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ បរសញ្ចេតនា កមតិ នោ អត្តសញ្ចេតនា ។ អត្ថិ ភិក្ខវេ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្តសញ្ចេតនា ច កមតិ បរសញ្ចេតនា ច ។ អត្ថិ ភិក្ខវេ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ នេវ អត្តសញ្ចេតនា កមតិ នោ បរសញ្ចេតនា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អត្តភាវប្បដិលាភាតិ ។

កាយនោះ រមែងមិនជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន វាចានោះ រមែងមិនជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ចិត្តនោះ រមែងមិនជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ខេត្ត រមែងមិនមាន... វត្ថុរមែងមិនមាន... អាយតនៈរមែងមិនមាន... អធិករណ៍ រមែងមិនជាបច្ច័យនាំឲ្យសុខទុក្ខជាខាងក្នុង កើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាពនេះមាន ៤ យ៉ាង ។ ការបានអត្តភាព ៤ យ៉ាងដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែលសញ្ចេតនា របស់ខ្លួននាំទៅ មិនមែនជាសញ្ចេតនា របស់បុគ្គលដទៃ នាំទៅក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែល សញ្ចេតនា របស់បុគ្គលដទៃនាំទៅ មិនមែនជាសញ្ចេតនារបស់ខ្លួននាំទៅ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែលសញ្ចេតនា របស់ខ្លួននាំទៅផង សញ្ចេតនារបស់បុគ្គលដទៃនាំទៅផងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាព ដែលសញ្ចេតនា របស់ខ្លួន នាំទៅក៏មិនមែន សញ្ចេតនារបស់បុគ្គលដទៃនាំទៅក៏មិនមែនក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ការបានអត្តភាពមាន ៤ យ៉ាងនេះឯង ។

៤៤



ឯវំ វុត្តេ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ តត្រ ភន្តេ យ្វាយំ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្តសញ្ចេតនា កមតិ នោ បរសញ្ចេតនា អត្តសញ្ចេតនាហេតុ តេសំ សត្តានំ តម្ហា កាយា ចុតិ ហោតិ ។ តត្រ ភន្តេ យ្វាយំ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ បរសញ្ចេតនា កមតិ នោ អត្តសញ្ចេតនា បរសញ្ចេតនាហេតុ តេសំ សត្តានំ តម្ហា កាយា ចុតិ ហោតិ ។ តត្រ ភន្តេ យ្វាយំ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្បដិលាភេ អត្តសញ្ចេតនា ច កមតិ បរសញ្ចេតនា ច អត្តសញ្ចេតនា ច បរសញ្ចេតនា ច ហេតុ តេសំ សត្តានំ តម្ហា កាយា ចុតិ ហោតិ ។

លុះព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតដែលព្រះអង្គសម្តែងសង្ខេបនេះ ខ្ញុំព្រះអង្គអាចយល់សេចក្តីដោយពិស្តារបានយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅ មិនមែនជាសញ្ចេតនា របស់បុគ្គលដទៃនាំទៅ ការច្យុតចាកកាយនោះ របស់ពួកសត្វទាំងនោះ រមែងមាន ព្រោះសញ្ចេតនារបស់ខ្លួនជាហេតុ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនារបស់បុគ្គលដទៃនាំទៅ មិនមែនសញ្ចេតនា របស់ខ្លួននាំទៅ ការច្យុតចាកកាយនោះ របស់ពួកសត្វទាំងនោះ រមែងមាន ព្រោះសញ្ចេតនារបស់បុគ្គលដទៃជាហេតុ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនារបស់ខ្លួននាំទៅផង សញ្ចេតនារបស់បុគ្គលដទៃនាំទៅផង ការច្យុតចាកកាយនោះ របស់ពួកសត្វទាំងនោះ រមែងមាន ព្រោះសញ្ចេតនារបស់ខ្លួនជាហេតុផង ព្រោះសញ្ចេតនារបស់បុគ្គលដទៃជាហេតុផង ។

៤៨



តត្រ ភន្តេ យ្វាយំ អត្តភាវប្បដិលាភោ យស្មឹ អត្តភាវប្ប-
ដិលាភេ នេវ អត្តសញ្ចេតនា កមតិ នោ បរសញ្ចេ-
តនា កតមេ តេន ទេវា ទដ្ឋព្វាតិ ។ នេវសញ្ញានា-
សញ្ញាយតនូបគា សារីបុត្ត ទេវា តេន ទដ្ឋព្វាតិ ។
កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ
សត្តា តម្ហា កាយា ចុតា អាគាមិនោ ហោន្តិ
អាគន្តារោ ឥត្ថត្តំ ។ កោ បន ភន្តេ ហេតុ កោ
បច្ចយោ យេន មិធេកច្ចេ សត្តា តម្ហា កាយា
ចុតា អនាគាមិនោ ហោន្តិ អនាគន្តារោ ឥត្ថត្តន្តិ ។
ឥធ សារីបុត្ត ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ
សញ្ញោជនានិ អប្បហីនានិ ហោន្តិ សោ ទិដ្ឋេវ
ធម្មេ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ
សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ
អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី
អបរិហីនោ កាលំ កុរុមានោ នេវសញ្ញានា-
សញ្ញាយតនូបគានំ ទេវានំ សហព្យតំ ឧបបជ្ជតិ

បពិត្រព្រះអង្គដ៏ចម្រើន បណ្តាការបានអត្តភាពទាំង ៤ នោះ ការបានអត្តភាព ដែលសញ្ចេតនា របស់ខ្លួននាំទៅក៏មិនមែន សញ្ចេតនារបស់បុគ្គលដទៃនាំទៅក៏មិនមែន គេគប្បីឃើញថាបានដល់ទេវតាពួកណា ។ ម្នាលសារីបុត្ត គេឃើញថាបានដល់ទេវតា ដែលកើតក្នុងនេវសញ្ញា-នាសញ្ញាយតនៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតចាកកាយ (នេវសញ្ញានាសញ្ញាយតនៈ) នោះហើយ ជាអាគាមិបុគ្គល មកកាន់អត្តភាពនេះទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតចាកកាយនោះហើយជាអនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានលះបង់ឱរម្ភាគិយសញ្ញោជនៈ តែបុគ្គលនោះ ក៏បានសម្រេចនេវសញ្ញានាសញ្ញាយតនៈក្នុងបច្ចុប្បន្ន បុគ្គលនោះក៏ត្រេកអរនឹងឈាននោះ ពេញចិត្តនឹងឈាននោះ ដល់នូវសេចក្តីរីករាយនិងឈាននោះ កាលលោកតាំងនៅក្នុងឈាននោះ ចុះចិត្តស៊ប់ក្នុងឈាននោះ សម្រេចសម្រាន្តដោយឈាននោះយ៉ាងច្រើន មិនបានឲ្យសាបសូន្យចាកឈាននោះទៅវិញ លុះដល់ធ្វើមរណកាលទៅ តែងទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនៈ

សោ តតោ ចុតោ អាគាមី ហោតិ អាគន្តា ឥត្ថត្តំ ។ ឥធ បន សារីបុត្ត ឯកច្ចស្ស បុគ្គលស្ស ឱរម្ភាគិយានិ សញ្ញោជនានិ បហីនានិ ហោន្តិ សោ ទិដ្ឋេវ ធម្មេ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ នេវសញ្ញានាសញ្ញាយតនុបគានំ ទេវានំ សហព្យតំ ឧបបជ្ជតិ សោ តតោ ចុតោ អនាគាមី ហោតិ អនាគន្តា ឥត្ថត្តំ ។ អយំ ខោ សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា តម្ហា កាយា ចុតា អាគាមិនោ ហោន្តិ អាគន្តារោ ឥត្ថត្តំ អយំ បន សារីបុត្ត ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា តម្ហា កាយា ចុតា អនាគាមិនោ ហោន្តិ អនាគន្តារោ ឥត្ថត្តន្តិ ។

កាលបុគ្គលនោះ ច្យុតចាកភពនោះ ក៏ជាអាគាមិបុគ្គល មកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត បំណែកបុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់ឱរម្ភាគិយសញ្ញោជនៈ បុគ្គលនោះបានសម្រេចនេវសញ្ញានាសញ្ញាយតនៈក្នុងបច្ចុប្បន្ន បុគ្គលនោះក៏ត្រេកអរនឹងឈាននោះ ពេញចិត្តនឹងឈាននោះ ដល់នូវសេចក្តីរីករាយដោយឈាននោះ កាលលោកតាំងនៅក្នុងឈាននោះ ចុះចិត្តស៊ប់ក្នុងឈាននោះ សម្រេចសម្រាន្តដោយឈាននោះយ៉ាងច្រើន មិនបានសាបសូន្យចាកឈាននោះទៅវិញ លុះដល់ធ្វើមរណកាលទៅ តែងទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនៈ កាលបុគ្គលនោះច្យុតចាកភពនោះ ក៏ជាអនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។ ម្នាលសារីបុត្ត នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតចាកកាយនោះ បានជាអាគាមិ-បុគ្គល មកកាន់អត្តភាពនេះទៀត ម្នាលសារីបុត្ត នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ ច្យុតចាកកាយនោះ បានជាអនាគាមិបុគ្គល មិនមកកាន់អត្តភាពនេះទៀត ។

[២២] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច អឌ្ឍមាសុប-សម្បន្នេន មេ អាវុសោ អត្ថប្បដិសម្ភិទា សច្ឆិកតា ឱធិសោ ព្យញ្ជនសោ តមហំ អនេកបរិយាយេន អាចិក្ខាមិ ទេសេមិ[១] បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ ។ យស្ស ខោ បនស្ស កង្ខា វា វិមតិ វា សោ មំ បញ្ហេន អហំ វេយ្យាករណេន សម្មុខីភូតោ នោ សត្ថា យោ នោ ធម្មានំ សុកុសលោ ។ អឌ្ឍមាសុបសម្បន្នេន មេ អាវុសោ ធម្មប្បដិសម្ភិទា សច្ឆិកតា ឱធិសោ ព្យញ្ជនសោ តមហំ អនេកបរិយាយេន អាចិក្ខាមិ ទេសេមិ[២] បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ ។

១ ឱ. ម. ឯត្តន្តរេ បកាសេមីតិ អត្ថិ ។

ចតុត្ថបណ្ណាសក សញ្ចេតនិយវគ្គ ទី ៣

[២២] ក្នុងទីនោះ ព្រះសារីបុត្តមានអាយុ បានហៅពួកភិក្ខុមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលតបថេរវាចានៃព្រះសារីបុត្តមានអាយុថា ព្រះករុណា អាវុសោ ។ ទើបព្រះសារីបុត្តមានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ ក៏អាចធ្វើឲ្យជាក់ច្បាស់នូវអត្ថប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់នឹងសម្តែង នឹងធ្វើឲ្យយល់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវអត្ថប្បដិសម្ភិទានោះ ដោយអនេកបរិយាយបាន ។ បើអ្នកណាមានសេចក្តីសង្ស័យ ងឿងឆ្ងល់ អ្នកនោះ ចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឈ្លៀវឆ្លាស លើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ ក៏អាចធ្វើឲ្យជាក់ច្បាស់នូវធម្មប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំ នឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យយល់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវធម្មប្បដិសម្ភិទានោះ ដោយអនេកបរិយាយបាន ។

យស្ស ខោ បនស្ស កង្ខា វា វិមតិ វា សោ មំ បញ្ហេន អហំ វេយ្យាករណេន សម្មុខីភូតោ នោ សត្ថា យោ នោ ធម្មានំ សុកុសលោ ។ អឌ្ឍមាសុប-សម្បន្នេន មេ អាវុសោ និរុត្តិប្បដិសម្ភិទា សច្ឆិកតា ឱធិសោ ព្យញ្ជនសោ តមហំ អនេកបរិយាយេន អាចិក្ខាមិ ទេសេមិ[១] បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ ។ យស្ស ខោ បនស្ស កង្ខា វា វិមតិ វា សោ មំ បញ្ហេន អហំ វេយ្យាករណេន សម្មុខីភូតោ នោ សត្ថា យោ នោ ធម្មានំ សុកុសលោ ។ អឌ្ឍមាសុបសម្បន្នេន មេ អាវុសោ បដិភាណប្បដិសម្ភិទា សច្ឆិកតា ឱធិសោ ព្យញ្ជនសោ តមហំ អនេកបរិយាយេន អាចិក្ខាមិ ទេសេមិ[១] បញ្ញាបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមិ ។

១ ឱ. ម. ឯត្ថន្តរេ បកាសេមីតិ អត្ថិ ។

បើអ្នកណា មានសេចក្តីសង្ស័យឬងឿងឆ្ងល់ អ្នកនោះ ចូរសួរប្រស្នា នឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្ងៀវឆ្ងាស លើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ អាចធ្វើឲ្យជាក់ច្បាស់នូវនិរុត្តិប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់នឹងសម្តែង នឹងធ្វើឲ្យយល់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់នូវនិរុត្តិប្បដិសម្ភិទានោះដោយអនេកបរិយាយបាន ។ បើអ្នកណាមានសេចក្តីសង្ស័យឬងឿងឆ្ងល់ អ្នកនោះ ចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងអាចឆ្លើយដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្ងៀវឆ្ងាសលើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំទើបនឹងទទួលឧបសម្បទាបានកន្លះខែ អាចធ្វើឲ្យជាក់ច្បាស់នូវបដិភាណប្បដិសម្ភិទា ដោយចំណែក ដោយព្យញ្ជនៈបាន ខ្ញុំនឹងប្រាប់ នឹងសម្តែង នឹងធ្វើឲ្យយល់ច្បាស់ នឹងតាំងផ្តើម នឹងបើក នឹងចែក នឹងធ្វើឲ្យរាក់ នូវបដិភាណប្បដិសម្ភិទានោះ ដោយអនេកបរិយាយបាន ។

យស្ស ខោ បនស្ស កង្ខា វា វិមតិ វា សោ មំ បញ្ហេន អហំ វេយ្យាករណេន សម្មុខីភូតោ ហោ សត្ថា យោ នោ ធម្មានំ សុកុសលោតិ ។

[២៣] អថខោ អាយស្មា មហាកោដ្ឋិតោ យេនា-យស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នត្ថញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេស-វិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេស-វិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ។

បើអ្នកឯណាមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ អ្នកនោះចូរសួរប្រស្នានឹងខ្ញុំចុះ ខ្ញុំនឹងឆ្លើយដោះស្រាយ ទាន់ព្រះសាស្តាទ្រង់ឆ្ងៀវឆ្លាសលើសលុបក្នុងធម៌ទាំងឡាយ គង់នៅចំពោះមុខយើងទាំងឡាយស្រាប់ហើយ ។

[២៣] គ្រានោះ ព្រះមហាកោដ្ឋិតៈមានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហា-កោដ្ឋិតៈមានអាយុអង្គុយក្នុងទីសមគួរហើយ បានសួរព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយ-តនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានទេឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ ។

៨០



មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ។ យថាកថំ បនាវុសោ ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោតិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អប្បបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា

ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួចមិនមានឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ អ្នកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ចុះសេចក្តីនៃភាសិតនេះ គប្បីយល់បានដោយប្រការដូចម្តេច ។ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់

៨១



នត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អប្បបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ ឥតិ វទំ អប្បបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេស-វិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អប្បបញ្ចំ បបញ្ចេតិ ។ យាវតា អាវុសោ ឆន្នំ ផស្សាយតនានំ គតិ តាវតា បបញ្ចស្ស គតិ យាវតា បបញ្ចស្ស គតិ តាវតា ឆន្នំ ផស្សាយតនានំ គតិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា បបញ្ចនិរោធោ បបញ្ចវូបសមោតិ ។

[២៤] អថខោ អាយស្មា អានន្ទោ យេនា-យស្មា មហាកោដ្ឋិតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកោដ្ឋិតេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ

អ្វីដទៃតិចតួចមិនមាន ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះ ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែន ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ ។ ម្នាលអាវុសោ ផស្សាយតនៈទាំង ៦ នៅប្រព្រឹត្តទៅបានដរាបណា បបញ្ចធម៌ (ធម៌ជាគ្រឿងយឺតយូរ) ក៏មាននៅដរាបនោះ បបញ្ចធម៌ នៅប្រព្រឹត្តទៅបានដរាបណា ផស្សាយតនៈទាំង ៦ ក៏ប្រព្រឹត្តទៅបានដរាបនោះ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ បបញ្ចធម៌ក៏រលត់ទៅ បបញ្ចធម៌ក៏ស្ងប់ទៅ ។

[២៤] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅរកព្រះមហាកោដ្ឋិតៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះមហាកោដ្ឋិតៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ

អាយស្មន្តំ មហាកោដ្ឋិតំ ឯតទវោច ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នត្ថញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេស-វិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ។ មា ហេវំ អាវុសោ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ

ក៏បានសួរព្រះមហាកោដ្ឋិតៈមានអាយុ ដូច្នេះថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួចនៅមានដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះដែរឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ ។ ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច នៅមានដែរឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមានឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះ មិនមានខ្លះឬ

## ចតុត្ថបណ្ណាសកេ សញ្ចេតនិយវគ្គោ តតិយោ

ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ឥតិ បុដ្ឋោ សមានោ មា ហេវំ អាវុសោតិ វទេសិ ។ យថាកថំ បនាវុសោ ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោតិ ។ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អបបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អបបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា អត្ថិ ច នត្ថិ ចញ្ញំ កិញ្ចីតិ ឥតិ វទំ អបបញ្ចំ បបញ្ចេតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា នេវត្ថិ នោ នត្ថញ្ញំ កិញ្ចីតិ ឥតិ វទំ អបបញ្ចំ បបញ្ចេតិ ។ យាវតា អាវុសោ ឆន្នំ ផស្សាយតនានំ គតិ

លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ កាលខ្ញុំសួរថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែនឬ លោកពោលថា ម្នាលអាវុសោ អ្នកកុំសួរយ៉ាងនេះឡើយ ។ ម្នាលអាវុសោ ចុះសេចក្តីនៃភាសិតនេះ គប្បីយល់បានដោយប្រការដូចម្តេច ។ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មាន ឈ្មោះថាធ្វើធម៌ដែលមិនបានយឺតយូរ ឲ្យយឺតយូរ កាលពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មិនមាន ឈ្មោះថាធ្វើធម៌មិនបានយឺតយូរឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានខ្លះមិនមានខ្លះ ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ កាលបើពោលថា ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ អ្វីដទៃតិចតួច មានក៏មិនមែន មិនមានក៏មិនមែន ឈ្មោះថាធ្វើធម៌មិនបានយឺតយូរ ឲ្យយឺតយូរ ។ ម្នាលអាវុសោ ផស្សាយតនៈទាំង ៦ នៅប្រព្រឹត្តទៅបានដរាបណា

តាវតា បបញ្ចស្ស គតិ យាវតា បបញ្ចស្ស គតិ តាវតា ឆន្នំ ផស្សាយតនានំ គតិ ឆន្នំ អាវុសោ ផស្សាយតនានំ អសេសវិរាគនិរោធា បបញ្ចនិរោធោ បបញ្ចវូបសមោតិ ។

[២៩] អថខោ អាយស្មា ឧបវានោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបវានោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កិន្នុ ខោ អាវុសោ(១) វិជ្ជាយន្តករោ ហោតីតិ ។ នោ ហីទំ អាវុសោ ។ កឹ បនាវុសោ(១) ចរណេនន្តករោ ហោតីតិ ។ នោ ហីទំ អាវុសោ ។ កិន្នុ ខោ អាវុសោ(១) វិជ្ជាចរណេនន្តករោ ហោតីតិ ។ នោ ហីទំ អាវុសោ ។ កឹបនាវុសោ(១) អញ្ញត្រ វិជ្ជាចរណេនន្តករោ ហោតីតិ ។ នោ ហីទំ អាវុសោ ។

---

១ ឱ. ម ឯត្ថន្តរេ សារីបុត្តាតិ អត្ថិ ។

បបញ្ចធម៌ ក៏ប្រព្រឹត្តទៅបានដរាបនោះ បបញ្ចធម៌ នៅប្រព្រឹត្តទៅបានដរាបណា ផស្សាយតនៈទាំង ៦ ក៏នៅប្រព្រឹត្តទៅបានដរាបនោះ ម្នាលអាវុសោ ព្រោះផស្សាយតនៈទាំង ៦ វិនាសរលត់មិនមានសេសសល់ បបញ្ចធម៌ក៏រលត់ទៅ បបញ្ចធម៌ក៏ស្ងប់រម្ងាប់ទៅ ។

[២៥] គ្រានោះ ព្រះឧបវាន: មានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះឧបវាន: មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏បានសួរព្រះសារីបុត្តមានអាយុថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជាឬ ។ ម្នាលអាវុសោ ដំណើរនេះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជានិងចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជានិងចរណៈឬ ។ ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ ។

កិន្នុ ខោ អាវុសោ[១] វិជ្ជាយន្តករោ ហោតីតិ ឥតិ បុដ្ឋោ សមានោ នោ ហីទំ អាវុសោតិ វទេសិ កឹ បនាវុសោ[១] ចរណេនន្តករោ ហោតីតិ ឥតិ បុដ្ឋោ សមានោ នោ ហីទំ អាវុសោតិ វទេសិ កិន្នុ ខោ អាវុសោ[១] វិជ្ជាចរណេនន្តករោ ហោតីតិ ឥតិ បុដ្ឋោ សមានោ នោ ហីទំ អាវុសោតិ វទេសិ កឹ បនាវុសោ[១] អញ្ញត្រ វិជ្ជាចរណេនន្តករោ ហោតីតិ ឥតិ បុដ្ឋោ សមានោ នោ ហីទំ អាវុសោតិ វទេសិ ។ យថាកថំ បនាវុសោ អន្តករោ ហោតីតិ ។ វិជ្ជាយ ចេ អាវុសោ អន្តករោ អភវិស្ស សឧបាទានោវ សមានោ អន្តករោ អភវិស្ស ចរណេន ចេ អាវុសោ អន្តករោ អភវិស្ស សឧបាទានោវ សមានោ អន្តករោ អភវិស្ស វិជ្ជាចរណេន ចេ អាវុសោ អន្តករោ អភវិស្ស សឧបាទានោវ សមានោ អន្តករោ អភវិស្ស អញ្ញត្រ វិជ្ជាចរណេន ចេ អាវុសោ អន្តករោ អភវិស្ស បុថុជ្ជនោ

---

១ ឱ. ម. ឯត្ថន្តរេ សារីបុត្តាតិ អត្ថិ ។

កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជា អ្នកក៏ពោលថា ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជានិងចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ កាលខ្ញុំសួរថា ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជានិងចរណៈឬ អ្នកពោលថា ម្នាលអាវុសោ ដំណើរនេះមិនដូច្នោះទេ ។ ម្នាលអាវុសោ ចុះបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយប្រការដូចម្តេច ។ ម្នាលអាវុសោ បើបុគ្គលនឹងធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជាហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថាធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយចរណៈហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថាធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ដោយវិជ្ជានិងចរណៈហើយ បុគ្គលប្រកបដោយឧបាទាន ក៏ឈ្មោះថា នឹងធ្វើនូវទីបំផុតទុក្ខបាន ម្នាលអាវុសោ បើបុគ្គលធ្វើនូវទីបំផុតទុក្ខបាន ព្រោះវៀរចាកវិជ្ជានិងចរណៈហើយ បុថុជ្ជនក៏ឈ្មោះថានឹងធ្វើនូវទីបំផុតទុក្ខបាន

អន្ធកាបោ អកវិស្ស បុថុជ្ជនោ ហិ អាវុសោ អញ្ញត្រ វិជ្ជាចរណេន ចរណាវិបន្នោ ខោ អាវុសោ យថាភូតំ ន ជានាតិ ន បស្សតិ ចរណសម្បន្នោ យថាភូតំ ជានាតិ បស្សតិ យថាភូតំ ជានំ បស្សំ អន្ធកាបោ ហោតីតិ ។

[៦៦] សទ្ធោ ភិក្ខវេ ភិក្ខុ ឯវំ សម្មា អាយាចមានោ អាយាចេយ្យ តាទិសោ ហោមិ យាទិសា សារីបុត្តមោគ្គល្លានាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវកានំ ភិក្ខូនំ យទិទំ សារីបុត្តមោគ្គល្លានា[១] ។ សទ្ធា ភិក្ខវេ ភិក្ខុនី ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសា ហោមិ យាទិសា ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ចាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវិកានំ ភិក្ខុនីនំ យទិទំ ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ច ។ សទ្ធោ ភិក្ខវេ ឧបាសកោ ឯវំ សម្មា អាយាចមានោ អាយាចេយ្យ តាទិសោ ហោមិ យាទិសោ ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោតិ ។

១ ឱ. ឥតោ បរំ ឥតិសទ្ទោ ទិស្សតិ ។

ម្នាលអាវុសោ ព្រោះបុថុជ្ជនវៀរចាកវិជ្ជានិងចរណៈ ម្នាលអាវុសោ បុគ្គលប្រាសចាកចរណៈហើយ រមែងមិនដឹងមិនឃើញ តាមសេចក្តីពិតបាន បុគ្គលប្រកបដោយចរណៈហើយ រមែងដឹង រមែងឃើញ តាមសេចក្តីពិតបាន កាលបុគ្គលដឹងឃើញតាមសេចក្តីពិត ក៏រមែងធ្វើនូវទីបំផុតទុក្ខបាន ។

[២៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា កាលបើប្រាថ្នា (ធ្វើខ្លួន) ឲ្យត្រឹមត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណសម្បត្តិដូចជាព្រះសារីបុត្ត និងព្រះមោគ្គល្លាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសារីបុត្តនិងមោគ្គល្លានទុំនុះទុកជាជញ្ជីង ជាបែបផែនដល់ពួកភិក្ខុជាសាវ័ករបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណ-សម្បត្តិ ដូចជាខេមាភិក្ខុនី និងឧប្បលវណ្ណាភិក្ខុនី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខេមាភិក្ខុនីនិងឧប្បលវណ្ណាភិក្ខុនីនុំះ ទុកជាជញ្ជីងជាបែបផែនដល់ពួកភិក្ខុនីជាសាវិការបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញមានគុណសម្បត្តិ ដូចជាចិត្តគហបតីនិងហត្ថកអាឡវកៈ ។

ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវកានំ ឧបាសកានំ យទិទំ ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោ ។ សទ្ធា ភិក្ខវេ ឧបាសិកា ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសា ហោមិ យាទិសា ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវិកានំ ឧបាសិកានំ យទិទំ ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតាតិ ។

[២៧] អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាហុលំ ភគវា ឯតទវោច យា ច រាហុល អជ្ឈត្តិកា បឋវីធាតុ យា ច ពាហិរា បឋវីធាតុ បឋវីធាតុនេវេសា(១) តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា

១ ឱ. ម. បឋវីធាតុរេវេសា ។

ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តគហបតីនិងហត្ថកអាឡវកនុ៎ះ ទុកជាជញ្ជីងជាបែបផែន ដល់ពួកឧបាសក ជាសាវករបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាអ្នកមានសទ្ធា កាលបើប្រាថ្នាឲ្យត្រូវ គួរប្រាថ្នាយ៉ាងនេះថា សូមឲ្យអាត្មាអញ មានគុណសម្បត្តិ ដូចជាឧបាសិកាឈ្មោះខុជ្ជុត្តរា និងវេឡុកណ្ដកិយានន្ទមាតា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខុជ្ជុត្តរាឧបាសិកានិងវេឡុកណ្ដកិយានន្ទមាតានុ៎ះ ទុកជាជញ្ជីងជាបែបផែន ដល់ពួកឧបាសិកាជាសាវិកា របស់តថាគត ។

[២៧] គ្រានោះឯង ព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា នែរាហុល បឋវីធាតុដែលជាខាងក្នុងខ្លួននិងបឋវីធាតុជាខាងក្រៅនុ៎ះ ក៏ជាបឋវីធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញបឋវីធាតុនោះ គួរតាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញបឋវីធាតុនុ៎ះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ

បឋវីធាតុយា និព្វិន្ទតិ បឋវីធាតុយា[១] ចិត្តំ វិរាជេតិ ។ យា ច រាហុល អជ្ឈត្តិកា អាបោធាតុ យា ច ពាហិរា អាបោធាតុ អាបោធាតុរេវេសា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាបោធាតុយា និព្វិន្ទតិ អាបោធាតុយា ចិត្តំ វិរាជេតិ ។ យា ច រាហុល អជ្ឈត្តិកា តេជោធាតុ យា ច ពាហិរា តេជោធាតុ តេជោធាតុរេវេសា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា តេជោធាតុយា និព្វិន្ទតិ តេជោធាតុយា ចិត្តំ វិរាជេតិ ។ យា ច រាហុល អជ្ឈត្តិកា វាយោធាតុ យា ច ពាហិរា វាយោធាតុ វាយោធាតុរេវេសា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា

---

១ ឱ. បញ្ញាយ ។

រមែងធុញទ្រាន់ក្នុងបឋវីធាតុ រមែងញុំាងចិត្តឲ្យនឿយណាយក្នុងបឋវី-ធាតុ ។ នែរាហុល អាបោធាតុដែលជាខាងក្នុងនិងអាបោធាតុជាខាងក្រៅនុ៎ះ ក៏ជាអាបោធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញអាបោធាតុនោះគួរតាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញអាបោធាតុនុ៎ះតាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងអាបោធាតុ រមែងញុំាងចិត្តឲ្យនឿយណាយក្នុងអាបោធាតុ ។ នែរាហុល តេជោធាតុដែលជាខាងក្នុងនិងតេជោធាតុជាខាងក្រៅនុ៎ះ ក៏ជាតេជោ-ធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញតេជោធាតុ តាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញតេជោធាតុនុ៎ះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងធុញទ្រាន់ក្នុងតេជោធាតុ រមែងញុំាងចិត្តឲ្យនឿយណាយក្នុងតេជោធាតុ ។ នែរាហុល វាយោធាតុដែលជាខាងក្នុង និងវាយោធាតុជាខាងក្រៅនុ៎ះ ក៏ជាវាយោធាតុដូចគ្នាទេ ភិក្ខុត្រូវឃើញវាយោធាតុនុ៎ះ គួរតាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ លុះភិក្ខុឃើញវាយោធាតុនុ៎ះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ តាមហេតុយ៉ាងនេះហើយ

វាយោធាតុយា និព្ពិន្ទតិ វាយោធាតុយា ចិត្តំ វិរាជេតិ ។ យតោ ខោ រាហុល ភិក្ខុ ឥមាសុ ចតូសុ ធាតូសុ នេវត្តានំ នាត្តនិយំ សមនុបស្សតិ អយំ វុច្ចតិ រាហុល ភិក្ខុ អច្ឆេជ្ជិ[១] តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

[២៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ សក្កាយនិរោធំ មនសិករោតិ តស្ស សក្កាយនិរោធំ មនសិករោតោ សក្កាយនិរោធេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន អធិមុច្ចតិ តស្ស ខោ ឯតំ[២] ភិក្ខវេ ភិក្ខុនោ ន សក្កាយនិរោធោ បាដិកង្ខោ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ លបកតេន[៣] ហត្ថេន សាខំ គណ្ហេយ្យ តស្ស សោ ហត្ថោ សជ្ជេយ្យបិ គណ្ហេយ្យបិ ពជ្ឈេយ្យបិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ

១ ឱ. អច្ឆេច្ឆិ ។ ២ ម. ឯវំ ។ ៣ ឱ. លសគតេន ។

រមែងចុញទ្រាន់ក្នុងវាយោធាតុ រមែងញុំាងចិត្តឲ្យនឿយណាយ ក្នុងវាយោធាតុ ។ នែរាហុល ភិក្ខុពិចារណាឃើញច្បាស់នូវធាតុទាំង ៤ នេះថា មិនមែនខ្លួន មិនមែនកើតក្នុងខ្លួន ក្នុងកាលណា នែរាហុល ភិក្ខុនេះតថាគតហៅថា បានផ្តាច់ផ្តិលតណ្ហា គាស់រំលើងសញ្ញោជនៈធ្វើទីបំផុតទុក្ខបានហើយ ព្រោះត្រាស់ដឹងនូវការលះសេចក្តីប្រកាន់តាមហេតុ ។

[២៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង តែងមានក្នុងលោក ។ បុគ្គល ៤ ពួកដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិ[១]ដ៏ល្អិតណាមួយ ភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការរំលត់សក្កាយ កាលភិក្ខុនោះ កំពុងធ្វើទុកក្នុងចិត្តនូវការរំលត់សក្កាយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនស្ទុងចុះក្នុងការរំលត់សក្កាយ ម្នាលភិក្ខុទាំងឡាយ ការរំលត់សក្កាយនុ៎ះ របស់ភិក្ខុនោះ មិនគប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានដៃប្រឡាក់ជ័រស្អិត ចាប់មែកឈើ ដៃបុរសនោះស្អិតជ្ជក់ជាប់ យ៉ាងណាមិញម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ

១ សំដៅយកសមាបត្តិទាំង ៨ សមាបត្តិណាមួយ ។ អដ្ឋកថា ។

សោ សក្កាយនិរោធំ មនសិករោតិ តស្ស សក្កាយ-និរោធំ មនសិករោតោ សក្កាយនិរោធេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ធាធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ ន សក្កាយ-និរោធោ ចាដិកង្ខោ ។ ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ សក្កាយនិរោធំ មនសិករោតិ តស្ស សក្កា-យនិរោធំ មនសិករោតោ សក្កាយនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ សក្កាយនិរោធោ ចាដិកង្ខោ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សុទ្ធេន ហត្ថេន សាខំ គណ្ហេយ្យ តស្ស សោ ហត្ថោ នេវ សជ្ជេយ្យ ន គណ្ហេយ្យ ន ពជ្ឈេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ សក្កាយនិរោធំ មនសិករោតិ តស្ស សក្កាយនិរោធំ មនសិករោតោ សក្កាយនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ

ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ (ការរំលត់សក្កាយ) កាលបើលោកធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងសក្កាយនិរោធ ម្នាលភិក្ខុទាំងឡាយ សក្កាយ-និរោធនុ៎ះ របស់ភិក្ខុនោះឯង មិនគប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្ត នូវសក្កាយនិរោធ កាលបើលោកធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសក្កាយនិរោធ ម្នាលភិក្ខុទាំងឡាយ សក្កាយ-និរោធនុ៎ះរបស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានដៃស្អាតចាប់មែកឈើ ដៃរបស់បុរសនោះ មិនស្អិត មិនកាន់ មិនជាប់ទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ កាលបើលោកធ្វើទុកក្នុងចិត្ត នូវសក្កាយនិរោធ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងសក្កាយនិរោធ

៦១



តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ សក្កាយនិរោធោ បាដិកង្ខោ ។ ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ អវិជ្ជាបភេទំ មនសិករោតិ តស្ស អវិជ្ជាបភេទំ មនសិករោតោ អវិជ្ជាបភេទេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ ន អវិជ្ជាបភេទោ បាដិកង្ខោ ។ សេយ្យថាបិ ភិក្ខវេ ជម្ពាលី[១] អនេកវស្សគណិកា តសា បុរិសោ យានិ ចេវ អាយមុខានិ តានិ បិទហេយ្យ យានិ ច អបាយមុខានិ តានិ វិវរេយ្យ ទេវោ ច ន សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវំ ហិ តស្សា ភិក្ខវេ ជម្ពាលិយា ន អាលិប្បភេទោ[២] បាដិកង្ខោ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ អវិជ្ជាបភេទំ មនសិករោតិ តស្ស អវិជ្ជាបភេទំ មនសិករោតោ អវិជ្ជាបភេទេ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ ន អវិជ្ជាបភេទោ បាដិកង្ខោ ។

១ ជម្ពាឡី ឥតិបិ បាឋោ ។ ២ អដ្ឋកថាយំ បាឡិប្បភេទោតិ ទិស្សតិ ឯតំ ឯកត្ថមេវ ទដ្ឋព្វំ ។

ម្នាលភិក្ខុទាំងឡាយ សក្កាយនិរោធនុ៎ះ របស់ភិក្ខុនោះឯង គប្បីបាន តាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុក ក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយ អវិជ្ជា ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះ របស់ភិក្ខុនោះឯង មិនគប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចត្រពាំងដ៏ស្មោកគ្រោកដែលកើតឡើង រាប់ដោយឆ្នាំដ៏ច្រើន បុរសបិទមាត់រង្វះ សម្រាប់បង្ហូរចូលរបស់ត្រពាំងនោះ បើកមាត់រង្វះ សម្រាប់បង្ហូរចេញ ភ្លៀងសោតក៏មិនគប្បីបង្អុរធារទឹកដោយប្រពៃ ម្នាល ភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ការធ្លាយភ្លឺត្រពាំងនុ៎ះ ក៏មិនសម្រេច បាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិដ៏ល្អិត ណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោក ធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ការទម្លាយអវិជ្ជា នុ៎ះរបស់ភិក្ខុនោះឯង មិនគប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។

ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ អវិជ្ជាបភេទំ មនសិករោតិ តស្ស អវិជ្ជាបភេទំ មនសិករោតោ អវិជ្ជាបភេទេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ អវិជ្ជាបភេទោ បាដិកង្ខោ ។ សេយ្យថាបិ ភិក្ខវេ ជម្ពាលី អនេកវស្សគណិកា តស្សា បុរិសោ យានិ ចេវ អាយមុខានិ តានិ បិទហេយ្យ យានិ ច អបាយ-មុខានិ តានិ វិវរេយ្យ ទេវោ ច សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវំ ហិ តស្សា ភិក្ខវេ ជម្ពាលិយា អាលិប្បភេទោ បាដិកង្ខោ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អញ្ញតរំ សន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរតិ សោ អវិជ្ជាបភេទំ មនសិករោតិ តស្ស អវិជ្ជាបភេទំ មន-សិករោតោ អវិជ្ជាបភេទេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ តស្ស ខោ ឯតំ ភិក្ខវេ ភិក្ខុនោ អវិជ្ជាបភេទោ បាដិកង្ខោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះរបស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចត្រពាំងស្មោកគ្រោកដែលកើតឡើង រាប់ដោយឆ្នាំដ៏ច្រើន បុរសបើកមាត់រង្វះ សម្រាប់បង្ហូរចូលរបស់ត្រពាំងនោះ បិទមាត់រង្វះសម្រាប់បង្ហូរចេញ ភ្លៀងសោតក៏បង្អុរនូវធារទឹកដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ការធ្លាយភ្លឺត្រពាំងនោះ ក៏សម្រេចបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបានចេតោវិមុត្តិដ៏ល្អិតណាមួយ ភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា កាលបើលោកធ្វើទុកក្នុងចិត្តនូវការទម្លាយអវិជ្ជា ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ ក្នុងការទម្លាយអវិជ្ជា ម្នាលភិក្ខុទាំងឡាយ ការទម្លាយអវិជ្ជានុ៎ះរបស់ភិក្ខុនោះឯង គប្បីបានតាមប្រាថ្នា ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះឯង តែងមានក្នុងលោក ។

៦៣

ចតុត្ថបណ្ណាសកេ សញ្ចេតនិយវគ្គោ តតិយោ

[២៩] អថខោ អាយស្មា អានន្ទោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កោ នុ ខោ អាវុសោ សារីបុត្ត ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ ន បរិនិព្វាយន្តីតិ ។ ឥធាវុសោ អានន្ទ សត្តា ឥមា ហានភាគិយា សញ្ញាតិ យថាភូតំ នប្បជានន្តិ ឥមា ឋិតិភាគិយា សញ្ញាតិ យថាភូតំ នប្បជានន្តិ ឥមា វិសេសភាគិយា សញ្ញាតិ យថាភូតំ នប្បជានន្តិ ឥមា និព្វេធភាគិយា សញ្ញាតិ យថាភូតំ នប្បជានន្តិ ។ អយំ ខោ អាវុសោ អានន្ទ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ ន បរិនិព្វា-យន្តីតិ ។ កោ បនាវុសោ សារីបុត្ត ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ ឥធាវុសោ អានន្ទ សត្តា ឥមា

ចតុត្ថបណ្ណាសក សញ្ចេតនិយវគ្គ ទី ៣

[២៩] គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោ សារីបុត្ត ហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះមិនបរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោ អានន្ទ សត្វទាំងឡាយ ក្នុងលោកនេះ មិនដឹងតាមពិតថា នេះជាហានភាគិយសញ្ញា (សញ្ញាជាចំណែកវិនាស) មិនដឹងតាមពិតថា នេះជាឋិតិភាគិយសញ្ញា (សញ្ញាជាចំណែកតាំងនៅគឺស្មើដើម) មិនដឹងតាមពិតថា នេះជាវិសេសភាគិយសញ្ញា (សញ្ញាជាចំណែកវិសេសឡើង គឺបានចំណេញ) មិនដឹងតាមពិតថា នេះជានិព្វេធភាគិយសញ្ញា (សញ្ញាជាចំណែកត្រាស់ដឹង) ។ ម្នាលអាវុសោ អានន្ទ នេះជាហេតុ នេះជាបច្ច័យដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោ សារីបុត្ត ចុះហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកននេះ បរិនិព្វានក្នុងបច្ចុប្បន្នភពនេះ ។ ម្នាលអាវុសោ អានន្ទ សត្វទាំងឡាយ ក្នុងលោកនេះ

ហានភាគិយា សញ្ញាតិ យថាភូតំ បជានន្តិ ឥមា ឋិតិភាគិយា សញ្ញាតិ យថាភូតំ បជានន្តិ ឥមា វិសេសភាគិយា សញ្ញាតិ យថាភូតំ បជានន្តិ ឥមា និព្វេធភាគិយា សញ្ញាតិ យថាភូតំ បជានន្តិ ។ អយំ ខោ អាវុសោ អានន្ទ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។

[៣០] ឯកំ សមយំ ភគវា ភោគនគរេ វិហរតិ អានន្ទចេតិយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចត្តារោមេ ភិក្ខវេ មហាបទេសេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច ភិក្ខវេ ចត្តារោ មហាបទេសា ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ

បានដឹងច្បាស់តាមពិតថា នេះជាហានភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជាឋិតិភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជាវិសេសភាគិយសញ្ញា បានដឹងច្បាស់តាមពិតថា នេះជានិព្វេធភាគិយ-សញ្ញា ។ ម្នាលអាវុសោ អានន្ទ នេះឯងជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យសត្វពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្នភពនេះឯង ។

[៣០] សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងអានន្ទចេតិយ(១) ក្បែរភោគនគរ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមហាបទេស (គ្រឿងសម្រាប់អាងយ៉ាងធំ) ៤ យ៉ាងនេះ អ្នកទាំងឡាយ ចូរស្តាប់ភាសិតនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះមហាបទេស ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីនិយាយយ៉ាងនេះថា

១ វិហារជាទីនៅរបស់អានន្ទយក្ស ។ អដ្ឋកថា ។

៦៨

ចតុត្ថបណ្ណាសកេ សញ្ចេតនិយវគ្គោ តតិយោ

សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេ-តព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱតរន្តិ ន វិនយេ សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ច ភិក្ខុនោ ទុគ្គហិតន្តិ ឥតិ ហិទំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ

ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ មិនប្រជុំចុះ គឺមិនមានក្នុងសូត្រ ទាំងមិនឃើញប្រាកដក្នុងវិន័យផងទេ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះ ជាប្រាកដ ទំនងជាភិក្ខុនេះរៀនខុសទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវចោលពាក្យនេះ ដោយទំនងដូច្នេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា

តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ សុត្តេ ចេវ ឱតរន្តិ វិនយេ ច សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ច ភិក្ខុនោ សុគ្គហិតន្តិ ។ ឥទំ ភិក្ខវេ បឋមំ មហាបទេសំ ធារេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ សង្ឃោ វិហរតិ សត្ថេរោ សប្បាមោក្ខោ តស្ស មេ សង្ឃស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ បទនិងព្យញ្ជនៈទាំងនោះកាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ដោយពិត ជាពាក្យដែលភិក្ខុនេះរៀនត្រូវល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាបឋមនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្ដាប់ បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ

៦៧

ចតុក្កបណ្ណាសកេ សញ្ចេតនិយវគ្គោ តតិយោ

សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱតរន្តិ ន វិនយេ សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តស្ស ច សង្ឃស្ស ទុគ្គហិតន្តិ ឥតិ ហីទំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ សង្ឃោ វិហរតិ សត្ថេរោ សប្បាមោក្ខោ តស្ស មេ សង្ឃស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្ប-ដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយ-មានានិ សុត្តេ ចេវ ឱតរន្តិ វិនយេ ច សន្ទិស្សន្តិ

ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិង ព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រទាំងមិនឃើញមានប្រាកដក្នុងវិន័យផងទេ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ដោយពិត ទំនងជាសង្ឃនោះរៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចោលពាក្យនេះ ដោយទំនងដូច្នេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្ដាប់ បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀនបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង

៦៨



និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តស្ស ច សង្ឃស្ស សុភាសិតន្តិ ។ ឥទំ ភិក្ខវេ ទុតិយំ មហាបទេសំ ធារេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ សម្ពហុលា ថេរា ភិក្ខូ វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេសំ មេ ថេរានំ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱតរន្តិ ន វិនយេ សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស

អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះមែន ជាពាក្យដែលព្រះសង្ឃនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ពីរនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុទាំងឡាយជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្ដាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រទាំងមិនឃើញសមក្នុងវិន័យផងទេ អ្នកទាំងឡាយ គប្បីដល់នូវសេចក្ដីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ដោយពិត

តេសញ្ច ថេរានំ ទុគ្គហិតន្តិ ឥតិ ហីទំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ សម្ពហុលា ថេរា ភិក្ខូ វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេសំ មេ ថេរានំ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុ-សាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្ប-ដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ សុត្តេ ចេវ ឱតរន្តិ វិនយេ ច សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តេសញ្ច ថេរានំ សុគ្គហិតន្តិ ។ ឥទំ ភិក្ខវេ តតិយំ មហាបទេសំ ធារេយ្យាថ ។

ទំនងជាព្រះថេរៈទាំងនោះរៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ ត្រូវអ្នកទាំងឡាយចោលពាក្យនេះ ដោយទំនង ដូច្នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ពួកភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ ត្រូវរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ដោយពិត ជាពាក្យដែលព្រះថេរៈទាំងនោះរៀនត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់បីនេះចុះ ។

ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ ឯកោ ថេរោ ភិក្ខុ វិហរតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ តស្ស មេ ថេរស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ ន ចេវ សុត្តេ ឱតរន្តិ ន វិនយេ សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ ន ចេវ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តស្ស ច ថេរស្ស ទុគ្គហិតន្តិ ឥតិ ហីទំ ភិក្ខវេ ឆឌ្ឌេយ្យាថ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អមុកស្មឹ នាម អាវាសេ ឯកោ ថេរោ ភិក្ខុ វិហរតិ

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈ ១ អង្គ នៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ គប្បីរៀនទូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើមិនប្រជុំចុះក្នុងសូត្រទាំងមិនឃើញសមក្នុងវិន័យផង់ទេ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះមិនមែនជាព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះដោយពិត ទំនងជាព្រះថេរៈនោះរៀនខុសហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចោលពាក្យនេះដោយទំនងដូច្នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ គប្បីនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈ ១ អង្គនៅក្នុងអាវាសឯណោះ

៧១



ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ តស្ស មេ ថេរស្ស សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនន្តិ តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា តានិ បទព្យញ្ជនានិ សាធុកំ ឧគ្គហេត្វា សុត្តេ ឱតារេតព្វានិ វិនយេ សន្ទស្សេតព្វានិ ។ តានិ ចេ សុត្តេ ឱតារិយមានានិ វិនយេ សន្ទស្សិយមានានិ សុត្តេ ចេវ ឱតរន្តិ វិនយេ ច សន្ទិស្សន្តិ និដ្ឋមេត្ថ គន្តព្វំ អទ្ធា ឥទំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តស្ស ច ថេរស្ស សុគ្គហិតន្តិ ។ ឥទំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ មហាបទេសាតិ ។

សញ្ចេតនិយវគ្គោ តតិយោ ។

ជាពហុស្សូត ចេះចាំគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ភាសិតរបស់ភិក្ខុនោះឡើយ លុះអ្នកទាំងឡាយ មិនត្រេកអរ មិនឃាត់ហើយ គប្បីរៀននូវបទនិងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យ ។ បទនិងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ ស្ទង់មើលក្នុងសូត្រ ប្រៀបធៀបមើលក្នុងវិន័យទៅហើយ បើប្រជុំចុះក្នុងសូត្រផង ឃើញសមក្នុងវិន័យផង អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនុ៎ះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ដោយពិតជាពាក្យដែលព្រះថេរៈនោះរៀនត្រូវហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់បួននេះចុះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាមហាបទេសទាំងបួន ។

ចប់ សញ្ចេតនិយវគ្គ ទី ៣ ។

៧២

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

# តស្សុទ្ទានំ

ចេតនា វិភត្តិ កោដ្ឋិត

អានន្ទ ឧបវាន បញ្ចមំ

អាយាចន រាហុល ជម្ពាលី

និព្វានំ មហាបទេសេន វគ្គោតិ ។

សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# ឧទ្ទាននៃសញ្ចេតនិយវគ្គនោះគឺ

*សម្តែងពីសញ្ចេតនា ១ ការចែកបដិសម្ភិទា ១ រឿងព្រះកោដ្ឋិតត្ថេរ ១ ព្រះអានន្ទត្ថេរ ១ ព្រះឧបវានត្ថេរ ១ ជាគម្រប់ ៥ ការប្រាថ្នាយកតម្រាប់ ១ រឿងព្រះរាហុលត្ថេរ ១ ការប្រៀបធៀបនឹងត្រពាំង ១ ព្រះនិព្វាន ១ មហាបទេស ១ ក្នុងវគ្គ ។*

# យោធាជីវវគ្គោ ចតុត្ថោ

[៣១] ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតោ យោធាជីវោ[១] រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ យោធាជីវោ ឋានកុសលោ ច ហោតិ ទូរេបាតី ច អក្ខណវេធី ច មហតោ ច កាយស្ស បទាលេតា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតោ យោធាជីវោ រាជារហោ ហោតិ រាជ-ភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ ឋានកុសលោ ច ហោតិ ទូរេបាតី ច អក្ខណវេធី ច មហតោ ច កាយស្ស បទាលេតា ។ កថញ្ច ភិក្ខវេ ភិក្ខុ ឋានកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។

១ ឱ. យោធជីវោ ។

# យោធាជីវវគ្គ ទី ៤

[៣១] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ (អ្នករស់នៅដោយឋានៈជាទាហាន) ប្រកបដោយអង្គ ៤ ទើបគួរជារាជបុរស ជារាជបម្រើ រាប់ថាជាអង្គ (អវយវៈ) របស់ព្រះរាជាបាន ។ អង្គ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ក្នុងលោកនេះ ជាអ្នកឈ្លាសវៃក្នុងជយ-ភូមិ ១ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់ត្រង់ ១ ជាអ្នកអាចទម្លាយនូវកងទ័ពដ៏ធំបាន ១ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ ប្រកបដោយអង្គ ៤ នេះឯង ទើបគួរជារាជបុរស ជារាជបម្រើ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ទើបជាអ្នកគួរទទួលគ្រឿងដែលគេនាំមកបូជា គួរទទួលរបស់ដែលគេទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏ដូច្នោះដែរ ។ ប្រកបដោយអង្គ ៤ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងជយភូមិ ១ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់ត្រង់ ១ ជាអ្នកទម្លាយនូវកងទ័ពដ៏ធំបាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកឈ្លាសក្នុងជយភូមិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។

សមាធាយ សិក្ខតិ សិក្ខាបទេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឋានកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ទូរេបាតី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ទូរេបាតី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខណវេធី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។

សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកឈ្វាសក្នុងជយភូមិយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់បានឆ្ងាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិត នូវរូបណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជារូបក្នុងខ្លួនក្តី ក្រៅខ្លួនក្តី គ្រោតគ្រោតក្តី ល្អិតក្តី អាក្រក់ក្តី ល្អក្តី នៅឆ្ងាយក្តី នៅជិតក្តី ទាំងអស់នុ៎ះ យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនអញ វេទនាណានីមួយ... សញ្ញាណានីមួយ... សង្ខារទាំងឡាយណានីមួយ... ភិក្ខុឃើញដោយបញ្ញាដ៏ប្រពៃតាមពិត នូវវិញ្ញាណណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាវិញ្ញាណក្នុងខ្លួនក្តី ក្រៅខ្លួនក្តី គ្រោតគ្រោតក្តី ល្អិតក្តី អាក្រក់ក្តី ល្អក្តី នៅឆ្ងាយក្តី នៅជិតក្តី ទាំងអស់នុ៎ះ យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនអញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់បានឆ្ងាយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបាញ់ត្រង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។

អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខណវេធី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ មហតោ កាយស្ស បទាលេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ មហន្តំ អវិជ្ជាខន្ធំ បទាលេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ មហតោ កាយស្ស បទាលេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[៣២] ចតុន្នំ ភិក្ខវេ ធម្មានំ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ។ កតមេសំ ចតុន្នំ ។ ជរាធម្មំ ។ មា ជីរីតិ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ។ ព្យាធិធម្មំ មា ព្យាធិយីតិ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ។

ដឹងច្បាស់តាមពិតថា នេះជាបដិបទាប្រព្រឹត្តទៅ ដើម្បីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់ត្រង់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកទម្លាយកងទ័ពធំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទម្លាយគំនរអវិជ្ជាដ៏ធំបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកទម្លាយកងទ័ពធំបានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៤ យ៉ាងនេះឯង ទើបគួរទទួលគ្រឿងបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។

[៣២] ម្នាលភិក្ខុទាំងឡាយ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាក្នុងលោក ជាអ្នកធានាធម៌ទាំង ៤ យ៉ាងបានទេ ។ ធម៌ទាំង ៤ យ៉ាង គឺអ្វីខ្លះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីគ្រាំគ្រាជាធម្មតា កុំគ្រាំគ្រាឡើយដូច្នេះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីឈឺចាប់ជាធម្មតា កុំឈឺចាប់ឡើយដូច្នេះ ។

មរណធម្មំ មា មិយ្យីតិ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ។ យានិ ខោ បន តានិ[១] បាបកានិ កម្មានិ សង្កិលេសិកានិ បោនោព្ភវិកានិ សទរានិ[២] ទុក្ខវិបាកានិ អាយតឹ-ជាតិជរាមរណិកានំ តេសំ វិបាកោ មា និព្វត្តីតិ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ធម្មានំ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មិន្តិ ។

[៣៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា

---

១ ម. តានិ (បុព្វេ អត្តនា កតានិ) ។ ២ ម. អសុទ្ធរានិ ។

មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា របស់ដែលមានសេចក្តីស្លាប់ជាធម្មតា កុំស្លាប់ឡើយដូច្នេះ ។ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាថា បាបកម្មទាំងឡាយណា ដែលប្រកបដោយសេចក្តីសៅហ្មង ធ្វើឲ្យមានភពថ្មី ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល នាំឲ្យមានជាតិជរាមរណៈតទៅ វិបាករបស់កម្មទាំងនោះ កុំកើតឡើយដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ មិនមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក ជាអ្នកធានាធម៌ទាំង ៤ យ៉ាងនេះឯង បានឡើយ ។

[៣៣] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ

## ៧៧



ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោច មយំ[១] ហិ ភោ គោតម ឯវំវាទី ឯវំទិដ្ឋី យោ កោចិ ទិដ្ឋំ ភាសតិ ឯវំ មេ ទិដ្ឋន្តិ នត្ថិ តតោ ទោសោ យោ កោចិ សុតំ ភាសតិ ឯវំ មេ សុតន្តិ នត្ថិ តតោ ទោសោ យោ កោចិ មុតំ ភាសតិ ឯវំ មេ មុតន្តិ នត្ថិ តតោ ទោសោ យោ កោចិ វិញ្ញាតំ ភាសតិ ឯវំ មេ វិញ្ញាតន្តិ នត្ថិ តតោ ទោសោតិ ។ នាហំ ព្រាហ្មណ សព្វំ ទិដ្ឋំ ភាសិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ ទិដ្ឋំ ន ភាសិតព្វន្តិ វទាមិ នាហំ ព្រាហ្មណ សព្វំ សុតំ ភាសិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ សុតំ ន ភាសិតព្វន្តិ វទាមិ

---

១ ឱ. ម. អហំ ។

ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា អ្នកណាមួយនិយាយចំពោះរូបដែលខ្លួនឃើញហើយថា ខ្ញុំបានឃើញយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះសំឡេង ដែលខ្លួនឮហើយថា ខ្ញុំបានឮយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះវត្ថុ ដែលខ្លួនបានហិត ភ្លក់ ពាល់ត្រូវថា ខ្ញុំបានហិត ភ្លក់ ពាល់ត្រូវយ៉ាងនេះ ឥតមានទោសអំពីអ្នកនោះ អ្នកណាមួយនិយាយចំពោះវត្ថុដែលខ្លួនបានដឹងច្បាស់ (ដោយចិត្ត) ថា ខ្ញុំបានដឹងច្បាស់យ៉ាងនេះ ឥតមានទោសអំពីអ្នកនោះទេ ។ ម្នាលព្រាហ្មណ៍ តថាគត មិនពោលថា បុគ្គលត្រូវតែនិយាយចំពោះរូបទាំងអស់ ដែលខ្លួនឃើញហើយទេ ម្នាលព្រាហ្មណ៍ តែថាតថាគត មិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះរូបទាំងអស់ ដែលខ្លួនឃើញហើយទេ ម្នាលព្រាហ្មណ៍ តថាគត មិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះសំឡេងទាំងអស់ ដែលខ្លួនឮហើយទេ ម្នាលព្រាហ្មណ៍ តែថាតថាគតមិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះសំឡេង ដែលខ្លួនឮហើយទេ

នាហំ ព្រាហ្មណ សព្វំ មុតំ ភាសិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ មុតំ ន ភាសិតព្វន្តិ វទាមិ នាហំ ព្រាហ្មណ សព្វំ វិញ្ញាតំ ភាសិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ វិញ្ញាតំ ន ភាសិតព្វន្តិ វទាមិ ។ យំ ហិ ព្រាហ្មណ ទិដ្ឋំ ភាសតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ ទិដ្ឋំ ន ភាសិតព្វន្តិ វទាមិ យញ្ច ខ្វស្ស ព្រាហ្មណ ទិដ្ឋំ ភាសតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ ទិដ្ឋំ ភាសិតព្វន្តិ វទាមិ

ម្នាលព្រាហ្មណ៍ តថាគត មិនពោលថា បុគ្គលត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈទាំងអស់ ដែលខ្លួនហិត ភ្លក់ ពាល់ត្រូវហើយទេ ម្នាលព្រាហ្មណ៍ តែថាតថាគត មិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈទាំងអស់ ដែលខ្លួនហិត ភ្លក់ ពាល់ត្រូវហើយទេ ម្នាលព្រាហ្មណ៍ តថាគត មិនពោលថា បុគ្គលត្រូវនិយាយចំពោះធម្មារម្មណ៍ទាំងអស់ ដែលខ្លួនដឹងច្បាស់ហើយទេ ម្នាលព្រាហ្មណ៍ តែថាតថាគត មិនពោលថា បុគ្គលមិនត្រូវនិយាយចំពោះធម្មារម្មណ៍ទាំងអស់ ដែលខ្លួនដឹងច្បាស់ហើយទេ ។ ម្នាលព្រាហ្មណ៍ តែថាតថាគត ពោលថា កាលបើបុគ្គលពោលចំពោះរូបណា ដែលបានឃើញហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅវិញ បុគ្គលមិនត្រូវនិយាយចំពោះរូប ដែលខ្លួនឃើញហើយបែបនេះទេ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលនោះ ពោលចំពោះរូបណា ដែលខ្លួនបានឃើញហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលគួរនិយាយចំពោះរូប ដែលខ្លួនបានឃើញបែបនេះ

៧៩



យំ ហិ ព្រាហ្មណ សុតំ ភាសតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ សុតំ ន ភាសិតព្វន្តិ វទាមិ យញ្ច ខ្វស្ស ព្រាហ្មណ សុតំ ភាសតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ សុតំ ភាសិតព្វន្តិ វទាមិ យំ ហិ ព្រាហ្មណ មុតំ ភាសតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ មុតំ ន ភាសិតព្វន្តិ វទាមិ យញ្ច ខ្វស្ស ព្រាហ្មណ មុតំ ភាសតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ មុតំ ភាសិតព្វន្តិ វទាមិ យំ ហិ ព្រាហ្មណ វិញ្ញាតំ ភាសតោ

ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលពោលចំពោះសំឡេងណា ដែលខ្លួនបានឮហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ បុគ្គលមិនគួរនិយាយចំពោះសំឡេងដែលខ្លួនបានឮបែបនេះ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលនោះ ពោលចំពោះសំឡេងណា ដែលខ្លួនបានឮហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលគួរនិយាយចំពោះសំឡេងបែបនេះ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលពោលចំពោះក្លិន រស ផោដ្ឋព្វៈណា ដែលខ្លួនបានហិត ភ្លក់ ពាល់ត្រូវហើយ អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ បុគ្គលមិនត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈ ដែលខ្លួនបានហិត ភ្លក់ ពាល់ត្រូវបែបនេះ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលនោះ ពោលចំពោះក្លិន រស ផោដ្ឋព្វៈណា ដែលខ្លួនបានហិត ភ្លក់ ពាល់ត្រូវហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលត្រូវនិយាយចំពោះក្លិន រស ផោដ្ឋព្វៈ ដែលខ្លួនបានហិត ភ្លក់ ពាល់ត្រូវបែបនេះ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលពោលចំពោះធម្មារម្មណ៍ណា ដែលខ្លួនដឹងច្បាស់ហើយ

អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបំ វិញ្ញាតំ ន ភាសិតព្វន្តិ វទាមិ យញ្ច ខ្វស្ស ព្រាហ្មណ វិញ្ញាតំ ភាសតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ វិញ្ញាតំ ភាសិតព្វន្តិ វទាមីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមីតិ ។

[៣៤] អថខោ ជានុស្សោណី ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជានុស្សោណី ព្រាហ្មណោ ភគវន្តំ ឯតទវោច មយំ[១] ហិ ភោ គោតម ឯវំវាទី ឯវំទិដ្ឋី នត្ថិ យោ សោ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្សាតិ ។ អត្ថិ ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស អត្ថិ

១ ឱ. ម. អហំ ។

អកុសលធម៌ទាំងឡាយ ចម្រើនឡើង កុសលធម៌ទាំងឡាយ សាបសូន្យទៅ បុគ្គលមិនត្រូវនិយាយចំពោះធម្មារម្មណ៍ ដែលខ្លួនបានដឹងច្បាស់បែបនេះទេ ម្នាលព្រាហ្មណ៍ តថាគត ពោលថា កាលបើបុគ្គលនោះ ពោលចំពោះធម្មារម្មណ៍ណា ដែលខ្លួនបានដឹងច្បាស់ហើយ អកុសលធម៌ទាំងឡាយ សាបសូន្យទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង បុគ្គលត្រូវនិយាយចំពោះធម្មារម្មណ៍ ដែលខ្លួនបានដឹងច្បាស់បែបនេះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈត្រេកអររីករាយនិងភាសិតរបស់ព្រះមានព្រះភាគ ហើយក៏ក្រោកចាកអាសនៈថយចេញទៅ ។

[៣៨] គ្រានោះ ជានុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះជានុស្សោណិព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកយើងខ្ញុំ តែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ មិនដែលមានឡើយ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ក៏មាន

បន ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។ កតមោ ច ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស ។ ឥធ ព្រាហ្មណ ឯកច្ចោ កាមេសុ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតបេមោ អវិគតបិបាសោ អវិគតបរិឡាហោ អវិគតតណ្ហោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញ-តរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ បិយា វត មំ កាមា ជហិស្សន្តិ បិយេ ចាហំ កាមេ ជហិស្សាមីតិ ។ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ[១] កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ ខោ ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស ។ បុន ចបរំ ព្រាហ្មណ ឥធេ-កច្ចោ កាយេ អវីតរាគោ ហោតិ អវិគតច្ឆន្ទោ អវិគតបេមោ អវិគតបិបាសោ អវិគតបរិឡាហោ

---

១ ឱ. ឧរត្តលំ កន្ទតិ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលអ្នកមានសេចក្ដីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្ដីស្លាប់ក៏មាន ។ ម្នាលព្រាហ្មណ៍ ចុះបុគ្គលអ្នកមានសេចក្ដីស្លាប់ជាធម្មតា ខ្លាច តក់ស្លុតនឹងសេចក្ដីស្លាប់ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្ដីពេញចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្ដៅក្រហាយ មិនទាន់ប្រាសចាកចំណង់ ក្នុងកាមទាំងឡាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះកើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា កាមទាំងឡាយដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញ មុខជានឹងលះបង់កាមទាំងឡាយ ជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ ក៏សោកស្ដាយលំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្ដីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្ដីស្លាប់ជាធម្មតានេះឯង តែងខ្លាចតក់ស្លុតនឹងសេចក្ដីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកសេចក្ដីពេញចិត្ត មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្ដៅក្រហាយ

អវិគតតណ្ហោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ បិយោ វត មំ កាយោ ជហិស្សតិ បិយញ្ចាហំ កាយំ ជហិស្សាមីតិ ។ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយម្បិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស ។ បុន ចបរំ ព្រាហ្មណ ឥធេកច្ចោ អកតកល្យាណោ ហោតិ អកតកុសលោ អកតភីរុត្តាណោ កត-ចាចោ កតលុទ្ទោ កតកិព្ពិសោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ អកតំ វត មេ កល្យាណំ អកតំ កុសលំ អកតំ ភីរុត្តាណំ កតំ ចាបំ កតំ លុទ្ទំ កតំ កិព្ពិសំ យាវតា ភោ អកតកល្យាណានំ អកតកុសលានំ អកតភីរុត្តាណានំ កតចាចានំ កតលុទ្ទានំ កតកិព្ពិសានំ គតិ តំ គតឹ បេច្ច គច្ឆាមីតិ ។

មិនទាន់ប្រាសចាកចំណង់ក្នុងកាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា រាងកាយជាទីស្រឡាញ់នឹងលះបង់អាត្មាអញ អាត្មាអញ នឹងលះបង់រាងកាយជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ ក៏សោកស្តាយ លំបាកខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានធ្វើអំពើល្អ មិនបានធ្វើអកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមក ហើយ បុគ្គលនោះ ក៏កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញ មិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមក អើហ្ន៎ គតិរបស់បុគ្គលដែលមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើអំពើជាទីការពារភ័យ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើលាមក ត្រឹមណា អាត្មាអញលះលោកនេះហើយ នឹងទៅកាន់គតិនោះ ។

៨៣



សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំបិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស ។ បុន ចបរំ ព្រាហ្មណ ឥធេកច្ចោ កង្ខី ហោតិ វិចិកិច្ឆី អនិដ្ឋំ គតោ សទ្ធម្មេ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញ-តរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ កង្ខី វតម្ហិ វិចិកិច្ឆី អនិដ្ឋំ គតោ សទ្ធម្មេតិ ។ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំបិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ភាយតិ សន្តាសំ អាបជ្ជតិ មរណស្ស ។ ឥមេ ខោ ព្រាហ្មណ ចត្តារោ មរណធម្មា សមានា ភាយន្តិ សន្តាសំ អាបជ្ជន្តិ មរណស្ស ។ កតមោ ច ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។ ឥធ ព្រាហ្មណ ឯកច្ចោ កាមេសុ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតបេមោ

បុគ្គលនោះ ក៏សោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីសន្ទិះសង្ស័យមិនជឿស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញ មានសេចក្តីសន្ទិះសង្ស័យ មិនជឿងស៊ប់ក្នុងព្រះសទ្ធម្ម ។ បុគ្គលនោះ ក៏សោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូងយំទួញ ដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងខ្លាច តក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ៤ ពួកនេះឯង តែងខ្លាចតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ ចុះបុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា មិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់

វិគតបិចាសោ វិគតបរិឡាហោ វិគតតណ្ហោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ន ឯវំ ហោតិ បិយា វត មំ កាមា ជហិស្សន្តិ បិយេ ចាហំ កាមេ ជហិស្សាមីតិ ។ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំ ខោ ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។ បុន ចបរំ ព្រាហ្មណ ឥធេកច្ចោ កាយេ វីតរាគោ ហោតិ វិគតច្ឆន្ទោ វិគតប្បេមោ វិគតបិចាសោ វិគតបរិឡាហោ វិគតតណ្ហោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ន ឯវំ ហោតិ បិយោ វត មំ កាយោ ជហិស្សតិ បិយញ្ចាហំ កាយំ ជហិស្សាមីតិ ។ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។

ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ក្នុងកាមទាំងឡាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ មិនដែលត្រិះរិះយ៉ាងនេះថា កាមទាំងឡាយដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញ មុខជានឹងលះបង់កាមទាំងឡាយជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រាសចាកតម្រេក ប្រាសចាកសេចក្តីពេញចិត្ត ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកចំណង់ក្នុងកាយ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ មិនដែលត្រិះរិះយ៉ាងនេះថា ឱរាងកាយដែលជាទីស្រឡាញ់ នឹងលះបង់អាត្មាអញ អាត្មាអញ មុខជានឹងលះបង់រាងកាយជាទីស្រឡាញ់ដែរ ។ បុគ្គលនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្តីវង្វេង ។

៨៤



អយំបិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។ បុន ចបរំ ព្រាហ្មណ ឥធេកច្ចោ អកតបាបោ ហោតិ អកតលុទ្ទោ អកតកិព្ពិសោ កតកល្យាណោ កតកុសលោ កតភីរុត្តាណោ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ អកតំ វត មេ បាបំ អកតំ លុទ្ទំ អកតំ កិព្ពិសំ កតំ កល្យាណំ កតំ កុសលំ កតំ ភីរុត្តាណំ យាវតា ភោ អកតបាបានំ អកតលុទ្ទានំ អកតកិព្ពិសានំ កតកល្យាណានំ កតកុសលានំ កតភីរុត្តាណានំ គតិ តំ គតឹ បេច្ច គច្ឆាមីតិ ។ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំបិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។

ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្ដីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្ដីស្លាប់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនធ្វើបាប មិនធ្វើអំពើអាក្រក់ មិនធ្វើអំពើលាមក ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យ បុគ្គលនោះ កើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញ មិនដែលធ្វើអំពើបាប មិនធ្វើអំពើអាក្រក់ មិនធ្វើអំពើលាមកទេ ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យ អើហ្ន៎ គតិរបស់បុគ្គលដែលមិនបានធ្វើបាប មិនបានធ្វើអំពើអាក្រក់ មិនបានធ្វើអំពើលាមក ធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែអំពើជាទីការពារភ័យត្រឹមណា អាត្មាអញលះលោកនេះហើយ នឹងទៅកាន់គតិនោះ ។ បុគ្គលនោះក៏មិនសោកស្ដាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្ដីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្ដីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្ដីស្លាប់ ។

បុន ចបរំ ព្រាហ្មណ ឥធេកច្ចោ អកង្ខី ហោតិ អវិចិកិច្ឆី និដ្ឋំ គតោ សទ្ធម្មេ តមេនំ អញ្ញតរោ គាឡ្ហោ រោគាតង្កោ ផុសតិ តស្ស អញ្ញតរេន គាឡ្ហេន រោគាតង្កេន ផុដ្ឋស្ស ឯវំ ហោតិ អកង្ខី វតម្ហិ អវិចិកិច្ឆី និដ្ឋំ គតោ សទ្ធម្មេតិ ។ សោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំបិ ខោ ព្រាហ្មណ មរណធម្មោ សមានោ ន ភាយតិ ន សន្តាសំ អាបជ្ជតិ មរណស្ស ។ ឥមេ ខោ ព្រាហ្មណ ចត្តារោ មរណធម្មា សមានា ន ភាយន្តិ ន សន្តាសំ អាបជ្ជន្តិ មរណស្មាតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[៣៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា សប្បិ-និយា តីរេ បរិព្វាជការាមេ បដិវសន្តិ សេយ្យថីទំ អន្ធភារោ[១] វធរោ[២] សកុលុទាយី ច បរិព្វាជកោ

១ ឱ. អន្នភារោ ។ ២ ឱ. ម. វរធរោ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសេចក្តីសន្ទិះសង្ស័យ ជាបុគ្គលជឿស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះកើតរោគធ្ងន់ណាមួយ កាលបើបុគ្គលនោះ កើតរោគធ្ងន់ណាមួយហើយ តែងត្រិះរិះយ៉ាងនេះថា ឱអាត្មាអញ លែងសន្ទិះសង្ស័យបានជឿស៊ប់ក្នុងព្រះសទ្ធម្មហើយ ។ បុគ្គលនោះ មិនសោកស្តាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំទួញ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតានេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ ម្នាលព្រាហ្មណ៍ បុគ្គលអ្នកមានសេចក្តីស្លាប់ជាធម្មតា ៤ ពួកនេះឯង តែងមិនខ្លាច មិនតក់ស្លុតនឹងសេចក្តីស្លាប់ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណៈស្មើជីវិតតាំងពីថ្ងៃនេះទៅ ។

[៣៥] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង បរិព្វាជកច្រើននាក់ សុទ្ធតែជាអ្នកល្បីឈ្មោះ អាស្រ័យនៅក្នុងបរិព្វាជការាម ក្បែរឆ្នេរស្ទឹងសប្បិនី គឺបរិព្វាជកឈ្មោះអន្នភារៈ ១ វធរៈ ១ សកុលុទាយី ១

អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន សប្បិនិយា តីរំ[១] បរិព្វាជការាមោ តេនុបសង្កមិ ។ តេន ខោ បន សមយេន តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ ឥតិបិ ព្រាហ្មណសច្ចានិ ឥតិបិ ព្រាហ្មណសច្ចានីតិ ។ អថខោ ភគវា យេន តេ បរិព្វាជកា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា តេ បរិព្វាជកេ ឯតទវោច កាយនុត្ថ បរិព្វាជកា ឯតរហិ កថាយ សន្និសិន្នា សន្និបតិតា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ ភោ គោតម អម្ហាកំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ ឥតិបិ ព្រាហ្មណសច្ចានិ ឥតិបិ ព្រាហ្មណសច្ចានីតិ ។ ចត្តារីមានិ បរិព្វាជកា ព្រាហ្មណសច្ចានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។

១ ឱ. ម. តីរេ ។

នឹងបរិព្វាជកឯទៀតដែលមានឈ្មោះល្បីល្បាញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ស្ដេចចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយទ្រង់ស្ដេចចូលទៅឯបរិព្វាជការាម ក្បែរឆ្នេរស្ទឹងសប្បិនីនោះ ។ កាលដែលពួកបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ អង្គុយប្រជុំសន្និបាតក្នុងសម័យនោះឯង អន្តរាកថានេះ កើតឡើងថា សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ ។ លំដាប់នោះ ព្រះមានព្រះភាគ ស្ដេចចូលទៅរកពួកបរិព្វាជកទាំងនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ទើបត្រាស់សួរបរិព្វាជកទាំងនោះ ដូច្នេះថា ម្នាលបរិព្វាជកទាំងឡាយ អម្បាញ់មិញអ្នកទាំងឡាយ អង្គុយប្រជុំនិយាយគ្នាអំពីរឿងអ្វី មួយទៀត អន្តរាកថារបស់អ្នកទាំងឡាយ ដូចម្ដេចដែលបញ្ឈប់ដាច់ទៅ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលដែលយើងខ្ញុំអង្គុយប្រជុំគ្នាក្នុងទីនេះ អន្តរាកថានេះកើតឡើងថា សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ សច្ចៈរបស់ពួកព្រាហ្មណ៍ដូច្នេះខ្លះ ។ ម្នាលបរិព្វាជកទាំងឡាយ សច្ចៈរបស់ពួកព្រាហ្មណ៍នេះមាន ៤ ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯងហើយទើបប្រកាសឲ្យដឹងច្បាស់ ។ សច្ចៈរបស់ពួកព្រាហ្មណ៍ ៤ តើដូចម្ដេច ។

ឥធ បរិព្វាជកា ព្រាហ្មណោ ឯវមាហ សព្វេ បាណា អវជ្ឈាតិ ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ នោ មុសា សោ តេន ន សមណោតិ មញ្ញតិ ន ព្រាហ្មណោតិ មញ្ញតិ ន សេយ្យោហមស្មីតិ មញ្ញតិ ន សទិសោហមស្មីតិ មញ្ញតិ ន ហីនោហ-មស្មីតិ មញ្ញតិ អបិច យទេវ តត្ថ សច្ចំ តទ-ភិញ្ញាយ បាណានំយេវ អនុទយាយ អនុកម្បាយ បដិបន្នោ ហោតិ ។ បុន ចបរំ បរិព្វាជកា ព្រាហ្មណោ ឯវមាហ សព្វេ កាមា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ នោ មុសា សោ តេន ន សមណោតិ មញ្ញតិ ន ព្រាហ្មណោតិ មញ្ញតិ ន សេយ្យោហមស្មីតិ មញ្ញតិ ន សទិសោហមស្មីតិ មញ្ញតិ ន ហីនោហមស្មីតិ មញ្ញតិ អបិច យទេវ តត្ថ សច្ចំ តទភិញ្ញាយ កាមានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ បុន ចបរំ បរិព្វាជកា ព្រាហ្មណោ ឯវមាហ សព្វេ ភវា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ

ម្នាលបរិញ្វាជកទាំងឡាយ ព្រាហ្មណ៍[១] ក្នុងលោកនេះ ពោលយ៉ាងនេះថា សត្វទាំងពួងមិនគួរសម្លាប់ ព្រាហ្មណ៍ កាលពោលដូច្នេះ ឈ្មោះថាពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះមិនប្រកាន់ថាជាសមណៈ មិនប្រកាន់ថាជាព្រាហ្មណ៍ មិនប្រកាន់ថាអញប្រសើរជាងគេ មិនប្រកាន់ថាអញស្មើនឹងគេ មិនប្រកាន់ថាអញថោកទាបជាងគេ ព្រោះតែការសម្លាប់នោះ គ្រាន់តែប្រតិបត្តិដើម្បីអាណិតអនុគ្រោះចំពោះសត្វទាំងឡាយ ព្រោះការត្រាស់ដឹងសច្ចៈនោះ ក្នុងការមិនសម្លាប់នោះ ប៉ុណ្ណោះ ។ ម្នាលបរិញ្វាជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា កាមទាំងពួង មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ព្រាហ្មណ៍ កាលពោលដូច្នេះ ឈ្មោះថាពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះ មិនប្រកាន់ថាជាសមណៈ មិនប្រកាន់ថាជាព្រាហ្មណ៍ មិនប្រកាន់ថាអញប្រសើរជាងគេ មិនប្រកាន់ថាអញស្មើនឹងគេ មិនប្រកាន់ថាអញថោកទាបជាងគេ ព្រោះតែសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិ ដើម្បីនឿយណាយ ធុញទ្រាន់ រំលត់កាមទាំងឡាយ ព្រោះការត្រាស់ដឹងនូវសច្ចៈនោះ ក្នុងដំណើរនោះ ប៉ុណ្ណោះ ។ ម្នាលបរិញ្វាជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា ភពទាំងពួងមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា

១ ព្រាហ្មណ៍ក្នុងទីនេះ សំដៅយកសមណៈក្នុងពុទ្ធសាសនា ។

ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ នោ មុសា សោ តេន ន សមណោតិ មញ្ញតិ ន ព្រាហ្មណោតិ មញ្ញតិ ន សេយ្យោហមស្មីតិ មញ្ញតិ ន សទិសោហមស្មីតិ មញ្ញតិ ន ហីនោហមស្មីតិ មញ្ញតិ អបិច យទេវ តត្ថ សច្ចំ តទភិញ្ញាយ ភវានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ បុន ចបរំ បរិព្វាជកា ព្រាហ្មណោ ឯវមាហ នាហំ ក្វចនិ កស្សចិ កិញ្ចនតស្មឹ[១] ន ច មម ក្វចនិ កត្ថចិ កិញ្ចនត្ថីតិ[២] ឥតិ វទំ ព្រាហ្មណោ សច្ចំ អាហ នោ មុសា សោ តេន ន សមណោតិ មញ្ញតិ ន ព្រាហ្មណោតិ មញ្ញតិ ន សេយ្យោហមស្មីតិ មញ្ញតិ ន សទិសោហមស្មីតិ មញ្ញតិ ន ហីនោហមស្មីតិ មញ្ញតិ អបិច យទេវ តត្ថ សច្ចំ តទភិញ្ញាយ អាកិញ្ចញ្ញំយេវ បដិបទំ បដិបន្នោ ហោតិ ។ ឥមានិ ខោ បរិព្វាជកា ចត្តារិ ព្រាហ្មណសច្ចានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

១ ឱ. កិញ្ចនំ តស្មឹ ។ ២ ឱ. ម. កិញ្ចនំ នត្ថីតិ ។

ព្រាហ្មណ៍កាលពោលដូច្នេះ ឈ្មោះថា ពោលពាក្យសច្ចៈ មិនមែនពោលមុសា ព្រាហ្មណ៍នោះ មិនប្រកាន់ថាជាសមណៈ មិនប្រកាន់ថាជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិ ដើម្បីនឿយណាយ ធុញទ្រាន់ រំលត់កពទាំងឡាយ ព្រោះការត្រាស់ដឹងសច្ចៈនោះ ក្នុងដំណើរនោះប៉ុណ្ណោះ ។ ម្នាលបរិព្វាជកទាំងឡាយ មួយទៀត ព្រាហ្មណ៍ពោលយ៉ាងនេះថា អាត្មាអញមិនមានក្នុងវត្ថុនីមួយ មិនមានក្នុងកង្វល់អ្នកណាមួយ អ្នកដទៃក៏មិនមានក្នុងវត្ថុនីមួយ ទាំងវត្ថុនីមួយរបស់ដទៃ ក៏មិនមានក្នុងកង្វល់នីមួយរបស់អញ ព្រាហ្មណ៍កាលពោលយ៉ាងនេះ ឈ្មោះថា ពោលពាក្យសច្ចៈ មិនមែនពោលមុសាទេ ព្រាហ្មណ៍នោះ មិនប្រកាន់ថាជាសមណៈ មិនប្រកាន់ថាជាព្រាហ្មណ៍ មិនប្រកាន់ថា អញប្រសើរជាងគេ មិនប្រកាន់ថា អញស្មើនឹងគេ មិនប្រកាន់ថា អញថោកទាបជាងគេ ព្រោះសេចក្តីយល់នោះ គ្រាន់តែប្រតិបត្តិអាកិញ្ចញ្ញប្បដិបទា (ផ្លូវដែលឥតកង្វល់) ព្រោះការត្រាស់ដឹងនូវសច្ចៈនោះ ក្នុងដំណើរនោះប៉ុណ្ណោះ ។ ម្នាលបរិព្វាជកទាំងឡាយ សច្ចៈរបស់ពួកព្រាហ្មណ៍ទាំង ៤ នេះឯង តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងហើយ ទើបប្រកាសឲ្យដឹងច្បាស់ ។

[៣៦] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កេន នុ ខោ ភន្តេ លោកោ នីយតិ កេន លោកោ បរិកស្សតិ កស្ស ច ឧប្បន្នស្ស វសំ គច្ឆតីតិ ។ សាធុ សាធុ ភិក្ខុ ភទ្ទកោ ខោ តេ ភិក្ខុ ឧម្មង្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ ភិក្ខុ បុច្ឆសិ កេន នុ ខោ ភន្តេ លោកោ នីយតិ កេន លោកោ បរិកស្សតិ កស្ស ច ឧប្បន្នស្ស វសំ គច្ឆតីតិ ។ ឯវំ ភន្តេ ។ ចិត្តេន ខោ ភិក្ខុ លោកោ នីយតិ ចិត្តេន បរិកស្សតិ ចិត្តស្ស ឧប្បន្នស្ស វសំ គច្ឆតីតិ ។ សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ ពហុស្សុតោ ធម្មធរោ ពហុស្សុតោ ធម្មធរោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ពហុស្សុតោ ធម្មធរោ ហោតីតិ ។

[៣៦] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោកលុះអំណាចរបស់អ្វីដែលកើតឡើង ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្តីឆ្លាសរបស់អ្នកស្រួលហើយ សេចក្តីវាងវៃរបស់អ្នកស្រួលហើយ សេចក្តីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតថា អ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីដឹកនាំសត្វលោកទៅ អ្វីទង់ទាញសត្វលោកទៅ មួយទៀត សត្វលោក លុះអំណាចរបស់អ្វីដែលកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ចិត្តដឹកនាំសត្វលោកទៅ ចិត្តទង់ទាញសត្វលោកទៅ សត្វលោក លុះអំណាចចិត្តដែលកើតឡើង ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏បានសួរប្រស្នា នឹងព្រះមានព្រះភាគ តទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូត អ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្តេច ។

៩១

## ចតុត្ថបណ្ណាសកេ យោធាជីវវគ្គោ ចតុត្ថោ

សាធុ សាធុ ភិក្ខុ ភទ្ទកោ ខោ តេ ភិក្ខុ ឧម្មង្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ ភិក្ខុ បុច្ឆសិ ពហុស្សុតោ ធម្មធរោ ពហុស្សុតោ ធម្មធរោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ពហុស្សុតោ ធម្មធរោ ហោតីតិ ។ ឯវំ ភន្តេ ។ ពហូ ខោ ភិក្ខុ មយា ធម្មា ទេសិតា សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ចតុប្បទាយ ចេបិ ភិក្ខុ គាថាយ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ ពហុស្សុតោ ធម្មធរោតិ អលំ វចនាយាតិ ។ សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ សុតវា និព្វេធិកប្បញ្ញោ សុតវា និព្វេធិកប្បញ្ញោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សុតវា និព្វេធិកប្បញ្ញោ ហោតីតិ ។ សាធុ សាធុ ភិក្ខុ

ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ សេចក្ដីឆ្លាសរបស់អ្នកស្រួលហើយ សេចក្ដីវាងវៃស្រួលហើយ សេចក្ដីសាកសួរល្អហើយ ម្នាលភិក្ខុ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ ជាពហុស្សូតអ្នកទ្រទ្រង់ធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាពហុស្សូតអ្នកទ្រទ្រង់ធម៌ តើដោយហេតុដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ធម៌ទាំងឡាយដែលតថាគត សម្ដែងទុកច្រើនយ៉ាង គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ បើភិក្ខុដឹងអត្ថនិងធម៌របស់គាថា ត្រឹមតែ ៤ បាទហើយ ជាអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ក៏គួរហៅថា ជាពហុស្សូតអ្នកទ្រទ្រង់ធម៌បាន ។ ភិក្ខុនោះ ត្រេកអររីករាយនិងភាសិតរបស់ព្រះមានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏សួរប្រស្នានឹងព្រះដ៏មានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ តើដោយហេតុដូចម្ដេច ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ

៩២



ភទ្ទកោ ខោ តេ ភិក្ខុ ឧម្មគ្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ ភិក្ខុ បុច្ឆសិ សុតវា និព្វេធិកប្បញ្ញោ សុតវា និព្វេធិកប្បញ្ញោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សុតវា និព្វេធិកប្បញ្ញោ ហោតីតិ ។ ឯវំ ភន្តេ ។ ឥធ ភិក្ខុ ភិក្ខុនោ ឥទំ ទុក្ខន្តិ សុតំ ហោតិ បញ្ញាយ ចស្ស អត្ថំ អតិវិជ្ឈ បស្សតិ អយំ ទុក្ខសមុទយោតិ សុតំ ហោតិ បញ្ញាយ ចស្ស អត្ថំ អតិវិជ្ឈ បស្សតិ អយំ ទុក្ខនិរោធោតិ សុតំ ហោតិ បញ្ញាយ ចស្ស អត្ថំ អតិវិជ្ឈ បស្សតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ សុតំ ហោតិ បញ្ញាយ ចស្ស អត្ថំ អតិវិជ្ឈ បស្សតិ ឯវំ ខោ ភិក្ខុ សុតវា និព្វេធិកប្បញ្ញោ ហោតីតិ ។ សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ បណ្ឌិតោ មហាបញ្ញោ បណ្ឌិតោ មហាបញ្ញោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ បណ្ឌិតោ មហាបញ្ញោ ហោតីតិ ។

ម្នាលភិក្ខុ សេចក្តីឆ្លាសរបស់អ្នកស្រួលហើយ សេចក្តីវាងវៃរបស់អ្នកស្រួលហើយ សេចក្តីសាកសួររបស់អ្នកល្អហើយ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលអ្នកបានស្តាប់ មានប្រាជ្ញាចាក់ធ្លុះ ដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ បានឮថា នេះទុក្ខ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខសមុទ័យ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខនិរោធ ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា បានឮថា នេះទុក្ខនិរោធ-គាមិនីបដិបទា ក៏ចាក់ធ្លុះយល់សេចក្តីនៃធម៌នោះដោយប្រាជ្ញា ម្នាលភិក្ខុ បុគ្គលអ្នកចេះដឹង មានប្រាជ្ញាចាក់ធ្លុះយ៉ាងនេះឯង ។ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគថា សាធុ ព្រះអង្គ ហើយក៏ក្រាលទូលសួរប្រស្នានឹងព្រះមានព្រះភាគ តទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិត អ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។

## ៩៣



សាធុ សាធុ ភិក្ខុ ភទ្ទកោ ខោ តេ ភិក្ខុ ឧម្មង្គោ ភទ្ទកំ បដិភាណំ កល្យាណី បរិបុច្ឆា ឯវំ ហិ ត្វំ ភិក្ខុ បុច្ឆសិ បណ្ឌិតោ មហាបញ្ញោ បណ្ឌិតោ មហាបញ្ញោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ បណ្ឌិតោ មហាបញ្ញោ ហោតីតិ ។ ឯវំ ភន្តេ ។ ឥធ ភិក្ខុ បណ្ឌិតោ មហាបញ្ញោ នេវត្តព្យាពាធាយ ចេតេតិ ន បរព្យាពាធាយ ចេតេតិ ន ឧភយព្យាពាធាយ ចេតេតិ អត្តហិតំ បរហិតំ ឧភយហិតំ សព្វលោកហិតមេវ ចិន្តយមានោ ចិន្តេតិ ឯវំ ខោ ភិក្ខុ បណ្ឌិតោ មហាបញ្ញោ ហោតីតិ ។

[៣៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទ-នីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុ សេចក្តីឆ្លាសរបស់អ្នកស្រួលហើយ សេចក្តីវាងវៃរបស់អ្នកស្រួលហើយ សេចក្តីសាកសួររបស់អ្នកល្អហើយ ដ្បិតអ្នកបានសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដែលព្រះអង្គត្រាស់ថា បណ្ឌិតអ្នកមានប្រាជ្ញាច្រើន បណ្ឌិតអ្នកមានប្រាជ្ញាច្រើន ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែន ។ ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិត អ្នកមានប្រាជ្ញាច្រើន ក្នុងសាសនានេះ មិនគិតដើម្បីបៀតបៀនខ្លួន មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង កាលបើគិត ក៏គិតតែប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ប្រយោជន៍ទាំងពីរខាង និងប្រយោជន៍ដល់លោកទាំងមូល ម្នាលភិក្ខុ ភិក្ខុជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើនយ៉ាងនេះឯង ។

[៣៧] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭករួចហើយ ក៏អង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវន្តំ ឯតទវោច ជានេយ្យ នុ ខោ ភោ គោតម អសប្បុរិសោ អសប្បុរិសំ អសប្បុរិសោ អយំ ភវន្តិ ។ អដ្ឋានំ ខោ ឯតំ ព្រាហ្មណ អនវ-កាសោ យំ អសប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ ជានេយ្យ បន ភោ គោតម អសប្បុរិសោ សប្បុរិសំ សប្បុរិសោ អយំ ភវន្តិ ។ ឯតម្បិ ខោ ព្រាហ្មណ អដ្ឋានំ អនវកាសោ យំ អសប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ជានេយ្យ នុ ខោ ភោ គោតម សប្បុរិសោ សប្បុរិសំ សប្បុរិសោ អយំ ភវន្តិ ។ ឋានំ ខោ ឯតំ ព្រាហ្មណ វិជ្ជតិ យំ សប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ជានេយ្យ បន ភោ គោតម សប្បុរិសោ អសប្បុរិសំ អសប្បុរិសោ អយំ ភវន្តិ ។ ឯតម្បិ ខោ ព្រាហ្មណ ឋានំ វិជ្ជតិ យំ សប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ អច្ឆរិយំ ភោ គោតម

លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីសមគួរ ហើយ បានទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតម ដ៏ចម្រើន អសប្បុរសគប្បីស្គាល់អសប្បុរសដូចគ្នាថា អ្នកនេះជា អសប្បុរស បានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះមិនសមហេតុ មិនសមផលទេ ដែលអសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជា អសប្បុរសដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះអសប្បុរសគប្បី ស្គាល់សប្បុរសថា អ្នកនេះជាសប្បុរសបានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរស គប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរសដូច្នេះ ។ បពិត្រព្រះគោតម ដ៏ចម្រើន សប្បុរសគប្បីស្គាល់សប្បុរសដូចគ្នាថា អ្នកនេះជាសប្បុរស បានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ទើបមានទំនងដែល ថា សប្បុរសគប្បីស្គាល់សប្បុរសដូចគ្នាថា អ្នកនេះជាសប្បុរសដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នក នេះជាអសប្បុរសបានដែរឬ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មានទំនងដែរ ដែលសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះ ជាអសប្បុរសដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់

អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ ភោតា គោតមេន អដ្ឋានំ ខោ ឯតំ ព្រាហ្មណ អនវកាសោ យំ អសប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ ឯតម្បិ ខោ ព្រាហ្មណ អដ្ឋានំ អនវកាសោ យំ អសប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ឋានំ ខោ ឯតំ ព្រាហ្មណ វិជ្ជតិ យំ សប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ឯតម្បិ ខោ ព្រាហ្មណ ឋានំ វិជ្ជតិ យំ សប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ ឯកមិទំ ភោ គោតម សមយំ តោទេយ្យស្ស ព្រាហ្មណស្ស បរិសតិ បរុបារម្ភំ វត្តេន្តិ ពាលោ អយំ រាជា ឯឡេយ្យោ យោ សមណេ រាមបុត្តេ អភិប្បសន្នោ សមណេ ច បន រាមបុត្តេ ឯវរូបំ បរមនិបច្ចការំ ករោតិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមី-ចិកម្មន្តិ ។ ឥមេបិ រញ្ញោ ឯឡេយ្យស្ស បរិហារកា ពាលា យមកោ មោគ្គល្លោ[១] ឧគ្គោ ជាវិជាកី[២] គន្ធព្វោ អគ្គិវេស្សោ យេ សមណេ រាមបុត្តេ អភិប្បសន្នា

១ ម. បុគ្គលោ ។ ២ ឱ. នាវិន្ទគី ។ អដ្ឋកថាយំ បន នាវិន្ទកី ឥតិ ទិស្សតិ ។

បពិត្រព្រះគោតមដ៏ចម្រើន ចំឡែកណាស់ ព្រោះពាក្យនេះ ព្រះគោតមដ៏ចម្រើន ត្រាស់ត្រូវហើយថា ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ មិនសមហេតុ មិនសមផលទេ ដែលថា អសប្បុរសគប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរសដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះមិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរសគប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរសដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ទើបមានទំនងពិត ដែលថា សប្បុរសគប្បីស្គាល់សប្បុរសបានថា អ្នកនេះជាសប្បុរសដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មានទំនងដែរ ដែលថាសប្បុរសគប្បីស្គាល់អសប្បុរសបានថា អ្នកនេះជាអសប្បុរសដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន សម័យមួយ ក្នុងបរិសទ្យរបស់តោទេយ្យព្រាហ្មណ៍ ពួកជននិយាយពាក្យជាទីតិះដៀលមនុស្សដទៃថា ស្តេចឯឡេយ្យៈនេះល្ងង់ ដែលទ្រង់ជ្រះថ្លាខ្លាំង ក្នុងសមណរាមបុត្រ ថែមទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរព ក្នុងសមណរាមបុត្រ ។ ទាំងពួកបរិវារៈរបស់ស្តេចឯឡេយ្យៈទាំងនេះ គឺយមកៈ ១ មោគ្គល្លៈ ១ ឧគ្គៈ ១ នាវិនាកី ១ គន្ធព្វ ១ អគ្គិវេស្ស ១ ក៏ល្ងង់ដែរ ដែលទៅជ្រះថ្លា ក្នុងសមណរាមបុត្រ

សមណេ ច បន រាមបុត្តេ ឯវរូបំ បរមនិបច្ចការំ ករោន្តិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ ត្យស្សុទំ តោទេយ្យោ ព្រាហ្មណោ ឥមិនា នយេន នេតិ តំ កឹ មញ្ញន្តិ ភោន្តោ បណ្ឌិតោ រាជា ឯឡេយ្យោ ករណីយាធិករណីយេសុ វចនីយាធិវចនីយេសុ អលមត្ថទសតរេហិ អលមត្ថទសតរោតិ ។ ឯវំ ភោ បណ្ឌិតោ រាជា ឯឡេយ្យោ ករណីយាធិករណីយេសុ វចនីយាធិវចនីយេសុ អលមត្ថទសតរេហិ អលមត្ថទសតរោតិ ។ យស្មា ខោ ភោ សមណោ រាមបុត្តោ រញ្ញា ឯឡេយ្យេន បណ្ឌិតេន បណ្ឌិតតរោ ករណីយាធិករណីយេសុ វចនីយាធិវចនីយេសុ អលមត្ថទសតរេន អលមត្ថទសតរោ តស្មា រាជា ឯឡេយ្យោ សមណេ រាមបុត្តេ អភិប្បសន្នោ សមណេ ច បន រាមបុត្តេ ឯវរូបំ បរមនិបច្ចការំ ករោតិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ តំ កឹ មញ្ញន្តិ

ហើយនាំគ្នាធ្វើសេចក្តីឱនលំទោនខ្ពស់បំផុតយ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរព ក្នុងសមណរាមបុត្រ ។ ប៉ុន្តែតោទេយ្យព្រាហ្មណ៍ ត្រឡប់ជាណែនាំពួកជនទាំងនោះ ដោយន័យនេះថា អ្នកដ៏ចម្រើនទាំងឡាយ សម្គាល់សេចក្តីនោះដូចម្តេច ស្តេចឯទ្បេយ្យជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើ ជាងពួកអ្នកប្រាជ្ញដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ ម្នាលអ្នកដ៏ចម្រើន យ៉ាងហ្នឹងហើយ ស្តេចឯទ្បេយ្យៈជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើ ជាងពួកអ្នកប្រាជ្ញដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន សមណរាមបុត្រជាអ្នកប្រាជ្ញគ្រាន់បើ ជាងស្តេចឯទ្បេយ្យៈដែលជាអ្នកប្រាជ្ញ សមណរាមបុត្រនោះ ជាអ្នកអាចយល់ប្រយោជន៍គ្រាន់បើជាងស្តេចឯទ្បេយ្យៈ ដែលជាអ្នកអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ហេតុនោះ បានជាស្តេចឯទ្បេយ្យៈ ជ្រះថ្លាខ្លាំងក្នុងសមណរាមបុត្រ ថែមទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុត យ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួល ប្រណម្យដៃ ធ្វើសេចក្តីគោរព ក្នុងសមណរាមបុត្រ ។ អ្នកដ៏ចម្រើនទាំងឡាយ សម្គាល់សេចក្តីនោះដូចម្តេច

៩៧



ភោន្តោ បណ្ឌិតា រញ្ញោ ឯឡេយ្យស្ស បរិហារកា យមកោ មោគ្គល្លោ ឧគ្គោ ណាវិណាកី គន្ធព្វោ អគ្គិវេស្សោ ការណីយានិការណីយេសុ វចនីយានិវចនីយេសុ អលមត្ថទសតរេហិ អលមត្ថទសតរាតិ[១] ។ ឯវំ ភោ បណ្ឌិតា រញ្ញោ ឯឡេយ្យស្ស បរិហារកា យមកោ មោគ្គល្លោ ឧគ្គោ ណាវិណាកី គន្ធព្វោ អគ្គិវេស្សោ ការណីយានិការណីយេសុ វចនីយានិវចនីយេសុ អលមត្ថទសតរេហិ អលមត្ថទសតរាតិ ។ យស្មា ខោ ភោ សមណោ រាមបុត្តោ រញ្ញោ ឯឡេយ្យស្ស បរិហារកេហិ បណ្ឌិតេហិ បណ្ឌិតតរោ ការណីយានិការណីយេសុ វចនីយានិវចនីយេសុ អលមត្ថទសតរេហិ អលមត្ថទសតរោ តស្មា រញ្ញោ ឯឡេយ្យស្ស បរិហារកា សមណេ រាមបុត្តេ អភិប្បសន្នា សមណេ ច បន រាមបុត្តេ ឯវរូបំ បរមនិបច្ចការំ ករោន្តិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ

១ ឱ. ម. អលមត្ថទសតរាតិ ។

ពួកបរិវាររបស់ស្តេចឯឡេយ្យៈ គឺយមកៈ មោគ្គល្លៈ ឧគ្គៈ នាវិនាកី គន្ធព្វៈ អគ្គិវេស្សៈ សុទ្ធតែជាអ្នកប្រាជ្ញអាចយល់ប្រយោជន៍ គ្រាន់បើជាងពួកអ្នកប្រាជ្ញ ដែលអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ នៃអ្នកដ៏ចម្រើន យ៉ាងហ្នឹងហើយ ពួកបរិវាររបស់ស្តេចឯឡេយ្យៈ គឺយមកៈ មោគ្គល្លៈ ឧគ្គៈ នាវិនាកី គន្ធព្វៈ អគ្គិវេស្សៈ ជាអ្នកប្រាជ្ញ អាចយល់ប្រយោជន៍គ្រាន់បើជាងពួកអ្នកប្រាជ្ញអាចយល់ប្រយោជន៍គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ។ នៃអ្នកដ៏ចម្រើន សមណរាមបុត្រ ជាអ្នកប្រាជ្ញ គ្រាន់បើជាងពួកបរិវាររបស់ស្តេចឯឡេយ្យៈ ដែលជាអ្នកប្រាជ្ញ ជាអ្នកយល់ប្រយោជន៍គ្រាន់បើជាងពួកបរិវារ ដែលអាចយល់ប្រយោជន៍ គ្រាន់បើ ក្នុងកិច្ចតូចនិងកិច្ចធំ ក្នុងពាក្យសម្តីទាបខ្ពស់ទាំងឡាយ ហេតុនោះបានជាពួកបរិវាររបស់ស្តេចឯឡេយ្យៈ ជ្រះថ្លាខ្លាំង ក្នុងសមណរាមបុត្រទាំងធ្វើសេចក្តីឱនលំទោនខ្ពស់បំផុត យ៉ាងនេះ គឺថ្វាយបង្គំ ក្រោកទទួលប្រណម្យដៃ ធ្វើសេចក្តីគោរព ក្នុងសមណរាមបុត្រ ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចំឡែកណាស់ ព្រោះពាក្យនេះ ព្រះគោតមដ៏ចម្រើន បានត្រាស់ត្រូវហើយថា

កោតា កោតមេន អដ្ឋានំ ខោ ឯតំ ព្រាហ្មណ អនវកាសោ យំ អសប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ ឯតម្បិ ខោ ព្រាហ្មណ អដ្ឋានំ អនវកាសោ យំ អសប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ឋានំ ខោ ឯតំ ព្រាហ្មណ វិជ្ជតិ យំ សប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយំ ភវន្តិ ។ ឯតំ ខោ ព្រាហ្មណ ឋានំ វិជ្ជតិ យំ សប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយំ ភវន្តិ ។ ឋាន្វេចតានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ ព្រាហ្មណ កាលំ មញ្ញសីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋា-យាសនា បក្កាមីតិ ។

ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះមិនសមហេតុ មិនសមផលទេ ដែលថា អសប្បុរស គប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ដូច្នេះ ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មិនសមហេតុ មិនសមផលដែរ ដែលថា អសប្បុរស គប្បីស្គាល់សប្បុរសថា អ្នកនេះជាសប្បុរសដូច្នេះ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះទើបមានទំនង ដែលថា សប្បុរស គប្បីស្គាល់សប្បុរសបានថា អ្នកនេះជាសប្បុរស ។ ម្នាលព្រាហ្មណ៍ ការណ៍នុ៎ះ ក៏មានទំនងដែរ ដែលថា សប្បុរស គប្បីស្គាល់អសប្បុរសថា អ្នកនេះជាអសប្បុរស ។ បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំនឹងទៅឥឡូវនេះ ព្រោះយើងខ្ញុំ ជាអ្នកមានកិច្ចច្រើន មានការត្រូវធ្វើច្រើន ។ ម្នាលព្រាហ្មណ៍ ឥឡូវនេះ អ្នកសម្គាល់នូវកាលគួរចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ រីករាយអនុមោទនាភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកទីអង្គុយចេញទៅ ។

## ៩៩

### ចតុត្ថបណ្ណាសកេ យោធាជីវវគ្គោ ចតុត្ថោ

[៣៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ ឧបកោ មណ្ឌិកាបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧបកោ មណ្ឌិកាបុត្តោ ភគវន្តំ ឯតទវោច អហំ ហិ ភន្តេ ឯវំវាទី ឯវំទិដ្ឋី យោ កោចិ បរុបារម្ភំ វត្តេតិ បរុបារម្ភំ វត្តេន្តោ សព្វោ សោ ន ឧប្បាទេតិ អនុប្បាទេន្តោ គារយ្ហោ ហោតិ ឧបវជ្ជោតិ ។ បរុបារម្ភំ ចេ ឧបក វត្តេតិ បរុបារម្ភំ វត្តេន្តោ ន ឧប្បាទេតិ អនុប្បាទេន្តោ គារយ្ហោ ហោតិ ឧបវជ្ជោ ត្វំ ខោ ឧបក បរុបារម្ភំ វត្តេសិ បរុបារម្ភំ វត្តេន្តោ ន ឧប្បាទេសិ អនុប្បាទេន្តោ គារយ្ហោសិ ឧបវជ្ជោតិ ។

ចតុត្ថបណ្ណាសក យោធាជីវវគ្គ ទី ៤

[៣៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ឧបកមណ្ឌិកាបុត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះឧបកមណ្ឌិកាបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះ តែងយល់យ៉ាងនេះថា បុគ្គលណាមួយនិយាយពាក្យតិះដៀលអ្នកដទៃ កាលបើនិយាយពាក្យតិះដៀលអ្នកដទៃ បុគ្គលទាំងអស់នោះឈ្មោះថា មិនញុំាងកុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ ឲ្យកើតឡើងបានទេ ក៏ឈ្មោះថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយទោស ។ ម្នាលឧបកៈ បើបុគ្គលនិយាយពាក្យតិះដៀលអ្នកដទៃ អ្នកដែលនិយាយពាក្យតិះដៀលអ្នកដទៃ រមែងមិនញុំាងកុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ឲ្យកើតឡើងទេ ក៏ឈ្មោះថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយទោស ម្នាលឧបកៈ អ្នកឯងនិយាយពាក្យតិះដៀលអ្នកដទៃ កាលបើអ្នកឯងនិយាយពាក្យតិះដៀលអ្នកដទៃ រមែងមិនញុំាងកុសលធម៌ឲ្យកើតឡើង កាលបើមិនញុំាងកុសលធម៌ឲ្យកើតឡើងបានទេ ក៏ឈ្មោះថា គួរគេតិះដៀលបាន ឈ្មោះថា ប្រកបដោយទោសហើយ ។

សេយ្យថាបិ ភន្តេ ឧម្មុជ្ជមានកំយេវ មហតា បាសេន ពន្ធេយ្យ ឯវមេវ ខោ អហំ ភន្តេ ឧម្មុជ្ជមានកោយេវ ភគវតា មហតា វាទបាសេន ពន្ធោតិ ។ ឥទំ អកុ-សលន្តិ ខោ ឧបក មយា បញ្ញត្តំ តត្ថ អបរិមាណា បទា អបរិមាណា ព្យញ្ជនា អបរិមាណា តថាគតស្ស ធម្មទេសនា ឥតិបីទំ អកុសលន្តិ តំ ខោ បនិទំ អកុសលំ បហាតព្វន្តិ ខោ ឧបក មយា បញ្ញត្តំ តត្ថ អបរិមាណា បទា អបរិមាណា ព្យញ្ជនា អបរិមាណា តថាគតស្ស ធម្មទេសនា ឥតិបីទំ អកុសលំ បហា-តព្វន្តិ ឥទំ កុសលន្តិ ខោ ឧបក មយា បញ្ញត្តំ តត្ថ អបរិមាណា បទា អបរិមាណា ព្យញ្ជនា អបរិមាណា តថាគតស្ស ធម្មទេសនា ឥតិបីទំ កុសលន្តិ តំ ខោ បនិទំ កុសលំ ភាវេតព្វន្តិ ខោ ឧបក មយា បញ្ញត្តំ តត្ថ អបរិមាណា បទា អបរិមាណា ព្យញ្ជនា អបរិមាណា តថាគតស្ស ធម្មទេសនា ឥតិបីទំ កុសលំ ភាវេតព្វន្តិ ។ អថខោ ឧបកោ មណ្ឌិកាបុត្តោ

បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុគ្គលយកអន្ទាក់ដ៏ធំ ទាក់កមនុស្ស ដែលទើបនឹងងើបឡើង (អំពីទឹក) យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែងើបឡើងភ្លាម ត្រូវព្រះមានព្រះភាគទាក់ ដោយអន្ទាក់គឺសម្តីដ៏ធំ ក៏យ៉ាងនោះដែរ ។ ម្នាលឧបកៈ តថាគត បញ្ញត្តទុកហើយថា របស់នេះជាអកុសល បទ ព្យញ្ជនៈ ធម្មទេសនា របស់តថាគតក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា របស់នេះជាអកុសល ព្រោះហេតុដូច្នេះៗ ម្នាលឧបកៈ រឿងនោះ តថាគត បញ្ញត្តទុកហើយថា របស់នេះជាអកុសល គួរតែលះបង់ចេញ បទ ព្យញ្ជនៈ ធម្មទេសនា របស់តថាគត ក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា អកុសលនេះ គួរលះបង់ចេញ ព្រោះហេតុដូច្នេះៗ ម្នាលឧបកៈ តថាគត បញ្ញត្តទុកហើយថា របស់នេះជាកុសល បទ ព្យញ្ជនៈ ធម្មទេសនា របស់តថាគត ក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា របស់នេះជាកុសល ព្រោះហេតុដូច្នេះៗ ម្នាលឧបកៈ រឿងនោះ តថាគត បញ្ញត្តទុកហើយថា របស់នេះជាកុសល គួរតែចម្រើន បទ ព្យញ្ជនៈ ធម្មទេសនា របស់តថាគត ក្នុងរឿងនោះ មានច្រើនប្រមាណមិនបានថា កុសលនេះ គួរតែចម្រើន ព្រោះហេតុដូច្នេះៗ ។ លំដាប់នោះ ឧបកមណ្ឌិកាបុត្រ

ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា យាវតកោ អហោសិ ភគវតា សទ្ធឹ កថាសល្លាបោ តំ សព្វំ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហីបុត្តស្ស អារោចេសិ ។ ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ កុបិតោ អនត្តមនោ ឧបកំ មណ្ឌិកាបុត្តំ ឯតទវោច យាវធំសីវតាយំ លោណការកទារកោ យាវមុខរោ យាវប្បគព្ភោ យត្រ ហិ នាម តំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អបសាទេតព្វំ[១] មញ្ញិស្សតិ អបេហិ តំ ឧបក វិនស្ស មា តំ អទ្ទសន្តិ ។

[៣៩] ចត្តារោមេ ភិក្ខវេ សច្ចិករណីយា ធម្មា ។ កតមេ ចត្តារោ ។ អត្ថិ ភិក្ខវេ ធម្មា កាយេន សច្ចិករណីយា អត្ថិ ភិក្ខវេ ធម្មា សតិយា សច្ចិករណីយា អត្ថិ ភិក្ខវេ ធម្មា ចក្ខុនា សច្ចិករណីយា អត្ថិ ភិក្ខវេ ធម្មា បញ្ញាយ សច្ចិករណីយា ។

១ ឱ. ម. អាសាទេតព្វំ ។

រីករាយ អនុមោទនា ភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកទី អង្គុយក្រាបថ្វាយបង្គំព្រះមានព្រះភាគ ដើរប្រទក្សិណ រួចហើយក៏ចូលទៅគាល់ព្រះបាទអជាតសត្តុវេទេហីបុត្រ ក្នុងដែនមគធៈ លុះចូលទៅដល់ហើយ ក៏ក្រាបទូលរឿងរ៉ាវដែលខ្លួនបានទៅគាល់ ចរចាជាមួយនឹងព្រះមានព្រះភាគគ្រប់ប្រការ ចំពោះព្រះបាទអជាតសត្តុវេទេហីបុត្រ ក្នុងដែនមគធៈ ។ កាលបើឧបកមណ្ឌិកាបុត្រ ក្រាបទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហីបុត្រ ក្នុងដែនមគធៈ ទ្រង់ខ្ញាល់តូចព្រះរាជហឫទ័យ ត្រាស់នឹងឧបកមណ្ឌិកាបុត្រដូច្នេះថា ឱក្មេងអ្នកស្រុកធ្វើអម្បិលនេះ លុបលាងគុណអ្វីម្ល៉េះ មាត់រឹងអ្វីម្ល៉េះ គឃ្លើនអ្វីម្ល៉េះ ព្រោះវាហ៊ានសម្គាល់ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ថាជាមនុស្ស ដែលគេមិនគួររាប់អាន នែឧបកៈ អ្នកឯងចូរចេញទៅ ចូរវិនាសទៅ កុំឲ្យអញឃើញឯង ។

[៣៩] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលត្រូវធ្វើឲ្យជាក់ច្បាស់នេះ មាន ៤ យ៉ាង ។ ធម៌ទាំង ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាមកាយក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយចក្ខុក៏មាន ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា[១] ក៏មាន ។

១ វិបស្សនាបញ្ញា ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយឈានបញ្ញា ឯមគ្គប្បញ្ញា ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយវិបស្សនាបញ្ញា ឯផលប្បញ្ញា សម្រេចដោយមគ្គប្បញ្ញា ឯបច្ចវេក្ខណប្បញ្ញា សម្រេចដោយផលបញ្ញា ។ អដ្ឋកថា ។

កតមេ ច ភិក្ខវេ ធម្មា កាយេន សច្ឆិករណីយា ។ អដ្ឋ មោក្ខា[១] ភិក្ខវេ កាយេន សច្ឆិករណីយា ។ កតមេ ច ភិក្ខវេ ធម្មា សតិយា សច្ឆិករណីយា ។ បុព្វេនិវាសោ ភិក្ខវេ សតិយា សច្ឆិករណីយា ។ កតមេ ច ភិក្ខវេ ធម្មា ចក្ខុនា សច្ឆិករណីយា ។ សត្តានំ ចុតុបបាតោ ភិក្ខវេ ចក្ខុនា សច្ឆិករណីយា ។ កតមេ ច ភិក្ខវេ ធម្មា បញ្ញាយ សច្ឆិករណីយា ។ អាសវានំ ខយោ ភិក្ខវេ បញ្ញាយ សច្ឆិករណីយា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ សច្ឆិករណីយា ធម្មាតិ ។

[៤០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ ភិក្ខុសង្ឃបរិវុតោ និសិន្នោ ហោតិ ។ អថខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ

១ ឱ. ម. វិមោក្ខា ។

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាមកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មោក្ខធម៌ ៨ ជាធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយនាមកាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុព្វេនិវាស ជាធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយសតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយចក្ខុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការច្យុតនិងការកើតឡើង របស់សត្វទាំងឡាយ ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការអស់អាសវៈ ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ទាំង ៤ នេះឯង ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ។

[៩០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមិគារមាតុប្បាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់មានព្រះភិក្ខុសង្ឃចោមរោម គង់នៅក្នុងថ្ងៃឧបោសថនោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ទតឃើញភិក្ខុសង្ឃ នៅស្ងៀមស្ងាត់ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា

១០៣

ចតុត្ថបណ្ណាសកេ យោធាជីវវគ្គោ ចតុត្ថោ

អប្បលាបាយំ ភិក្ខវេ បរិសា និប្បលាបាយំ ភិក្ខវេ បរិសា សុទ្ធា សារេ បតិដ្ឋិតា តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសា យថារូបា បរិសា ទុល្លភា ទស្សនាយបិ លោកស្មឹ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសា យថារូបា បរិសា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសា យថារូបាយ បរិសាយ អប្បម្បិ ទិន្នំ ពហុំ ហោតិ ពហុំ ទិន្នំ ពហុតរំ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសា យថារូបំ បរិសំ អលំ យោជនគណនានិបិ ទស្សនាយ គន្តុំ អបិ បុដំសេនាបិ ។ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ ។ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ទេវប្បត្តា វិហរន្តិ

ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មិនមានការចរចាអ្វី ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មិនមានការស្តីនិយាយអ្វី ជាបរិសទ្យស្អាតតាំងនៅក្នុងខ្លឹមធម៌ បរិសទ្យមានសភាពយ៉ាងណា ដែលក្រនឹងបានឃើញក្នុងលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ បរិសទ្យមានសភាពយ៉ាងណា ដែលគួរទទួលគ្រឿងបូជា គួរទទួលរបស់ ទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ ទានមានប្រមាណតិច ដែលគេឲ្យដល់បរិសទ្យមានសភាពយ៉ាងណា ហើយបានផលច្រើន ទានច្រើន ដែលគេឲ្យហើយរឹងរឹតតែមានផលច្រើនឡើងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ បរិសទ្យណា ដែលគួរគេស្ពាយស្បៀងទៅមើល សូម្បីអស់ទីពប់ទាំងយោជន៍ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ មានគុណសម្បត្តិយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពជាទេវតា[១]

---

១ បានសម្រេចទិព្វវិហារធម៌ ជាធម៌ឲ្យកើតជាឧបបត្តិទេពផង សម្រេចអរហត្ត ព្រោះទិព្វវិហារធម៌ គឺនៅក្នុងចតុត្ថជ្ឈាន ហើយបានសម្រេចអរហត្តផង ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ព្រហ្មប្បត្តា វិហរន្តិ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អានេញ្ជប្បត្តា វិហរន្តិ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរិយប្បត្តា វិហរន្តិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ទេវប្បត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧប-សម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧប-សម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ទេវប្បត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ព្រហ្មប្បត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពជាព្រហ្ម[១] ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពមិនញាប់ញ័រ[២] ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុដែលសម្រេចភាពជាអរិយៈ[៣] ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាទេវតា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈវិចារៈបាន ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ព្រោះប្រាសចាកបីតិ ។ បេ ។ ចូលកាន់តតិយជ្ឈាន ព្រោះលះសុខបានផង លះទុក្ខបានផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាទេវតា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាព្រហ្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទិសខាងលើ ខាងក្រោម និងទទឹង គឺទិសតូចៗ

---

១ បានសម្រេចព្រហ្មវិហារធម៌ ជាធម៌ឲ្យបានកើតជាព្រហ្មផង សម្រេចអរហត្ត ព្រោះព្រហ្មវិហារធម៌ គឺនៅក្នុងព្រហ្មវិហារធម៌ទាំង ៤ ហើយសម្រេចអរហត្តផង ។
២ បានសម្រេចឈានមិនញាប់ញ័រ ជាឈានឲ្យសម្រេចភាពមិនញាប់ញ័រផង សម្រេចអរហត្តបាន ព្រោះឈានមិនញាប់ញ័រ គឺនៅក្នុងអរូបជ្ឈានទាំង ៤ ហើយសម្រេចអរហត្តផង ។
៣ កន្លងភាពជាបុថុជ្ជន ហើយសម្រេចភាពជាអរិយៈ គឺបានសម្រេចមគ្គ ៤ ផល ៣ ចំពោះតែអរិយសច្ចទាំង ៤ ។ អដ្ឋកថា ។

សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ព្រហ្មប្បត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អានេញ្ជប្បត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម

មានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកកទាំងមូល ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងអស់ មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទិសខាងលើ ខាងក្រោម និងទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាព្រហ្មយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពមិនញាប់ញ័រ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងរូបសញ្ញា ដោយអាការទាំងពួង ព្រោះរលត់បដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ពិចារណាថា អាកាសមិនមានទីបំផុត បានសម្រេចអាកាសនញ្ចាយតនជ្ឈាន កន្លងអាកាសានញ្ចាយតនជ្ឈាន ដោយអាការទាំងពួង ហើយ ពិចារណាថា វិញ្ញាណ មិនមានទីបំផុត បានសម្រេចវិញ្ញាណញ្ចាយតនជ្ឈាន កន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយអាការទាំងពួង

នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អានេញ្ជប្បត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរិយប្បត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយប្បត្តោ ហោតីតិ ។

យោធាជីវវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

យោធា បាដិភោគ សុតំ
អភយំ សមណសច្ចេន បញ្ចមំ
ឧម្មគ្គវស្សការោ ឧបកោ
សច្ឆិកិរិយា ច ឧបោសថោតិ ។

*ហើយពិចារណាថា របស់អ្វីតិចតួចមិនមាន បានសម្រេចអាកិញ្ចញ្ញាយ-តនជ្ឈាន កន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយអាការទាំងពួង ហើយបានសម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពមិនញាប់ញ័រយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសម្រេចភាពជាអរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលសម្រេចភាពជាអរិយៈយ៉ាងនេះឯង ។*

ចប់ យោធាជីវវគ្គ ទី ៤ ។

## ឧទ្ទាននៃយោធាជីវវគ្គនោះគឺ

*និយាយអំពីការប្រៀបធៀបនឹងយោធាជីវៈ ១ ការធានាមិនបាន ១ របស់ដែលឮហើយ ១ ការមិនខ្លាចស្លាប់ ១ និងសមណសច្ចៈ ១ ជាគម្រប់ប្រាំ រឿងភិក្ខុឆ្លាស ១ វស្សការព្រាហ្មណ៍ ១ រឿងឧបកៈ ១ ធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ ១ ព្រះមានព្រះភាគទ្រង់គង់ក្នុងថ្ងៃឧបោសថ ១ ។*

# មហាវគ្គោ បញ្ចមោ

[៤១] សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា សុប្បដិវិទ្ធានំ ចត្តារោ[១] អានិសំសា បាដិកង្ខា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស តេ ធម្មា សោតានុ-គតា ហោន្តិ វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ សោ មុដ្ឋស្សតិ កាលំ កុរុមានោ អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ ។ តស្ស តត្ថ សុខិនោ ធម្មបទា បិលបន្តិ[២] ។ ទន្ធោ ភិក្ខវេ សតុប្បាទោ អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ ។ សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា សុប្បដិវិទ្ធានំ អយំ បឋមោ អានិសំសោ បាដិកង្ខោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ

១ ម. ចត្តារោមេ ។ ២ ឱ. ធម្មបទានិបិ លបន្តិ ។ ម. ធម្មបទា បិលវន្តិ ។

# មហាវគ្គ ទី ៥

[៤១] ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ជាធម៌ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ។ អានិសង្ស ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រៀនទូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្ម វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិបាន ។ ភិក្ខុនោះ ភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកធម៌ទាំងឡាយ រមែងប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខ ក្នុងទេវនិកាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថាជាការយឺតយូរ[១] ឯសត្វនោះ វេលាដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ១ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀនទូវធម៌គឺ សុត្តៈ គេយ្យៈ

១ ស្មារតីដែលកើតឡើង ១ ភ្លែត ទុកជាយឺតយូរ ឯសត្វដែលមានអានិសង្សធម៌ក្នុងខ្លួន វេលានឹងសម្រេចមគ្គផលបានឆាប់រហ័សជាងស្មារតី ១ ភ្លែតនោះឯង ។

វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស តេ ធម្មា សោតានុគតា ហោន្តិ វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ សោ មុដ្ឋស្សតិ កាលំ កុរុមានោ អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ ។ តស្ស តត្ថ នហេវ ខោ សុខិនោ ធម្មបទា បិលបន្តិ អបិច ខោ ឥទ្ធិមា ចេតោវសិប្បត្តោ ទេវបរិសាយ ធម្មំ ទេសេតិ ។ តស្ស ឯវំ ហោតិ អយំ វា សោ ធម្មវិនយោ យត្ថាហំ បុព្វេ ព្រហ្មចរិយំ អចរិន្តិ ។ ទន្ធោ ភិក្ខវេ សតុប្បា-ទោ អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ កុសលោ ភេរិសទ្ទស្ស សោ អទ្ធានមគ្គប្បដិបន្នោ ភេរិសទ្ទំ សុណេយ្យ តស្ស នហេវ ខោ អស្ស កង្ខា វា វិមតិ វា ភេរិសទ្ទោ នុ ខោ ន នុ ខោ ភេរិសទ្ទោតិ អថខោ ភេរិសទ្ទោត្វេវ និដ្ឋំ គច្ឆេយ្យ

វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ធម៌ទាំងនោះជាសភាវៈ ចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ ។ ភិក្ខុនោះភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនសូវប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខក្នុងទេវនិកាយនោះ ប៉ុន្តែជាអ្នកមានឫទ្ធិដល់នូវសេចក្តីស្ទាត់ជំនាញខាងផ្លូវចិត្ត សម្តែងធម៌ដល់ទេវបរិសទ្យបាន ។ ទេវតានោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា នេះគឺធម្មវិន័យនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិឈ្មោះថាយឺតយូរ សត្វនោះដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសជាអ្នកឈ្លាសវៃ ខាងសំឡេងស្គរ បុរសនោះដើរទៅកាន់ផ្លូវឆ្ងាយ បានឮសំឡេងស្គរ បុរសនោះ ក៏មិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់នឹងសំឡេងស្គរនោះថា សំឡេងស្គរមែន ឬមិនមែនសំឡេងស្គរទេ ដូច្នេះឡើយ បុរសនោះគប្បីដល់នូវសេចក្តីចូលចិត្តថាសំឡេងស្គរ ដោយពិត

១០៩



ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ ។ បេ ។ ខិប្បំយេវ វិសេសគាមី ហោតិ សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា សុប្បដិវិទ្ធានំ អយំ ទុតិយោ អានិសំសោ បាដិកង្ខោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស តេ ធម្មា សោតានុគតា ហោន្តិ វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ សោ មុដ្ឋស្សតិ កាលំ កុរុមានោ អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ ។ តស្ស តត្ថ នហេវ ខោ សុខិនោ ធម្មបទា បិលបន្តិ នបិ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ ទេវបរិសាយ ធម្មំ ទេសេតិ ។ អបិច ខោ ទេវបុត្តោ ទេវបរិសាយ ធម្មំ ទេសេតិ ។ តស្ស ឯវំ ហោតិ អយំ វា សោ ធម្មវិនយោ យត្ថាហំ បុព្វេ ព្រហ្មចរិយំ អចរិន្តិ ។ ទន្ធោ ភិក្ខវេ សតុប្បាទោ អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ ។

មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។ បេ ។ ជាអ្នកដល់នូវគុណវិសេស ឆាប់រហ័ស ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ ។ ភិក្ខុនោះ ភ្លេចស្មារតីធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខក្នុងទេវនិកាយនោះឡើយ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសម្តែងធម៌ ដល់ទេវបរិសទ្យបានឡើយ ។ គ្រាន់តែជាទេវបុត្ត អាចសម្តែងធម៌ ដល់ទេវបរិសទ្យបានប៉ុណ្ណោះ ។ ទេវបុត្តនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញបានប្រព្រឹត្ត ព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា នេះគឺធម្មវិន័យនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិឈ្មោះថាយឺតយូរ សត្វនោះដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។

សេយ្យថាបិ ភិក្ខវេ បុរិសោ កុសលោ សង្ខសទ្ទស្ស សោ អទ្ធានមគ្គប្បដិបន្នោ សង្ខសទ្ទំ សុណេយ្យ តស្ស នហេវ ខោ អស្ស កង្ខា វា វិមតិ វា សង្ខសទ្ទោ នុ ខោ ន នុ ខោ សង្ខសទ្ទោតិ អថខោ សង្ខសទ្ទោត្វេវ និដ្ឋំ គច្ឆេយ្យ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ ។ បេ ។ ខិប្បំយេវ វិសេសគាមី ហោតិ ។ សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា សុប្បដិវិទ្ធានំ អយំ តតិយោ អានិសំសោ បាដិ-កង្ខោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មំ បរិយា-បុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស តេ ធម្មា សោតានុគតា ហោន្តិ វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ សោ មុដ្ឋស្សតិ កាលំ កុរុមានោ អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ ។ តស្ស តត្ថ នហេវ ខោ សុខិនោ ធម្មបទា បិលបន្តិ នបិ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរស ជាអ្នកឈ្លាសវៃនឹងសំឡេងស័ង្ខ បុរសនោះដើរទៅកាន់ផ្លូវឆ្ងាយ បានឮសំឡេងស័ង្ខ បុរសនោះក៏មិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់នឹងសំឡេងស័ង្ខនោះថា សំឡេងស័ង្ខមែន ឬមិនមែនសំឡេងស័ង្ខទេ បុរសនោះគប្បីដល់នូវសេចក្តីចូលចិត្តថា ជាសំឡេងស័ង្ខដោយពិត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។ បេ ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៣ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់ត្រចៀករឿយៗ នៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ ។ ភិក្ខុនោះ ក៏ភ្លេចស្មារតី ធ្វើមរណ-កាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដដល់ភិក្ខុនោះ ដែលមានសេចក្តីសុខក្នុងទេវនិកាយនោះ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញខាងផ្លូវចិត្ត

ទេវបរិសាយ ធម្មំ ទេសេតិ នបិ ទេវបុត្តោ ទេវបរិ-
សាយ ធម្មំ ទេសេតិ អបិច ខោ ឱបបាតិកោ
ឱបបាតិកំ សារេតិ សរសិ ត្វំ មារិស យត្ថ មយំ
បុព្វេ ព្រហ្មចរិយំ អចរិម្ហាតិ ។ សោ ឯវមាហ
សរាមិ មារិស សរាមិ មារិសាតិ ។ ទន្ធោ ភិក្ខវេ
សតុប្បាទោ អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី
ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទ្វេ សហាយកា
សហបំសុកីឡកា តេ កទាចិ ករហចិ កត្ថចិ
អញ្ញមញ្ញំ សមាគច្ឆេយ្យុំ តមេនំ សហាយកោ[១]
សហាយកំ ឯវំ វទេយ្យ ឥទម្បិ[២] សម្ម សរសីតិ ។
សោ ឯវំ វទេយ្យ សរាមិ សម្ម សរាមិ សម្មាតិ
ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ធម្មំ បរិយាបុណាតិ ។ បេ ។
ខិប្បំយេវ វិសេសគាមី ហោតិ ។ សោតានុគតានំ ភិក្ខវេ
ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា
សុប្បដិវិទ្ធានំ អយំ ចតុត្ថោ អានិសំសោ ចាដិកង្ខោ ។

---

១ ម. អញ្ញោ បន សហាយកោ ។ ២ ឱ. ម. ឥទម្បិ សម្ម សរសិ ឥទម្បិ មេ សម្ម សរសីតិ ។

ហើយសម្តែងធម៌ ដល់ទេវបរិសទ្យ ទាំងមិនមែនជាទេវបុត្ត អាចសម្តែងធម៌ ដល់ទេវបរិសទ្យបានទេ តែបើមានឱបបាតិកសត្វ រំលឹកនូវឱបបាតិកសត្វថា ម្នាលគ្នាយើង ពួកយើងបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុនក្នុងធម្មវិន័យណា អ្នករលឹកបាននូវធម្មវិន័យនោះដែរឬ ។ ទេវបុត្តនោះក៏និយាយយ៉ាងនេះថា ម្នាលគ្នាយើង យើងរលឹកបាន ម្នាលគ្នាយើង យើងរលឹកបាន ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិឈ្មោះថាយឺតយូរ សត្វនោះដល់នូវគុណវិសេស ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចសំឡាញ់ពីរនាក់ លេងអាចម៍ដីជាមួយគ្នា សំឡាញ់ទាំងពីរនាក់នោះ មកជួបគ្នាក្នុងទីណាម្តងៗ សំឡាញ់ម្នាក់ក៏និយាយទៅនឹងសំឡាញ់ម្នាក់នោះយ៉ាងនេះថា នែសំឡាញ់ ឯងរលឹកបាននូវហេតុនេះដែរឬទេ ។ សំឡាញ់នោះ គប្បីតបយ៉ាងនេះថា នែសំឡាញ់ អញរលឹកបាន នែសំឡាញ់ អញរលឹកបាន មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។ បេ ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។

សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ មនសានុបេក្ខិតានំ ទិដ្ឋិយា សុប្បដិវិទ្ធានំ ឥមេ ចត្តារោ អានិសំសា បាដិកង្ខាតិ ។

[៤២] ចត្តារីមានិ ភិក្ខវេ ឋានានិ ចតូហិ ឋានេហិ វេទិតព្វានិ ។ កតមានិ ចត្តារិ ។ សំវាសេន ភិក្ខវេ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា(១) បញ្ញវតា នោ ទុប្បញ្ញេន(២) ។ សំវោហារេន ភិក្ខវេ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេន ។ អាបទាសុ ភិក្ខវេ ថាមោ វេទិតព្វោ សោ ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេន ។ សាកច្ឆាយ ភិក្ខវេ បញ្ញា វេទិតព្វា

---

១ ម. អមនសិករោតា ។ ២ ម. ទុប្បញ្ញេនាតីតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង ៤ ប្រការនេះនៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ចាក់ធ្លុះ ដោយទិដ្ឋិ រមែងកើតប្រាកដ ។

[៩២] ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ នេះ បុគ្គលគប្បីដឹងច្បាស់ដោយហេតុ ៤ ប្រការ ។ ហេតុ ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សីល បុគ្គលគប្បីដឹងបាន ដោយការនៅរួមគ្នា តែសីលនោះបុគ្គលធ្វើទុកក្នុងចិត្តខ្លីខ្លាមិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន ទាំងបុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្អាតបុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្តីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្លីខ្លាមិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបាន ទាំងបុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំង បុគ្គលគប្បីដឹងបានក្នុងកាលដែលមានសេចក្តីអន្តរាយ តែកម្លាំងនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្លីខ្លាមិនគប្បីដឹងបានទេ បុគ្គលមានប្រាជ្ញាដោយមិនធ្វើទុកក្នុងចិត្ត ក៏មិនគប្បីដឹងបានទាំងបុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញា បុគ្គលគប្បីដឹងបានដោយការសាកច្ឆា

សា ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិការោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេន ។ សំវាសេន ភិក្ខវេ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិការោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សំវសមានោ ឯវំ ជានាតិ ទីឃរត្តំ ខោ អយមាយស្មា ខណ្ឌការី ឆិទ្ទការី សពលការី កម្មាសការី ន សតតការី ន សតតវុត្តី[១] សីលេសុ ទុស្សីលោ អយមាយស្មា នាយមាយស្មា សីលវាតិ ។ ឥធ បន ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សំវសមានោ ឯវំ ជានាតិ ទីឃរត្តំ ខោ អយមាយស្មា អខណ្ឌការី អច្ឆិទ្ទការី អសពលការី អកម្មាសការី សតតការី សតតវុត្តី

១ ឱ. សន្តតការី ន សន្តតវុត្តី ។

ក៏តែប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា មិនគប្បីដឹងបាន ដោយកាលជាអង្វែង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សីលគឺបុគ្គលដឹងបាន ដោយការនៅរួមគ្នា តែសីលនោះបុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលនៅរួមជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា យូរមកហើយ លោកមានអាយុនេះ ជាអ្នកធ្វើសីលឲ្យដាច់ ធ្វើសីលឲ្យធ្លុះ ធ្វើសីលឲ្យពព្រុស ធ្វើសីលឲ្យពពាល មិនមែនជាអ្នកធ្វើសីលឲ្យខ្ជាប់ខ្ជួន មិនមែនជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ លោកមានអាយុនេះ ជាអ្នកទ្រុស្តសីល លោកមានអាយុនេះ មិនមែនជាអ្នកមានសីលទេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលក្នុងលោកនេះ កាលនៅរួមជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា យូរមកហើយ លោកមានអាយុនេះ មិនមែនជាអ្នកធ្វើសីលឲ្យដាច់ មិនមែនធ្វើសីលឲ្យធ្លុះ មិនមែនធ្វើសីលឲ្យពព្រុស មិនមែនធ្វើសីលឲ្យពពាលទេ ជាអ្នកធ្វើសីលឲ្យខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តខ្ជាប់ខ្ជួន

សីលេសុ សីលវា អយមាយស្មា នាយមាយស្មា ទុស្សីលោតិ ។ សំវាសេន ភិក្ខវេ សីលំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ សំវោហារេន ភិក្ខវេ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សំវោហារមានោ ឯវំ ជានាតិ អញ្ញថា ខោ អយមាយស្មា ឯកេន ឯកោ វោហរតិ អញ្ញថា ទ្វីហិ អញ្ញថា តីហិ អញ្ញថា សម្ពហុលេហិ វោក្កមតិ

ក្នុងសីលទាំងឡាយ លោកមានអាយុនេះ ជាអ្នកមានសីល លោកមានអាយុនេះ មិនមែនទ្រុស្តសីលឡើយ ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សីលបុគ្គលគប្បីដឹងបាន ដោយការនៅរួមគ្នា តែសីលនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ គឺតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីស្អាតបុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្តីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញា ក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនោះ ពាក្យនុ៎ះគឺតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលនិយាយជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា លោកមានអាយុនេះ កាលនិយាយជាមួយនឹងមនុស្សម្នាក់ ដោយឡែកផ្សេង លុះនិយាយនឹងមនុស្សពីរនាក់ ដោយឡែកផ្សេង និយាយនឹងមនុស្ស ៣ នាក់ ដោយឡែកផ្សេង និយាយនឹងមនុស្សច្រើននាក់ ដោយឡែកផ្សេង

១១៨



អយមាយស្មា បុរិមវោហារា បច្ឆិមវោហារំ អបរិ-
សុទ្ធវោហារោ អយមាយស្មា ណាយមាយស្មា បរិសុទ្ធ-
វោហារោតិ ។ ឥធ បន ភិក្ខវេ បុគ្គលោ បុគ្គលេន
សទ្ធឹ សំវោហារមាណោ ឯវំ ជាណាតិ យថា ខោ
អយមាយស្មា ឯកេន ឯកោ វោហារតិ តថា ទ្វីហិ តថា
តីហិ តថា សម្ពហុលេហិ ណាយមាយស្មា វោក្កមតិ
បុរិមវោហារា បច្ឆិមវោហារំ បរិសុទ្ធវោហារោ អយមា-
យស្មា ណាយមាយស្មា អបរិសុទ្ធវោហារោតិ ។ សំវោហា-
រេន ភិក្ខវេ សោចេយ្យំ វេទិតព្វំ តញ្ច ខោ ទីឃេន
អទ្ធុណា ន ឥត្តរំ មនសិករោតោ ណោ អមនសិករោតោ
បញ្ញវតា ណោ ទុប្បញ្ញេណាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ
បដិច្ច វុត្តំ ។ អាបទាសុ ភិក្ខវេ ថាមោ វេទិតព្វោ

មុន លោកមានអាយុនេះ និយាយពាក្យក្រោយខុសគ្នានឹងពាក្យមុន លោកមានអាយុនេះ មានសម្តីមិនបរិសុទ្ធទេ លោកដ៏មានអាយុនេះ មិនមែនជាអ្នកមានសម្តីបរិសុទ្ធទេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលក្នុងលោកនេះ កាលនិយាយជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា លោកមានអាយុនេះ តែម្នាក់ឯង តែងនិយាយនឹងមនុស្សម្នាក់យ៉ាងណា និយាយនឹងមនុស្សពីរនាក់ ក៏យ៉ាងនោះដែរ និយាយនឹងមនុស្ស ៣ នាក់ក៏យ៉ាងនោះដែរ និយាយនឹងមនុស្សច្រើននាក់ក៏យ៉ាងនោះដែរ លោកមានអាយុនេះ និយាយពាក្យក្រោយមិនខុសគ្នានឹងពាក្យមុន លោកមានអាយុនេះ ជាអ្នកមានសម្តីបរិសុទ្ធ លោកមានអាយុនេះ មិនមែនជាអ្នកមានសម្តីមិនបរិសុទ្ធទេ ។ ពាក្យណា ដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីស្អាតបុគ្គលគប្បីដឹងបាន ដោយការនិយាយគ្នា តែសេចក្តីស្អាតនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ កម្លាំងបុគ្គលគប្បីដឹងបាន ក្នុងកាលដែលមានអន្តរាយ

សោ ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិករោតា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ឯកច្ចោ ញាតិព្យសនេន វា ផុដ្ឋោ សមានោ ភោគព្យសនេន វា ផុដ្ឋោ សមានោ រោគព្យសនេន វា ផុដ្ឋោ សមានោ ន ឥតិ បដិ-សញ្ចិក្ខតិ តថាភូតោ ខោ អយំ លោកសន្និវាសោ តថាភូតោ អត្តភាវប្បដិលាភោ យថាភូតេ លោក-សន្និវាសេ យថាភូតេ អត្តភាវប្បដិលាភេ អដ្ឋ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា ច បសំសា ច សុខញ្ច ទុក្ខញ្ចាតិ ។ សោ ញាតិព្យសនេន វា ផុដ្ឋោ សមានោ ភោគព្យសនេន វា ផុដ្ឋោ សមានោ រោគព្យ-សនេន វា ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ ញាតិព្យសនេន វា ផុដ្ឋោ សមានោ

តែកម្លាំងនុ៎ះបុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសនៃភោគសម្បទពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសដោយរោគពាល់ត្រូវក្តី មិនពិចារណាឲ្យឃើញច្បាស់ថា លោកសន្និវាស និងការបាននូវអត្តភាពនេះកើតឡើងតាមទំនង ដែលលោកធម៌ទាំង ៨ តែងប្រព្រឹត្តទៅតាមសត្វលោក ក្នុងលោកសន្និវាស និងការបាននូអត្តភាព (នោះឯង) ទាំងសត្វលោក ក៏រមែងប្រព្រឹត្តទៅតាមលោកធម៌ទាំង ៨ ប្រការ គឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ លុះបុគ្គលនោះ ត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសនៃភោគសម្បទពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសដោយរោគពាល់ត្រូវក្តី ក៏សោកសង្រេង លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេងវេងវោង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះទៀត ក្នុងលោកនេះ ជាអ្នកត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវក្តី

ភោគព្យសនេន វា ផុដ្ឋោ សមានោ រោគព្យសនេន វា ផុដ្ឋោ សមានោ ឥតិ បដិសញ្ចិក្ខតិ តថាភូតោ ខោ អយំ លោកសន្និវាសោ តថាភូតោ អត្តភាវប្បដិលាភោ យថាភូតេ លោកសន្និវាសេ យថាភូតេ អត្តភាវប្បដិលាភេ អដ្ឋ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា បសំសា ច សុខញ្ច ទុក្ខញ្ចាតិ ។ សោ ញាតិព្យសនេន វា ផុដ្ឋោ សមានោ ភោគព្យសនេន វា ផុដ្ឋោ សមានោ រោគព្យសនេន វា ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អាបទាសុ ភិក្ខវេ ថាមោ វេទិតព្វោ សោ ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិករោតា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ សាកច្ឆាយ ភិក្ខវេ បញ្ញា វេទិតព្វា

ត្រូវសេចក្តីវិនាសនៃភោគសម្ប័ទពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសដោយរោគពាល់ត្រូវក្តី ទើបពិចារណាឃើញច្បាស់ដូច្នេះថា លោកសន្និវាសនិងការបាននូវអត្តភាពនេះ កើតឡើងតាមទំនង ដែលលោកធម៌ទាំង ៨ រមែងប្រព្រឹត្តទៅតាមសត្វលោក ក្នុងលោកសន្និវាស និងការបាននូវអត្តភាព (នោះឯង) ទាំងសត្វលោក ក៏រមែងប្រព្រឹត្តទៅតាមលោកធម៌ទាំង ៨ ប្រការគឺ លាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ លុះបុគ្គលនោះ កាលត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសនៃភោគសម្ប័ទពាល់ត្រូវក្តី ត្រូវសេចក្តីវិនាសដោយរោគពាល់ត្រូវក្តី មិនសោកសង្រេង មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង ទ្រហោយំ មិនដល់នូវសេចក្តីវង្វេងផេងផោង ។ ពាក្យណាដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ កម្លាំង បុគ្គលគប្បីដឹងបាន ក្នុងកាលដែលមានសេចក្តីអន្តរាយ តែកម្លាំងនោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាបុគ្គលគប្បីដឹងបាន ដោយការសាកច្ឆា

សា ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា
នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេនាតិ
ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។
ឥធ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សាកច្ឆាយ-
មានោ ឯវំ ជានាតិ យថា ខោ ឥមស្ស អាយស្មតោ
ឧម្មង្គោ យថា ច អភិនីហារោ យថា ច បញ្ហា-
សមុទាចារោ ទុប្បញ្ញោ អយមាយស្មា នាយមាយស្មា
បញ្ញវា ។ តំ កិស្ស ហេតុ ។ តថា ហិ អយមា-
យស្មា ន ចេវ គម្ភីរំ អត្ថបទំ ឧទាហរតិ សន្តំ
បណីតំ អតក្កាវចរំ និបុណំ បណ្ឌិតវេទនីយំ យញ្ច
អយមាយស្មា ធម្មំ ភាសតិ តស្ស ច ន បដិពលោ
សង្ខិត្តេន វា វិត្ថារេន វា អត្ថំ អាចិក្ខិតុំ ទេសេតុំ
បញ្ញាបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុំ
ទុប្បញ្ញោ អយមាយស្មា នាយមាយស្មា បញ្ញវាតិ ។

ក៏ប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជាមិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញា ព្រោះការមិនធ្វើទុកក្នុងចិត្តក៏មិនគប្បីដឹងបាន បុគ្គលឥតប្រាជ្ញាក៏មិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ កាលពោលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា រមែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកមានអាយុនេះ យ៉ាងណាមួយទៀត អភិនីហារ[១] របស់លោកមានអាយុនេះ យ៉ាងណាការចោទសួរប្រស្នារបស់លោកមានអាយុនេះ យ៉ាងណា លោកមានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកមានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាដោយសេចក្តីពិត លោកមានអាយុនេះ មិនសម្តែងនូវអត្ថនិងបទ ដ៏ជ្រាលជ្រៅដ៏ស្អាត ឧត្តម បុគ្គលមិនគប្បីស្ទង់ប្រមើលដោយការត្រិះរិះ ជាធម៌ល្អិតមានតែបណ្ឌិតទើបដឹងបាន មួយទៀត លោកមានអាយុនេះ ពោលនូវធម៌ឯណា មិនអាចនឹងប្រាប់ សម្តែង បញ្ញត្ត តែងតាំងបើកចំហ ចែករលែក ធ្វើឲ្យរាក់ឡើងនូវសេចក្តីអធិប្បាយនៃធម៌នោះដោយសង្ខេប ឬដោយពិស្តារឡើយ លោកមានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកមានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេ ។

១ អដ្ឋកថា ថា ការបង្អោនចិត្តទៅដោយការតាក់តែងប្រស្នា ។

១១៩



សេយ្យថាបិ ភិក្ខវេ ចក្ខុមា បុរិសោ ឧទករហទស្ស តីរេ ឋិតោ បស្សេយ្យ បរិត្តំ មច្ឆំ ឧម្មុជ្ជមានំ តស្ស ឯវមស្ស យថា ខោ ឥមស្ស មច្ឆស្ស ឧម្មង្គោ យថា ច ឩមិឃាតោ យថា ច វេគាយិតត្តំ បរិត្តោ អយំ មច្ឆោ នាយំ មច្ឆោ មហន្តោតិ ឯវមេវ ខោ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សាកច្ឆាយ-មានោ ឯវំ ជានាតិ យថា ខោ ឥមស្ស អាយស្មតោ ឧម្មង្គោ ។ បេ ។ ទុប្បញ្ញោ អយមាយស្មា នាយ-មាយស្មា បញ្ញវាតិ ឥទ បន ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សាកច្ឆាយមានោ ឯវំ ជានាតិ យថា ខោ ឥមស្ស អាយស្មតោ ឧម្មង្គោ យថា ច អភិនីហារោ យថា ច បញ្ហសមុទាចារោ បញ្ញវា អយមាយស្មា នាយមាយស្មា ទុប្បញ្ញោ ។ តំ កិស្ស ហេតុ ។ តថា ហិ អយមាយស្មា គម្ភីរញ្ចេវ អត្ថបទំ ឧទាហរតិ សន្តំ បណីតំ អតក្កាវចរំ និបុណំ

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានចក្ខុ ឈរក្បែរមាត់ច្រាំងនៃអន្លង់ទឹក គប្បីឃើញត្រីតូចកំពុងងើបឡើង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ការងើបឡើងនៃត្រីនេះយ៉ាងណា មួយទៀត ការពន្លៀកនៃត្រីនេះយ៉ាងណា សន្ទុះនៃត្រីនេះយ៉ាងណា ត្រីនេះជាត្រីតូច ត្រីនេះ មិនមែនជាត្រីធំទេ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលសាកច្ឆា ជាមួយនឹងបុគ្គលផងគ្នា រមែងដឹងច្បាស់យ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកមានអាយុនេះ យ៉ាងណា ។ បេ ។ លោកមានអាយុនេះ ជាអ្នកឥតប្រាជ្ញា លោកមានអាយុនេះ មិនមែនជាអ្នកមានប្រាជ្ញាទេ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលក្នុងលោកនេះ កាលសាកច្ឆាជាមួយនឹងបុគ្គលផងគ្នា រមែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកដ៏មានអាយុនេះ យ៉ាងណា មួយទៀត អភិនីហារនៃលោកមានអាយុនេះ យ៉ាងណា ការចោទសួរនូវប្រស្នានៃលោកមានអាយុនេះ យ៉ាងណា លោកមានអាយុនេះ ជាអ្នកមានប្រាជ្ញា លោកមានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាដោយសេចក្តីពិត លោកមានអាយុនេះ តែងសម្តែងនូវអត្ថនិងបទដ៏ជ្រៅដ៏ស្អាត ឧត្តម បុគ្គលមិនគប្បីស្ទង់ប្រមើលដោយការត្រិះរិះ ជាធម៌ល្អិត

បណ្ឌិតវេទនីយំ យញ្ច អយមាយស្មា ធម្មំ ភាសតិ តស្ស ច បដិពលោ សង្ខិត្តេន វា វិត្ថារេន វា អត្ថំ អាចិក្ខិតុំ ទេសេតុំ បញ្ញាបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុំ បញ្ញវា អយមាយស្មា ណាយមាយស្មា ទុប្បញ្ញោតិ ។ សេយ្យថាបិ ភិក្ខវេ ចក្ខុមា បុរិសោ ឧទករហទស្ស តីរេ ឋិតោ បស្សេយ្យ មហន្តំ មច្ឆំ ឧម្មុជ្ជមានំ តស្ស ឯវមស្ស យថា ខោ ឥមស្ស មច្ឆស្ស ឧម្មង្គោ យថា ច ឩមិឃាតោ យថា ច វេគាយិតត្តំ មហន្តោ អយំ មច្ឆោ ណាយំ មច្ឆោ បរិត្តោតិ ឯវមេវ ខោ ភិក្ខវេ បុគ្គលោ បុគ្គលេន សទ្ធឹ សាកច្ឆាយមានោ ឯវំ ជានាតិ យថា ខោ ឥមស្ស អាយស្មតោ ឧម្មង្គោ ។ បេ ។ បញ្ញវា អយមាយស្មា ណាយមាយស្មា ទុប្បញ្ញោតិ ។

មានតែបណ្ឌិតទើបដឹងបាន លោកមានអាយុនេះ ពោលនូវធម៌ណា ក៏អាចនឹងប្រាប់ សម្តែង បញ្ញត្ត តែងតាំង បើកចំហ ចែករលែក ធ្វើឲ្យរាក់នូវសេចក្តីអធិប្បាយនៃធម៌នោះ ដោយសេចក្តីសង្ខេប ឬដោយសេចក្តីពិស្តារបាន លោកមានអាយុនេះ ជាអ្នកមានប្រាជ្ញា លោកមានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសមានចក្ខុ ឈរក្បែរមាត់ច្រាំងនៃអន្លង់ទឹក គប្បីឃើញត្រីធំដែលកំពុងងើបឡើង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ការងើបឡើងរបស់ត្រីនេះយ៉ាងណា មួយទៀត ការពន្លៀកនៃត្រីនេះយ៉ាងណា សន្ទុះនៃត្រីនេះយ៉ាងណា ត្រីនេះជាត្រីធំ ត្រីនេះមិនមែនជាត្រីតូចទេ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលសាកច្ឆា ជាមួយនឹងបុគ្គលផងគ្នា តែងដឹងយ៉ាងនេះថា សេចក្តីវាងវៃក្នុងប្រស្នារបស់លោកមានអាយុនេះ យ៉ាងណា ។ បេ ។ លោកមានអាយុនេះ ជាអ្នកមានប្រាជ្ញាលោកមានអាយុនេះ មិនមែនជាអ្នកឥតប្រាជ្ញាទេ ក៏យ៉ាងនោះឯង ។

សាកច្ឆាយ ភិក្ខវេ បញ្ញា វេទិតព្វា សា ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ មនសិករោតា នោ អមនសិការា បញ្ញវតា នោ ទុប្បញ្ញេនាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ឋានានិ ឥមេហិ ចតូហិ ឋានេហិ វេទិតព្វានីតិ ។

[៤៣] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភទ្ទិយោ លិច្ឆវិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភទ្ទិយោ លិច្ឆវិ ភគវន្តំ ឯតទវោច សុតំ មេតំ ភន្តេ មាយាវី សមណោ គោតមោ អាវដ្ដនិមាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ ។ យេ តេ ភន្តេ ឯវមាហំសុ មាយាវី សមណោ គោតមោ អាវដ្ដនិមាយំ ជានាតិ

ពាក្យណា ដែលតថាគតពោលហើយថា ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញា បុគ្គលគប្បីដឹងបាន ដោយការសាកច្ឆា តែប្រាជ្ញានោះ បុគ្គលធ្វើទុកក្នុងចិត្តខ្ជីខ្ជា មិនគប្បីដឹងបាន បុគ្គលមានប្រាជ្ញាមិនគប្បីដឹងបាន ព្រោះការមិនធ្វើទុកក្នុងចិត្ត បុគ្គលឥតប្រាជ្ញាមិនគប្បីដឹងបាន ដោយកាលជាអង្វែងដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៤ នេះ បុគ្គលគប្បីដឹងបាន ដោយហេតុទាំង ៤ នេះ ។

[៤៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងកូដាគារសាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះឯង ស្តេចលិច្ឆវី ព្រះនាមភទ្ទិយៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ កាលស្តេចភទ្ទិយលិច្ឆវី គង់ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ជាអ្នកមានកិច្ចកល ចេះនូវកិច្ចកលសម្រាប់បោកប្រាស តែងបោកប្រាសពួកសាវ័ករបស់អន្យតិរ្ថិយ ។ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណា បានពោលយ៉ាងនេះថា ព្រះសមណ-គោតម ព្រះអង្គជាអ្នកមានកិច្ចកល ចេះនូវកិច្ចកលសម្រាប់បោកប្រាស

យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ អនព្ភក្ខាតុកាមា ហិ មយំ ភន្តេ ភគវន្តន្តិ ។ ឯថ តុម្ហេ ភទ្ទិយ មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិ-តក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ ។ យទា តុម្ហេ ភទ្ទិយ អត្តនាវ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ ភទ្ទិយ បជហេយ្យាថ ។ តំ កឹ មញ្ញថ ភទ្ទិយ

តែងបោកប្រាសពួកសាវ័ក របស់អន្យតិរ្ថិយទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយនោះ ឈ្មោះថា ពោលពាក្យតាមព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ មិនមែនពោលបង្កាច់ ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ពោលនូវធម៌ដ៏សមគួរដល់ធម៌ផង ការប្រព្រឹត្តទៅតាមវាទៈ ដែលប្រកបដោយធម៌ឯណានីមួយ ក៏មិនដល់នូវហេតុដែលគួរតិះដៀលផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា យើងខ្ញុំព្រះអង្គ មិនមែនជាអ្នកចង់ពោលបង្កាច់ ព្រះមានព្រះភាគទេ ។ ម្នាលភទ្ទិយៈ អ្នកចូរមក អ្នកចូរកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយសេចក្តីត្រិះរិះតាមអាការៈ កុំជឿប្រកាន់ដោយឃើញសមនឹងយោបល់ កុំជឿប្រកាន់ចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូនៃយើង ។ ម្នាលភទ្ទិយៈ អ្នកគប្បីដឹងដោយខ្លួនឯងថា ធម៌ទាំងនេះ ជាអកុសល ធម៌ទាំងនេះ ប្រកបដោយទោស ធម៌ទាំងនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះ ដែលបុគ្គលសមាទាន ឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខដូច្នេះ ក្នុងកាលណា ម្នាលភទ្ទិយៈ អ្នកគប្បីលះបង់ក្នុងកាលនោះចុះ ។ ម្នាលភទ្ទិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច

លោភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ អហិតាយ ភន្តេ ។ លុទ្ធោ បនាយំ ភទ្ទិយ បុរិសបុគ្គលោ លោភេន អភិភូតោ បរិយាទិន្នចិត្តោ បាណំបិ ហនតិ អទិន្នំបិ អាទិយតិ បរទារំបិ គច្ឆតិ មុសាបិ ភណតិ បរំបិ តត្ថត្តាយ សមាទបេតិ យំស ហោតិ[១] ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភទ្ទិយ ទោសោ... មោហោ... សារម្ភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ អហិតាយ ភន្តេ ។ សារម្ភោ[២] បនាយំ ភទ្ទិយ បុរិសបុគ្គលោ សារម្ភេន អភិភូតោ បរិយាទិន្នចិត្តោ បាណំបិ ហនតិ អទិន្នំបិ អាទិយតិ បរទារំបិ គច្ឆតិ មុសាបិ ភណតិ បរំបិ តត្ថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

---

១ ម. យំ បហោតីតិ អត្ថិ ។ ២ ម. សារទ្ធោ ។

កាលសេចក្តីលោភកើតឡើង ក្នុងសន្តានរបស់បុរស កើតឡើងដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនជាប្រយោជន៍ទេ ។ ម្នាលភទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកល្មោភ ដែលលោភៈគ្របសង្កត់ហើយ មានចិត្តដែលលោភៈរួបរឹតហើយ តែងសម្លាប់នូវសត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងភរិយាអ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ បបួលអ្នកដទៃដោយអំពើនោះខ្លះ ដែលឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខអស់កាលជាយូរអង្វែងមែនឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មែនហើយ ។ ម្នាលភទ្ទិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ទោសៈ... មោហៈ... ការប្រណាំងប្រជែងកាលកើតឡើង ខាងក្នុងសន្តានចិត្តរបស់បុរស រមែងកើតឡើង ដើម្បីជាប្រយោជន៍ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនជាប្រយោជន៍ទេ ។ ម្នាលភទ្ទិយៈ បុរសបុគ្គលនេះ ជាអ្នកប្រណាំងប្រជែងដែលការប្រណាំងប្រជែងគ្របសង្កត់ហើយ មានចិត្តដែលការប្រណាំងប្រជែងរួបរឹតហើយ តែងសម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងភរិយារបស់បុគ្គលដទៃខ្លះ ពោលពាក្យកុហកខ្លះ បបួលអ្នកដទៃដោយអំពើនោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខ អស់កាលជាយូរអង្វែងមែនឬទេ ។

ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភទ្ទិយ ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុបសត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេ ។ សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ឥតិ ខោ ភទ្ទិយ យំ តំ អវោចុម្ហ ឯត្ថ តុម្ហេ ភទ្ទិយ មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ ។

បពិត្រព្រះអង្គដ៏ចម្រើន មែនហើយ ។ ម្នាលភទ្ទិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងនេះ ជាកុសលឬជាអកុសល ។ បពិត្រព្រះអង្គដ៏ចម្រើន ជាអកុសល ។ ប្រកបដោយទោសឬមិនប្រកបដោយទោសទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រកបដោយទោស ។ វិញ្ញូជនតិះដៀលឬវិញ្ញូជនសរសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញូជនតិះដៀល ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខ ឬមួយពុំមែនទេ ឬក៏ក្នុងដំណើរនុ៎ះ មានប្រការដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខ ក្នុងដំណើរនុ៎ះ យើងខ្ញុំព្រះអង្គយល់យ៉ាងនេះ ។ ម្នាលភទ្ទិយៈ យើងបានពោលពាក្យណាដូច្នេះថា ម្នាលភទ្ទិយៈ អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយការត្រិះរិះគ្នាន់ កុំជឿប្រកាន់ដោយការនឹកស្មាន កុំជឿប្រកាន់ដោយការត្រិះរិះតាមអាការៈ កុំជឿប្រកាន់ដោយការយល់ត្រូវនឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូរបស់យើង ។

យទា តុម្ហេ ភទ្ទិយ អត្តនា វ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ ភទ្ទិយ បជហេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឯថ តុម្ហេ ភទ្ទិយ មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ ។ យទា តុម្ហេ ភទ្ទិយ អត្តនា វ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុបសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ ភទ្ទិយ ឧបសម្បជ្ជ វិហរេយ្យាថ ។

ម្នាលភទ្ទិយៈ ក្នុងកាលណា អ្នកគប្បីដឹងដោយខ្លួនឯងពិតថា ធម៌ទាំងនេះ ជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនតិះដៀល ធម៌ទាំងនេះដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខ ម្នាលភទ្ទិយៈ ក្នុងកាលនោះ អ្នកត្រូវលះបង់ចេញ ពាក្យណាដែលតថាគតបានពោលទុកហើយ ដូច្នេះ ពាក្យដែលតថាគតពោលទុកហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលភទ្ទិយៈ អ្នកចូរមក អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយការគ្នេរគ្នាន់ កុំជឿប្រកាន់ដោយការនឹកស្មាន កុំជឿប្រកាន់ដោយការត្រិះរិះតាមអាការៈ កុំជឿប្រកាន់ដោយការយល់ត្រូវ នឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូរបស់យើង ។ ម្នាលភទ្ទិយៈ ក្នុងកាលណា អ្នកគប្បីដឹងដោយខ្លួនឯងពិតៗ ថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះ មិនប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ម្នាលភទ្ទិយៈ ក្នុងកាលនោះ អ្នកគប្បីសម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ចុះ ។

តំ កឹ មញ្ញថ ភទ្ទិយ អលោភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ ហិតាយ ភន្តេ ។ អលុទ្ធោ បនាយំ ភទ្ទិយ បុរិសបុគ្គលោ លោភេន អនភិភូតោ អបរិយាទិណ្ណ-ចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ បរំបិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភទ្ទិយ អទោសោ... អមោហោ... អសារម្ភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ ហិតាយ ភន្តេ ។ អសារម្ភោ បនាយំ ភទ្ទិយ បុរិសបុគ្គលោ សារម្ភេន អនភិភូតោ អបរិយា-ទិណ្ណចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ

ម្នាលកាឡាមៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អលោភៈ កាលកើតឡើង ខាងក្នុងសន្តានចិត្តរបស់បុរស រមែងកើតឡើង ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាប្រយោជន៍មែន ។ ម្នាលកាឡាមៈ បុរសបុគ្គលនេះ ជាអ្នកមិនលោភ មិនត្រូវលោភៈ គ្របសង្កត់ហើយ មានចិត្តដែលលោភៈមិនរួបរឹតហើយ រមែងមិនសម្លាប់សត្វ មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ មិនប្រព្រឹត្តខុសក្នុងភរិយារបស់បុគ្គលដទៃ មិននិយាយកុហក ទាំងបបួលបុគ្គលដទៃ ដើម្បីអំពើនោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខអស់កាលជាយូរអង្វែងឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលកាឡាមៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អទោសៈ... អមោហៈ... សេចក្តីមិនប្រណាំងប្រជែង កាលកើតឡើង ខាងក្នុងសន្តានចិត្តរបស់បុរស រមែងកើតឡើង ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាប្រយោជន៍មែន ។ ម្នាលកាឡាមៈ បុរសបុគ្គលនេះ ជាអ្នកមិនមានសេចក្តីប្រណាំងប្រជែង មិនត្រូវសេចក្តីប្រណាំងប្រជែងគ្របសង្កត់ហើយ មានចិត្តដែលសេចក្តីប្រណាំងប្រជែងមិនរួបរឹតហើយ រមែងមិនសម្លាប់សត្វ មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ

ន បរទារំ គច្ឆតិ ន មុសា ភណតិ បរំបិ តត្ថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយ សំវត្តតីតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ កុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ អនវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុបសត្ថា វាតិ ។ វិញ្ញុបសត្ថា ភន្តេ ។ សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។

មិនប្រព្រឹត្តខុស ក្នុងកិរិយារបស់បុគ្គលដទៃ មិននិយាយកុហក ទាំង បបួលបុគ្គលដទៃ ដើម្បីអំពើនោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បី ជាប្រយោជន៍និងសេចក្ដីសុខ អស់កាលជាយូរអង្វែង ។ បពិត្រ ព្រះអង្គដ៏ចម្រើន យ៉ាងនេះមែន ។ ម្នាលកទ្ទិយៈ អ្នកសម្គាល់ សេចក្ដីនេះដូចម្ដេច ធម៌ទាំងនេះជាកុសល ឬជាអកុសល ។ បពិត្រ ព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះជាកុសល ។ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនប្រកប ដោយទោសទេ ។ វិញ្ញូជនតិះដៀល ឬវិញ្ញូជនសរសើរ ។ បពិត្រ ព្រះអង្គដ៏ចម្រើន វិញ្ញូជនសរសើរ ។ ធម៌ទាំងឡាយ ដែលបុគ្គល សមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខឬមិនមែនទេ ឬមួយក្នុងដំណើរនោះ មានប្រការដូចម្ដេច ទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គល សមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ ក្នុងដំណើរនោះ យើងខ្ញុំព្រះអង្គយល់យ៉ាងនេះ ។

ឥតិ ខោ ភទ្ទិយ យំ តំ អវោចុម្ហ ឯត្ថ តុម្ហេ ភទ្ទិយ មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ ។ យទា តុម្ហេ ភទ្ទិយ អត្តនា វ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុបសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ ភទ្ទិយ ឧបសម្បជ្ជ វិហរេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ យេ ខោ តេ ភទ្ទិយ លោកេ សន្តោ សប្បុរិសា តេ សាវកំ ឯវំ សមាទបេតិ ឯហិ ត្វំ អម្ភោ បុរិស លោភំ វិនេយ្យ វិនេយ្យ វិហរាហិ

ម្នាលភទ្ទិយៈ យើងបានពោលពាក្យណាដូច្នេះថា ម្នាលភទ្ទិយៈ ក្នុងដំណើរនុ៎ះ អ្នកកុំជឿប្រកាន់ដោយការឮតៗ គ្នា កុំជឿប្រកាន់ដោយការនិយាយតៗ គ្នា កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល កុំជឿប្រកាន់ដោយការអាងតម្រា កុំជឿប្រកាន់ដោយការត្រិះរិះគ្នាន់ កុំជឿប្រកាន់ដោយការនឹកស្មាន កុំជឿប្រកាន់ដោយការត្រិះរិះតាមអាការៈ កុំជឿប្រកាន់ដោយការយល់ត្រូវនឹងទិដ្ឋិរបស់ខ្លួន កុំជឿប្រកាន់ដោយការជឿចំពោះបុគ្គលដែលគួរជឿ កុំជឿប្រកាន់ថា សមណៈជាគ្រូរបស់យើង ។ ម្នាលភទ្ទិយៈ ក្នុងកាលណា អ្នកត្រូវដឹងដោយខ្លួនឯងពិតៗ ថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះ មិនប្រកបដោយទោស ធម៌ទាំងនេះ ដែលវិញ្ញូជនសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ម្នាលភទ្ទិយៈ អ្នកគប្បីចូលទៅសម្រេចសម្រាន្ត ក្នុងកាលនោះចុះ ពាក្យណា ដែលតថាគតពោលទុកហើយ ដូច្នេះ ពាក្យដែលតថាគតពោលហើយនុ៎ះ ព្រោះអាស្រ័យសេចក្តីនេះឯង ។ ម្នាលភទ្ទិយៈ សប្បុរសទាំងឡាយណា ដែលជាអ្នកស្ងប់រម្ងាប់ក្នុងលោក សប្បុរសទាំងនោះ តែងបបួលសាវ័កយ៉ាងនោះថា ម្នាលបុរសដ៏ចម្រើន អ្នកចូរមកនេះ អ្នកចូរបន្ទោបង់ កម្ចាត់បង់នូវលោភៈ ហើយសម្រេចសម្រាន្ត

១២៩



លោភំ វិនេយ្យ វិនេយ្យ វិហរន្តោ ន លោភជំ កម្មំ ករិស្សសិ កាយេន វាចាយ មនសា ទោសំ វិនេយ្យ វិនេយ្យ វិហរាហិ ទោសំ វិនេយ្យ វិនេយ្យ វិហរន្តោ ន ទោសជំ កម្មំ ករិស្សសិ កាយេន វាចាយ មនសា មោហំ វិនេយ្យ វិនេយ្យ វិហរាហិ មោហំ វិនេយ្យ វិនេយ្យ វិហរន្តោ ន មោហជំ កម្មំ ករិស្សសិ កាយេន វាចាយ មនសា សារម្ភំ វិនេយ្យ វិនេយ្យ វិហរាហិ សារម្ភំ វិនេយ្យ វិនេយ្យ វិហរន្តោ ន សារម្ភជំ កម្មំ ករិស្សសិ កាយេន វាចាយ មន-សាតិ ។ ឯវំ វុត្តេ ភទ្ទិយោ លិច្ឆវិ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អបិនុ តាហំ ភទ្ទិយ ឯវំ អវចំ ឯហិ មេ ត្វំ ភទ្ទិយ សាវកោ ហោហិ អហំ តេ សត្ថា ភវិស្សាមីតិ ។

កាលអ្នកបន្ទោបង់ កម្ចាត់បង់នូវលោភៈបានហើយនឹងមិនធ្វើកម្ម ដែលកើតអំពីលោភៈ ដោយកាយវាចាចិត្តឡើយ ចូរអ្នកបន្ទោបង់ កម្ចាត់បង់នូវទោសៈ ហើយសម្រេចសម្រាន្តនៅ កាលអ្នកបន្ទោបង់ កម្ចាត់បង់នូវទោស ហើយនឹងមិនធ្វើកម្ម ដែលកើតអំពីទោសៈ ដោយកាយវាចាចិត្តឡើយ ចូរអ្នកបន្ទោបង់ កម្ចាត់បង់នូវមោហៈហើយ សម្រេចសម្រាន្តនៅ កាលបើអ្នកបន្ទោបង់ កម្ចាត់បង់នូវមោហៈហើយនឹងមិនធ្វើកម្ម ដែលកើតអំពីមោហៈ ដោយកាយវាចាចិត្តឡើយ អ្នកចូរបន្ទោបង់ កម្ចាត់បង់នូវសេចក្តីប្រណាំងប្រជែង ហើយសម្រេចសម្រាន្តនៅ កាលអ្នកបន្ទោបង់ កម្ចាត់បង់នូវសេចក្តីប្រណាំងប្រជែងហើយនឹងមិនធ្វើកម្ម ដែលកើតអំពីសេចក្តីប្រណាំងប្រជែង ដោយកាយវាចាចិត្តឡើយ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ស្តេចភទ្ទិយលិច្ឆវី ក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ។ ម្នាលភទ្ទិយៈ តថាគតបានពោលយ៉ាងនេះ ដល់អ្នកថា ម្នាលភទ្ទិយៈ អ្នកចូរចូលមក អ្នកចូរជាសាវ័ករបស់តថាគតចុះ តថាគតនឹងជាគ្រូរបស់អ្នកដូច្នេះខ្លះដែរឬ ។

ដោ ហោតំ ភន្តេ ។ ឯវំវាទី ខោ មំ ភទ្ទិយ ឯវមក្ខាយី ឯកេ សមណព្រាហ្មណា អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តិ មាយាវី សមណោ គោតមោ អាវដ្ដនិមាយំ ជានាតិ យាយ អញ្ញតិត្ថិយានំ សាវកេ អាវដ្ដេតីតិ ។ ភទ្ទិកា ភន្តេ អាវដ្ដនិមាយា កល្យាណី ភន្តេ អាវដ្ដនិមាយា ។ បិយា មេ ភន្តេ ញាតិសាលោហិតា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ បិយានំ មេ អស្ស ញាតិសាលោហិតានំ ទីឃរត្តំ ហិតាយ សុខាយ ។ សព្វេ ចេបិ ភន្តេ ខត្តិយា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ សព្វសម្បិស្ស ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ ។

មិនមែនដូច្នោះទេព្រះអង្គ ។ ម្នាលភទ្ទិយៈ សមណៈនិងព្រាហ្មណ៍ពួកមួយ ពោលពាក្យបង្កាច់តថាគត ដែលជាអ្នកមានវាទៈយ៉ាងនេះ បានពោលទុកយ៉ាងនេះ ដោយពាក្យមិនពិត ជាពាក្យទទេ ជាពាក្យកុហក ជាពាក្យមិនមែនថា ព្រះសមណគោតម ជាអ្នកមានកិច្ចកល បេះនូវកិច្ចកលជាគ្រឿងបោកប្រាស តែងបោកប្រាសពួកសាវ័ករបស់អន្យតិរ្ថិយទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន កិច្ចកលជាគ្រឿងបោកប្រាសជាកិច្ចកលដ៏ប្រសើរ បពិត្រព្រះអង្គដ៏ចម្រើន កិច្ចកលជាគ្រឿងបោក-ប្រាស (នេះ) ជាកិច្ចដ៏ល្អ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកញាតិនិងសាលោហិតជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ ត្រូវចាញ់បោក ដោយកលជាគ្រឿងបោកប្រាសនេះ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកញាតិនិងសាលោហិត ដែលជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើក្សត្រិយ៍ទាំងពួង ត្រូវចាញ់បោក ដោយកលជាគ្រឿងបោកប្រាសនេះ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលជាយូរអង្វែង ។

១៣១



សព្វេ ចេបិ ភន្តេ ព្រាហ្មណា... វេស្សា... សុទ្ទា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ សព្វេសម្បិស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវមេតំ ភទ្ទិយ ឯវមេតំ ភទ្ទិយ ។ សព្វេ ចេបិ ភទ្ទិយ ខត្តិយា អាវដ្ដេយ្យុំ អកុសលធម្មប្បហានាយ កុសលធម្មូប-សម្បទាយ សព្វេសម្បិស្ស ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ ។ សព្វេ ចេបិ ភទ្ទិយ ព្រាហ្មណា... វេស្សា... សុទ្ទា អាវដ្ដេយ្យុំ អកុសលធម្មប្បហានាយ កុសលធម្មូបសម្បទាយ សព្វេសម្បិស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយ ។ សទេវកោ ចេបិ ភទ្ទិយ លោកោ សមារកោ សព្រហ្មកោ សស្ស-មណព្រាហ្មណី បជា សទេវមនុស្សា អាវដ្ដេយ្យុំ អកុសលធម្មប្បហានាយ កុសលធម្មូបសម្បទាយ

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង... ពួកវេស្សៈ... ពួកសុទ្ទៈ ត្រូវចាញ់បោក ដោយកលជាគ្រឿងបោកប្រាសនេះ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលកទ្ទិយៈ ពាក្យនុ៎ះពិតយ៉ាងនេះមែន ម្នាលកទ្ទិយៈ ពាក្យនុ៎ះពិតយ៉ាងនេះមែន ។ ម្នាលកទ្ទិយៈ ប្រសិនបើក្សត្រិយ៍ទាំងពួង ត្រូវចាញ់បោក ដើម្បីឲ្យលះបង់អកុសលធម៌ នឹងបំពេញកុសលធម៌ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលកទ្ទិយៈ ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង... ពួកវេស្សៈ... ពួកសុទ្ទៈត្រូវចាញ់បោក ដើម្បីឲ្យលះបង់នូវអកុសលធម៌ នឹងបំពេញកុសលធម៌ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសត្វលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ត្រូវចាញ់បោក ដើម្បីឲ្យលះបង់នូវអកុសលធម៌ នឹងបំពេញកុសលធម៌ (អំពើនោះ)

សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទីឃរត្តំ ហិតាយ សុខាយ ។ ឥមេ ចេបិ ភទ្ទិយ មហាសាលា ឥមាយ អាវដ្ដនិយា អាវដ្ដេយ្យុំ អកុស-លធម្មប្បហានាយ កុសលធម្មូបសម្បទាយ ឥមេ-សម្បិស្ស មហាសាលានំ ទីឃរត្តំ ហិតាយ សុខាយ សចេ ចេតេយ្យុំ កោ បន វាទោ មនុស្សភូតស្សាតិ ។

[៤៤] ឯកំ សមយំ អាយស្មា អានន្ទោ កោឡិយេសុ វិហរតិ សាបុគំ នាម កោឡិយានំ និគមោ ។ អថខោ សម្ពហុលា សាបុគិយា កោឡិយបុត្តា យេនាយស្មា អានន្ទោ តេនុបសង្ក-មឹសុ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ សាបុ-គិយេ កោឡិយបុត្តេ អាយស្មា អានន្ទោ ឯតទវោច

មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់សត្វលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រម ទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស អស់កាលជាយូរអង្វែង ។ ម្នាលភទ្ទិយៈ ប្រសិនបើដើមសាលព្រឹក្សធំៗ ទាំងនេះ ត្រូវចាញ់បោកប្រាស ដោយកលជាគ្រឿងបោកប្រាសនេះ ដើម្បីឲ្យលះបង់នូវអកុសលធម៌ នឹងបំពេញកុសលធម៌ (អំពើនោះ) មុខជាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ដល់ពួកដើម សាលព្រឹក្សធំៗ ទាំងនេះ អស់កាលជាយូរអង្វែង ប្រសិនបើ ដើម សាលព្រឹក្សទាំងនោះ ចេះត្រិះរិះ នឹងបាច់និយាយទៅថ្វី ដល់សត្វ ដែលជាមនុស្ស ។

[៤៤] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងនិគម ឈ្មោះសាបុគ របស់ពួកកោឡិយជន ក្នុងដែនកោឡិយៈ ។ គ្រានោះឯង ពួកកោឡិយបុត្ត អ្នកសាបុគនិគមជាច្រើន ចូលទៅរកព្រះអានន្ទមាន អាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកកោឡិយបុត្ត អ្នកសាបុគនិគម អង្គុយ ក្នុងទីសមគួរហើយ ទើបព្រះអានន្ទមានអាយុ បានពោលពាក្យនេះថា

១៣៣



ចត្តារីមានិ ព្យគ្ឃបជ្ជា បារិសុទ្ធិប្បធានិយង្គានិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតានិ សតានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ ។ កតមានិ ចត្តារិ ។ សីលបារិសុទ្ធិប្បធានិយង្គំ ចិត្តបារិសុទ្ធិប្បធានិយង្គំ ទិដ្ឋិបារិសុទ្ធិប្បធានិយង្គំ វិមុត្តិបារិសុទ្ធិប្បធានិយង្គំ ។ កតមញ្ច ព្យគ្ឃបជ្ជា សីលបារិសុទ្ធិប្បធានិយង្គំ ។ ឥធ ព្យគ្ឃបជ្ជា ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ វុច្ចតិ ព្យគ្ឃបជ្ជា សីលបារិសុទ្ធិ ឥតិ ឯវរូបំ សីលបារិសុទ្ធឹ អបរិបូរំ វា បរិបូរេស្សាមិ បរិបូរំ វា តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ ។

ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនេះ មាន ៤ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកហើយដោយល្អ ដើម្បីសេចក្ដីបរិសុទ្ធដល់ពួកសត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវញេយ្យធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធមាន ៤ តើដូចម្ដេច ។ គឺអង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនៃសីល ១ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនៃចិត្ត ១ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនៃទិដ្ឋិ ១ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនៃវិមុត្តិ ១ ។ ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ អង្គនៃសេចក្ដីព្យាយាម ដើម្បីសេចក្ដីបរិសុទ្ធនៃសីល តើដូចម្ដេច ។ ម្នាលអ្នកព្យគ្ឃបជ្ជៈទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ បានសមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយថា អាត្មាអញ នឹងធ្វើសីលបារិសុទ្ធិ មានសភាពយ៉ាងនេះ ដែលមិនទាន់ពេញលេញឲ្យពេញលេញក្ដី នឹងអនុគ្រោះនូវសីលបារិសុទ្ធិ ដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្ដី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្ដីបរិសុទ្ធនៃសីល ។

យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ឥទំ វុច្ចតិ ព្យគ្ឃបជ្ជា សីលបារិសុទ្ធិប្បធានិយង្គំ ។ កាតមញ្ច ព្យគ្ឃបជ្ជា ចិត្តបារិសុទ្ធិប្បធានិយង្គំ ។ ឥធ ព្យគ្ឃបជ្ជា ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជា ចិត្តបារិសុទ្ធិ ឥតិ ឯវរូបំ ចិត្តបារិសុទ្ធឹ អបរិបូរំ វា បរិបូរេស្សាមិ បរិបូរំ វា តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ ។ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ឥទំ វុច្ចតិ ព្យគ្ឃបជ្ជា ចិត្តបារិសុទ្ធិប្បធានិយង្គំ ។ កាតមញ្ច ព្យគ្ឃបជ្ជា ទិដ្ឋិបារិសុទ្ធិប្បធានិយង្គំ ។ ឥធ ព្យគ្ឃបជ្ជា ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។

សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តីឯណា ដែលមានក្នុងការអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថាជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីល ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយគិតថា អាត្មាអញ នឹងធ្វើចិត្តបារិសុទ្ធិ មានសភាពយ៉ាងនេះដែលមិនទាន់ពេញលេញ ឲ្យពេញលេញឡើងក្តី និងអនុគ្រោះនូវចិត្តបារិសុទ្ធិ ដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃចិត្ត ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តីឯណា ដែលមានក្នុងការអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថាជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្ត ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិ តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។

អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជា ទិដ្ឋិចារិសុទ្ធិ ឥតិ ឯវរូបំ ទិដ្ឋិចារិសុទ្ធឹ អបរិបូរំ វា បរិបូរេស្សាមិ បរិបូរំ វា តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ ។ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ឥទំ វុច្ចតិ ព្យគ្ឃបជ្ជា ទិដ្ឋិចារិសុទ្ធិប្ប-ធានិយង្គំ ។ កតមញ្ច ព្យគ្ឃបជ្ជា វិមុត្តិចា-រិសុទ្ធិប្បធានិយង្គំ ។ ស ខោ សោ ព្យគ្ឃបជ្ជា អរិយសាវកោ ឥមិនា ច សីលចារិសុទ្ធិប្បធានិយង្គេន សមន្នាគតោ ឥមិនា ច ចិត្តចារិសុទ្ធិប្បធានិយង្គេន សមន្នាគតោ ឥមិនា ច ទិដ្ឋិចារិសុទ្ធិប្បធានិយង្គេន សមន្នាគតោ រជនីយេសុ ធម្មេសុ ចិត្តំ វិរាជេតិ វិមោចនីយេសុ ធម្មេសុ ចិត្តំ វិមោចេតិ ។ សោ រជនីយេសុ ធម្មេសុ ចិត្តំ វិរាជេត្វា

ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ដោយត្រិះរិះដូច្នេះថា អាត្មាអញ នឹងធ្វើទិដ្ឋិបារិសុទ្ធិ មានសភាពយ៉ាងនេះដែលមិនទាន់ពេញលេញ ឲ្យពេញលេញក្តី នឹងជួយអនុគ្រោះនូវទិដ្ឋិបារិសុទ្ធិដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថាសេចក្តីបរិសុទ្ធិនៃទិដ្ឋិ ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តី ឯណា ដែលមាននៅក្នុងអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថាជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិ ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ ចុះអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃវិមុត្តិ តើដូចម្តេច ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ អរិយសាវ័កនោះ ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃសីលនេះផង ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃចិត្តនេះផង ប្រកបដោយអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិនៃទិដ្ឋិនេះផង ទើបធ្វើចិត្តឲ្យនឿយណាយ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃតម្រេក ធ្វើចិត្តឲ្យផុតស្រឡះ ក្នុងធម៌ទាំងឡាយ ដែលគួរឲ្យរួចផុតស្រឡះ ។ លុះអរិយសាវ័កនោះ ធ្វើចិត្តឲ្យនឿយណាយ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃតម្រេកហើយ

វិមោចនីយេសុ ធម្មេសុ ចិត្តំ វិមោចេត្វា សម្មាវិមុត្តឹ ផុសតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជា វិមុត្តិបារិសុទ្ធិ ឥតិ ឯវរូបំ វិមុត្តិបារិសុទ្ធឹ អបរិបូរំ វា បរិបូរេស្សាមិ បរិបូរំ វា តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ ។ យោ តត្ថ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវាណី ច សតិ ច សម្បជញ្ញញ្ច ឥទំ វុច្ចតិ ព្យគ្ឃបជ្ជា វិមុត្តិបារិសុទ្ធិប្បធានិយង្គំ ។ ឥមានិ ខោ ព្យគ្ឃបជ្ជា ចត្តារិ បារិសុទ្ធិប្បធានិយង្គានិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតានិ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយាតិ ។

ធ្វើចិត្តឲ្យផុតស្រឡះ ក្នុងធម៌ទាំងឡាយ ដែលគួរឲ្យរួចផុតស្រឡះហើយ ទើបពាល់ត្រូវនូវវិមុត្តិដោយប្រពៃ ដោយត្រិះរិះថា អាត្មាអញ នឹងធ្វើវិមុត្តិបារិសុទ្ធិដែលមិនទាន់ពេញលេញ ឲ្យពេញលេញក្តី នឹងអនុគ្រោះវិមុត្តិបារិសុទ្ធិដែលពេញលេញហើយ ក្នុងទីនោះៗ ដោយបញ្ញាក្តី ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថា សេចក្តីបរិសុទ្ធនៃវិមុត្តិ ។ សេចក្តីគាប់ចិត្តក្តី សេចក្តីព្យាយាមក្តី សេចក្តីសង្វាតក្តី សេចក្តីខ្មីឃ្មាតក្តី សេចក្តីមិនរួញរាក្តី សតិក្តី សម្បជញ្ញៈក្តី ឯណា ដែលមាននៅក្នុងសេចក្តីអនុគ្រោះនោះ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ នេះឈ្មោះថាជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធនៃវិមុត្តិ ។ ម្នាលពួកអ្នកព្យគ្ឃបជ្ជៈ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធមាន ៤ នេះ ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកហើយដោយប្រពៃ ដើម្បីសេចក្តីបរិសុទ្ធរបស់សត្វទាំង-ឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវញេយ្យធម៌ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

[៤៨] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ វប្បោ សក្កោ និគណ្ឋសាវកោ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វប្បំ សក្កំ និគណ្ឋសាវកំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច ឥធស្ស វប្ប កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ អវិជ្ជាវិរាគា វិជ្ជុប្បាទា បស្សសិ នោ ត្វំ វប្ប តណ្ឋានំ[១] យតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ[២] អភិសម្បរាយន្តិ ។ បស្សាមហំ ភន្តេ តណ្ឋានំ ឥធស្ស ភន្តេ បុព្វេ បាបកម្មំ កតំ អវិបក្កវិបាកំ តតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ អភិសម្បរាយន្តិ ។ អយមេវ ខោ បនាយស្មតោ មហាមោគ្គល្លានស្ស វប្បេន សក្កេន និគណ្ឋសាវកេន សទ្ធឹ កថា វិប្បកតា ហោតិ[៣] ។

១ ឱ. ម. តំ ឋានំ ។ ២ ម. អន្វាស្សវេយ្យុំ ។ ៣ ម. សទ្ធឹ អន្តរាកថា ហោតិ វិប្បកតាតិ ទិស្សន្តិ ។

[៤៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងសក្កជនបទ ។ គ្រានោះ វប្បសក្យៈជាសាវ័កនិគ្រន្ថ បានចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមហាមោគ្គល្លានមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថអង្គុយក្នុងទីសមគួរហើយ ទើបព្រះមហាមោគ្គល្លានមានអាយុ បានពោលដូច្នេះថា ម្នាលវប្បៈ បុគ្គលក្នុងលោកនេះ គប្បីសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃវិជ្ជា អាសវៈទាំងឡាយ ដែលជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញហេតុនោះដែរឬទេ ។ បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណាឃើញនូវហេតុនោះដែរ បពិត្រព្រះថេរៈដ៏ចម្រើន បាបកម្មដែលបុគ្គលធ្វើក្នុងកាលពីដើម ជាវិបាកដែលមិនទាន់ឲ្យផល ក្នុងលោកនេះទេ ព្រោះហេតុនោះ បានជាអាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ។ ការនិយាយជាមួយនឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏បានឈប់ផ្អាកត្រឹមប៉ុណ្ណោះ ។ គ្រានោះ ព្រះមានព្រះភាគ

អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច កាយនុត្ថ មោគ្គល្លាន ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរា-កថា វិប្បកតាតិ ។ ឥធាហំ ភន្តេ វប្បំ សក្កំ និគណ្ឋសាវកំ ឯតទវោចំ ឥធស្ស វប្ប កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ អវិជ្ជាវិរាគា វិជ្ជុប្បាទា បស្សសិ នោ ត្វំ វប្ប តណ្ឋានំ យតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ អភិស-ម្បរាយន្តិ ។ ឯវំ វុត្តេ ភន្តេ វប្បោ សក្កោ និគណ្ឋ-សាវកោ មំ ឯតទវោច បស្សាមហំ ភន្តេ តណ្ឋានំ ឥធស្ស ភន្តេ បុព្វេ បាបកម្មំ កតំ អវិបក្កវិបាកំ

ស្តេចចេញចាកផលសមាបត្តិ ក្នុងវេលាសាយណ្ហសម័យ ទើបស្តេចទៅកាន់ឧបដ្ឋានសាលា លុះស្តេចទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់រួចហើយ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះមហាមោគ្គល្លានមានអាយុ ដូច្នេះថា ម្នាលមោគ្គល្លាន អ្នកអង្គុយប្រជុំនិយាយគ្នា ដោយរឿងអ្វី អម្បាញ់មិញនេះ ចុះអន្តរាកថា (ពាក្យជាចន្លោះ) ដូចម្តេច ដែលអ្នកបានពោលផ្អាកទុក ។ បពិត្រព្រះអង្គដ៏ចម្រើន នៅទីនេះ ខ្ញុំព្រះអង្គបានពោលពាក្យនេះ នឹងវប្បសក្យៈជាសាវ័ករបស់និគ្រន្ថថា ម្នាលវប្បៈ បុគ្គលក្នុងលោកនេះ គប្បីសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃវិជ្ជា អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ វប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថបានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះថេរៈដ៏ចម្រើន ខ្ញុំព្រះករុណារមែងឃើញនូវហេតុនោះដែរ បពិត្រព្រះថេរៈដ៏ចម្រើន បាបកម្មដែលបុគ្គលធ្វើក្នុងកាលពីមុន ជាវិបាកដែលមិនទាន់ឲ្យផល ក្នុងលោកនេះ

តតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ អភិសម្បរាយន្តិ អយំ ខោ នោ ភន្តេ វប្បេន សក្កេន និគណ្ឋសាវកេន សទ្ធឹ កថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។ អថខោ ភគវា វប្បំ សក្កំ និគណ្ឋសាវកំ ឯតទវោច សចេ ខោ មេ ត្វំ វប្ប អនុញ្ញេយ្យំ ចេវ អនុជានេយ្យាសិ បដិក្កោសិតព្វញ្ច បដិក្កោសេយ្យាសិ យស្ស ច មេ ភាសិតស្ស អត្ថំ ន ជានេយ្យាសិ មមេវ តត្ថុត្តរឹ បដិបុច្ឆេយ្យាសិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ សិយា នោ ឯត្ថ កថាសល្លាបោតិ ។ អនុញ្ញេយ្យញ្ចាហំ ភន្តេ ភគវតោ អនុជានិស្សាមិ បដិក្កោសិតព្វញ្ច បដិក្កោសិស្សាមិ យស្ស ចាហំ ភគវតោ ភាសិតស្ស អត្ថំ ន ជានិស្សាមិ ភគវន្តំ យេវេត្ថុត្តរឹ បដិបុច្ឆិស្សាមិ

ព្រោះហេតុនោះ បានជាអាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន បពិត្រព្រះអង្គដ៏ចម្រើន នេះគឺការនិយាយជាមួយនឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ ដែលយើងខ្ញុំព្រះអង្គបានពោលផ្អាកទុក ក៏ស្រាប់តែព្រះមានព្រះភាគ ស្តេចមកដល់ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងវប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថដូច្នេះថា ម្នាលវប្បៈ ប្រសិនបើអ្នកយល់ព្រមចំពោះពាក្យ ដែលគួរយល់ព្រមតាមផង គួរហាមឃាត់ចំពោះពាក្យ ដែលគួរហាមឃាត់ផង មួយទៀត អ្នកមិនទាន់ដឹងនូវសេចក្តីអធិប្បាយ នៃភាសិតណារបស់តថាគត គួរអ្នកសាកសួរនឹងតថាគត ក្នុងសេចក្តីអធិប្បាយនៃសុភាសិតនោះ តទៅទៀតចុះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះដូចម្តេច ។ ការសន្ទនានៃយើងខ្ញុំព្រះអង្គ គប្បីមានក្នុងដំណើរនុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងយល់ព្រមតាមចំពោះពាក្យដែលគួរយល់ព្រមតាមផង នឹងហាមឃាត់ចំពោះពាក្យ ដែលគួរហាមឃាត់ផង មួយទៀត ខ្ញុំព្រះអង្គ មិនទាន់ដឹងនូវសេចក្តីអធិប្បាយនៃភាសិតណារបស់ព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងទូលសាកសួរចំពោះព្រះមានព្រះភាគ ក្នុងសេចក្តីអធិប្បាយនៃភាសិតនោះ តទៅទៀតថា

១៤០



ឥទំ ភន្តេ កាចំ ឥមស្ស កោ អត្ថោតិ ។ ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។ តំ កឹ មញ្ញសិ វប្ប យេ កាយសមារម្ភប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា កាយសមារម្ភា បដិវិរ-តស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ បស្សសិ នោ ត្វំ វប្ប តណ្ឋានំ យតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ អភិសម្បរាយន្តិ ។ នោ ហេតំ ភន្តេ ។

បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះដូចម្ដេច សេចក្ដីអធិប្បាយនៃភាសិតនេះដូចម្ដេច ។ ការសន្ទនានៃយើងខ្ញុំព្រះអង្គ ចូរមានក្នុងដំណើរនុ៎ះ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្ដៅក្រហាយ រមែងកើតឡើង ព្រោះកាយកម្មជាបច្ច័យ អាសវៈទាំងឡាយ ដែលប្រកបដោយទុក្ខ ក្ដៅក្រហាយទាំងនោះ រមែងមិនមានដល់បុគ្គល ដែលវៀរស្រឡះចាកកាយកម្ម បុគ្គលនោះ រមែងមិនធ្វើនូវកម្មថ្មីផង នូវកម្មចាស់ផង លុះពាល់ត្រូវ (នូវកម្ម) ហើយ រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅអ្នកផងចូលមកមើល គួរបង្អោនទុកក្នុងខ្លួន ពួកអ្នកប្រាជ្ញគប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។

តំ កឹ មញ្ញសិ វប្ប វចីសមារម្ភប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា វចីសមារម្ភា បដិវិរតស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ បស្សសិ នោ ត្វំ វប្ប តណ្ឋានំ យតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា អស្សវេយ្យុំ អភិសម្បរាយន្តិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញសិ វប្ប យេ មនោសមារម្ភប្បច្ចយា ឧប្បជ្ជន្តិ អាសវា វិឃាតបរិឡាហា មនោសមារម្ភា បដិវិរតស្ស ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ

ម្នាលវប្បៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្តៅក្រហាយ រមែងកើតឡើង ព្រោះវចីកម្មជាបច្ច័យ អាសវៈដែលប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ រមែងមិនមានដល់បុគ្គល ដែលវៀរចាកវចីកម្ម យ៉ាងនេះឡើយ បុគ្គលនោះមិនធ្វើនូវកម្មថ្មីផង នូវកម្មចាស់ផង លុះពាល់ត្រូវ (នូវកម្ម) ហើយ រមែងធ្វើឲ្យអស់ទៅ ដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅឲ្យអ្នកផងចូលមកមើលបាន គួរបង្អោនទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អាសវៈទាំងឡាយឯណា ដែលប្រកបដោយទុក្ខ ក្តៅក្រហាយ រមែងកើតឡើង ព្រោះមនោកម្មជាបច្ច័យ អាសវៈទាំងឡាយប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ តែងមិនមានដល់បុគ្គល ដែលវៀរចាកមនោកម្មយ៉ាងនេះឡើយ បុគ្គលនោះក៏មិនធ្វើកម្មថ្មីផង កម្មចាស់ផង លុះពាល់ត្រូវ (នូវកម្ម) ហើយ រមែងធ្វើឲ្យអស់ទៅ

សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបន-
យិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ បស្សសិ នោ ត្វំ វប្ប
តណ្ហាឋានំ យតោនិទានំ បុរិសំ ទុក្ខវេទនិយា អាសវា
អស្សវេយ្យុំ អភិសម្បរាយន្តិ ។ នោ ហេតំ ភន្តេ ។
តំ កឹ មញ្ញសិ វប្ប យេ អវិជ្ជាបច្ចយា ឧប្បជ្ជន្តិ
អាសវា វិឃាតបរិឡាហា អវិជ្ជាវិរាគា វិជ្ជុប្បាទា ឯវំស
តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ សោ នវញ្ច
កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តី-
ករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា
ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហិ ។ បស្សសិ
នោ ត្វំ វប្ប តណ្ហាឋានំ យតោនិទានំ បុរិសំ ទុក្ខ-
វេទនិយា អាសវា អស្សវេយ្យុំ អភិសម្បរាយន្តិ ។

ដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទា គ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅអ្នកផងឲ្យចូលមកមើលបាន គួរបង្អោនមកទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អាសវៈទាំងឡាយ ដែលប្រកបដោយទុក្ខ ក្តៅក្រហាយ រមែងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ អាសវៈទាំងឡាយ ប្រកបដោយទុក្ខ ក្តៅក្រហាយទាំងនោះ រមែងមិនមាន ព្រោះប្រាសចាកអវិជ្ជា ព្រោះកើតឡើងនៃវិជ្ជាយ៉ាងនេះ បុរសនោះក៏មិនធ្វើកម្មថ្មីផង កម្មចាស់ផង លុះពាល់ត្រូវ (នូវកម្ម) ហើយ រមែងធ្វើឲ្យអស់ទៅដោយបដិបទា ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាបដិបទាគ្មានជរា ឲ្យផលមិនរង់ចាំកាល គួរហៅអ្នកផងឲ្យចូលមកមើលបាន គួរបង្អោនមកទុកក្នុងខ្លួន ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ អាសវៈទាំងឡាយ ជាបច្ច័យនៃទុក្ខវេទនា គប្បីគ្របសង្កត់នូវបុរស ក្នុងលោកខាងមុខបាន ព្រោះហេតុឯណា ម្នាលវប្បៈ ចុះអ្នកឃើញនូវហេតុនោះដែរឬទេ ។

ដោ ហោតុំ ភន្តេ ។ ឯវំ សម្មាវិមុត្តចិត្តស្ស ខោ វប្ប ភិក្ខុនោ ឆ សតតវិហារា អធិគតា ហោន្តិ សោ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ សោ កាយបរិយន្តិកំ វេទនំ វេទិយមានោ កាយបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទិយមានោ ជីវិតបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតី ភវិស្សន្តីតិ បជានាតិ ។ សេយ្យថាបិ វប្ប ថូណំ បដិច្ច ឆាយា បញ្ញាយតិ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ តំ ថូណំ មូលេ ឆិន្ទេយ្យ

បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលវប្បៈ ភិក្ខុដែលមានចិត្តផុតស្រឡះហើយ ដោយប្រពៃយ៉ាងនេះ តែងបានសម្រេចនូវធម៌ ៦ ប្រការជាគ្រឿងនៅរឿយៗ ភិក្ខុនោះ បានឃើញរូបដោយចក្ខុក៏មិនជាសោមនស្ស មិនជាទោមនស្សឡើយ តែងព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន ឮសំឡេងដោយត្រចៀកហើយ... ធុំក្លិនដោយច្រមុះហើយ... ជញ្ជាបរសដោយអណ្តាតហើយ... ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយហើយ... ដឹងធម្មារម្មណ៍ដោយចិត្តហើយ ក៏ជាអ្នកមិនសោមនស្ស មិនទោមនស្សឡើយ តែងនៅព្រងើយកន្តើយ មានស្មារតីដឹងខ្លួន ។ ភិក្ខុនោះ កាលទទួលវេទនា កំណត់ដោយកាយ តែងដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយកាយ កាលទទួលវេទនាកំណត់ដោយជីវិត តែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាកំណត់ដោយជីវិត លុះបែកធ្លាយរាងកាយ បន្ទាប់អំពីការអស់ជីវិតទៅ ក៏ដឹងច្បាស់ថា ការទទួលអារម្មណ៍ទាំងអស់ ដែលអាត្មាអញមិនបានត្រេកអរក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ទៅខាងមុខ ។ ម្នាលវប្បៈ ប្រៀបដូចស្រមោលមានប្រាកដ ព្រោះអាស្រ័យដើមឈើ កាលនោះមានបុរសកាន់ចប និង កញ្ជើដើរមក បុរសនោះ ក៏កាប់ដើមឈើនោះត្រង់គល់

មូលេ ឆេត្វា បលិខណេយ្យ បលិខណិត្វា មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡិមត្តានិបិ សោ តំ ជូណំ ខណ្ឌាខណ្ឌិកំ ឆិន្ទេយ្យ ខណ្ឌា-ខណ្ឌិកំ ឆេត្វា ផាលេយ្យ ផាលេត្វា សកលិកំ ការេយ្យ សកលិកំ ការិត្វា វាតាតបេ វិសោសេយ្យ វាតាតបេ វិសោសេត្វា អគ្គិនា ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ការេយ្យ មសឹ ការិត្វា មហាវាតេ វា ឱផុនេយ្យ នទិយា វា សីឃសោតាយ បវាហេយ្យ ឯវំ ហិស្ស វប្ប យា ជូណំ បដិច្ច ឆាយា សា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹអ-នុប្បាទធម្មា ។ ឯវមេវ ខោ វប្ប ឯវំសម្មាវិមុត្តចិត្តស្ស ភិក្ខុនោ ឆ សតតវិហារា អធិគតា ហោន្តិ ។ សោ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា...

លុះកាប់គល់ហើយ ក៏ជីកគាស់ លុះជីកគាស់ហើយ ក៏រំលើងឫសគល់ដោយហោចទៅ សូម្បីប៉ុនចម្រៀកស្បូវភ្លាំង (ក៏មិនឲ្យសល់) បុរសនោះក៏កាត់ដើមឈើនោះ ឲ្យជាកំណាត់តូចធំ លុះកាត់ឲ្យជាកំណាត់តូចធំបានហើយ ក៏ពុះ លុះពុះហើយ ក៏ធ្វើឲ្យជាចម្រៀក ។ លុះធ្វើឲ្យជាចម្រៀកៗ ហើយ ក៏ហាលសំដិលក្នុងទីមានខ្យល់និងកម្ដៅថ្ងៃ លុះហាលសំដិលក្នុងទីមានខ្យល់និងកម្ដៅថ្ងៃហើយ ដ៏ដុតដោយភ្លើង លុះដុតដោយភ្លើងហើយ ក៏ធ្វើឲ្យជាធ្យូង លុះធ្វើឲ្យជាធ្យូងហើយ ក៏ជះពោយទៅលើខ្យល់ដ៏ខ្លាំង ឬបណ្ដែតតាមខ្សែទឹកដែលហូរខ្លាំងក្នុងទន្លេ ម្នាលវប្បៈ ស្រមោលឯណាដែលអាស្រ័យនឹងដើមឈើ ស្រមោលនោះ មានឫសគល់ដាច់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតចុង ធ្វើមិនឲ្យមានបែបភាពមានកិរិយាមិនកើតឡើង តទៅទៀតជាធម្មតា មានឧបមាយ៉ាងណា ។ ម្នាលវប្បៈ ភិក្ខុដែលមានចិត្តផុតស្រឡះហើយ ដោយប្រពៃយ៉ាងនេះតែងបានសម្រេចធម៌ ៦ ប្រការជាគ្រឿងនៅរឿយៗ ក៏មានឧបមេយ្យដូច្នោះដែរ ។ ភិក្ខុនោះបានឃើញរូបដោយចក្ខុហើយ ក៏មិនជាសោមនស្សមិនជាទោមនស្ស រមែងនៅព្រងើយកន្តើយ ជាអ្នកមានស្មារតីដឹងខ្លួន ឮសំឡេងដោយត្រចៀកហើយ... ធុំក្លិនដោយច្រមុះហើយ... ជញ្ជាបរសដោយអណ្ដាតហើយ . . . ពាល់ត្រូវផោដ្ឋព្វៈដោយកាយហើយ. . .

មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ សោ កាយបរិយន្តិកំ វេទនំ វេទិយមានោ កាយបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ជីវិតបរិយន្តិកំ វេទនំ វេទិយមានោ ជីវិតបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតី ភវិស្សន្តីតិ បជានាតិ ។ ឯវំ វុត្តេ វប្បោ សក្កោ និគណ្ឋសាវកោ ភគវន្តំ ឯតទវោច សេយ្យថាបិ ភន្តេ បុរិសោ ឧទយត្ថិកោ អស្សបណិយំ បោសេយ្យ សោ ឧទយញ្ចេវ នាធិគច្ឆេយ្យ[១] ឧត្តរិញ្ច កិលមថស្ស វិឃាតស្ស ភាគី អស្ស ឯវមេវ ខោ អហំ ភន្តេ ឧទយត្ថិកោ ពាលេ និគណ្ឋេ បយិរុបាសឹ

១ ឱ. ន លភេយ្យ ។

ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ មិនជាសោមនស្ស មិនទោមនស្សឡើយ តែងនៅព្រងើយកន្តើយ ជាអ្នកមានស្មារតី ដឹងខ្លួន ។ ភិក្ខុនោះ កាលទទួលវេទនា កំណត់ដោយកាយ ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយកាយ កាលទទួលវេទនា កំណត់ដោយជីវិត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនា កំណត់ដោយជីវិត លុះបែកធ្លាយរាងកាយ បន្ទាប់អំពីការអស់ទៅនៃជីវិត ក៏ដឹងច្បាស់ថា ការទទួលអារម្មណ៍ទាំងពួង ដែលអាត្មាអញ មិនបានត្រេកអរហើយ ក្នុងលោកនេះ នឹងមានសេចក្តីត្រជាក់ទៅខាងមុខ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វប្បសក្យៈ ជាសាវ័ករបស់និគ្រន្ថ បានក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុរសមានសេចក្តីត្រូវការ ដោយសេចក្តីចម្រើន ក៏ចិញ្ចឹមកូនសេះ បុរសនោះក៏នៅតែមិនបានសេចក្តីចម្រើន ថែមទាំងបានតែសេចក្តីលំបាក និងសេចក្តីព្រួយលើសឡើងទៅទៀតផង មានឧបមាយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយសេចក្តីចម្រើន ក៏ចូលទៅបម្រើពួកនិគ្រន្ថ ដែលជាមនុស្សល្ងង់

សោហំ ឧទយញ្ចេវ ជានិកច្ចឹ ឧត្តរិញ្ច កិលមថស្ស វិឃាតស្ស ភាគី អហោសឹ ។ ឯសាហំ ភន្តេ អជ្ជតគ្គេ យោ មេ ពាលេសុ និក្កណ្ឋេសុ បសាទោ តំ មហាវាតេ វា ឱផុណាមិ នទិយា វា សីឃស្សោ-តាយ បវាហេមិ ។ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ខ្ញុំព្រះអង្គនោះ ក៏មិនបានទទួលសេចក្តីចម្រើន ថែមទាំងបានតែសេចក្តីលំបាក សេចក្តីព្រួយលើសឡើងទៅទៀត ក៏មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងអំពីថ្ងៃនេះជាដើមទៅ សេចក្តីជ្រះថ្លា របស់ខ្ញុំព្រះអង្គឯណា ក្នុងពួកនិគ្រន្ថពាល ខ្ញុំព្រះអង្គនឹងជះចោលសេចក្តីជ្រះថ្លានោះទៅតាមខ្យល់ដ៏ខ្លាំង ឬនឹងបណ្តែតសេចក្តីជ្រះថ្លានោះទៅតាមខ្សែទឹកដែលហូរខ្លាំងក្នុងទន្លេ ។ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គភ្លឺច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះដូចបុគ្គលទ្រោលប្រទីបបំភ្លឺ ក្នុងទីងងឹតដោយគិតថា បុរសមានភ្នែកភ្លឺនឹងមើលឃើញនូវរូបទាំងឡាយបាន យ៉ាងណា ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គសូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

ចតុត្ថបណ្ណាសកេ មហាវគ្គោ បញ្ចមោ

[៤៦] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ សាឡ្ហោ ច លិច្ឆវិ អភយោ ច លិច្ឆវិ យេន ភគវា តេនុ-បសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ សាឡ្ហោ លិច្ឆវិ ភគវន្តំ ឯតទវោច សន្តិ ភន្តេ ឯកេ សមណព្រាហ្មណា ទ្វយេន ឱឃស្ស និត្ថរណំ បញ្ញាបេន្តិ សីលវិសុទ្ធិហេតុ ច តបោជិ-គុច្ឆាហេតុ ច ។ ឥធ ភន្តេ ភគវា កិមាហាតិ ។ សីលវិសុទ្ធឹ ខោ អហំ សាឡ្ហ អញ្ញតរំ សាមញ្ញង្គន្តិ វទាមិ ។ យេ តេ សាឡ្ហ សមណព្រាហ្មណា តបោជិគុច្ឆវាទា តបោជិគុច្ឆសារា តបោជិគុច្ឆអល្លីនា វិហរន្តិ អភព្វា តេ ឱឃស្ស និត្ថរណាយ ។ យេបិ តេ សាឡ្ហ សមណព្រាហ្មណា អបរិសុទ្ធកាយសមាចារា អបរិសុទ្ធវចីសមាចារា

[៤៦] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលាក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ក្សត្រិយ៍លិច្ឆវី ព្រះនាមសាឡ្ហៈ និងក្សត្រិយ៍លិច្ឆវីព្រះនាមអភយៈ នាំគ្នាចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះសាឡ្ហលិច្ឆវី គង់ក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ពួក ១ បញ្ញត្តនូវការរលាស់ខ្លួន ចេញចាកឱឃៈ ដោយហេតុពីរប្រការ គឺសីលវិសុទ្ធិជាហេតុ ១ តបោជិគុច្ឆា (ការខ្ពើម បាបដោយប្រព្រឹត្តតបៈ គឺធ្វើទុក្ករកិរិយា) ជាហេតុ ១ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូចម្តេច ក្នុងរឿងនេះ ។ ម្នាលសាឡ្ហៈ តថាគតពោលនូវសីលវិសុទ្ធិ ថាជាអង្គនៃសមណ-ធម៌មួយ ។ ម្នាលសាឡ្ហៈ ពួកសមណព្រាហ្មណ៍ណា ជាអ្នក ពោលនូវតបោជិគុច្ឆា មានតបោជិគុច្ឆាជាខ្លឹមសារ ជាប់ជំពាក់ក្នុងតបោ-ជិគុច្ឆា ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីរលាស់ខ្លួនចេញ ចាកឱឃៈបានទេ ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ ណា ដែលមានកាយសមាចារមិនបរិសុទ្ធ មានវចីសមាចារមិនបរិសុទ្ធ*

អបរិសុទ្ធមនោសមាចារា អបរិសុទ្ធាជីវា អភព្វា តេ ញាណទស្សនាយ អនុត្តរាយ សម្ពោធាយ ។ សេយ្យថាបិ សាឡ្ហ បុរិសោ នទឹ តរិតុកាមោ តិណ្ហំ កុឋារឹ អាទាយ វនំ បវិសេយ្យ សោ តត្ថ បស្សេយ្យ មហតឹ សាលលដ្ឋឹ ឧជុំ នវំ អកុក្កុច្ចកជាតំ តមេនំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា អគ្គេ ឆិន្ទេយ្យ អគ្គេ ឆេត្វា សាខាបលាសំ សុវិសោធិតំ វិសោធេយ្យ សាខាបលាសំ សុវិសោធិតំ វិសោធេត្វា កុឋារីហិ តច្ឆេយ្យ កុឋារីហិ តច្ឆេត្វា វាសីហិ តច្ឆេយ្យ វាសីហិ តច្ឆេត្វា លេខណិយា លិខេយ្យ លេខណិយា លិខិត្វា បាសាណគុឡេន ធោវេយ្យ បាសាណគុឡេន ធោវេត្វា នទឹ បតារេយ្យ ។ តំ កឹ មញ្ញសិ សាឡ្ហ ភព្វោ នុ ខោ សោ បុរិសោ នទឹ តរិតុន្តិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុ[១] ហិ ភន្តេ សាលលដ្ឋិ ពហិទ្ធា សុបរិកម្មកតា អន្តោ អវិសុទ្ធា ។

១ ឱ. អសុ ហិ ។

មានមនោសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង (នូវអរហត្ត) ដ៏ប្រសើរបានឡើយ ។ ម្នាលសាឡ្ហៈ ប្រៀបដូចបុរសប្រាថ្នានឹងឆ្លងនូវទន្លេ ក៏កាន់ដឹងដ៏មុត ដើរចូលទៅកាន់ព្រៃ បុរសនោះបានឃើញដើមសាលព្រឹក្សមួយដើមដ៏ធំ មានដើមត្រង់សាវ មិនមានសេចក្តីវង្វៀស (មិនវៀចក្ងិកក្ងក់) ក្នុងព្រៃនោះហើយ ក៏កាត់នូវដើមសាលព្រឹក្សនោះត្រង់គល់ លុះកាត់គល់ហើយ ក៏កាត់ចុង លុះកាត់ចុងហើយ ក៏លួសមែកនិងស្លឹកឲ្យស្អាតល្អ លុះលួសមែកនិងស្លឹកឲ្យស្អាតល្អហើយ ក៏ចាំងដោយដឹងទាំងឡាយ លុះចាំងដោយដឹងរួចហើយ ក៏ច្រាស់ដោយកាំបិត លុះច្រាស់ដោយកាំបិតរួចហើយ ក៏លាក់ដោយគ្រឿងលាក់ លុះលាក់ដោយគ្រឿងលាក់រួចហើយ ក៏ដុសដោយដុំថ្ម លុះដុសដោយដុំថ្មហើយ ក៏បណ្តែតទៅក្នុងទន្លេ ។ ម្នាលសាឡ្ហៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសនោះអាចឆ្លងទន្លេរួចឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនអាចឆ្លងបានទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាដើមសាលព្រឹក្សឯណោះ គេធ្វើបរិកម្មល្អតែខាងក្រៅ ខាងក្នុងមិនស្អាតទេ ។

តស្សេតំ ចាជិកង្ខំ សាលលដ្ឋិ សំសីទិស្សតិ បុរិសោ អនយព្យសនំ អាបជ្ជិស្សតីតិ(១) ។ ឯវមេវ ខោ សាឡ្ហ យេ តេ សមណព្រាហ្មណា តចោជិគុច្ឆវាទា តចោជិគុច្ឆសារា តចោជិគុច្ឆអល្លីនា វិហរន្តិ អភព្វា តេ ឱឃស្ស និត្ថរណាយ ។ យេបិ តេ សាឡ្ហ សមណព្រាហ្មណា អបរិសុទ្ធកាយសមាចារា អបរិសុទ្ធវចីសមាចារា អបរិសុទ្ធមនោសមាចារា អបរិសុទ្ធាជីវា អភព្វា តេ ញាណទស្សនាយ អនុត្តរាយ សម្ពោធាយ ។ យេ ច ខោ តេ សាឡ្ហ សមណព្រាហ្មណា ន តចោជិគុច្ឆវាទា ន តចោជិគុច្ឆសារា ន តចោជិគុច្ឆអល្លីនា វិហរន្តិ ភព្វា តេ ឱឃស្ស និត្ថរណាយ ។ យេបិ តេ សាឡ្ហ សមណព្រាហ្មណា បរិសុទ្ធកាយសមាចារា បរិសុទ្ធវចីសមាចារា បរិសុទ្ធមនោសមាចារា បរិសុទ្ធាជីវា ភព្វា តេ ញាណទស្សនាយ អនុត្តរាយ សម្ពោធាយ ។

---

១ ឱ. អាបជ្ជតីតិ ។

ហេតុនុ៎ះនឹងមានប្រាកដដល់បុរសនោះគឺថា ដើមសាលព្រឹក្សនឹងលិចចុះ ឯបុរសក៏នឹងដល់នូវសេចក្តីមិនចម្រើន នឹងវិនាសទៅមិនខាន មានឧបមាយ៉ាងណា ។ ម្នាលសាឡ្ហៈ ពួកសមណព្រាហ្មណ៍ណា ជាអ្នកពោលនូវតបោជិគុច្ឆា មានតបោជិគុច្ឆាជាខ្លឹមសារ ជាប់ជំពាក់ក្នុងតបោជិគុច្ឆា សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីរលាស់ខ្លួនចេញចាកឱឃៈបានឡើយ ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា ដែលមានកាយសមាចារមិនបរិសុទ្ធ មានវចីសមាចារមិនបរិសុទ្ធ មានមនោសមាចារមិនបរិសុទ្ធ មានអាជីវៈមិនបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង (នូវអរហត្ត) ដ៏ប្រសើរបាន មានឧបមេយ្យដូច្នោះដែរ ។ ម្នាលសាឡ្ហៈ ចំណែកពួកសមណព្រាហ្មណ៍ណា ជាអ្នកមិនពោលនូវតបោជិគុច្ឆា មិនមានតបោជិគុច្ឆាជាខ្លឹមសារ មិនជាប់ជំពាក់ក្នុងតបោជិគុច្ឆា សមណ-ព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីរលាស់ខ្លួន ចេញចាកឱឃៈបាន ។ ម្នាលសាឡ្ហៈ មួយទៀត ពួកសមណព្រាហ្មណ៍ណា មានកាយ-សមាចារបរិសុទ្ធ មានវចីសមាចារបរិសុទ្ធ មានមនោសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹង (នូវអរហត្ត) ដ៏ប្រសើរបាន ។

សេយ្យថាបិ សាឡ្ហ បុរិសោ ជជ្ជី តរិតុកាមោ តិណ្ហំ កុឋារឹ អាទាយ វនំ បវិសេយ្យ សោ តត្ថ បស្សេយ្យ មហតឹ សាលលដ្ឋឹ ឧជុំ នវំ អកុក្កុច្ចកជាតំ តមេនំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា អគ្គេ ឆិន្ទេយ្យ អគ្គេ ឆេត្វា សាខាបលាសំ សុវិសោធិតំ វិសោធេយ្យ សាខាបលាសំ សុវិសោធិតំ វិសោធេត្វា កុឋារីហិ តច្ឆេយ្យ កុឋារីហិ តច្ឆេត្វា វាសីហិ តច្ឆេយ្យ វាសីហិ តច្ឆេត្វា និខាទនំ អាទាយ អន្តោ សុវិសោធិតំ វិសោធេយ្យ អន្តោ សុវិសោធិតំ វិសោធេត្វា លេខណិយា លិខេយ្យ លេខណិយា លិខិត្វា ចាសាណគុឡេន ធោវេយ្យ ចាសាណគុឡេន ធោវេត្វា នាវំ ករេយ្យ នាវំ កត្វា ផិយារិត្តំ[១] ពន្ធេយ្យ ផិយារិត្តំ ពន្ធិត្វា ជជ្ជឹ បតារេយ្យ ។ តំ កឹ មញ្ញសិ សាឡ្ហ ភព្វោ នុ ខោ សោ បុរិសោ ជជ្ជឹ តរិតុន្តិ ។ ឯវំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុ ហិ ភន្តេ សាលលដ្ឋិ

១ ផិយារិត្តន្តិបិ ។

ម្នាលសាឡ្ហៈ ប្រៀបដូចបុរសប្រាថ្នានឹងឆ្លងទន្លេ ក៏កាន់ដឹងដ៏មុតដើរចូលទៅកាន់ព្រៃ បុរសនោះក៏ឃើញដើមសាលព្រឹក្សដ៏ធំត្រង់សាវ មិនមានសេចក្តីវង្វៀសក្នុងព្រៃនោះហើយ ក៏កាត់ដើមសាលព្រឹក្សនោះត្រង់គល់ លុះកាត់គល់ហើយ ក៏កាត់ចុង លុះកាត់ចុងហើយ ក៏លួសមែកនិងស្លឹកឲ្យស្អាតល្អ លុះលួសមែកនិងស្លឹកឲ្យស្អាតល្អហើយ ទើបចាំងដោយដឹងទាំងឡាយ លុះចាំងដោយដឹងរួចហើយ ក៏ច្រាស់ដោយកាំបិត លុះច្រាស់ដោយកាំបិតរួចហើយ ក៏យកពន្លាកដាប់ខាងក្នុងឲ្យស្អាតល្អ លុះដាប់ខាងក្នុងឲ្យស្អាតល្អហើយ ក៏លាក់ដោយគ្រឿងលាក់ លុះលាក់ដោយគ្រឿងលាក់រួចហើយ ក៏ដុសដោយដុំថ្ម លុះដុសដោយដុំថ្មរួចហើយ ក៏ធ្វើឲ្យបានជាទូក លុះធ្វើបានជាទូករួចហើយ ក៏ចងច្រវាថែវ លុះចងច្រវាថែវរួចហើយ ក៏បណ្តែតទៅក្នុងទន្លេ ។ ម្នាលសាឡ្ហៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសនោះអាចឆ្លងទន្លេរួចបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អាចឆ្លងបាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ដើមសាលព្រឹក្សឯណោះ

១៨១



ពហិទ្ធា សុបរិកម្មកតា អន្តោ សុវិសុទ្ធា នាវា កតា និយាវិត្តុំ ពទ្ធា ។ តស្សេតំ បាដិកង្ខំ នាវា ន សំសីទិស្សតិ បុរិសោ សោត្ថិនា បារំ គមិស្សតីតិ ។ ឯវមេវ ខោ សាឡ្ហ យេ តេ សមណព្រាហ្មណា ន តបោជិគុច្ឆវាទា ន តបោជិគុច្ឆសារា ន តបោជិគុច្ឆ-អល្លីនា វិហរន្តិ ភព្វា តេ ឱឃស្ស និត្ថរណាយ ។ យេបិ តេ សាឡ្ហ សមណព្រាហ្មណា បរិសុទ្ធកាយ-សមាចារា បរិសុទ្ធវចីសមាចារា បរិសុទ្ធមនោសមាចារា បរិសុទ្ធាជីវា ភព្វា តេ ញាណទស្សនាយ អនុត្តរាយ សម្ពោធាយ ។ សេយ្យថាបិ សាឡ្ហ យោធាជីវោ ពហូនិ ចេបិ កណ្ឌចិត្តកានិ ជានាតិ អថខោ សោ តីហិ ឋានេហិ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខំ គច្ឆតិ ។ កតមេហិ តីហិ ។ ទូរេបាតី ច អក្ខណវេធី ច មហតោ ច កាយស្ស បទាលេតា ។

គេធ្វើបរិកម្មល្អ ទាំងខាងក្រៅទាំងខាងក្នុងស្អាតល្អ ទាំងទុកគេក៏បានចង ប្រវាចែវរួចហើយ ។ ហេតុនុ៎ះនឹងមានប្រាកដដល់បុរសនោះ គឺទូកក៏ មិនលិច បុរសក៏នឹងឆ្លងដល់ត្រើយនាយដោយសួស្តីបាន មានឧបមា យ៉ាងណា ។ ម្នាលសាឡ្ហៈ ពួកសមណព្រាហ្មណ៍ណា មិនមែនជា អ្នកពោលនូវតបោជិគុច្ឆា មិនមានតបោជិគុច្ឆា ជាខ្លឹមសារ មិនជាប់ ជំពាក់ក្នុងតបោជិគុច្ឆា សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បី រលាស់ខ្លួន ចេញចាកឱឃៈបាន ។ ម្នាលសាឡ្ហៈ មួយទៀត ពួក សមណព្រាហ្មណ៍ណា មានកាយសមាចារបរិសុទ្ធ មានវចី-សមាចារបរិសុទ្ធ មានមនោសមាចារបរិសុទ្ធ មានអាជីវៈបរិសុទ្ធ សមណព្រាហ្មណ៍ទាំងនោះ ទើបគួរដើម្បីញាណទស្សនៈ ដើម្បី ត្រាស់ដឹង (នូវអរហត្ត) ដ៏ប្រសើរបាន មានឧបមេយ្យដូច្នោះ ដែរ ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន តែងស្គាល់នូវសរដ៏វិចិត្រ ទាំងឡាយដ៏ច្រើន ទាហាននោះ ជាអ្នកគួរដល់ព្រះរាជា ជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ស្តេច ដោយហេតុ ៣ យ៉ាងដោយពិត ។ ហេតុ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យធ្លាក់ចុះក្នុងទីឆ្ងាយបាន ១ បាញ់ត្រង់គ្នានខណៈ ១ បាញ់ទម្លុះទម្លាយពួកធំ ៗ បាន ១ ។

សេយ្យថាបិ សាឡ្ហ យោធាជីវោ ទុរេចាតី ឯវមេវ ខោ សាឡ្ហ អរិយសាវកោ សម្មាសមាធិ ហោតិ សម្មាសមាធិ សាឡ្ហ អរិយសាវកោ យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោ-ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ សេយ្យថាបិ សាឡ្ហ យោធាជីវោ អក្ខណវេធី ឯវមេវ ខោ សាឡ្ហ អរិយសាវកោ សម្មាទិដ្ឋិ ហោតិ

ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន បាញ់សរឲ្យធ្លាក់ចុះក្នុងទីឆ្ងាយបានយ៉ាងណា ម្នាលសាឡ្ហ អរិយសាវ័ក មានចិត្តតម្កល់ខ្ជាប់ដោយប្រពៃ ក៏យ៉ាងនោះដែរ ម្នាលសាឡ្ហៈ អរិយសាវ័ក មានចិត្តតម្កល់ខ្ជាប់ដោយប្រពៃ តែងពិចារណាឃើញនូវរូបនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្ដីពិតយ៉ាងនេះថា រូបឯណានីមួយ ជាអតីត អនាគតនិងបច្ចុប្បន្ន ទោះខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ឬរូបឯណា ដែលមានក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី ក៏ពិចារណាឃើញនូវរូបទាំងអស់នោះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ វេទនាឯណានីមួយ... សញ្ញាឯណានីមួយ... សង្ខារទាំងឡាយឯណានីមួយ... វិញ្ញាណឯណានីមួយ ដែលជាអតីត អនាគតនិងបច្ចុប្បន្ន ទោះនៅខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី វិញ្ញាណឯណា ដែលមានក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី ក៏ពិចារណាឃើញនូវវិញ្ញាណទាំងអស់នោះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន អ្នកបាញ់ត្រង់គ្មានខណៈយ៉ាងណា ម្នាលសាឡ្ហៈ អរិយសាវ័កអ្នកឃើញត្រូវ ក៏យ៉ាងនោះដែរ

សម្មាទិដ្ឋិ សាឡ្ហ អរិយសាវកោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ សេយ្យថាបិ សាឡ្ហ យោជាជីវោ មហន្តោ កាយស្ស បទាលេតា ឯវមេវ ខោ សាឡ្ហ អរិយសាវកោ សម្មាវិមុត្តិ ហោតិ សម្មាវិមុត្តិ សាឡ្ហ អរិយសាវកោ មហន្តំ អវិជ្ជាខន្ធំ បទាលេតីតិ ។

[៤៧] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ មល្លិកា ទេវី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ មល្លិកា ទេវី ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ ទស្សនាយ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។

ម្នាលសាឡ្ហៈ អរិយសាវ័ក អ្នកឃើញត្រូវ តែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ តែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលសាឡ្ហៈ ប្រៀបដូចទាហាន បាញ់ទម្លាយកង់ទ័ពធំៗ បានយ៉ាងណា ម្នាលសាឡ្ហៈ អរិយសាវ័ក អ្នកមានចិត្តផុតស្រឡះ ដោយប្រពៃក៏យ៉ាងនោះដែរ ម្នាលសាឡ្ហៈ អរិយសាវ័ក ដែលមានចិត្តផុតស្រឡះ ដោយប្រពៃហើយ តែងទម្លាយនូវគំនរនៃអវិជ្ជាដ៏ធំបាន ។

[៤៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ នាងមល្លិកាទេវី ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងមល្លិកាទេវី អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ជាមនុស្សកំសត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានស័ក្តិតូចផង

កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ ទស្សនាយ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ មហេសក្ខោ ច ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ មហេសក្ខោ ចាតិ ។ ឥធ មល្លិកេ ឯកច្ចោ មាតុគ្គាមោ កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។

បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានស័ក្តិធំ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ មានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ជាអ្នកប្រកបដោយពណ៌សម្បុរនិងទ្រង់ទ្រាយដ៏ឧត្តមផង តែជាអ្នកកំសត់ មានទ្រព្យតិច មានភោគៈតិចមានស័ក្តិតូចផង។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរនិងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានស័ក្តិធំផង ។ ម្នាលនាងមល្លិកា មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តីចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្ត ខឹងព្យាបាទ រឹងត្អឹងធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។

សោ[១] ន ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ ឥស្សាមនកោ[២] ខោ បន ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ឥស្សតិ ឧបទុស្សតិ ឥស្សំ ពន្ធតិ ។ សោ ចេ តតោ ចុតោ[៣] ឥត្ថត្តំ អាគច្ឆតិ សោ យត្ថ យត្ថ បច្ចាជាយតិ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ ទស្សនាយ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។ ឥធ បន មល្លិកេ ឯកច្ចោ មាតុគ្គាមោ កោធនោ ហោតិ ឧបាយាស-ពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ

---

១ ឱ. ម. សា ។ ២ ឱ. ឥស្សមានិកា ។ ម. ឥស្សាមនិកា ។ ៣ ឱ. ម. សា ចេ តតោ ចុតា ។

មាតុគ្រាមនោះ មិនដែលឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសំណាក់ គ្រឿងប្រទីប ដល់សមណៈឬព្រាហ្មណ៍ឡើយ ជាអ្នកមានចិត្តឫស្យា តែងឫស្យា ប្រទូស្តចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះនិងការបូជា របស់ជនទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ ជាអ្នកមានសម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ជាអ្នកកំសត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានស័ក្តិតូចផង ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តីចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹង ព្យាបាទ រឹងត្អឹង ធ្វើនូវសេចក្តីក្រោធ ទោសៈនិងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ តែមាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសំណាក់និងគ្រឿងប្រទីប ដល់សមណៈឬព្រាហ្មណ៍

អនិស្សាមនកោ ខោ បន ហោតិ បរលាភសក្ការ-
គរុការមាននវន្ទនបូជនាសុ ន ឥស្សតិ ន ឧប-
ទុស្សតិ ន ឥស្សំ ពន្ធតិ ។ សោ ចេ តតោ
ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យត្ថ យត្ថ
បច្ចាជាយតិ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ
ទស្សនាយ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ
មហេសក្ខោ ច ។ ឥធ បន មល្លិកេ ឯកច្ចោ
មាតុគាមោ អក្កោធនោ ហោតិ អនុបាយាសពហុលោ
ពហុម្បិ វុត្តោ សមានោ នាភិសជ្ជតិ ន កុប្បតិ
ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច
អប្បច្ចយញ្ច បាតុករោតិ ។ សោ ទាតា ហោតិ
សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ
មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ អនិស្សាម-
នកោ ខោ បន ហោតិ បរលាភសក្ការគរុការមាន-
នវន្ទនបូជនាសុ ន ឥស្សតិ ន ឧបទុស្សតិ ន ឥស្សំ ពន្ធតិ ។

ទាំងមិនមានចិត្តប្រកបដោយឫស្យា រមែងមិនមានឫស្យា មិនប្រទូស្តមិនចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អាន សំពះនិងការបូជា របស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ប៉ុន្តែជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មានស័ក្តិធំ ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ តែមាតុគ្រាមនោះ មិនដែលឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីបដល់សមណៈឬព្រាហ្មណ៍ឡើយ ទាំងជាអ្នកមានចិត្តប្រកបដោយឫស្យា តែងឫស្យា ប្រទូស្តចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះនិងការបូជា របស់បុគ្គលទាំងឡាយដទៃ ។

សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យត្ថ យត្ថ បច្ចាជាយតិ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។ ឥធ បន មល្លិកេ ឯកច្ចោ មាតុគ្គាមោ អក្កោធនោ ហោតិ អនុបាយាសពហុលោ ពហុម្បិ វុត្តោ សមានោ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សោ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថបទីបេយ្យំ អនិស្សាមនកោ ខោ បន ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ន ឥស្សតិ ន ឧបទុស្សតិ ន ឥស្សំ ពន្ធតិ ។ សោ ចេ តតោ ចុតោ ឥត្ថត្តំ អាគច្ឆតិ សោ យត្ថ យត្ថ បច្ចាជាយតិ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ

ប្រសិនបើ មាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះកើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរនិងទ្រង់ទ្រាយ ដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់ មានទ្រព្យតិច មានភោគៈតិច មានស័ក្តិតូច ។ ម្នាលនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធទោសៈនិងសេចក្តីមិនត្រេកអរឲ្យកើតប្រាកដឡើង ។ មាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ដល់សមណៈឬព្រាហ្មណ៍ ទាំងជាអ្នកមានចិត្តមិនប្រកបដោយឫស្យា តែងមិនឫស្យា មិនប្រទូស្ត មិនចងសេចក្តីឫស្យា ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះនិងការបូជា របស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង

បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ មហេសក្ខោ ច ។ អយំ ខោ មល្លិកេ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ ទស្សនាយ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។ អយំ បន មល្លិកេ ហេតុ អយំ បច្ចយោ យេន មិធេ-កច្ចោ មាតុគ្គាមោ ទុព្វណ្ណោ ច ហោតិ ទុរូបោ សុបាបិកោ ទស្សនាយ អឌ្ឍោ ច ហោតិ មហទ្ធ-នោ មហាភោគោ មហេសក្ខោ ច ។ អយំ ខោ មល្លិកេ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ អភិរូបោ ច ហោតិ ទស្សនីយោ បាសា-ទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ទលិទ្ទោ ច ហោតិ អប្បស្សកោ អប្បភោគោ អប្បេសក្ខោ ច ។ អយំ បន មល្លិកេ ហេតុ អយំ បច្ចយោ យេន មិធេកច្ចោ មាតុគ្គាមោ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ

ប្រកបដោយពណ៌ សម្បុរនិងទ្រង់ទ្រាយដ៏ឧត្តមផង ទាំងជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានស័ក្តិធំផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ មានសម្បុរអាក្រក់ផង អាក្រក់មើលណាស់ផង ជាអ្នកខ្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានស័ក្តិតូចផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ មានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ផង ប៉ុន្តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានស័ក្តិធំផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរនិងទ្រង់ទ្រាយដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់ មានទ្រព្យតិច មានភោគៈតិច មានស័ក្តិតូចផង ។ ម្នាលនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ មានរូបល្អផង គួរជាទីពិតពិលរមិលមើលផង គួរជាទីជ្រះថ្លាផង

១៤៩



បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ មហេសក្ខោ ចាតិ ។ ឯវំ វុត្តេ មល្លិកា ទេវី ភគវន្តំ ឯតទវោច សា នូនាហំ[1] ភន្តេ អញ្ញាយ ជាតិយា កោធនា អហោសឹ ឧបាយាសពហុលា អប្បម្បិ វុត្តា សមានា អភិសជ្ជឹ កុប្បឹ ព្យាបជ្ជឹ បតិត្ថីយឹ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសឹ សាហំ ភន្តេ ឯតរហិ ទុព្វណ្ណា ទុរូបា សុបាបិកា ទស្សនាយ ។ សា នូនាហំ[1] ភន្តេ អញ្ញាយ ជាតិយា អទាសឹ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ សាហំ ភន្តេ ឯតរហិ អឌ្ឍា មហទ្ធនា មហាភោគា ។ សា នូនាហំ ភន្តេ អញ្ញាយ ជាតិយា អនិស្សាមនកា អហោសឹ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ន ឥស្សឹ ន ឧបទុស្សឹ ន ឥស្សំ ពន្ធឹ

---

១ ឱ. ម. យន្នូនាហំ ។

ប្រកបដោយពណ៌សម្បុរនិងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានស័ក្តិធំផង ។ កាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មល្លិកាទេវី ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹង ព្យាបាទ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើង ក្នុងជាតិមុនដោយពិត បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានពណ៌សម្បុរអាក្រក់ រូបអាក្រក់ អាក្រក់មើលណាស់ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបទីដេក ផ្ទះសំណាក់ និងគ្រឿងប្រទីប ដល់សមណៈឬព្រាហ្មណ៍ក្នុងជាតិមុនដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ជាអ្នកមិនមានចិត្តឫស្យា មិនច្រណែន មិនប្រទូស្ត មិនចងសេចក្តីច្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អាន សំពះនិងការបូជា របស់បុគ្គលទាំងឡាយដទៃ អំពីជាតិមុន

សាហំ ភន្តេ ឯតរហិ មហេសក្ខា ។ សន្តិ ខោ បន ភន្តេ ឥមស្មឹ រាជកុលេ ខត្តិយកញ្ញាបិ ព្រាហ្មណកញ្ញាបិ គហបតិកញ្ញាបិ តាសាហំ ឥស្សរាធិបច្ចំ ការេមិ ឯសាហំ ភន្តេ អជ្ជតគ្គេ អកោធនា ភវិស្សាមិ អនុបាយាសពហុលា ពហុម្បិ វុត្តា សមានា នាភិសជ្ជិស្សាមិ ន កុប្បិស្សាមិ ន ព្យាបជ្ជិស្សាមិ ន បតិត្ថីយិស្សាមិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករិស្សាមិ ទស្សាមិ សមណស្ស ព្រាហ្មណស្ស អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថប្បទីបេយ្យំ អនិស្សាមនកា ភវិស្សាមិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ន ឥស្សិស្សាមិ ន ឧបទុស្សិស្សាមិ ន ឥស្សំ ពន្ធិស្សាមិ ។ អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសិកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានស័ក្តិធំដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ខត្តិយកញ្ញាខ្លះ ព្រាហ្មណកញ្ញាខ្លះ គហបតិកញ្ញាខ្លះ ដែលមានក្នុងរាជត្រកូលនេះ កញ្ញាទាំងនោះ ខ្ញុំព្រះអង្គតែងធ្វើជាធំ ជាអធិបតីលើកញ្ញាទាំងនោះ បពិត្រព្រះអង្គដ៏ចម្រើន តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំព្រះអង្គជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើង ខ្ញុំព្រះអង្គនឹងឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ផ្ទះដំណាក់ និងគ្រឿងប្រទីប ដល់សមណៈឬព្រាហ្មណ៍ ខ្ញុំព្រះអង្គនឹងមិនមានចិត្តឫស្យា មិនច្រណែន មិនប្រទូស្ត មិនចងនូវសេចក្តីច្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អាន សំពះនិងការបូជា របស់បុគ្គលទាំងឡាយដទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសិកា អ្នកដល់នូវសរណៈ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះតទៅ ។

[៤៨] ចត្តារោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ នេវ អត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ ។ សោ ច អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។

ចតុត្ថបណ្ណាសក មហាវគ្គ ទី ៥

[៤៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយ ៤ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គល ៤ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿផដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មិនជាអ្នកដុតកម្តៅខ្លួន មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃ មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ ១ ។ ឯបុគ្គលដែលមិនជាអ្នកដុតកម្តៅខ្លួន និងមិនដុតកម្តៅបុគ្គលដទៃនោះឯង ជាអ្នកឥតមានតណ្ហាគ្រឿងស្រេកឃ្លាន រលត់កិលេស មានសន្តានដ៏ត្រជាក់ ទទួលសុខជាប្រក្រតី សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរ ក្នុងកាលជាបច្ចុប្បន្ន ។

កថញ្ច ភិក្ខវេ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ នឯហិភទន្តិកោ នតិដ្ឋភទន្តិកោ នាភិហដំ ន ឧទ្ទិស្សកតំ ន និមន្តនំ សាទិយតិ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សំកិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកដុតកម្ដៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្ដៅខ្លួន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកអាក្រាត លះបង់មារយាទល្អ ស៊ីលិទ្ធដៃ ឬជម្រះឧច្ចារៈ ដោយម្រាមដៃ បើគេអញ្ជើញឲ្យចូលមក ក៏មិនមក គេឃាត់ថា ឈប់ក៏មិនឈប់ មិនត្រេកអរនឹងភត្ត ដែលគេនាំមកមុន មិនត្រេកអរនឹងភត្ត ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចដែលគេនិមន្តបុគ្គលនោះ មិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ឆែឬកន្ទ្រាប៉ី មិនទទួលភត្តដែលគេនាំមកកន្លងធរណីទ្វារ មិនទទួលភត្តដែលគេនាំមកកន្លងកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកកន្លងអង្រែ មិនទទួលភត្តរបស់មនុស្សពីរនាក់ ដែលកំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តក្នុងទីដែលមានពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកដែលត្រាំ បុគ្គលនោះ ទទួលភត្តចំពោះតែក្នុងផ្ទះ ១ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ១ ពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយពីរពំនូតខ្លះ

សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកម្បិ អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ សត្តាហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ សោ សាកភក្ខោបិ ហោតិ សាមាកភក្ខោបិ ហោតិ និវារភក្ខោបិ ហោតិ ទទ្ទុលភក្ខោបិ ហោតិ និយាសភក្ខោបិ ហោតិ ហដភក្ខោបិ ហោតិ កណភក្ខោបិ ហោតិ អាចាមភក្ខោបិ ហោតិ បិញ្ញាកភក្ខោបិ ហោតិ តិណភក្ខោបិ ហោតិ គោមយភក្ខោបិ ហោតិ វនមូលផលាហារោ យាបេតិ បវត្តផលភោជី សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដកានិបិ ធារេតិ អជិនំបិ ធារេតិ អជិនក្ខិបំបិ ធារេតិ កុសចីរំបិ ធារេតិ

ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍ ១ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍ ២ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍ ៧ ខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ បុគ្គលនោះប្រកបដោយសេចក្តីព្យាយាម ក្នុងការផ្លាស់ប្តូរនូវការបរិភោគភត្តរំលងកន្លះខែខ្លះ មានសភាពដូច្នេះឯង បុគ្គលនោះ មានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្លួយជាអាហារខ្លះ មានកំទេចស្បែកជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្មៅឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើនិងផ្លែឈើ ក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើ ដែលជ្រុះស្រាប់ខ្លះ បុគ្គលនោះ ស្លៀកដណ្តប់សំពត់សម្បកធ្មៃខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ស្លៀកដណ្តប់សំពត់ដែលគេបកចេញអំពីសាកសពខ្លះ ស្លៀកដណ្តប់សំពត់បង្សុកូលខ្លះ ស្លៀកដណ្តប់សំពត់សម្បកឈើខ្លះ ស្លៀកដណ្តប់ស្បែកខ្លាខ្លះ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកដណ្តប់សំពត់ស្បូវភ្លាំងខ្លះ

វាកចីរំបិ ធារេតិ ផលកចីរំបិ ធារេតិ កេសកម្ពលំបិ ធារេតិ វាលកម្ពលំបិ ធារេតិ ឧលូកបក្ខំបិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ ហោតិ អាសនប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សាយតតិយកម្បិ ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនានុយោគមនុយុត្តោ វិហរតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ។ កថញ្ច ភិក្ខវេ បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ។

ស្លៀកដណ្តប់សំពត់ ដែលគេត្បាញដោយសម្បកក្រចៅខ្លះ ស្លៀកដណ្តប់សំពត់ ចម្រៀកក្តារខ្លះ ស្លៀកដណ្តប់សំពត់កម្ពល ដែលគេត្បាញដោយសក់មនុស្សខ្លះ ស្លៀកដណ្តប់សំពត់កម្ពល ដែលគេត្បាញដោយរោមកន្ទុយសត្វខ្លះ ស្លៀកដណ្តប់សំពត់ ដែលគេត្បាញដោយស្លាបមៀមខ្លះ ទុកសក់និងពុកមាត់ ប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយការទុកសក់និងពុកមាត់ខ្លះ ឈរជ្រង់សម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោងប្រកបរឿយៗ នូវសេចក្តីព្យាយាមអង្គុយច្រហោងខ្លះ ប្រកបដោយបន្ទែកបន្លា[១] សម្រេចការដេកលើបន្ទែកដ៏ហើយដោយបន្លាខ្លះ ប្រកបរឿយៗ នូវសេចក្តីព្យាយាម ដោយការចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ (បុគ្គលនោះ) ប្រកបរឿយៗ នូវសេចក្តីព្យាយាមដុតកម្តៅកាយ មានប្រការៈច្រើនយ៉ាងមានសភាពយ៉ាងនេះ ដោយប្រការៈដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាអ្នកដុតកម្តៅខ្លួន ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដុតកម្តៅបុគ្គលដទៃប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ តើដូចម្តេច ។

---

១ យកបន្លាដែក ឬបន្លាជាប្រក្រតីទៅបោះនឹងផែនដី ហើយក្រាលកម្រាលស្បែកលើបន្លានោះហើយ សម្រេចនូវឥរិយាបថ មានឈរដើរជាដើម ។ អដ្ឋកថា ។

ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឱរព្ភិកោ ហោតិ សូក-
រិកោ សាកុណិកោ មាគវិកោ លុទ្ទោ មច្ឆឃាតកោ
ចោរោ ចោរឃាតកោ ពន្ធនាគារិកោ យេ វា បនញ្ញេបិ
កេចិ កុរូរកម្មន្តា ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ
បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ។
កថញ្ច ភិក្ខវេ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិ-
តាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុ-
យោគមនុយុត្តោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ
រាជា វា ហោតិ ខត្តិយោ មុទ្ធាភិសិត្តោ ព្រាហ្មណោ វា
មហាសាលោ សោ បុរត្ថិមេន នគរស្ស នវំ សន្ថា-
គារំ ការាបេត្វា កេសមស្សុំ ឱហារេត្វា ខរាជិនំ
និវាសេត្វា សប្បិតេលេន កាយំ អព្ភញ្ជិត្វា មិគវិសា-
ណេន បិដ្ឋឹ កណ្ឌុវមានោ សន្ថាគារំ បវិសតិ
សទ្ធឹ មហេសិយា ព្រាហ្មណេន ច បុរោហិតេន

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់បក្សី សម្លាប់ម្រឹគ ជាព្រាន ជាអ្នកសម្លាប់ត្រី ជាចោរ ជាអ្នកសម្លាប់ចោរ ជានាយគុក ឬពួកជនឯទៀតណាមួយ ដែលមានអំពើអាក្រក់ (បែបនេះដែរ) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គល ដទៃ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកដុត កម្តៅខ្លួន ប្រកបព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅ បុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាព្រះ រាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយក្តី ជាព្រាហ្មណមហាសាលក្តី បុគ្គលនោះ បានឲ្យគេសាងរោងយញ្ញថ្មី ខាងកើតនគរ រួចឲ្យគេ កោរសក់ពុកមាត់ពុកចង្កាឲ្យ ហើស្លៀកស្បែកខ្លាទាំងក្រចក លាប កាយដោយខ្លាញ់ថ្លានិងប្រេង ហើយយកស្នែងម្រឹគ អេះខ្នងដើរចូល ទៅកាន់រោងយញ្ញ ជាមួយនឹងអគ្គមហេសី និងព្រាហ្មណ៍ បុរោហិត

សោ តត្ថ អនន្តរហិតាយ ភូមិយា ហរិតុបលិត្តាយ សេយ្យំ កប្បេតិ ឯកិស្សា គាវិយា សរូបវច្ឆាយ យំ ឯកស្មឹ ថនេ ខីរំ ហោតិ តេន រាជា យាបេតិ យំ ទុតិយស្មឹ ថនេ ខីរំ ហោតិ តេន មហេសី យាបេតិ យំ តតិយស្មឹ ថនេ ខីរំ ហោតិ តេន ព្រាហ្មណោ បុរោហិតោ យាបេតិ យំ ចតុត្ថស្មឹ ថនេ ខីរំ ហោតិ តេន អគ្គឹ ជុហតិ អវសេសេន វច្ឆកោ យាបេតិ សោ ឯវមាហ ឯត្តកា ឧសភា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា អជា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា ឧរព្ភា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា រុក្ខា ឆិជ្ជន្តុ យូបត្ថាយ ឯត្តកា ទព្ភា លុយន្តុ ពរិហិសត្ថាយាតិ ។ យេបិស្ស តេ ហោន្តិ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ ទណ្ឌតជ្ជិតា ភយតជ្ជិតា អស្សុមុខា រុទមានា បរិកម្មានិ ករោន្តិ ។

បុគ្គលនោះ សម្រេចការដេកលើផែនដី ប្រាសចាកកម្រាលដែលគេលាប លទដោយពណ៌ខៀវ ក្នុងពេលយញ្ញនោះ ព្រះរាជាបានញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយទឹកដោះក្នុងដោះទីមួយ របស់មេគោមួយ ដែល មានកូនមានរូបប្រហែលនឹងមេវា អគ្គមហេសីញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត ទៅ ដោយទឹកដោះក្នុងដោះទីពីរ ព្រាហ្មណ៍ បុរោហិតញ៉ាំងអត្តភាពឲ្យ ប្រព្រឹត្តទៅ ដោយទឹកដោះក្នុងដោះទីបី បានបូជាភ្លើងដោយទឹកដោះក្នុង ដោះទីបួន កូនគោបានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទឹកដោះដ៏ សេសសល់ ព្រះរាជានោះបានត្រាស់យ៉ាងនេះថា ពួកជនចូរសម្លាប់គោ ឈ្មោលប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់គោស្ទាវប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់មេគោជំទង់ប៉ុណ្ណេះ ដើម្បីប្រ-យោជន៍ដល់យញ្ញ ចូរសម្លាប់ពពែប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរសម្លាប់ចៀមប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់យញ្ញ ចូរកាប់ឈើប៉ុណ្ណេះ ដើម្បីប្រយោជន៍ជាសសរយញ្ញ ចូរដកស្មៅដំណោកទន្សាយប៉ុណ្ណេះ ដើម្បី ប្រយោជន៍ដល់យញ្ញ ។ ជនពួកណាទោះបីជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាអ្នក ធ្វើការងារក្តី ជនពួកនោះ លុះត្រូវគេគម្រាមដោយអាជ្ញា ត្រូវភ័យគ្រប សង្កត់ហើយ ក៏មានមុខជោកដោយទឹកភ្នែកទួញយំ ធ្វើបរិកម្មផ្សេង ៗ ។

## ១៦៧



ឯវំ ខោ ភិក្ខវេ បុគ្គលោ អត្តន្តបោ ច ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ។ កតមញ្ច ភិក្ខវេ បុគ្គលោ នេវ អត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ ។ សោ ច អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកដុតកម្តៅខ្លួន ប្រកបព្យាយាម ជាគ្រឿងដុតកម្តៅខ្លួនផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនជាអ្នកដុតកម្តៅខ្លួន មិនប្រកបការព្យាយាម ជាគ្រឿងដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃ មិនប្រកបព្យាយាម ជាគ្រឿងដុតកម្តៅបុគ្គលដទៃ តើដូចម្តេច ។ ឯបុគ្គលមិនជាអ្នកដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃនោះឯង ជាអ្នកឥតមានតណ្ហាគ្រឿងស្រេកឃ្លាន រលត់កិលេស មានសន្តានដ៏ត្រជាក់ ទទួលសុខជាប្រក្រតី សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរបំផុត ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលមកកាន់ភពថ្មីទៀត កើតឡើងក្នុងលោកនេះ ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចនឹងប្រកាសបាន ។

សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្តំ បហាយ មហន្តំ វា ញាតិបរិវដ្តំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។

ព្រះអង្គទ្រង់សម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ។ គហបតីក្តី បុត្តនៃគហបតីក្តី ជនដែលកើតក្នុងត្រកូលណាមួយក្តី រមែងស្តាប់នូវធម៌នោះ លុះបានស្តាប់នូវធម៌នោះហើយ រមែងបាននូវសទ្ធា ក្នុងព្រះតថាគត បុគ្គលនោះលុះប្រកបដោយការបាននូវសទ្ធានោះហើយ រមែងពិចារណាឃើញដូច្នេះថា ឃរាវាសប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាផ្លូវហូរមកនៃធូលីគឺកិលេស ឯបព្វជ្ជាទើបមានឱកាស កាលបើអាត្មាអញ នៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យពេញបរិបូណ៌បរិសុទ្ធទាំងអស់ដូចជាស័ង្ខដែលបុគ្គលដុសខាត់បានឡើយ បើដូច្នោះគួរតែអាត្មាអញ កោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់ជ្រលក់ទឹកអម្ចត់ ចេញចាកផ្ទះ បួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ ។ លុះកាលជាខាងក្រោយមក បុគ្គលនោះក៏បានលះបង់គំនរទ្រព្យតិចខ្លះ លះបង់គំនរទ្រព្យច្រើនខ្លះ លះបង់វង្សញាតិច្រើនខ្លះ លះបង់វង្សញាតិតិចខ្លះ ហើយកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយ៍ជ្រលក់ទឹកអម្ចត់ ចេញចាកផ្ទះមកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ ។

១៦៩



សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតិ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី វិរតោ មេថុនា[១] គាមធម្មា មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ

១ ម. អនាចារី វិរតោ អសទ្ធម្មា ។

បុគ្គលនោះបានបួសយ៉ាងនេះហើយ ក៏ជាអ្នកបរិបូណ៌ដោយសិក្ខានិងសាជីវៈរបស់ភិក្ខុទាំងឡាយ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ជាអ្នកកាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ ជាអ្នកមិនលួច មានខ្លួនដ៏ស្អាត លះបង់អព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុនធម្មជារបស់អ្នកស្រុក លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលតែពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរអ្នកផងជឿបាន មិនពោលបំភ្លាត់សត្វលោក លះបង់បិសុណាវាចា វៀរស្រឡះចាកបិសុណាវាចា ជាអ្នកបានឮពាក្យ ក្នុងសំណាក់នៃពួកជនឯណោះហើយ មិននាំទៅប្រាប់ ដល់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះឡើយ ឬបានឮពាក្យ ក្នុងសំណាក់នៃពួកជនឯណោះហើយ មិននាំយកមកប្រាប់ដល់ពួកជនឯណោះ ដើម្បីបំបែកពួកជនឯណោះឡើយ ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាហើយ ឬបន្ថែមកម្លាំងឲ្យ ដល់ពួកជនដែលព្រមព្រៀងគ្នាហើយ ជាអ្នកមានសេចក្តីព្រមព្រៀង ជាទីត្រេកអរ

សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ សោ ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ឯកភត្តិកោ ហោតិ រត្តូបរតោ បដិវិរតោ វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ អាមកធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ អាមកមំសប្បដិគ្គហណា បដិវិរតោ ហោតិ

ត្រេកអរក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ជាអ្នកពោលវាចាដែលធ្វើឲ្យព្រមព្រៀងគ្នា លះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា វាចាណាដែលឥតទោស ជាសុខដល់ត្រចៀក គួរឲ្យអ្នកផងស្រឡាញ់ពេញហឫទ័យ ជាសម្តីអ្នកក្រុង ជាទីត្រេកអរដល់ជនច្រើននាក់ ជាទីពេញចិត្តដល់ជនច្រើននាក់ ក៏ពោលតែវាចាបែបនោះ លះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកពោលពាក្យក្នុងការគួរ ពោលតែពាក្យដែលពិតប្រាកដ ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ពោលតែពាក្យដែលជាវិន័យ ពោលតែពាក្យមានឱកាសជាទីតម្កល់ទុក ក្នុងហឫទ័យប្រកបដោយគ្រឿងអាង មានគ្រឿងកំណត់ ប្រកបដោយប្រយោជន៍តាមកាលគួរ ។ បុគ្គលនោះ វៀរស្រឡះចាកកិរិយាធ្វើពីជគាមនិងភូតគាមឲ្យវិនាស ជាអ្នកបរិភោគភត្តតែមួយពេល វៀរបរិភោគក្នុងរាត្រី វៀរបរិភោគក្នុងកាលខុស វៀរចាកការមើលនូវល្បែងរាំច្រៀង និងភ្លេងប្រគំដែលជាសត្រូវដល់កុសលធម៌ វៀរចាកការទ្រទ្រង់ការប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ វៀរចាកទីដេក ទីអង្គុយដ៏ប្រសើរ វៀរចាកការទទួលនូវមាសនិងប្រាក់ វៀរចាកការទទួលនូវធញ្ញជាតិស្រស់ វៀរចាកការទទួលសាច់ឆៅ

១៧១

ឥត្ថីកុមារិកាបដិគ្គហណា បដិវិរតោ ហោតិ ទាសីទា-
សប្បដិគ្គហណា បដិវិរតោ ហោតិ អជេឡកប្បដិគ្គ-
ហណា បដិវិរតោ ហោតិ កុក្កុដសូករប្បដិគ្គហណា
បដិវិរតោ ហោតិ ហត្ថិគវាស្សវឡវប្បដិគ្គហណា
បដិវិរតោ ហោតិ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ
ហោតិ ទូតេយ្យប្បហីណគមនានុយោគា បដិវិរតោ
ហោតិ កយវិក្កយា បដិវិរតោ ហោតិ តុលាកូដកំ-
សកូដមានកូដា បដិវិរតោ ហោតិ ឧក្កោដនវញ្ចន-
និកតិសាវិយោគា បដិវិរតោ ហោតិ ឆេទនវធពន្ធបរា-
មោសអាលោបសហសាការា បដិវិរតោ ហោតិ ។
សោ សន្តុដ្ឋោ ហោតិ កាយបរិហារកេន ចីវរេន
កុច្ឆិបរិហារកេន បិណ្ឌបាតេន យេន យេនេវ
បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ
នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្ត-
ភារោវ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយ-
បរិហារកេន ចីវរេន កុច្ឆិបរិហារកេន បិណ្ឌបាតេន
យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។

វៀរចាកការទទួលស្រីនិងកុមារី វៀរចាកការទទួលខ្ញុំស្រីនិងខ្ញុំប្រុស វៀរចាកការទទួលពពែនិងចៀម វៀរចាកការទទួលមាន់និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោល ញី វៀរចាកការទទួលស្រែនិងចម្ការ វៀរចាកការប្រកបនូវទូតកម្ម គឺការនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រហស្ថនឹងទៅដោយគេប្រើ អំពីផ្ទះមួយទៅផ្ទះមួយ វៀរចាកការទិញនិងការលក់ដូរ វៀរចាកការបញ្ឆោតឬបន្លំដោយជញ្ជីង បញ្ឆោតដោយភាជន៍ក្រឡែមាស (ជាដើម) បញ្ឆោតដោយរង្វាស់រង្វាល់ វៀរចាកការប្រកបនូវអំពើវៀច បញ្ឆោតបំភាន់ បញ្ឆោតបោកប្រាស បន្លំដោយរបស់ក្លែង វៀរចាកការកាត់ (នូវអវយវៈមានដៃជាដើម) សម្លាប់ ចាប់ចង លាក់ខ្លួនពួនចាំធ្វើអំពើអាក្រក់និងកំហែងយកទ្រព្យគេ ។ បុគ្គលនោះ ជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយនិងបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ កាលបើចេញទៅកាន់ទីណាៗ ក៏កាន់យកតែ (បរិក្ខារ) ប៉ុណ្ណោះចេញទៅ ។ ដូចជាសកុណជាតិមានស្លាប ទោះហើរទៅកាន់ទីណាៗ ក៏មានតែស្លាបរបស់ខ្លួនជាភារៈប៉ុណ្ណោះហើរទៅ យ៉ាងណា ភិក្ខុជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ និងបិណ្ឌបាត ជាគ្រឿងរក្សាផ្ទៃ ទោះទៅកាន់ទីណាក៏កាន់យកតែ (បរិក្ខារ) ប៉ុណ្ណោះហើយចេញទៅ យ៉ាងនោះដែរ ។

សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុ-ព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នា-គតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។

បុគ្គលនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលចំពោះនូវសុខមិនមានទោស ក្នុងសន្តាននៃខ្លួន ។ បុគ្គលនោះ បានឃើញរូបដោយចក្ខុហើយ តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក... បានធុំក្លិនដោយច្រមុះ... បានទទួលរសដោយអណ្តាត... បានពាល់ត្រូវផ្សព្វដោយកាយ... បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ បុគ្គលនោះប្រកបដោយការសង្រួមឥន្ទ្រិយដ៏ប្រសើរនេះ ទទួលសុខដែលមិនច្រឡំ ដោយកិលេសជាខាងក្នុង ។

សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារប្បស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ[១] វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ

១ ឱ. ឥតោ បរំ (ឥមាយ ច អរិយាយ សន្តុដ្ឋិយា សមន្នាគតោតិ) ទស្សន្តិ ។

បុគ្គលនោះ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការឈានទៅមុខនិងការឈានថយក្រោយ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការមើលទៅមុខ និងមើលផ្សេងៗ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការបត់ចូលនិងលាចេញ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការទ្រទ្រង់នូវសំឃាដី បាត្រនិងចីវរ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការបរិបភោគ ផឹក ទំពាស៊ីនិងទទួលរស ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងឧច្ចារបប្បស្សាវកម្ម ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងការដើរ ឈរ អង្គុយ លក់ ភ្ញាក់ពីដេក និយាយ នៅស្ងៀម ។ បុគ្គលនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈ ដ៏ប្រសើរនេះផង ប្រកបដោយសតិនិងសម្បជញ្ញៈដ៏ប្រសើរនេះផង សេពគប់នូវសេនាសនៈស្ងាត់គឺ ព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ លុះបុគ្គលនោះ ត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាខាងក្រោយកត្តវិញ ក៏ពត់ភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មាតីឲ្យមានមុខឆ្ពោះ (ទៅរកកម្មដ្ឋាន) ។ បុគ្គលនោះលះបង់នូវអភិជ្ឈាក្នុងលោក

វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ

មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់នូវព្យាបាទនិង សេចក្តីប្រទូស្ត មានចិត្តមិនមានព្យាបាទ មានសេចក្តីអនុគ្រោះ ដោយ ប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តចាកព្យាបាទនិងសេចក្តី ប្រទូស្តលះបង់នូវថីនមិទ្ធៈ គឺសេចក្តីងងុយងោកងក់ មានថីនមិទ្ធៈទៅ ប្រាសហើយ មានសេចក្តីសម្គាល់នូវពន្លឺ មានស្មារតី មានសេចក្តីដឹង ខ្លួន ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយសោយ ចិត្ត មានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ ក្នុងសន្តាន ជម្រះចិត្តចាក ឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆា គឺសេចក្តីងឿងឆ្ងល់ មានចិត្តឆ្លងផុតចាក វិចិកិច្ឆា មិនមានសេចក្តីសង្ស័យក្នុងកុសលធម៌ ជម្រះចិត្តចាកវិចិកិច្ឆា ។ បុគ្គលនោះ លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសនៃចិត្ត ជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកម្លាំង ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ បុគ្គលនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស មានឧបក្កិលេសទៅប្រាស មានសភាពជាចិត្តទន់ភ្លន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនដល់នូវការរំភើបទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តឆ្ពោះទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញាជា គ្រឿងរលឹកតាមនូវខន្ធ ដែលសត្វធ្លាប់អាស្រ័យនៅហើយ ក្នុងកាលមុន

១៧៤

ចតុត្ថបណ្ណាសកេ មហាវគ្គោ បញ្ចមោ

សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិស-តសហស្សំបិ អនេកោបិ សំវដ្តកប្បេ អនេកោបិ វិវដ្តកប្បេ អនេកោបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខ-ទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទចាទឹ តត្រាចាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមា-យុបរិយន្តោ សោ តតោ ចុតោ ឥធុបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ

បុគ្គលនោះ រមែងរលឹកតាមនូវបុព្វេនិវាស គឺខន្ធដែលមនុស្សសត្វធ្លាប់អាស្រ័យនៅឡើយ ក្នុងភពមុនជាច្រើនប្រការ ការរលឹកបាននោះតើដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អស់សំវដ្តកប្ប គឺកប្បដែលវិនាសជាច្រើនខ្លះ អស់វិវដ្តកប្ប គឺកប្បដែលចម្រើនជាច្រើនខ្លះ អស់សំវដ្តវិវដ្តកប្ប គឺកប្បវិនាសនិងកប្បចម្រើនជាច្រើនខ្លះថា អាត្មាអញ បានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញ ច្យុតចាកភពនោះហើយ ទៅកើតក្នុងភពឯណោះ ដែលអាត្មាអញ បានទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកភពនោះហើយ ទើបបានមកកើតក្នុងភពនេះដូច្នេះ រលឹកតាមនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការៈគឺសម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រកូល ដោយប្រការៈដូច្នេះឯង

សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតុបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ

បុគ្គលនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ភ្លន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនរំភើប ទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ បុគ្គលនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធស្អាត កន្លងបង់នូវចក្ខុ ជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុតនិងកើតឡើង ថោកទាបនិងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯពួកសត្វនេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌ដូច្នេះ

១៧៧



ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន
សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ
បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ
យថាកម្មុបគេ សត្តេ បជានាតិ សោ ឯវំ សមាហិតេ
ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិ-
លេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ
អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ
ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុ-
ទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ
យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិប-
ទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ
បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ
អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ
អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។

មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បាន ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ជាសត្វថោកទាប និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិ អាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ បុគ្គលនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជា ចិត្តទន់ភ្លន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនរំភើបទៅ តាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ បុគ្គលនោះ រមែងដឹង ច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុ កើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់ តាមពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់ តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុ កើតឡើងនៃអាសវៈ ដឹងច្បាស់តាមពិតថា នេះជាទីរលត់នៃអាសវៈ ដឹង ច្បាស់តាមពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់នៃអាសវៈ ។

តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជា-សវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯវំ ខោ ភិក្ខវេ បុគ្គលោ នេវ អត្តន្តបោ ហោតិ ន អត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរ-បរិតាបនានុយោគមនុយុត្តោ ។ សោ ច អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតីភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

កាលបើបុគ្គលនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងថា ចិត្ត(នៃអាត្មាអញ) ផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈដែលអាត្មាអញប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញ ក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនជាអ្នកដុតកម្តៅខ្លួន ទាំងមិនប្រកបព្យាយាមជាគ្រឿងដុតកម្តៅខ្លួន មិនជាអ្នកដុតកម្តៅបុគ្គលដទៃ ទាំងមិនប្រកបព្យាយាមជាគ្រឿងដុតកម្តៅបុគ្គលដទៃ យ៉ាងនេះឯង ។ បុគ្គលដែលមិនដុតកម្តៅខ្លួន ទាំងមិនដុតកម្តៅបុគ្គលដទៃនោះ ជាបុគ្គលមិនមានតណ្ហាគ្រឿងស្រេកឃ្លាន រលត់ទុក្ខ ជាអ្នកមានសន្តានចិត្តដ៏ត្រជាក់ ទទួលតែសេចក្តីសុខ សម្រេចសម្រាន្តនៅ ដោយចិត្តដ៏ប្រសើរ ក្នុងកាលជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះឯង មានប្រាកដនៅក្នុងលោក ។

[៤៩] តណ្ហំ វោ ភិក្ខវេ ទេសេស្សាមិ ជាលិនឹ សំសរិតំ វិសដំ វិសត្តិកំ យាយ អយំ លោកោ ឧទ្ធស្តោ បរិយោនទ្ធោ តន្តាកុលកជាតោ គុលាគុណ្ឋិ-កជាតោ មុញ្ជបព្វជភូតោ អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តតិ តំ សុណាថ សាធុកំ មនសិ-ករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមា ច សា ភិក្ខវេ តណ្ហា ជាលិនី សំសរិតា វិសដា វិសត្តិកា យាយ អយំ លោកោ ឧទ្ធស្តោ បរិយោនទ្ធោ តន្តាកុលកជាតោ គុលាគុណ្ឋិកជាតោ[១] មុញ្ជបព្វជ-ភូតោ អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តតិ ។

១ គុលាគុណ្ឌិកជាតោតិបិ ។

[៤៩] ម្នាលភិក្ខុទាំងឡាយ សត្វលោកនេះ ត្រូវតណ្ហាណារួបរឹតឲ្យរន្ធត់ហើយ មានសន្តានសាំញ៉ាំដូចជាដម្បាញ ស្មុគស្មាញដូចជាអំបោះជាងដម្បាញ ដែលជំពាក់ប្រទ្បាក់ដោយទឹកបាយ ចាក់កណ្តាញ់ដូចជាស្មៅយាបូងនិងស្មៅដំណេកទន្សាយ មិនងាយប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តថាគតនឹងសម្តែងនូវតណ្ហានោះ ដែលជាគ្រឿងចាក់ស្រែះ នាំសត្វឲ្យត្រាច់រង្គាត់ផ្សាយទៅជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ចុះសត្វលោក ដែលតណ្ហាណារួបរឹតឲ្យរន្ធត់ហើយ មានសន្តានសាំញ៉ាំដូចជាដម្បាញ ស្មុគស្មាញដូចជាអំបោះជាងដម្បាញ ដែលជំពាក់ប្រទ្បាក់ ដោយទឹកបាយ ចាក់កណ្តាញ់ដូចជាស្មៅយាបូងនិងស្មៅដំណេកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តណ្ហាជាគ្រឿងចាក់ស្រែះនាំសត្វឲ្យត្រាច់រង្គាត់ផ្សាយទៅជាប់នៅ ក្នុងអារម្មណ៍ផ្សេង ៗ នោះ តើដូចម្តេច ។

អដ្ឋារស ខោ បនិមានិ ភិក្ខវេ តណ្ហាវិចរិតានិ អជ្ឈត្តិកស្សុបាទាយ អដ្ឋារស តណ្ហាវិចរិតានិ ពាហិរស្សុបាទាយ ។ កតមានិ តានិ អដ្ឋារស តណ្ហាវិចរិតានិ អជ្ឈត្តិកស្សុបាទាយ ។ អស្មីតិ ភិក្ខវេ សតិ ឥត្ថស្មីតិ ហោតិ ឯវស្មីតិ ហោតិ អញ្ញថាស្មីតិ ហោតិ អសស្មីតិ ហោតិ សតស្មីតិ ហោតិ សន្តិ ហោតិ ឥត្ថំ សន្តិ ហោតិ ឯវំ សន្តិ ហោតិ អញ្ញថា សន្តិ ហោតិ អបិ[១] សន្តិ ហោតិ អបិ[១] ឥត្ថំ សន្តិ ហោតិ អបិ[១] ឯវំ សន្តិ ហោតិ អបិ[១]

១ ឱ. អបិហ ។ ម. អបិហំ ។

ម្នាលភិក្ខុទាំងឡាយ តណ្ហាវិចរិត (ការប្រព្រឹត្តទៅនៃតណ្ហា) ដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្នុងនេះ មាន ១៨ តណ្ហាវិចរិត ដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្រៅក៏មាន ១៨ ដែរ ។ តណ្ហាវិចរិតដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្នុង ១៨ នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញទៀងដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការៈដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដូច្នេះខ្លះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះខ្លះដូច្នេះ

១៨១



អញ្ញថា សន្តិ ហោតិ ភវិស្សន្តិ ហោតិ ឥត្ថំ ភវិស្សន្តិ ហោតិ ឯវំ ភវិស្សន្តិ ហោតិ អញ្ញថា ភវិស្សន្តិ ហោតិ ។ ឥមានិ អដ្ឋារស តណ្ហាវិចរិតានិ អជ្ឈត្តិកស្សុបាទាយ ។ កតមានិ អដ្ឋារស តណ្ហាវិចរិតានិ ពាហិរស្សុបាទាយ ។ ឥមិនា អស្មីតិ ភិក្ខវេ សតិ ឥមិនា ឥត្ថស្មីតិ ហោតិ ឥមិនា ឯវស្មីតិ ហោតិ ឥមិនា អញ្ញថាស្មីតិ ហោតិ ឥមិនា អសស្មីតិ ហោតិ ឥមិនា សតស្មីតិ ហោតិ ឥមិនា សន្តិ ហោតិ ឥមិនា ឥត្ថំ សន្តិ ហោតិ

ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការៈដទៃខ្លះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការៈដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន យ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការៈដទៃដូច្នេះ ក៏រមែងមាន ។ ទាំង ១៨ នេះ ជាតណ្ហាវិចរិត ដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្នុង ។ តណ្ហាវិចរិត ១៨ ដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្រៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីប្រកាន់ថា អាត្មាអញមាន ដោយខន្ធនេះដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការៈនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមាន យ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការៈដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញទៀង ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការៈនេះ ដោយខន្ធនេះដូច្នេះ

ឥមិនា ឯវំ សន្តិ ហោតិ ឥមិនា អញ្ញថា សន្តិ ហោតិ ឥមិនា អបិ សន្តិ ហោតិ ឥមិនា អបិ ឥត្ថំ សន្តិ ហោតិ ឥមិនា អបិ ឯវំ សន្តិ ហោតិ ឥមិនា អបិ អញ្ញថា សន្តិ ហោតិ ឥមិនា ភវិស្សន្តិ ហោតិ ឥមិនា ឥត្ថំ ភវិស្សន្តិ ហោតិ ឥមិនា ឯវំ ភវិស្សន្តិ ហោតិ ឥមិនា អញ្ញថា ភវិស្សន្តិ ហោតិ ។ ឥមានិ អដ្ឋារស តណ្ហាវិចរិតានិ ពាហិរស្សុបាទាយ ។ ឥតិ អដ្ឋារស តណ្ហាវិចរិតានិ អជ្ឈត្តិកស្សុបាទាយ អដ្ឋារស តណ្ហាវិចរិតានិ ពាហិរស្សុបាទាយ ។

ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដោយប្រការៈដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយខន្ធនេះ ដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយប្រការៈនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយប្រការៈដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការៈដូច្នេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការៈដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន ។ ទាំង ១៨ នេះ ជាតណ្ហាវិចរិត ដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្រៅ ។ តណ្ហាវិចរិតដែអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្នុងមាន ១៨ និងតណ្ហាវិចរិតដែលអាស្រ័យ (ខន្ធបញ្ចកៈ) ខាងក្រៅ ១៨ ដោយប្រការដូច្នេះ ។

ឥមានិ វុច្ចន្តិ ភិក្ខវេ ឆត្តឹស តណ្ហាវិចរិតានិ ឥតិ ឯវរូបានិ អតីតានិ ឆត្តឹស តណ្ហាវិចរិតានិ អនាគតានិ ឆត្តឹស តណ្ហាវិចរិតានិ បច្ចុប្បន្នានិ ឆត្តឹស តណ្ហាវិចរិតានិ អដ្ឋតណ្ហាវិចរិតសតំ ហោតិ ។ អយំ ខោ សា ភិក្ខវេ តណ្ហា ជាលិនី សំសរិតា វិសដា វិសត្តិកា យាយ អយំ លោកោ ឧទ្ធស្តោ បរិយោនទ្ធោ តន្តាកុលកជាតោ គុលាគុណ្ឋិកជាតោ មុញ្ជបព្វជភូតោ អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តតីតិ ។

[៤០] ចត្តារីមានិ ភិក្ខវេ[១] ជាយន្តិ ។ កតមានិ ចត្តារិ ។ បេមា បេមំ ជាយតិ បេមា ទោសោ ជាយតិ ទោសា បេមំ ជាយតិ ទោសា ទោសោ ជាយតិ ។ កថញ្ច ភិក្ខវេ បេមា បេមំ ជាយតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលស្ស ឥដ្ឋោ ហោតិ កន្តោ មនាបោ

១ ម. ឯត្ថន្តរេ បេមានីតិ អត្ថិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា តណ្ហាវិចរិតនោះ មាន ៣៦ មានសភាពយ៉ាងនេះដូច្នេះ គឺតណ្ហាវិចរិតជាអតីត ៣៦ តណ្ហាវិចរិតជាអនាគត ៣៦ តណ្ហាវិចរិតជាបច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិចរិត ១០៨ ។ ម្នាលភិក្ខុទាំងឡាយ សត្វលោកនេះត្រូវតណ្ហាណា រួបរឹតឲ្យរន្ធត់ហើយ ជាសត្វមានសន្តានសាំញុាំដូចជាដម្បាញ ស្មុគស្មាញដូចជាអំបោះ ជាដម្បាញដែលជំពាក់ប្រទាក់ ដោយទឹកបាយ ចាក់កណ្ដាញ់ដូចជាស្មៅយាប្លង់និងស្មៅដំណេកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ តណ្ហានេះឯង ជាគ្រឿងចាក់ស្រែះ នាំសត្វឲ្យត្រាច់រង្គាត់ផ្សាយទៅជាប់នៅ ក្នុងអារម្មណ៍ផ្សេងៗ ។

[៥០] ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាង រមែងកើតមាន ។ ធម្មជាត ៤ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីស្រឡាញ់កើត ព្រោះសេចក្ដីស្រឡាញ់ ១ សេចក្ដីប្រទូស្តកើត ព្រោះសេចក្ដីស្រឡាញ់ ១ សេចក្ដីស្រឡាញ់កើត ព្រោះសេចក្ដីប្រទូស្ត១ សេចក្ដីប្រទូស្តកើត ព្រោះសេចក្ដីប្រទូស្ត១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីស្រឡាញ់កើត ព្រោះសេចក្ដីស្រឡាញ់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គល

តំ បរេ ឥដ្ឋេន កាន្តេន មនាបេន សមុទាចរន្តិ ។ តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ ឥដ្ឋោ កាន្តោ មនាបោ តំ បរេ ឥដ្ឋេន កាន្តេន មនាបេន សមុទាចរន្តីតិ សោ តេសុ បេមំ ជនេតិ ។ ឯវំ ខោ ភិក្ខវេ បេមា បេមំ ជាយតិ ។ កថញ្ច ភិក្ខវេ បេមា ទោសោ ជាយតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលស្ស ឥដ្ឋោ ហោតិ កាន្តោ មនាបោ តំ បរេ អនិដ្ឋេន អកាន្តេន អមនាបេន សមុទា-ចរន្តិ ។ តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ ឥដ្ឋោ កាន្តោ មនាបោ តំ បរេ អនិដ្ឋេន អកាន្តេន អមនាបេន សមុទាចរន្តីតិ សោ តេសុ ទោសំ ជនេតិ ។ ឯវំ ខោ ភិក្ខវេ បេមា ទោសោ ជាយតិ ។

ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។ បុគ្គល (អ្នកចូលចិត្ត) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្តដែរ បុគ្គលនោះក៏ធ្វើសេចក្តីស្រឡាញ់ ឲ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីស្រឡាញ់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើតមាន ព្រោះសេចក្តីស្រឡាញ់តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល (អ្នកចូលចិត្ត) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តសោះ បុគ្គលនោះក៏ធ្វើសេចក្តីប្រទូស្តឲ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើត ព្រោះសេចក្តីស្រឡាញ់ យ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ទោសា បេមំ ជាយតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលស្ស អនិដ្ឋោ ហោតិ អកន្តោ អមនាបោ តំ បរោ អនិដ្ឋេន អកន្តេន អមនាបេន សមុទាចរតិ ។ តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ អនិដ្ឋោ អកន្តោ អមនាបោ តំ បរោ អនិដ្ឋេន អកន្តេន អមនាបេន សមុទាចរតីតិ សោ តេសុ បេមំ ជនេតិ ។ ឯវំ ខោ ភិក្ខវេ ទោសា បេមំ ជាយតិ ។ កថញ្ច ភិក្ខវេ ទោសា ទោសោ ជាយតិ ។ ឥធ ភិក្ខវេ បុគ្គលោ បុគ្គលស្ស អនិដ្ឋោ ហោតិ អកន្តោ អមនាបោ តំ បរោ ឥដ្ឋេន កន្តេន មនាបេន សមុទាចរតិ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើតឡើង ព្រោះសេចក្តីប្រទូស្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល (អ្នកមិនពេញចិត្ត) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណា មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត របស់អាត្មាអញ ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តដែរ បុគ្គលនោះ ក៏ធ្វើសេចក្តីស្រឡាញ់ឲ្យកើត ក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីប្រទូស្តយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើត ព្រោះសេចក្តីប្រទូស្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់បុគ្គល ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។

តស្ស ឯវំ ហោតិ យោ ខោ ម្យាយំ បុគ្គលោ អនិជ្ជោ អកាង្គោ អមជាចោ តំ បរេ ឥជ្ជេន កាង្គេន មជាបេន សមុជាចរន្តីតិ សោ តេសុ ធោសំ ជនេតិ ។ ឯវំ ខោ ភិក្ខវេ ធោសា ធោសោ ជាយតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ជាយន្តិ ។

យស្មឹ ភិក្ខវេ សមយេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ យំ បិស្ស បេមា បេមំ ជាយតិ តំ បិស្ស តស្មឹ សមយេ ន ហោតិ យោ បិស្ស បេមា ធោសោ ជាយតិ សោ បិស្ស តស្មឹ សមយេ ន ហោតិ យំ បិស្ស ធោសា បេមំ ជាយតិ តំ បិស្ស តស្មឹ សមយេ ន ហោតិ យោ បិស្ស ធោសា ធោសោ ជាយតិ សោ បិស្ស តស្មឹ សមយេ ន ហោតិ ។

បុគ្គល (ជាអ្នកមិនពេញចិត្ត) នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណា មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរក ចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្តទៅវិញ បុគ្គលនោះ ក៏ធ្វើសេចក្តីប្រទូស្តឲ្យកើត ក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រទូស្តកើត ព្រោះសេចក្តីប្រទូស្តយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះឯង តែងកើតមាន ។

ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុស្ងប់ស្ងាត់ ចាកកាមទាំងឡាយ ។ បេ ។ បានដល់បឋមជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ ក៏មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ ។

យស្មឹ ភិក្ខវេ សមយេ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ យំ បិស្ស បេមា បេមំ ជាយតិ តំ បិស្ស តស្មឹ សមយេ ន ហោតិ យោ បិស្ស បេមា ទោសោ ជាយតិ សោ បិស្ស តស្មឹ សមយេ ន ហោតិ យំ បិស្ស ទោសា បេមំ ជាយតិ តំ បិស្ស តស្មឹ សមយេ ន ហោតិ យោ បិស្ស ទោសា ទោសោ ជាយតិ សោ បិស្ស តស្មឹ សមយេ ន ហោតិ ។ យស្មឹ ភិក្ខវេ សមយេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា

ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈទាំងឡាយ ។ បេ ។ បានដល់នូវទុតិយជ្ឈាន ។ បេ ។ នូវតតិយជ្ឈាន ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ មិនមានដល់ភិក្ខុនោះក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ មិនមានដល់ភិក្ខុនោះក្នុងសម័យនោះ សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ មិនមានដល់ភិក្ខុនោះក្នុងសម័យនោះ សេចក្តីប្រទូស្តឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ មិនមានដល់ភិក្ខុនោះ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ

ឧបសម្បជ្ជ វិហរតិ យំ បិស្សុ បេមា បេមំ ជាយតិ តំ បិស្សុ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ យោ បិស្សុ បេមា ទោសោ ជាយតិ សោ បិស្សុ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ យំ បិស្សុ ទោសា បេមំ ជាយតិ តំ បិស្សុ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ យោ បិស្សុ ទោសា ទោសោ ជាយតិ សោ បិស្សុ បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន ឧស្សេនេតិ ន បដិស្សេនេតិ ន ធូបាយតិ ន បជ្ជលតិ ន បជ្ឈាយតិ ។

សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីស្រឡាញ់នោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀត ជាធម្មតា សេចក្តីប្រទូស្តឯណាកើតដល់ភិក្ខុនោះ ព្រោះសេចក្តីស្រឡាញ់ក្តី សេចក្តីប្រទូស្តនោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀតជាធម្មតា សេចក្តីស្រឡាញ់ឯណា កើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីស្រឡាញ់នោះ ភិក្ខុនោះក៏បានលះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើត ដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅទៀតជាធម្មតា សេចក្តីប្រទូស្តឯណាកើតដល់ភិក្ខុនោះ ព្រោះសេចក្តីប្រទូស្តក្តី សេចក្តីប្រទូស្តនោះ ភិក្ខុនោះក៏លះបង់ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសល់នៅតែទីកើតដូចជាទីកើតនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព លែងមានកំណើតតទៅជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មិនរលោរលាំ មិនតបត មិនរបិញរបុញ មិនធុរឆេះ មិនសុបសៅ ។

កថញ្ច ភិក្ខវេ ភិក្ខុ ឧស្សេនេតិ ។ ឥធ ភិក្ខវេ ភិក្ខុ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ សញ្ញំ អត្តតោ សមនុបស្សតិ សញ្ញាវន្តំ វា អត្តានំ អត្តនិ វា សញ្ញំ សញ្ញាយ វា អត្តានំ សង្ខារេ អត្តតោ សមនុបស្សតិ សង្ខារវន្តំ វា អត្តានំ អត្តនិ វា សង្ខារេ សង្ខារេសុ វា អត្តានំ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឧស្សេនេតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន ឧស្សេនេតិ ។ ឥធ ភិក្ខវេ ភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុរលោរលាំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ ពិចារណាឃើញនូវរូបថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថា មានវេទនាខ្លះ ពិចារណាឃើញនូវវេទនាថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវេទនាខ្លះ ពិចារណាឃើញនូវសញ្ញាថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានសញ្ញាខ្លះ ពិចារណាឃើញនូវសញ្ញាថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងសញ្ញាខ្លះ ពិចារណាឃើញនូវសង្ខារទាំងឡាយថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានសង្ខារខ្លះ ពិចារណាឃើញនូវសង្ខារថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងពួកសង្ខារខ្លះ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញនូវវិញ្ញាណថាតាំងនៅក្នុងខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរលោរលាំ ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរលោរលាំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ អត្តតោ សមនុបស្សតិ ន វេទនាវន្តំ វា អត្តានំ ន អត្តនិ វា វេទនំ ន វេទនាយ វា អត្តានំ ន សញ្ញំ អត្តតោ សមនុបស្សតិ ន សញ្ញាវន្តំ វា អត្តានំ ន អត្តនិ វា សញ្ញំ ន សញ្ញាយ វា អត្តានំ ន សង្ខារេ អត្តតោ សមនុបស្សតិ ន សង្ខារវន្តំ វា អត្តានំ ន អត្តនិ វា សង្ខារេ ន សង្ខារេសុ វា អត្តានំ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន ឧស្សេនេតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បដិស្សេនេតិ ។ ឥធ ភិក្ខវេ ភិក្ខុ

មិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញនូវរូបថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងរូបខ្លះ មិនពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានវេទនាខ្លះ មិនពិចារណាឃើញនូវវេទនាថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវេទនាខ្លះ មិនពិចារណាឃើញនូវសញ្ញាថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានសញ្ញាខ្លះ មិនពិចារណាឃើញនូវសញ្ញា ថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងសញ្ញាខ្លះ មិនពិចារណាឃើញនូវពួកសង្ខារថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួន ថាមានសង្ខារខ្លះ មិនពិចារណាឃើញនូវពួកសង្ខារថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងពួកសង្ខារខ្លះ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានវិញ្ញាណខ្លះ មិនពិចារណាឃើញនូវវិញ្ញាណថាតាំងនៅក្នុងខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាតាំងនៅក្នុងវិញ្ញាណខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរលោរលាំ ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុតបត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

១៩១



អក្កោសន្តំ បច្ចក្កោសតិ រោសន្តំ បដិរោសតិ ភណ្ឌន្តំ បដិភណ្ឌតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បដិសេ្សនេតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន បដិសេ្សនេតិ ។ ឥធ ភិក្ខវេ ភិក្ខុ អក្កោសន្តំ ន បច្ចក្កោសតិ រោសន្តំ ន បដិរោសតិ ភណ្ឌន្តំ ន បដិភណ្ឌតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន បដិសេ្សនេតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធូបាយតិ ។ អស្មីតិ ភិក្ខវេ សតិ ឥត្ថស្មីតិ ហោតិ ឯវស្មីតិ ហោតិ អញ្ញថាស្មីតិ ហោតិ អសស្មីតិ ហោតិ សតស្មីតិ ហោតិ សន្តិ ហោតិ ឥត្ថំ សន្តិ ហោតិ ឯវំ សន្តិ ហោតិ អញ្ញថា សន្តិ ហោតិ

ជេរតបចំពោះបុគ្គលដែលជេរ ខឹងតបចំពោះបុគ្គលដែលខឹង ឈ្លោះតប ចំពោះបុគ្គលដែលឈ្លោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកតបត ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនតបត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនជេរតប ចំពោះបុគ្គលដែលជេរ មិនខឹងតបចំពោះបុគ្គលដែលខឹង មិនឈ្លោះ តបចំពោះបុគ្គលដែលឈ្លោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនតបត ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរបិញរបុញ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្ដីប្រកាន់ថា អាត្មាអញមានដោយប្រការ ដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញមានដោយប្រការដទៃដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញទៀងដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា អាត្មាអញសូន្យដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា សូមឲ្យអាត្មាអញមានដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ថា សូម ឲ្យអាត្មាអញមាន ដោយប្រការនេះដូច្នេះ ក៏រមែងមាន សេចក្ដីប្រកាន់ ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្ដី ប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏រមែងមាន

អបិ សន្តិ ហោតិ អបិ ឥត្ថំ សន្តិ ហោតិ អបិ ឯវំ សន្តិ ហោតិ អបិ អញ្ញថា សន្តិ ហោតិ ភវិស្សន្តិ ហោតិ ឥត្ថំ ភវិស្សន្តិ ហោតិ ឯវំ ភវិស្សន្តិ ហោតិ អញ្ញថា ភវិស្សន្តិ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ធូបាយតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន ធូបាយតិ ។ អស្មីតិ ភិក្ខវេ អសតិ ឥត្ថស្មីតិ ន ហោតិ ឯវស្មីតិ ន ហោតិ អញ្ញថាស្មីតិ ន ហោតិ អសស្មីតិ ន ហោតិ សតស្មីតិ ន ហោតិ សន្តិ ន ហោតិ

សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្វះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះដូច្នេះខ្វះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះខ្វះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃខ្វះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃដូច្នេះ ក៏រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរបិញរបុញដោយប្រការយ៉ោងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរបិញរបុញតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានសេចក្តីប្រកាន់ថា អាត្មាអញមានដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមានដោយប្រការនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះដូច្នេះ ក៏មិនមាន

១៩៣



ឥត្ថំ សន្តិ ន ហោតិ ឯវំ សន្តិ ន ហោតិ អញ្ញថា សន្តិ ន ហោតិ អបិ សន្តិ ន ហោតិ អបិ ឥត្ថំ សន្តិ ន ហោតិ អបិ ឯវំ សន្តិ ន ហោតិ អបិ អញ្ញថា សន្តិ ន ហោតិ ភវិស្សន្តិ ន ហោតិ ឥត្ថំ ភវិស្សន្តិ ន ហោតិ ឯវំ ភវិស្សន្តិ ន ហោតិ អញ្ញថា ភវិស្សន្តិ ន ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន ឧច្ចាយតិ ។ កាថញ្ច ភិក្ខវេ ភិក្ខុ បជ្ជលតិ ។ ឥមិនា អស្មីតិ ភិក្ខវេ សតិ ឥមិនា ឥត្ថស្មីតិ ហោតិ ឥមិនា ឯវស្មីតិ ហោតិ

សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះដូច្នេះខ្លះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះខ្លះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃខ្លះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមានដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន យ៉ាងនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃដូច្នេះ ក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនរបិញរបុញដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធុរឆេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្តីប្រកាន់ថា អាត្មាអញមាន ដោយខន្ធនេះដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការនេះដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន

ឥមិនា អញ្ញថាស្មីតិ ហោតិ ឥមិនា អសស្មីតិ ហោតិ ឥមិនា សតស្មីតិ ហោតិ ឥមិនា សន្តិ ហោតិ ឥមិនា ឥត្ថំ សន្តិ ហោតិ ឥមិនា ឯវំ សន្តិ ហោតិ ឥមិនា អញ្ញថា សន្តិ ហោតិ ឥមិនា អបិ សន្តិ ហោតិ ឥមិនា អបិ ឥត្ថំ សន្តិ ហោតិ ឥមិនា អបិ ឯវំ សន្តិ ហោតិ ឥមិនា អបិ អញ្ញថា សន្តិ ហោតិ ឥមិនា ភវិស្សន្តិ ហោតិ ឥមិនា ឥត្ថំ ភវិស្សន្តិ ហោតិ

សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញទៀង ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយខន្ធនេះ ដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយ ប្រការនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃ ដោយខន្ធ នេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញ មាន ដោយប្រការនេះខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តី ប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការ ដទៃខ្លះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន

ឥមិនា ឯវំ ភវិស្សន្តិ ហោតិ ឥមិនា អញ្ញថា ភវិស្សន្តិ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បជ្ជលតិ ។ កាថញ្ច ភិក្ខវេ ភិក្ខុ ន បជ្ជលតិ ។ ឥមិនា អស្មីតិ ភិក្ខវេ អសតិ ឥមិនា ឥត្ថស្មីតិ ន ហោតិ ឥមិនា ឯវស្មីតិ ន ហោតិ ឥមិនា អញ្ញថាស្មីតិ ន ហោតិ ឥមិនា អសស្មីតិ ន ហោតិ ឥមិនា សតស្មីតិ ន ហោតិ ឥមិនា សន្តិ ន ហោតិ ឥមិនា ឥត្ថំ សន្តិ ន ហោតិ ឥមិនា ឯវំ សន្តិ ន ហោតិ ឥមិនា អញ្ញថា សន្តិ ន ហោតិ ឥមិនា អបិ សន្តិ ន ហោតិ

សេចក្តីប្រកាន់ថា អាត្មាអញនឹងមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុធុរឆេះ ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធុរឆេះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានសេចក្តីប្រកាន់ថា អាត្មាអញមាន ដោយខន្ធនេះដូច្នេះ សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញមាន ដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញទៀង ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញសូន្យ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានយ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមានខ្លះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន

ឥមិនា អបិ ឥត្ថំ សន្តិ ន ហោតិ ឥមិនា អបិ ឯវំ សន្តិ ន ហោតិ ឥមិនា អបិ អញ្ញថា សន្តិ ន ហោតិ ឥមិនា ភវិស្សន្តិ ន ហោតិ ឥមិនា ឥត្ថំ ភវិស្សន្តិ ន ហោតិ ឥមិនា ឯវំ ភវិស្សន្តិ ន ហោតិ ឥមិនា អញ្ញថា ភវិស្សន្តិ ន ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន បជ្ជលតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បជ្ឈាយតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ន ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បជ្ឈាយតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន បជ្ឈាយតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ អស្មិមានោ បហីនោ ហោតិ

សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការនេះខ្វះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន យ៉ាងនេះខ្វះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា សូមឲ្យអាត្មាអញមាន ដោយប្រការដទៃខ្វះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន យ៉ាងនេះ ដោយខន្ធនេះដូច្នេះ ក៏មិនមាន សេចក្តីប្រកាន់ថា អាត្មាអញនឹងមាន ដោយប្រការដទៃ ដោយខន្ធនេះដូច្នេះ ក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនធុរឆេះ ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសញ្ជប់សញ្ជឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ មិនបានលះបង់ ទាំងមិនបានផ្តាច់ផ្តិលឫសគល់ មិនធ្វើទីកើតដូចជាទីកើតនៃដើមត្នោត មិនធ្វើឲ្យលែងមានបែបភាពជាអស្មិមានះ មិនមែនជាមិនមានកំណើត តទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសញ្ជប់សញ្ជឹង ដោយប្រការយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនសញ្ជប់សញ្ជឹង តើដូចម្តេច ។

១៩៧



ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយ-
តឹអនុប្បាទធម្មោ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន
បជ្ឈាយតីតិ ។

មហាវគ្គោ បញ្ចមោ ។

ចតុត្ថោ បណ្ណាសកោ សមត្តោ ។

## តស្សុទ្ទានំ

សោតានុគតំ ឋានំ ភទ្ទិយ
សាបុគី ច វប្ប សាឡ្ហោ ច
មល្លិក អត្តន្តចោ
តណ្ហាបេមេន ច ទសា តេតិ ។

ម្នាលភិក្ខុទាំងឡាយ អស្មិមានះ ភិក្ខុក្នុងសាសនានេះ បានលះបង់ទាំងបានផ្តាច់ផ្តិលឫសគល់ ធ្វើទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើឲ្យលែងមានបែបភាពជាអស្មិមានះ មិនមានកំណើតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនសញ្ជប់សញ្ជឹង ដោយប្រការយ៉ាងនេះឯង ។

មហាវគ្គ ទី ៥ ។

ចប់ បណ្ណាសក ទី ៤ ។

# ឧទ្ទាននៃមហាវគ្គនោះគឺ

និយាយអំពីអានិសង្សនៃធម៌ដែលបានបញ្ជូនចិត្តស្តាប់ ១ អំពីហេតុ ៤ យ៉ាង ១ អំពីភទ្ទិយលិច្ឆវី ១ អំពីកោឡិយបុត្តក្នុងនិគមឈ្មោះសាបុគិយ ១ អំពីវប្បសក្យៈ ១ អំពីសាឡ្ហលិច្ឆវី ១ អំពីមល្លិកាទេវី ១ អំពីបុគ្គលអ្នកព្យាយាមដុតកម្តៅនូវខ្លួន ១ អំពីតណ្ហា ១ អំពីសេចក្តីស្រឡាញ់ ១ រួមជា ១០ ប្រការ ។

# បណ្ណាសកាសង្គហិតា វគ្គា

## សប្បុរិសវគ្គោ បឋមោ

[៨១] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុ-រិសេន សប្បុរិសតរញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ សុរាមេ-រយមជ្ជប្បមាទដ្ឋាយី ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។ កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ

# បណ្ណាសកាសង្គហិតវគ្គ

## សប្បុរិសវគ្គ ទី ១

[៥១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែង ជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែង ជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ និយាយពាក្យកុហក ផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែង ជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង

អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសាវាទេ សមាទបេតិ អត្តនា ច សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ បរញ្ច សុរាមេរយមជ្ជប្បមាទដ្ឋានេ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ

កាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យផង ប្រព្រឹត្តខុស ក្នុងកាមទាំង-ឡាយ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង និយាយកុហក ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយកុហកផង ផឹកទឹកស្រវឹងគឺ សុរានិងមេរ័យ ជាទីតាំងនៃសេចក្ដីប្រមាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្ដីប្រមាទផង ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា អសប្បុរសក្រៃលែង ជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយចុះសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្ដីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែង ជាងសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការសម្លាប់សត្វផង

អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ អត្តនា ច សុរាមេរយ-មជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ បរញ្ច សុរាមេរយ-មជ្ជប្បមាទដ្ឋានា វេរមណិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

[៤២] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុរិ-សេន សប្បុរិសតរញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសប្បុរិសោ ។

វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង វៀរចាកការនិយាយកុហក ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយកុហកផង វៀរចាកការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីប្រមាទផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែង ជាងសប្បុរស ។

[៩២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែង ជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែង ជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។ កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច អស្សទ្ធោ ហោតិ បរញ្ច អស្សទ្ធិយេ[១] សមាទបេតិ អត្តនា ច អហិរិកោ ហោតិ បរញ្ច អហិរិកតាយ សមាទបេតិ អត្តនា ច អនោត្តប្បី ហោតិ បរញ្ច អនោត្តប្បេ[២] សមាទបេតិ អត្តនា ច អប្បស្សុតោ ហោតិ បរញ្ច អប្បស្សុតេ សមាទបេតិ អត្តនា ច កុសីតោ ហោតិ បរញ្ច កោសជ្ជេ សមាទបេតិ អត្តនា ច មុដ្ឋស្សតិ ហោតិ បរញ្ច មុដ្ឋស្សច្ចេ សមាទបេតិ អត្តនា ច ទុប្បញ្ញោ ហោតិ បរញ្ច ទុប្បញ្ញតាយ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ

---
១ ឱ. អសទ្ធាយ ។ ២ ឱ. អនោត្តប្បិតាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា មិនខ្មាសបាប មិនក្តៅនឹងបាប ជាអ្នកមិនចេះដឹង ខ្ជិលច្រអូស មិនមានស្មារតី មិនមានប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាង អសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោក នេះ ជាអ្នកមិនមានសទ្ធា ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានសទ្ធាផង មិនខ្មាសបាប ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនខ្មាសបាបផង មិនក្តៅនឹងបាប ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនក្តៅនឹងបាបផង មិនបានចេះដឹង ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនចេះដឹងផង ខ្ជិលច្រអូសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការខ្ជិលច្រអូសផង មិនមានស្មារតី ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានស្មារតីផង មិនមានប្រាជ្ញា ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានប្រាជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ

សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវីរិយោ ហោតិ សតិមា ហោតិ បញ្ញវា ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ បរញ្ច សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច ហិរិមា ហោតិ បរញ្ច ហិរិមតាយ[១] សមាទបេតិ អត្តនា ច ឱត្តប្បី ហោតិ បរញ្ច ឱត្តប្បេ សមាទបេតិ អត្តនា ច ពហុស្សុតោ ហោតិ បរញ្ច ពាហុសច្ចេ សមាទបេតិ អត្តនា ច អារទ្ធវីរិយោ ហោតិ បរញ្ច វីរិយារម្ភេ សមាទបេតិ អត្តនា ច ឧបដ្ឋិតស្សតិ ហោតិ បរញ្ច សតិប្បដ្ឋានេ សមាទបេតិ អត្តនា ច បញ្ញាសម្បន្នោ ហោតិ បរញ្ច បញ្ញាសម្បទាយ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

---

១ ឱ. ហិរិមន្តេ ។ ម. ហិរិសម្បទាយ ។

ជាអ្នកមានសទ្ធា ខ្មាសបាប ខ្លាចនឹងបាប ចេះដឹងច្រើន ប្រារព្ធព្យាយាម មានស្មារតី មានប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការបរិបូណ៌ដោយសទ្ធាផង ខ្មាសបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការខ្មាសបាបផង ខ្លាចនឹងបាបដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការខ្លាចនឹងបាបផង ចេះដឹងច្រើនដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចេះដឹងច្រើនផង ប្រារព្ធព្យាយាមដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រារព្ធព្យាយាមផង មានស្មារតីដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមានស្មារតីផង បរិបូណ៌ដោយប្រាជ្ញាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការបរិបូណ៌ដោយប្រាជ្ញាផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

២០៣

បណ្ណាសកាសង្គហិតោ សប្បុរិសវគ្គោ បឋមោ

[៨៣] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុ-រិសេន សប្បុរិសតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។ កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសា-វាទេ សមាទបេតិ អត្តនា ច បិសុណាវាចោ ហោតិ

[៥៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យរោយរាយ ឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង កាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យផង ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង និយាយពាក្យកុហកដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យកុហកផង និយាយពាក្យញុះញង់ដោយខ្លួនឯងផង

បរេញ្ច បិសុណាយ វាចាយ សមាទបេតិ អត្តនា ច ផរុសវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមាទបេតិ អត្តនា ច សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ

ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យញុះញង់ផង និយាយពាក្យទ្រគោះដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យទ្រគោះផង និយាយពាក្យរោយរាយ ឥតប្រយោជន៍ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការនិយាយពាក្យរោយរាយ ឥតប្រយោជន៍ផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ វៀរចាកការនិយាយពាក្យកុហក វៀរចាកការនិយាយពាក្យញុះញង់ វៀរចាកការនិយាយពាក្យទ្រគោះ វៀរចាកការនិយាយពាក្យរោយរាយឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការសម្លាប់សត្វផង វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យដោយខ្លួនឯងផង ទាំងបបួលអ្នកដទៃ ក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង

អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

[៥៤] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុរិសេន សប្បុរិសតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ ។ បេ ។ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិកោ ហោតិ ។

វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយផង វៀរចាកការនិយាយពាក្យកុហកដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យកុហកផង វៀរចាកការនិយាយពាក្យញុះញង់ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យញុះញង់ផង វៀរចាកការនិយាយពាក្យទ្រគោះដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យទ្រគោះផង វៀរចាកការនិយាយពាក្យរោយរាយ ឥតប្រយោជន៍ដោយខ្លួនឯង ទាំងបបួលជនដទៃ ក្នុងការវៀរចាកការនិយាយពាក្យរោយរាយ ឥតប្រយោជន៍ផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

[៥៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ ច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ។

អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។ កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ ។ បេ ។ អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អត្តនា ច ព្យាបន្នចិត្តោ ហោតិ បរញ្ច ព្យាបាទេ សមាទបេតិ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ អនភិជ្ឈាលុ ហោតិ អព្យា-បន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ ។ បេ ។ អត្តនា ច អនភិជ្ឈាលុ ហោតិ បរញ្ច អនភិជ្ឈាយ សមាទបេតិ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង ។ បេ ។ ច្រើនដោយអភិជ្ឈា ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងអភិជ្ឈាផង មានចិត្តព្យាបាទ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាបាទផង ជាមិច្ឆាទិដ្ឋិ ដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងមិច្ឆាទិដ្ឋិផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។ បេ ។ មិនច្រើនដោយអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងកិរិយាវៀរចាកការសម្លាប់សត្វផង ។ បេ ។ មិនច្រើនដោយអភិជ្ឈាដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានអភិជ្ឈាផង

អត្តនា ច អព្យាបន្នចិត្តោ ហោតិ បរញ្ច អព្យាបាទេ សមាទបេតិ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

[៥៥] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុរិសេន សប្បុរិសតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ មិច្ឆាសង្កប្បោ ហោតិ មិច្ឆាវាចោ ហោតិ មិច្ឆាកម្មន្តោ ហោតិ មិច្ឆាអាជីវោ ហោតិ មិច្ឆាវាយាមោ ហោតិ មិច្ឆាសតិ ហោតិ មិច្ឆាសមាធិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។ កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ អត្តនា ច មិច្ឆាសង្កប្បោ ហោតិ បរញ្ច មិច្ឆាសង្កប្បេ សមាទបេតិ អត្តនា ច មិច្ឆាវាចោ ហោតិ

មិនមានចិត្តព្យាបាទដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការមិនមានព្យាបាទផង ជាសម្មាទិដ្ឋិដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសម្មាទិដ្ឋិផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

[៩៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះជាអ្នកមានសេចក្តីឃើញខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានការព្យាយាមខុស មានសេចក្តីរលឹកខុស មានការតាំងចិត្តខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះជាអ្នកមានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង មានសេចក្តីត្រិះរិះខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីត្រិះរិះខុសផង មានវាចាខុសដោយខ្លួនឯងផង

បរញ្ច មិច្ឆាវាចាយ សមាទបេតិ អត្តនា ច មិច្ឆាកម្មន្តោ ហោតិ បរញ្ច មិច្ឆាកម្មន្តេ សមាទបេតិ អត្តនា ច មិច្ឆាអាជីវោ ហោតិ បរញ្ច មិច្ឆាអាជីវេ សមាទបេតិ អត្តនា ច មិច្ឆាវាយាមោ ហោតិ បរញ្ច មិច្ឆាវាយាមេ សមាទបេតិ អត្តនា ច មិច្ឆាសតិ ហោតិ បរញ្ច មិច្ឆាសតិយា សមាទបេតិ អត្តនា ច មិច្ឆាសមាធិ ហោតិ បរញ្ច មិច្ឆាសមាធិម្ហិ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ ហោតិ សម្មាកម្មន្តោ ហោតិ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ

ទាំងបបួលជនដទៃ ក្នុងវាចាខុសផង មានការងារខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការងារខុសផង មានការចិញ្ចឹមជីវិតខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចិញ្ចឹមជីវិតខុសផង មានការព្យាយាមខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាយាមខុសផង មានសេចក្តីរលឹកខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីរលឹកខុសផង មានការតាំងចិត្តខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការតាំងចិត្តខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានការព្យាយាមត្រូវ មានសេចក្តីរលឹកត្រូវ មានការតាំងចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការឃើញត្រូវផង

អត្តនា ច សម្មាសង្កប្បោ ហោតិ បរញ្ច សម្មាសង្កប្បេ សមាទបេតិ អត្តនា ច សម្មាវាចោ ហោតិ បរញ្ច សម្មាវាចាយ សមាទបេតិ អត្តនា ច សម្មាកម្មន្តោ ហោតិ បរញ្ច សម្មាកម្មន្តេ សមាទបេតិ អត្តនា ច សម្មាអាជីវោ ហោតិ បរញ្ច សម្មាអាជីវេ សមាទបេតិ អត្តនា ច សម្មាវាយាមោ ហោតិ បរញ្ច សម្មាវាយាមេ សមាទបេតិ អត្តនា ច សម្មាសតិ ហោតិ បរញ្ច សម្មាសតិយា សមាទបេតិ អត្តនា ច សម្មាសមាធិ ហោតិ បរញ្ច សម្មាសមាធិម្ហិ សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

[៤៦] អសប្បុរិសញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសេន អសប្បុរិសតរញ្ច សប្បុរិសញ្ច សប្បុរិសេន សប្បុរិសតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ អសប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ ។ បេ ។ មិច្ឆាញាណី ហោតិ មិច្ឆាវិមុត្តិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសោ ។

មានសេចក្តីត្រិះរិះត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីត្រិះរិះត្រូវផង មានវាចាត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងវាចាត្រូវផង មានការងារត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការងារត្រូវផង មានការចិញ្ចឹមជីវិតត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការចិញ្ចឹមជីវិតត្រូវផង មានការព្យាយាមត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការព្យាយាមត្រូវផង មានសេចក្តីរលឹកត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីរលឹកត្រូវផង មានការតាំងចិត្តត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការតាំងចិត្តត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

[៥៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអសប្បុរសផង នូវអសប្បុរសក្រៃលែងជាងអសប្បុរសផង នូវសប្បុរសផង នូវសប្បុរសក្រៃលែងជាងសប្បុរសផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុស ។ បេ ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរស ។

កតមោ ច ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច មិច្ឆាញាណី ហោតិ បរញ្ច មិច្ឆា-ញាណេ សមាទបេតិ អត្តនា ច មិច្ឆាវិមុត្តិ ហោតិ បរញ្ច មិច្ឆាវិមុត្តិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ អសប្បុរិសេន អសប្បុរិសតរោ ។ កតមោ ច ភិក្ខវេ សប្បុរិសោ ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ ។ បេ ។ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសោ ។ កតមោ ច ភិក្ខវេ សប្បុរិសេន សប្បុរិសតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច សម្មាញាណី ហោតិ បរញ្ច សម្មាញាណេ សមាទបេតិ អត្តនា ច សម្មាវិមុត្តិ ហោតិ បរញ្ច សម្មាវិមុត្តិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ សប្បុរិសេន សប្បុរិសតរោតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរសក្រៃលែងជាងអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ បេ ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អសប្បុរសក្រៃលែងជាងអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវ ។ បេ ។ មានញាណត្រូវ មានការរួចត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសក្រៃលែងជាងសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ បេ ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណត្រូវផង ។ មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរសក្រៃលែងជាងសប្បុរស ។

២១១

បណ្ណាសកាសង្គហិតោ សប្បុរិសវគ្គោ បឋមោ

[៤៧] បាបញ្ច វោ ភិក្ខវេ ទេសេស្សាមិ បាបេន បាបតរញ្ច កល្យាណញ្ច កល្យាណេន កល្យាណតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ បាបោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ បាបោ ។ កតមោ ច ភិក្ខវេ បាបេន បាបតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ ។ បេ ។ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ បាបេន បាបតរោ ។ កតមោ ច ភិក្ខវេ កល្យាណោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណោ ។ កតមោ ច ភិក្ខវេ កល្យាណេន កល្យាណតរោ ។

[៥៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលលាមកផង នូវបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមកផង នូវបុគ្គលល្អផង នូវបុគ្គលល្អក្រៃលែងជាងបុគ្គលល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។ មានសេចក្តីឃើញខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការសម្លាប់សត្វផង ។ បេ ។ មានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។ បេ ។ មានសេចក្តីឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អក្រៃលែងជាងបុគ្គលល្អ តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ ។ បេ ។ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណេន កល្យាណតរោតិ ។

[៤៨] ចាបញ្ច វោ ភិក្ខវេ ទេសេស្សាមិ ចាបេន ចាបតរញ្ច កល្យាណញ្ច កល្យាណេន កល្យាណ-តរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ចាចោ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ ។ បេ ។ មិច្ឆាញាណី ហោតិ មិច្ឆាវិមុត្តិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចាចោ ។ កតមោ ច ភិក្ខវេ ចាបេន ចាបតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច មិច្ឆាញាណី ហោតិ បរញ្ច មិច្ឆាញាណេ សមាទបេតិ អត្តនា ច មិច្ឆាវិមុត្តិ ហោតិ បរញ្ច មិច្ឆាវិមុត្តិយា សមាទបេតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងកិរិយាវៀរចាកការសម្លាប់សត្វផង ។ បេ ។ មានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ។

[៩៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលលាមកផង នូវបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមកផង នូវបុគ្គលល្អផង នូវបុគ្គលល្អក្រៃលែងជាងបុគ្គលល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ មានសេចក្តីឃើញខុស ។ បេ ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ បេ ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ។

អយំ វុច្ចតិ ភិក្ខវេ ចាបេន ចាបតរោ ។ កតមោ ច ភិក្ខវេ កល្យាណោ ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ ។ បេ ។ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណោ ។ កតមោ ច ភិក្ខវេ កល្យាណេន កល្យាណតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច សមាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច សម្មាញាណី ហោតិ បរញ្ច សម្មាញាណេ សមាទបេតិ អត្តនា ច សម្មាវិមុត្តិ ហោតិ បរញ្ច សម្មាវិមុត្តិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណេន កល្យាណតរោតិ ។

[៤៩] ចាបធម្មញ្ច វោ ភិក្ខវេ ទេសេស្សាមិ ចាបធម្មេន ចាបធម្មតរញ្ច កល្យាណធម្មញ្ច កល្យា-ណធម្មេន កល្យាណធម្មតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ចាបធម្មោ ។ ឥធ ភិក្ខវេ ឯកច្ចោ ចាណាតិចាតី ហោតិ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវ ។ បេ ។ មានញាណត្រូវ មានការរួចត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្អក្រៃលែងជាងបុគ្គលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ បេ ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណត្រូវផង មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ។

[៥៩] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌ល្អផង នូវបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។

មិច្ឆាទិដ្ឋិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ បាបធម្មោ ។ កតមោ ច ភិក្ខវេ បាបធម្មេន បាបធម្មតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ ។ បេ ។ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ បាបធម្មេន បាបធម្មតរោ ។ កតមោ ច ភិក្ខវេ កល្យាណធម្មោ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណធម្មោ ។ កតមោ ច ភិក្ខវេ កល្យាណធម្មេន កល្យាណធម្មតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ ។ បេ ។ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណធម្មេន កល្យាណធម្មតរោតិ ។

មានសេចក្តីឃើញខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការសម្លាប់សត្វផង ។ បេ ។ មានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ មានសេចក្តីឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងកិរិយាវៀរចាកបាណាតិបាតផង ។ បេ ។ មានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ ។

[៦០] ចាបជម្មញ្ច វោ ភិក្ខវេ ទេសេស្សាមិ ចាបជម្មេន ចាបជម្មតរញ្ច កល្យាណជម្មញ្ច កល្យាណជម្មេន កល្យាណជម្មតរញ្ច តំ សុណាថ ។ បេ ។ កតមោ ច ភិក្ខវេ ចាបជម្មោ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ ។ បេ ។ មិច្ឆាញាណី ហោតិ មិច្ឆាវិមុត្តិ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចាបជម្មោ ។ កតមោ ច ភិក្ខវេ ចាបជម្មេន ចាបជម្មតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច មិច្ឆាញាណី ហោតិ បរញ្ច មិច្ឆាញាណេ សមាទបេតិ អត្តនា ច មិច្ឆាវិមុត្តិ ហោតិ បរញ្ច មិច្ឆាវិមុត្តិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ ចាបជម្មេន ចាបជម្មតរោ ។ កតមោ ច ភិក្ខវេ កល្យាណជម្មោ ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ ។ បេ ។ សម្មាញាណី ហោតិ សម្មាវិមុត្តិ ហោតិ ។

[៦០] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ផង នូវបុគ្គលមានធម៌ល្អផង នូវបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវពាក្យនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុស ។ បេ ។ មានញាណខុស មានការរួចខុស ។ ម្នាលភិក្ខុទាំងឡាយនេះហៅថា បុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញខុសផង ។ បេ ។ មានញាណខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងញាណខុសផង មានការរួចខុសដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងការរួចខុសផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកឃើញត្រូវ ។ បេ ។ មានញាណត្រូវ មានការរួចត្រូវ ។

អយំ វុច្ចតិ ភិក្ខវេ កល្យាណធម្មោ ។ កតមោ ច ភិក្ខវេ កល្យាណធម្មេន កល្យាណធម្មតរោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ ។ បេ ។ អត្តនា ច សម្មាញាណី ហោតិ បរញ្ច សម្មាញាណេ សមាទបេតិ អត្តនា ច សម្មាវិមុត្តិ ហោតិ បរញ្ច សម្មាវិមុត្តិយា សមាទបេតិ ។ អយំ វុច្ចតិ ភិក្ខវេ កល្យាណធម្មេន កល្យាណធម្មតរោតិ ។

សប្បុរិសវគ្គោ បឋមោ ។

## តស្សុទ្ទានំ

សិក្ខាបទញ្ច អស្សទ្ធំ
សត្តជាសោ អថោ ច ទសកម្មំ
អដ្ឋង្គិកញ្ច ទសមគ្គំ ទ្វេ
ចាបធម្មា អបរេ ទ្វេតិ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីឃើញត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃ ក្នុងសេចក្តីឃើញត្រូវផង ។ បេ ។ មានញាណត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងញាណត្រូវផង មានការរួចត្រូវដោយខ្លួនឯងផង ទាំងបបួលជនដទៃក្នុងការរួចត្រូវផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ ។

ចប់ សប្បុរិសវគ្គ ទី ១ ។

# ឧទ្ទាននៃសប្បុរិសវគ្គនោះគឺ

និយាយអំពីសិក្ខាបទ ១ អំពីបុគ្គលមិនមានសទ្ធា ១ អំពីធម៌ ៧ នាំឲ្យវិនាស ១ មួយយ៉ាងទៀត និយាយអំពីកម្មទាំង ១០ ប្រការ ១ អំពីមគ្គប្រកបដោយអង្គ ៨ ប្រការ ១ អំពីមគ្គ ១០ ប្រការ ១ អំពីបាបធម៌ ២ ប្រការ ១ អំពីបាបធម៌ ២ ប្រការដទៃទៀត ១ ។

## សោភនវគ្គោ ទុតិយោ

[៦១] ចត្តារោមេ ភិក្ខវេ បរិសទូសនា ។ កតមេ ចត្តារោ ។ ភិក្ខុ ភិក្ខវេ[១] ទុស្សីលោ ចាបធម្មោ បរិសទូសនោ ភិក្ខុនី ភិក្ខវេ ទុស្សីលា ចាបធម្មា បរិសទូសនា ឧបាសកោ ភិក្ខវេ ទុស្សីលោ ចាប-ធម្មោ បរិសទូសនោ ឧបាសិកា ភិក្ខវេ ទុស្សីលា ចាបធម្មា បរិសទូសនា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បរិសទូសនា ។ ចត្តារោមេ ភិក្ខវេ បរិសសោភនា ។ កតមេ ចត្តារោ ។ ភិក្ខុ ភិក្ខវេ[១] សីលវា កល្យា-ណធម្មោ បរិសសោភនោ ភិក្ខុនី ភិក្ខវេ សីលវតី កល្យាណធម្មា បរិសសោភនា ឧបាសកោ ភិក្ខវេ សីលវា កល្យាណធម្មោ បរិសសោភនោ ឧបាសិកា ភិក្ខវេ សីលវតី កល្យាណធម្មា បរិសសោភនា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ បរិសោភនាតិ ។

---

១ ឱ. ម. ឥធ ភិក្ខវេ ភិក្ខូតិ ទិស្សតិ ។

# សោភនវគ្គ ទី ២

[៦១] ម្នាលភិក្ខុទាំងឡាយ ការទ្រុស្តបរិសទ្យនេះ មាន ៤ យ៉ាង ។ ការទ្រុស្តបរិសទ្យ ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីទ្រុស្តសីល មានធម៌លាមក ឈ្មោះថា ទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសកទ្រុស្តសីល មានធម៌លាមក ឈ្មោះថាទ្រុស្តបរិសទ្យ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទ្រុស្តសីល មានធម៌លាមកឈ្មោះថា ទ្រុស្តបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ការទ្រុស្តបរិសទ្យ មាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើបរិសទ្យឲ្យល្អមាន ៤ យ៉ាង ។ ការធ្វើបរិសទ្យឲ្យល្អមាន ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីល មានធម៌ល្អ ឈ្មោះថាធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមានសីល មានធម៌ល្អឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសកមានសីលមានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាមានសីល មានធម៌ល្អ ឈ្មោះថា ធ្វើបរិសទ្យឲ្យល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើបរិសទ្យឲ្យល្អមាន ៤ យ៉ាងនេះឯង ។

[៦២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន មិច្ឆាទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន សម្មាទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៦៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន អកតញ្ញុតា អកតវេទិតា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

[៦២] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ មិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ សម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[៦៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ អកតញ្ញូអកតវេទិតា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន កតញ្ញុតា កតវេទិតា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៦៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ ។ បេ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ ។ បេ ។

[៦៥] មិច្ឆាទិដ្ឋិកោ ហោតិ មិច្ឆាសង្កប្បោ ហោតិ មិច្ឆាវាចោ ហោតិ មិច្ឆាកម្មន្តោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មា-វាចោ ហោតិ សម្មាកម្មន្តោ ហោតិ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ កតញ្ញូកតវេទិតា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[៦៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ គឺបុគ្គលជាអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយពាក្យកុហក ១ ។ បេ ។ គឺបុគ្គលជាអ្នកវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយពាក្យកុហក ១ ។ បេ ។

[៦៥] បុគ្គលមានសេចក្តីឃើញខុស ១ មានសេចក្តីត្រិះរិះខុស ១ មានវាចាខុស ១ មានការងារខុស ១ ។ បេ ។ បុគ្គលមានសេចក្តីឃើញត្រូវ ១ មានសេចក្តីត្រិះរិះត្រូវ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ ។ បេ ។

[៦៦] មិច្ឆាអាជីវោ ហោតិ មិច្ឆាវាយាមោ ហោតិ មិច្ឆាសតិ ហោតិ មិច្ឆាសមាធិ ហោតិ ។ បេ ។ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ ។ បេ ។

[៦៧] អទិដ្ឋេ ទិដ្ឋវាទី ហោតិ អស្សុតេ សុតវាទី ហោតិ អមុតេ មុតវាទី ហោតិ អវិញ្ញាតេ វិញ្ញាតវាទី ហោតិ ។ បេ ។ អទិដ្ឋេ អទិដ្ឋវាទី ហោតិ អស្សុតេ អស្សុតវាទី ហោតិ អមុតេ អមុតវាទី ហោតិ អវិញ្ញាតេ អវិញ្ញាតវាទី ហោតិ ។ បេ ។

[៦៨] ទិដ្ឋេ អទិដ្ឋវាទី ហោតិ សុតេ អស្សុតវាទី ហោតិ មុតេ អមុតវាទី ហោតិ វិញ្ញាតេ អវិញ្ញាតវាទី ហោតិ ។ បេ ។

[៦៦] បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតខុស ១ មានសេចក្តីព្យាយាមខុស ១ មានសេចក្តីរលឹកខុស ១ មានសេចក្តីតាំងចិត្តខុស ១ ។ បេ ។ បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតត្រូវ ១ មានសេចក្តីព្យាយាមត្រូវ ១ មានសេចក្តីរលឹកត្រូវ ១ មានសេចក្តីតាំងចិត្តត្រូវ ១ ។ បេ ។

[៦៧] បុគ្គលអ្នកពោលថាឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថាឮក្នុងរបស់ដែលមិនបានឮ ១ ពោលថាហិតជញ្ចក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហិតជញ្ចក់ប៉ះពាល់ ១ ពោលថាដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។ បេ ។ បុគ្គលអ្នកពោលថាមិនឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថាមិនឮក្នុងរបស់ដែលមិនបានឮ ១ ពោលថាមិនបានហិតជញ្ចក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហឹតជញ្ចក់ប៉ះពាល់ ១ ពោលថាមិនដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។ បេ ។

[៦៨] បុគ្គលអ្នកពោលថា មិនឃើញក្នុងរបស់ ដែលបានឃើញ ១ ពោលថាមិនឮក្នុងរបស់ដែលបានឮ ១ ពោលថាមិនបានហិតជញ្ចក់ប៉ះពាល់ក្នុងរបស់ដែលបានហិតជញ្ចក់ប៉ះពាល់ ១ ពោលថាមិនដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។ បេ ។

ទិដ្ឋេ ទិដ្ឋវាទី ហោតិ សុតេ សុតវាទី ហោតិ មុតេ មុតវាទី ហោតិ វិញ្ញាតេ វិញ្ញាតវាទី ហោតិ ។បេ។ [៦៩] អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ ។ បេ ។ សទ្ធោ ហោតិ សីលវា ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ។ បេ ។

[៧០] អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ បេ ។ សទ្ធោ ហោតិ សីលវា ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

សោភនវគ្គោ ទុតិយោ ។

បុគ្គលអ្នកពោលថា ឃើញក្នុងរបស់ដែលបានឃើញ ១ ពោលថាឮក្នុងរបស់ដែលបានឮ ១ ពោលថា ហិតជញ្ជក់ប៉ះពាល់ ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា ដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។ បេ ។

[៦៩] បុគ្គលជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ មិនខ្មាសបាប ១ មិនក្តៅនឹងបាប ១ ។ បេ ។ បុគ្គលជាអ្នកមានសទ្ធា ១ មានសីល ១ ខ្មាសបាប ១ ក្តៅនឹងបាប ១ ។ បេ ។

[៧០] បុគ្គលជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ ខ្ជិលច្រអូស ១ គ្មានបញ្ញា ១ ។ បេ ។ បុគ្គលជាអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

ចប់ សោភនវគ្គ ទី ២ ។

# តស្សុទ្ទានំ

បរិសា  ទិដ្ឋិ  អកតញ្ញុតា
ចាណាតិបាតាបិ  ទ្វេ  មគ្គា
ទ្វេ  វោហារបថា  វុត្តា
ហិរិកំ  ទុប្បញ្ញេន  ចាតិ ។

---

សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# ឧទ្ទាននៃសោភនវគ្គនោះគឺ

និយាយអំពីការទ្រុស្តបរិសទ្យនិងការធ្វើបរិសទ្យឲ្យល្អ ១ អំពីជនអ្នកប្រកបដោយធម៌ មានមិច្ឆាទិដ្ឋិជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ មានអកតញ្ញុតាជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ មានបាណាតិបាតជាដើម ១ អំពីជនអ្នកប្រកបដោយធម៌ ជាផ្លូវពីរប្រការ ១ អំពីគន្លងនៃវោហារពីរយ៉ាងដែលបុគ្គលពោលហើយ ១ អំពីជនអ្នកប្រកបដោយធម៌មានហិរិជាដើម ១ អំពីជនអ្នកប្រកបដោយធម៌មានការមិនមានបញ្ញាជាដើម ១ ។

---

# ទុច្ចរិតវគ្គោ តតិយោ

[៧១] ចត្តារីមានិ ភិក្ខវេ វចីទុច្ចរិតានិ ។ កាតមានិ ចត្តារិ ។ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ វចីទុច្ចរិតានិ ។ ចត្តារីមានិ ភិក្ខវេ វចីសុច-រិតានិ ។ កាតមានិ ចត្តារិ ។ សច្ចវាចា អបិសុណា វាចា សណ្ហា វាចា មន្តាភាសា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ វចីសុចរិតានីតិ ។

[៧២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កាតមេហិ ចតូហិ ។ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន មិច្ឆាទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ

# ទុច្ចរិតវគ្គ ទី ៣

[៧១] ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតនេះមាន ៤ យ៉ាង ។ វចីទុច្ចរិត ៤ យ៉ាង តើដូចម្តេច ។ គឺការនិយាយកុហក ១ និយាយញុះញង់ ១ និយាយពាក្យទ្រគោះ ១ និយាយពាក្យរោយរាយឥតប្រយោជន៍ ១ ។ ម្នាលភិក្ខុទាំងឡាយ វចីទុច្ចរិតមាន ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិតនេះមាន ៤ យ៉ាង ។ វចីសុចរិត ៤ យ៉ាង តើដូចម្តេច ។ គឺនិយាយពាក្យពិត ១ មិននិយាយពាក្យញុះញង់ ១ និយាយពាក្យពីរោះ ១ និយាយដោយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ វចីសុចរិតមាន ៤ យ៉ាងនេះឯង ។

[៧២] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ មិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួន ឲ្យមានគុណជីកចោល កម្ចាត់ចោលផង

សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ ចតូហិ ។ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន សម្មាទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

[៧៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ ចតូហិ ។ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោ-ទុច្ចរិតេន អកតញ្ញុតា អកតវេទិតា ។ បេ ។

ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួន មិនឲ្យមានគុណជីកចោល កម្ចាត់ចោលផង មិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ សម្មាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួន មិនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកមិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។

[៧៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា ពាល មិនឈ្លាស ជាអសប្បុរស រមែងរក្សានូវខ្លួនឲ្យមានគុណជីកចោល កម្ចាត់ចោលផង ជាអ្នកប្រកបដោយទោសផង ត្រូវពួកវិញ្ញូជនតិះដៀលផង បានបាបច្រើនផង ។ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច ។ (គឺប្រកប) ដោយកាយ-ទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ អកតញ្ញូអកតវេទិតា ១ ។ បេ ។

កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន កតញ្ញុតា កតវេទិតា ។ បេ ។

[៧៤] បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ ។ បេ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ ។ បេ ។

[៧៥] មិច្ឆាទិដ្ឋិកោ ហោតិ មិច្ឆាសង្កប្បោ ហោតិ មិច្ឆាវាចោ ហោតិ មិច្ឆាកម្មន្តោ ហោតិ ។ បេ ។ សម្មាទិដ្ឋិកោ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាចោ ហោតិ សម្មាកម្មន្តោ ហោតិ ។ បេ ។

[៧៦] មិច្ឆាអាជីវោ ហោតិ មិច្ឆាវាយាមោ ហោតិ មិច្ឆាសតិ ហោតិ មិច្ឆាសមាធិ ហោតិ ។ បេ ។ សម្មាអាជីវោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ ។ បេ ។

(ប្រកប) ដោយកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ កតញ្ញូ-កតវេទិតា ១ ។ បេ ។

[៧៤] បុគ្គលជាអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ និយាយពាក្យកុហក ១ ។ បេ ។ បុគ្គលជាអ្នកវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ ។ បេ ។

[៧៥] បុគ្គលជាអ្នកមានសេចក្តីឃើញខុស ១ មានសេចក្តីត្រិះរិះខុស ១ មានវាចាខុស ១ មានការងារខុស ១ ។ បេ ។ បុគ្គលជាអ្នកមានសេចក្តីឃើញត្រូវ ១ មានសេចក្តីត្រិះរិះត្រូវ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ ។ បេ ។

[៧៦] បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតខុស ១ មានការព្យាយាមខុស ១ មានការរលឹកខុស ១ មានការតាំងចិត្តខុស ១ ។ បេ ។ បុគ្គលជាអ្នកមានការចិញ្ចឹមជីវិតត្រូវ ១ មានការព្យាយាមត្រូវ ១ មានការរលឹកត្រូវ ១ មានការតាំងចិត្តត្រូវ ១ ។ បេ ។

[៧៧] អទិដ្ឋេ ទិដ្ឋវាទី ហោតិ អស្សុតេ សុតវាទី ហោតិ អមុតេ មុតវាទី ហោតិ អវិញ្ញាតេ វិញ្ញាតវាទី ហោតិ ។ បេ ។ អទិដ្ឋេ អទិដ្ឋវាទី ហោតិ អស្សុតេ អស្សុតវាទី ហោតិ អមុតេ អមុតវាទី ហោតិ អវិញ្ញាតេ អវិញ្ញាតវាទី ហោតិ ។ បេ ។

[៧៨] ទិដ្ឋេ អទិដ្ឋវាទី ហោតិ សុតេ អស្សុតវាទី ហោតិ មុតេ អមុតវាទី ហោតិ វិញ្ញាតេ អវិញ្ញាតវាទី ហោតិ ។ បេ ។ ទិដ្ឋេ ទិដ្ឋវាទី ហោតិ សុតេ សុតវាទី ហោតិ មុតេ មុតវាទី ហោតិ វិញ្ញាតេ វិញ្ញាតវាទី ហោតិ ។ បេ ។

[៧៧] បុគ្គលអ្នកពោលថាឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថាឮក្នុងរបស់ដែលមិនបានឮ ១ ពោលថាហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថាដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។ បេ ។ បុគ្គលអ្នកពោលថា មិនឃើញក្នុងរបស់ដែលមិនបានឃើញ ១ ពោលថាមិនឮក្នុងរបស់ដែលមិនបានឮ ១ ពោលថាមិនបានហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលមិនបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថាមិនដឹងច្បាស់ក្នុងរបស់ដែលមិនបានដឹងច្បាស់ ១ ។ បេ ។

[៧៨] បុគ្គលអ្នកពោលថាមិនឃើញក្នុងរបស់ដែលមិនឃើញ ១ ពោលថាមិនឮក្នុងរបស់ដែលបានឮ ១ ពោលថា មិនហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថា មិនដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។ បេ ។ បុគ្គលអ្នកពោលថាឃើញក្នុងរបស់ដែលបានឃើញ ១ ពោលថា ឮក្នុងរបស់ដែលបានឮ ១ ពោលថាហិតជញ្ជក់ប៉ះពាល់ក្នុងរបស់ដែលបានហិតជញ្ជក់ប៉ះពាល់ ១ ពោលថាដឹងច្បាស់ក្នុងរបស់ដែលបានដឹងច្បាស់ ១ ។ បេ ។

## ២២៧



[៧៩] អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ ។ បេ ។ សទ្ធោ ហោតិ សីលវា ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ។ បេ ។

[៨០] អស្សទ្ធោ ហោតិ ទុស្សីលោ ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ ។ បេ ។ សទ្ធោ ហោតិ សីលវា ហោតិ អារទ្ធវីរិយោ ហោតិ បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

[៨១] ចត្តារោមេ ភិក្ខវេ ការី ។ កាតមេ ចត្តារោ ។ ចិន្តាការី សុតការី អត្ថការី បដិភាណការី ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ការីតិ ។

ទុច្ចរិតវគ្គោ តតិយោ ។

បណ្ណាសកាសង្គហិត ទុច្ចរិតវគ្គ ទី ៣

[៧៩] បុគ្គលអ្នកមិនមានសទ្ធា ១ អ្នកទ្រុស្តសីល ១ មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីក្តៅនឹងបាប ១ ។ បេ ។ បុគ្គលជាអ្នកមានសទ្ធា ១ ជាអ្នកមានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីក្តៅនឹងបាប ១ ។ បេ ។

[៨០] បុគ្គលអ្នកមិនមានសទ្ធា ១ អ្នកទ្រុស្តសីល ១ មានសេចក្តីខ្ជិលច្រអូស ១ មិនមានបញ្ញា ១ ។ បេ ។ បុគ្គលអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ឈ្មោះថា បណ្ឌិត ឈ្លាស ជាសប្បុរស រមែងរក្សានូវខ្លួនមិនឲ្យមានគុណជីកចោលកម្ចាត់ចោលផង ជាអ្នកមិនមានទោសផង មិនត្រូវពួកវិញ្ញូជនតិះដៀលផង បានបុណ្យច្រើនផង ។

[៨១] ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញនេះមាន ៤ ពួក ។ អ្នកប្រាជ្ញ ៤ ពួក តើដូចម្តេច ។ គឺអ្នកប្រាជ្ញព្រោះគិត ១ អ្នកប្រាជ្ញព្រោះស្តាប់ ១ អ្នកប្រាជ្ញព្រោះអាស្រ័យសេចក្តី ១ អ្នកប្រាជ្ញព្រោះប្រាជ្ញាវាងវៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកប្រាជ្ញមាន ៤ ពួកនេះឯង ។

ចប់ ទុច្ចរិតវគ្គ ទី ៣ ។

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ចតុក្កនិបាតោ

# តស្សុទ្ទានំ

ទុច្ចរិតំ ទិដ្ឋិ អកតញ្ញូ ច

ចាណាតិចាតា បិ ទ្វេ មគ្គា

ទ្វេ វោហារ បថា វុត្តា

អហិរិកំ ទុប្បញ្ញ កវី ជា ចាតិ ។

# ឧទ្ទាននៃទុច្ចរិតវគ្គនោះគឺ

*និយាយអំពីទុច្ចរិត ១ អំពីមិច្ឆាទិដ្ឋិ ១ អំពីបុគ្គលប្រកបដោយធម៌មានអកតញ្ញុតាជាដើម ១ អំពីបុគ្គលប្រកបដោយធម៌មានបាណាតិបាតជាដើម ១ អំពីផ្លូវពីរប្រការ ១ អំពីគន្លងពាក្យពោលពីរប្រការដែលពោល ១ អំពីបុគ្គលប្រកបដោយធម៌មានសេចក្ដីខ្មាសបាបជាដើម ១ អំពីបុគ្គលប្រកបដោយធម៌មានមិនមានប្រាជ្ញាជាដើម ១ អំពីអ្នកប្រាជ្ញ ៤ ពួក ១ ។*

# កម្មវគ្គោ ចតុត្ថោ

[៨២] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កាតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៣] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កាតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ

# កម្មវគ្គ ទី ៩

[៨២] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបាន ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាស ប្រាប់ ។ កម្ម ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្ម ខ្មៅ[១] មានវិបាកខ្មៅ[២] ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស[៣] មាន វិបាកស[៤] ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស[៥] មាន វិបាកទាំងខ្មៅទាំងស[៦] ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅ មិនស[៧] មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ ប្រភេទនេះ តថាគតបានធ្វើឲ្យជាក់ ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៣] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យ ជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន

---

១ បានដល់អកុសលកម្មបថ ១០ ។ ២ នាំសត្វឲ្យទៅកើតក្នុងអបាយ ។ ៣ បានដល់កុសលកម្មបថ ១០ ។ ៤ នាំសត្វឲ្យទៅកើតក្នុងឋានសួគ៌ ។ ៥ កម្មដែលលាយគ្នា ។ ៦ ឲ្យទទួលទុក្ខខ្លះ ទទួលសុខខ្លះ ។ ៧ សំដៅយកចតុមគ្គញ្ញាណដែលជាគុណជាតធ្វើឲ្យអស់កម្ម ។

ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ សោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ លោកំ ឧបបជ្ជតិ ។ តមេនំ សព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈា ផស្សា ផុសន្តិ ។ សោ សព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈំ វេទនំ វេទិយតិ ឯកន្តទុក្ខំ សេយ្យថាបិ សត្តា នេរយិកា ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ

ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះតាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារ ប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោស លុះបុគ្គលនោះតាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារ ប្រកបដោយទោស តាក់តែងមនោសង្ខារ ប្រកបដោយទោសហើយ រមែងចូលទៅកាន់លោកដែលប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយ ប្រកបដោយទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកប្រកបដោយទុក្ខ ។ បុគ្គលនោះកាលផស្សៈទាំងឡាយប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងរងវេទនាប្រកបដោយទុក្ខ មានសេចក្តីលំបាកដោយពិតដូចពួកសត្វដែលកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

២៣១



អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ ។ សោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ លោកំ ឧបបជ្ជតិ ។ តមេនំ អព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ អព្យាបជ្ឈា ផស្សា ផុសន្តិ ។ សោ អព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ អព្យាបជ្ឈំ វេទនំ វេទិយតិ ឯកន្តសុខំ សេយ្យថាបិ ទេវា សុភកិណ្ហា ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំបិ អព្យា-បជ្ឈំបិ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ មនោសង្ខារំ អភិសង្ខរោតិ ។ សោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរិត្វា

គាត់តែងកាយសង្ខារ មិនមានទោស គាត់តែងវចីសង្ខារ មិនមានទោស គាត់តែងមនោសង្ខារ មិនមានទោស ។ លុះបុគ្គលនោះ គាត់តែងកាយសង្ខារ មិនមានទោស គាត់តែងវចីសង្ខារ មិនមានទោស គាត់តែងមនោសង្ខារ មិនមានទោស រមែងចូលទៅកាន់លោកដែលមិនមានទុក្ខ ។ ផស្សៈទាំងឡាយ ដែលមិនមានទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកមិនមានទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ មិនមានទុក្ខពាល់ត្រូវហើយ រមែងរងនូវវេទនាមិនមានទុក្ខ មានតែសេចក្តីសុខដោយពិត ដូចពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ គាត់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ គាត់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ គាត់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ។ លុះបុគ្គលនោះគាត់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ

សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ លោកំ ឧបបជ្ជតិ ។ តមេនំ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈាបិ អព្យាបជ្ឈាបិ ផស្សា ផុសន្តិ ។ សោ សព្យាបជ្ឈេហិបិ អព្យាបជ្ឈេហិបិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ វេទនំ វេទិយតិ វោកិណ្ណសុខទុក្ខំ[១] សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហ-អសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ តត្រ ភិក្ខវេ យម្បិទំ កម្មំ កណ្ហំ កណ្ហវិបាកំ តស្ស បហានាយ យា ចេតនា យម្បិទំ កម្មំ សុក្កំ សុក្កវិបាកំ តស្ស បហានាយ យា ចេតនា យម្បិទំ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ តស្ស បហានាយ យា ចេតនា

---

១ ឱ. វោកិណ្ណំ សង្កិណ្ណំ សុខទុក្ខំ ។

តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ រមែងចូលទៅកាន់លោក មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ ផស្សៈទាំងឡាយ មានទុក្ខខ្លះ មិនមានទុក្ខខ្លះ តែង ពាល់ត្រូវនូវបុគ្គលដែលចូលទៅកាន់លោក មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ពាល់ត្រូវហើយ រមែងរងនូវវេទនា មានទុក្ខខ្លះ មិនមានទុក្ខខ្លះ ជាវេទនា មានសុខនិងទុក្ខលាយគ្នា ដូចមនុស្សពួកខ្លះ ទេវតាពួកខ្លះ វិនិបាតពួកខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំង ៤ នោះ ចេតនាដើម្បីលះកម្មខ្មៅ មានវិបាកខ្មៅឯណា ចេតនាដើម្បីលះកម្មស មានវិបាកសឯណា ចេតនាដើម្បីលះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅទាំងស ឯណា

ឥទំ វុច្ចតិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៤] អថខោ សិខាមោគ្គល្លានោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សិខាមោគ្គល្លានោ ព្រាហ្មណោ ភគវន្តំ ឯតទវោច បុរិមានិ ភោ គោតម ទិវសានិ បុរិមតរានិ សោណកាយនោ មាណវោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ ឯតទវោច សមណោ គោតមោ សព្វកម្មានំ អកិរិយំ បញ្ញាបេតិ សព្វកម្មានំ ខោ បន អកិរិយំ បញ្ញាបេន្តោ ឧច្ឆេទំ អាហ លោកស្ស កម្មសច្ចាយំ ភោ លោកោ កម្មសមារម្ភដ្ឋាយីតិ ។ ទស្សនំបិ ខោ អហំ ព្រាហ្មណ សោណកាយនស្ស មាណវស្ស នាភិជានាមិ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨២] គ្រានោះ ព្រាហ្មណ៍ឈ្មោះសិខាមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសិខាមោគ្គល្លានព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន កាលពីថ្ងៃមុនៗ យូរមកហើយ មាណពឈ្មោះសោណកាយនៈចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ក៏និយាយនឹងខ្ញុំព្រះអង្គដូច្នេះថា ព្រះសមណគោតម បញ្ញត្តនូវការមិនធ្វើនូវកម្មទាំងពួង កាលព្រះអង្គបញ្ញត្តនូវការមិនធ្វើនូវកម្មទាំងពួង ឈ្មោះថាពោលឧច្ឆេទ (សេចក្តីដាច់សូន្យ) នៃលោក បពិត្រព្រះអង្គដ៏ចម្រើន លោកនេះជាកម្មសច្ចៈ (មានកម្មជាសភាវៈ) ជាកម្មសមារម្ភដ្ឋាយី (តាំងនៅដោយការធ្វើកម្ម) ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតមិនដែលបានឃើញសោណកាយនមាណពសោះ

កុតោ បនេវរូបោ កថាសល្លាបោ ។ ចត្តារីមានិ ព្រាហ្មណ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។ អត្ថិ ព្រាហ្មណ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ព្រាហ្មណ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ព្រាហ្មណ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ព្រាហ្មណ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ព្រាហ្មណ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ព្រាហ្មណ ឯកច្ចោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ សោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ លោកំ ឧបបជ្ជតិ ។ តមេនំ សព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈា ផស្សា ផុសន្តិ ។

ការចរចាពាក្យ មានសភាពយ៉ាងនោះ នឹងមានមកពីណា ។ ម្នាល ព្រាហ្មណ៍ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលព្រាហ្មណ៍ កម្មខ្មៅមានវិបាកខ្មៅ ក៏មាន ម្នាលព្រាហ្មណ៍ កម្មស មានវិបាកស ក៏មាន ម្នាលព្រាហ្មណ៍ កម្ម ទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ក៏មាន ម្នាលព្រាហ្មណ៍ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលព្រាហ្មណ៍ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារប្រកបដោយទោស តាក់តែង មនោសង្ខារប្រកបដោយទោស លុះបុគ្គលនោះ តាក់តែងកាយសង្ខារ ប្រកបដោយទោស តាក់តែងវចីសង្ខារប្រកបដោយទោស តាក់ តែងមនោសង្ខារប្រកបដោយទោសហើយ រមែងចូលទៅកាន់លោក ប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយប្រកបដោយទុក្ខ រមែង ពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកប្រកបដោយទុក្ខ ។

សោ សព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈំ វេទនំ វេទិយតិ ឯកន្តទុក្ខំ សេយ្យថាបិ សត្តា នេរយិកា ។ ឥទំ វុច្ចតិ ព្រាហ្មណ កម្មំ កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច ព្រាហ្មណ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ព្រាហ្មណ ឯកច្ចោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ សោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា អព្យា-បជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ លោកំ ឧបបជ្ជតិ ។ តមេនំ អព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ អព្យា-បជ្ឈា ផស្សា ផុសន្តិ ។ សោ អព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ អព្យាបជ្ឈំ វេទនា វេទិ-យតិ ឯកន្តសុខំ សេយ្យថាបិ ទេវា សុភកិណ្ហា ។ ឥទំ វុច្ចតិ ព្រាហ្មណ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ព្រាហ្មណ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ព្រាហ្មណ ឯកច្ចោ

បុគ្គលនោះ កាលផស្សៈទាំងឡាយ ពាល់ត្រូវហើយ រមែងរងនូវវេទនាប្រកបដោយទុក្ខ មានសេចក្ដីលំបាកដោយពិត ដូចពួកសត្វដែលកើតក្នុងនរក ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលព្រាហ្មណ៍ ចុះកម្មស មានវិបាកស តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារមិនមានទោស តាក់តែងវចីសង្ខារមិនមានទោស តាក់តែងមនោសង្ខារមិនមានទោស លុះបុគ្គលនោះ តាក់តែងកាយសង្ខារមិនមានទោស តាក់តែងវចីសង្ខារមិនមានទោស តាក់តែងមនោសង្ខារមិនមានទោសហើយ រមែងចូលទៅកាន់លោកដែលមិនប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយដែលមិនប្រកបដោយទុក្ខ រមែងពាល់ត្រូវនូវបុគ្គលនោះ ដែលចូលទៅកាន់លោកដែលមិនប្រកបដោយទុក្ខ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ មិនប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងទទួលនូវវេទនាមិនប្រកបដោយទុក្ខ មានតែសេចក្ដីសុខដោយពិត ដូចពួកទេវតាជាន់សុភកិណ្ហៈ ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មស មានវិបាកស ។ ម្នាលព្រាហ្មណ៍ ចុះកម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ

សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ មនោសង្ខារំ អភិសង្ខរោតិ សោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ លោកំ ឧបបជ្ជតិ ។ តមេនំ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈាបិ អព្យា-បជ្ឈាបិ ផស្សា ផុសន្តិ ។ សោ សព្យាបជ្ឈេហិបិ អព្យាបជ្ឈេហិបិ ផស្សេហិ ផុដ្ឋោ សមានោ សព្យា-បជ្ឈំបិ អព្យាបជ្ឈំបិ វេទនំ វេទិយតិ វោកិណ្ណសុខ-ទុក្ខំ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា ។ ឥទំ វុច្ចតិ ព្រាហ្មណា កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ព្រាហ្មណា កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។

តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ លុះបុគ្គលនោះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងវចីសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ តាក់តែងមនោសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ហើយរមែងចូលទៅកាន់លោក ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ផស្សៈទាំងឡាយ ប្រកបដោយទុក្ខខ្លះ មិនប្រកបដោយទុក្ខខ្លះ រមែងពាល់ត្រូវនូវបុគ្គលនោះដែលចូលទៅកាន់លោក ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ។ បុគ្គលនោះ កាលផស្សៈទាំងឡាយ ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ ពាល់ត្រូវហើយ រមែងទទួលវេទនា ប្រកបដោយទុក្ខខ្លះ មិនមានទុក្ខខ្លះ មានសុខនិងទុក្ខច្រឡំគ្នា ដូចមនុស្សពួកខ្លះ ទេវតាពួកខ្លះ វិនិបាតពួកខ្លះ ។ ម្នាលព្រាហ្មណ៍ នេះហៅថា កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅ ទាំងស ។ ម្នាលព្រាហ្មណ៍ ចុះកម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។

២៣៧



តត្រ ព្រាហ្មណ យម្បិទំ កម្មំ កណ្ហំ កណ្ហវិបាកំ តស្ស បហានាយ យា ចេតនា យម្បិទំ កម្មំ សុក្កំ សុក្កវិបាកំ តស្ស បហានាយ យា ចេតនា យម្បិទំ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ តស្ស បហានាយ យា ចេតនា ឥទំ វុច្ចតិ ព្រាហ្មណ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ព្រាហ្មណ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៤] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ

ម្នាលព្រាហ្មណ៍ បណ្តាកម្មទាំង ៤ នោះ ចេតនាដើម្បីលះបង់កម្មខ្មៅ មានវិបាកខ្មៅឯណា ចេតនាដើម្បីលះបង់កម្មស មានវិបាកសឯណា ចេតនាដើម្បីលះបង់កម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅ ទាំងស ឯណា ម្នាលព្រាហ្មណ៍ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលព្រាហ្មណ៍ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

ចាណាតិចាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ ចាណាតិចាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ តត្រ ភិក្ខវេ យម្បិទំ កម្មំ កណ្ហំ កណ្ហវិបាកំ ។ បេ ។

ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ជាអ្នកនិយាយកុហក ជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្ដីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មសមានវិបាកស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្ដីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅទាំងស តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារមានទោសខ្លះ មិនមានទោសខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្ម មិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកម្មទាំង ៤ នោះ កម្មខ្មៅមានវិបាកខ្មៅឯណា ។ បេ ។

២៣៩

ឥទំ វុច្ចតិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៦] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចេន[១] មាតា ជីវិតា វោរោបិតា ហោតិ បិតា ជីវិតា វោរោបិតោ ហោតិ អរហំ ជីវិតា វោរោបិតោ ហោតិ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទិតំ ហោតិ សង្ឃោ ភិន្នោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។

១ ឱ. ម. ឯកច្ចោ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៦] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅ ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកផ្តាច់ផ្តិលជីវិតមាតា ផ្តាច់ផ្តិលជីវិតបិតា ផ្តាច់ផ្តិលព្រះជន្មាយុ ព្រះអរហន្តខីណាស្រព មានចិត្តប្រទូស្តព្រះតថាគត ញុំាងលោហិតឲ្យពុរពងឡើង ជាអ្នកបំបែកសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។

កតមញ្ច ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហ-អសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ តត្រ ភិក្ខវេ យម្បិទំ កម្មំ កណ្ហំ កណ្ហវិបាកំ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមិនរំពៃទ្រព្យអ្នកដទៃ មានចិត្តមិនព្យាបាទ មានសេចក្តីយល់ឃើញត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្ម ទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្ម មិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកម្មទាំង ៤ នោះ កម្មខ្មៅ មានវិបាកខ្មៅឯណា ។ បេ ។

ឥទំ វុច្ចតិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហាអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៧] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហា-អសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំ កាយសង្ខារំ អភិ-សង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ

ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៧] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្មទាំង ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅមានវិបាកខ្មៅ ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារប្រកបដោយទោស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៨] ចត្តារីមានិ ភិក្ខវេ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានិ ។ កតមានិ ចត្តារិ ។ អត្ថិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ អត្ថិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ អត្ថិ

តាក់តែងកាយសង្ខារមិនមានទោស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះ មិនមានទោសខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ សេចក្តីយល់ឃើញត្រូវ ។ បេ ។ ការតម្កល់ចិត្តត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៨] ម្នាលភិក្ខុទាំងឡាយ កម្ម ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសប្រាប់ ។ កម្ម ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កម្មខ្មៅ មានវិបាកខ្មៅក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មស មានវិបាកស ក៏មាន

២៤៣



ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ អត្ថិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហ-អសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខ-រោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ កណ្ហវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ សុក្កំ សុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សព្យាបជ្ឈំបិ អព្យាបជ្ឈំបិ កាយសង្ខារំ អភិសង្ខ-រោតិ ។ បេ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ ។ កតមញ្ច ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ សតិសម្ពោជ្ឈង្គោ ធម្មវិច-យសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ

ម្នាលភិក្ខុទាំងឡាយ កម្មទាំងខ្មៅ ទាំងស មានវិបាកទាំងខ្មៅ ទាំងស ក៏មាន ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មខ្មៅ មានវិបាកខ្មៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារប្រកបដោយទោស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មខ្មៅមានវិបាកខ្មៅ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មស មានវិបាកស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ តាក់តែងកាយសង្ខារមិនមានទោស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មស មានវិបាកស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅ ទាំងស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តាក់តែងកាយសង្ខារ មានទោសខ្លះមិនមានទោសខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាកម្មទាំងខ្មៅទាំងស មានវិបាកទាំងខ្មៅ ទាំងស ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ។ សតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ

បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខា-សម្ពោជ្ឈង្គោ ។ ឥទំ វុច្ចតិ ភិក្ខវេ កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ កម្មានិ មយា សយំ អភិញ្ញា សច្ឆិកត្វា បវេទិតានីតិ ។

[៨៩] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចីកម្មេន សាវជ្ជេន មនោកម្មេន សាវជ្ជាយ ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ អនវជ្ជេន កាយកម្មេន អន-វជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន អនវជ្ជាយ ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មទាំង ៤ យ៉ាងនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសប្រាប់ ។

[៨៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ទិដ្ឋិប្រកបដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ នេះ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

[៩០] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ សព្យាបជ្ឈេន កាយកម្មេន សព្យាបជ្ឈេន វចីកម្មេន សព្យាបជ្ឈេន មនោកម្មេន សព្យាបជ្ឈាយ ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ អព្យាបជ្ឈេន កាយកម្មេន អព្យាបជ្ឈេន វចីកម្មេន អព្យាបជ្ឈេន មនោកម្មេន អព្យាបជ្ឈាយ ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[៩១] ឥធេវ ភិក្ខវេ បឋមោ សមណោ[១] ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហិ ឯវមេតំ ភិក្ខវេ សម្មា សីហនាទំ នទថ ។

១ កត្ថចិ សមណោតិ ទិស្សតិ បឋមោតិ នត្ថិ ។

[៩០] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ទិដ្ឋិប្រកបដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងទៅកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

[៩១] ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មាន ក្នុងធម្មវិន័យនេះ សមណៈទី ២ ក៏មាន ក្នុងធម្មវិន័យនេះ សមណៈទី ៣ ក៏មាន ក្នុងធម៌វិន័យនេះ សមណៈទី ៤ ក៏មាន ក្នុងធម៌វិន័យនេះ បរប្បវាទ (លទ្ធិ) ទាំងឡាយ សូន្យចាកពួកសមណៈដទៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបន្លឺសីហនាទ ដោយប្រពៃយ៉ាងនេះចុះ ។

កតមោ ច ភិក្ខវេ បឋមោ សមណោ[១] ។ ឥធ ភិក្ខវេ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។ អយំ ភិក្ខវេ បឋមោ សមណោ[១] ។ កតមោ ច ភិក្ខវេ ទុតិយោ សមណោ ។ ឥធ ភិក្ខវេ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ អយំ ភិក្ខវេ ទុតិយោ សមណោ ។ កតមោ ច ភិក្ខវេ តតិយោ សមណោ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ អយំ ភិក្ខវេ តតិយោ សមណោ ។ កតមោ ច ភិក្ខវេ ចតុត្ថោ សមណោ ។ ឥធ ភិក្ខវេ ភិក្ខុ

១ កត្ថចិ សមណោតិ ទិស្សតិ បឋមោតិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់សំយោជនៈ ៣ ជាសោតាបន្នបុគ្គល មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមណៈទី ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ២ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់សំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈស្រាលស្តើង ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយទើបធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមណៈទី ២ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ឱរម្ភាគិយសំយោជនៈ ៥ ជាឱបបាតិកកំណើត បរិនិព្វានក្នុងទីនោះ មិនបានវិលត្រឡប់ ចាកលោកនោះជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមណៈទី ៣ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមណៈទី ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ ភិក្ខវេ ចតុត្ថោ សមណោ ។ ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេហិ អញ្ញេហិ ឯវមេតំ ភិក្ខវេ សម្មា សីហនាទំ នទថាតិ ។

[៩២] សប្បុរិសំ ភិក្ខវេ និស្សាយ ចត្តារោ អានិសំសា បាដិកង្ខា ។ កតមេ ចត្តារោ ។ អរិយេន សីលេន វឌ្ឍតិ អរិយេន សមាធិនា វឌ្ឍតិ អរិយាយ បញ្ញាយ វឌ្ឍតិ អរិយាយ វិមុត្តិយា វឌ្ឍតិ ។ សប្បុរិសំ ភិក្ខវេ និស្សាយ ឥមេ ចត្តារោ អានិសំសា បាដិកង្ខាតិ ។

កម្មវគ្គោ ចតុត្ថោ ។

បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមណៈទី ៤ ។ ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ២ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៣ ក៏មានក្នុងធម្មវិន័យនេះ សមណៈទី ៤ ក៏មានក្នុងធម្មវិន័យនេះ បរប្បវាទ (លទ្ធិ) ទាំងឡាយ សូន្យចាកពួកសមណៈដទៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបន្លឺនូវសីហនាទ ដោយប្រពៃយ៉ាងនេះចុះ ។

[៩២] ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការ កើតប្រាកដឡើងបាន ព្រោះអាស្រ័យសប្បុរស ។ អានិសង្ស ៤ ប្រការ តើដូចម្តេចខ្លះ ។ បុគ្គល (អាស្រ័យសប្បុរស) រមែងចម្រើនដោយសីលដ៏ប្រសើរ រមែងចម្រើនដោយសមាធិដ៏ប្រសើរ រមែងចម្រើនដោយបញ្ញាដ៏ប្រសើរ រមែងចម្រើនដោយវិមុត្តិដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការនេះ កើតឡើងប្រាកដបាន ព្រោះអាស្រ័យសប្បុរស ។

ចប់  កម្មវគ្គ  ទី  ៤  ។

# គសុទ្ទានំ

សង្ខិត្តវិត្ថារ  សោណកាយន

សិក្ខាបទំ  អរិយមគ្គោ

ពោជ្ឈង្គំ  សាវជ្ជញ្ចេវ  អព្យាបជ្ឈំ

សមណោ  ច  សប្បុរិសានិសំសោតិតិ  ។

សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត

# ឧទ្ទាននៃកម្មវគ្គនោះគឺ

និយាយអំពីកម្ម ៤ យ៉ាង ដោយសង្ខេបនិងពិស្តារ អំពីរឿងសោណកាយនមាណពពោលថា ព្រះមានព្រះភាគទ្រង់បញ្ញត្តកម្មទាំងពួងថាជាអកិរិយវាទ អំពីកម្មទាំងខ្មៅទាំងស ចែកជាសិក្ខាបទ អំពីកម្មមិនខ្មៅមិនស បានដល់អរិយមគ្គ អំពីកម្មមិនខ្មៅមិនស បានដល់ពោជ្ឈង្គ អំពីកម្មប្រកបដោយទោស ៤ យ៉ាង អំពីកម្មមិនមានទោស ៤ យ៉ាង អំពីសមណៈ ៤ ពួក អំពីអានិសង្សអាស្រ័យសប្បុរស ៤ យ៉ាង ។

# អាបត្តិភយវគ្គោ បញ្ចមោ

[៩៣] ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច អបិ នុ តំ អានន្ទ អធិករណំ វូបសន្តន្តិ ។ កុតោ តំ ភន្តេ អធិករណំ វូបសមិស្សតិ អាយស្មតោ ភន្តេ អនុរុទ្ធស្ស វាហិយោ នាម សទ្ធិវិហារិកោ កេវលកប្បំ សង្ឃភេទាយ ឋិតោ តត្រាយស្មា អនុរុទ្ធោ ន ឯកវាចិកម្បិ ពណិតព្វំ មញ្ញតីតិ ។ កទា បនានន្ទ អនុរុទ្ធោ សង្ឃមជ្ឈេ អធិក-រណេសុ វោយុញ្ជតិ ន នុ អានន្ទ យានិ កានិចិ អធិករណានិ ឧប្បជ្ជន្តិ សព្វានិ តានិ តុម្ហេ ចេវ វូបសមេថ សារីបុត្តមោគ្គល្លានា ច ។ ចត្តារោមេ អានន្ទ អត្ថវសេ សម្បស្សមានោ បាបភិក្ខុ សង្ឃភេទេន នន្ទតិ ។ កតមេ ចត្តារោ ។

# អាបត្តិភយវគ្គ ទី ៥

[៩៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុគង់ក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគបានត្រាស់សួរថា ម្នាលអានន្ទ អធិករណ៍នោះបានរម្ងាប់ហើយឬ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អធិករណ៍នោះនឹងរម្ងាប់អំពីណាបាន បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់អនុរុទ្ធមានអាយុឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកសង្ឃ ឥតឈប់ឈរ ក្នុងរឿងនោះ ព្រះអនុរុទ្ធដ៏មានអាយុ ក៏មិនឃើញមានស្តីថាអ្វីសូម្បីតែ ១ ម៉ាត់ក៏គ្មាន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ចុះអនុរុទ្ធធ្លាប់ចូលគំនិតក្នុងអធិករណ៍នាកណ្តាលសង្ឃ ពីកាលណាមក ម្នាលអានន្ទ អធិករណ៍ទាំងឡាយណាមួយ កើតឡើង អធិករណ៍ទាំងនោះ គួរតែអ្នកទាំងឡាយផងសារីបុត្តនិងមោគ្គល្លានផង រម្ងាប់ មិនមែនទេឬ ។ ម្នាលអានន្ទ ភិក្ខុបាបកាលបើឃើញច្បាស់នូវអំណាចប្រយោជន៍ ៤ យ៉ាងនេះ រមែងត្រេកអរដោយការបំបែកសង្ឃ ។ អំណាចប្រយោជន៍ ៤ យ៉ាង ដូចម្តេចខ្លះ ។

ឥធានន្ទ ចាបភិក្ខុ ទុស្សីលោ ហោតិ ចាបជម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណាប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ តស្ស ឯវំ ហោតិ សចេ ខោ មំ ភិក្ខូ ជានិស្សន្តិ ទុស្សីលោ ចាបជម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណាប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោតិ សមគ្គា មំ សន្តា ជាសេស្សន្តិ វត្វា បន មំ ន ជាសេស្សន្តីតិ ។ ឥទំ អានន្ទ បឋមំ អត្ថវសំ សម្បស្សមានោ ចាបភិក្ខុ សង្ឃេភេទេន នន្ទតិ ។ បុន ចបរំ អានន្ទ ចាបភិក្ខុ មិច្ឆាទិដ្ឋិកោ ហោតិ អន្តគ្គាហិកាយ ទិដ្ឋិយា សមន្នាគតោ ។ តស្ស ឯវំ ហោតិ សចេ ខោ មំ ភិក្ខូ ជានិស្សន្តិ មិច្ឆាទិដ្ឋិកោ អន្តគ្គាហិកាយ ទិដ្ឋិយា សមន្នាគតោតិ

ម្នាលអានន្ទ ភិក្ខុបាបក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌លាមក មានអំពើមិនស្អាត មានមារយាទគួរឲ្យអ្នកផង រលឹកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយក្នុង មានចិត្តទទឹក ដោយរាគាទិក្កិលេស ជាមនុស្សជ្រោកជ្រាក ភិក្ខុបាបនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាភិក្ខុទ្រុស្តសីល មានធម៌លាមក មានអំពើមិនស្អាត មានមារយាទគួរឲ្យអ្នកផង រលឹកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយក្នុង មានចិត្តទទឹក ដោយរាគាទិក្កិលេស ជាមនុស្សជ្រោកជ្រាក កាលភិក្ខុទាំងឡាយព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ១ នេះ ទើបត្រេកអរដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាប មានសេចក្តីយល់ខុស ប្រកបដោយអន្តគ្គាហិកទិដ្ឋិ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាភិក្ខុមានសេចក្តីយល់ខុស ប្រកបដោយអន្តគ្គាហិកទិដ្ឋិ

សមគ្គា មំ សង្ឃា នាសេស្សន្តិ វគ្គា បន មំ ន នាសេស្សន្តីតិ ។ ឥទំ អានន្ទ ទុតិយំ អត្ថវសំ សម្បស្សមានោ ចាបភិក្ខុ សង្ឃភេទេន នន្ទតិ ។ បុន ចបរំ អានន្ទ ចាបភិក្ខុ មិច្ឆាអាជីវោ ហោតិ មិច្ឆាអាជីវេន ជីវិតំ កប្បេតិ ។ តស្ស ឯវំ ហោតិ សចេ ខោ មំ ភិក្ខូ ជានិស្សន្តិ មិច្ឆាអាជីវោ មិច្ឆាអាជីវេន ជីវិតំ កប្បេតីតិ សមគ្គា មំ សង្ឃា នាសេស្សន្តិ វគ្គា បន មំ ន នាសេស្សន្តីតិ ។ ឥទំ អានន្ទ តតិយំ អត្ថវសំ សម្បស្សមានោ ចាបភិក្ខុ សង្ឃភេទេន នន្ទតិ ។ បុន ចបរំ អានន្ទ ចាបភិក្ខុ លាភកាមោ ហោតិ សក្ការកាមោ អនវញ្ញត្តិកាមោ ។ តស្ស ឯវំ ហោតិ សចេ ខោ មំ ភិក្ខូ ជានិស្សន្តិ លាភកាមោ សក្ការកាមោ អនវញ្ញត្តិកាមោតិ សមគ្គា មំ សង្ឃា ន សក្ករិស្សន្តិ ន គរុករិស្សន្តិ ន មានេស្សន្តិ ន បូជេស្សន្តិ វគ្គា បន មំ សក្ករិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តីតិ ។ ឥទំ អានន្ទ ចតុត្ថំ អត្ថវសំ សម្បស្សមានោ ចាបភិក្ខុ

កាលភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ២ នេះទើបត្រេកអរ ដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាបមានការចិញ្ចឹមជីវិតខុស សម្រេចជីវិតដោយមិច្ឆាជីវៈ ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាអ្នកចិញ្ចឹមជីវិតខុស សម្រេចជីវិតដោយមិច្ឆាជីវៈ កាលភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា មុខជានឹងធ្វើអញឲ្យវិនាស បើបែកគ្នាហើយ នឹងធ្វើអញឲ្យវិនាសមិនបានឡើយ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ៣ នេះ ទើបត្រេកអរ ដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបាបជាអ្នកប្រាថ្នាលាភ ប្រាថ្នាសក្ការៈ ប្រាថ្នាមិនឲ្យគេមើលងាយ ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួកភិក្ខុដឹងថា អញជាអ្នកប្រាថ្នាលាភ ប្រាថ្នាសក្ការៈ ប្រាថ្នាមិនឲ្យគេមើលងាយ កាលភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា មុខជានឹងមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាអញឡើយ បើបែកគ្នាហើយ នឹងធ្វើសក្ការៈ គោរពរាប់អានបូជាអញ ។ ម្នាលអានន្ទ ភិក្ខុបាបកាលឃើញច្បាស់នូវអំណាចប្រយោជន៍ទី ៤ នេះ

សង្ឃភេទេន នន្ទតិ ។ ឥមេ ខោ អានន្ទ ចត្តារោ អត្ថវសេ សម្បស្សមានោ ចាបភិក្ខុ សង្ឃភេទេន នន្ទតីតិ ។

[៩៤] ចត្តារីមានិ ភិក្ខវេ អាបត្តិភយានិ ។ កតមានិ ចត្តារិ ។ សេយ្យថាបិ ភិក្ខវេ ចោរំ អាគុចារឹ គហេត្វា រញ្ញោ ទស្សេយ្យុំ អយន្តេ ទេវ ចោរោ អាគុចារី ឥមស្ស ទេវោ ទណ្ឌំ បណេតូតិ ។ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ ឥមំ បុរិសំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទថាតិ ។ តមេនំ រញ្ញោ បុរិសា ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃា-ដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទេយ្យុំ ។

ទើបត្រេកអរដោយការបំបែកសង្ឃ ។ ម្នាលអានន្ទ ភិក្ខុបាបកាល ឃើញអំណាចប្រយោជន៍ទាំង ៤ នេះ រមែងត្រេកអរដោយការបំបែកសង្ឃ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ ភ័យកើតព្រោះអាបត្តិនេះមាន ៤ យ៉ាង ។ ភ័យ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចរាជបុរស ចាប់ចោរប្រព្រឹត្តអាក្រក់ មកថ្វាយព្រះរាជា ហើយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស បុរសនេះ ជាចោរប្រព្រឹត្តអាក្រក់ សូមទ្រង់ដាក់ព្រះរាជអាជ្ញាចោរនេះ ។ ព្រះរាជាទ្រង់ត្រាស់នឹងរាជបុរសនោះយ៉ាងនេះថា នែប្រស្តែង ចូរអ្នកទាំងឡាយនាំគ្នា ទៅចាប់បុរសនេះ ចងស្ពាយសេកឲ្យខ្ជាប់ ដោយខ្សែដ៏មាំ ហើយកោរត្រងោល ទូងស្គរដ៏យដែលមានសំឡេងឮខ្លាំង នាំបណ្តើរ អាក្រោស សព្វច្រកសព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាត់ក្បាលខាងត្បូងព្រះនគរ ។ រាជបុរសទាំងឡាយ ក៏ចាប់បុរសនោះចងស្ពាយសេកឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរត្រងោល ទូងស្គរដែលមានសំឡេងឮខ្លាំង នាំបណ្តើរអាក្រោស សព្វច្រក សព្វផ្លូវត្រឡែងកែង រួចនាំចេញតាមទ្វារខាងត្បូង ហើយកាត់ក្បាល ខាងត្បូងព្រះនគរ ។

២៤៣



តត្រញ្ញតរស្ស ថលដ្ឋស្ស[១] បុរិសស្ស ឯវមស្ស បាបកំ វត ភោ អយំ បុរិសោ កម្មំ អកាសិ គារយ្ហំ សីសច្ឆេជ្ជំ យត្រ ហិ នាម រញ្ញោ បុរិសា ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយា រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស សីសំ ឆិន្ទិស្សន្តិ សោ វតស្សាយំ[២] ឯវរូបំ បាបកម្មំ ន ករេយ្យ[៣] សីសច្ឆេជ្ជន្តិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឯវំ តិព្វា ភយសញ្ញា បច្ចុបដ្ឋិតា ហោតិ បារាជិកេសុ ធម្មេសុ តស្សេតំ បាដិកង្ខំ អនាបន្នោ វា បារាជិកំ ធម្មំ ន អាបជ្ជិស្សតិ អាបន្នោ វា បារាជិកំ ធម្មំ យថាធម្មំ បដិករិស្សតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ កាឡកំ វត្ថំ បរិធាយ កេសេ បកិរិត្វា មុសលំ ខន្ធេ អារោបេត្វា មហាជនកាយំ ឧបសង្កមិត្វា

---

១ ម. ពាលដ្ឋស្ស ។ ២ ឱ. ម. វតស្សាហំ ។ ៣ ឱ. ម. ន ករេយ្យំ គារយ្ហំ ។

ក្នុងទីនោះមានបុរស ១ នាក់ឈរក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះ បានធ្វើអំពើអាក្រក់ ជាអំពើគួរតិះដៀល គួរគេកាត់ក្បាល ទៅហើយហ្ន៎ មើលចុះហ្ន៎ រាជបុរសចាប់បុរសនោះ ចងស្ពាយសេកឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរត្រងោល ទួងស្គរជ័យដែលមានសំឡេងឮខ្លាំង នាំបណ្តើរអាក្រោស សព្វច្រក សព្វផ្លូវត្រឡែងកែងរួចនាំចេញតាមទ្វារខាងត្បូង ហើយកាត់ក្បាល ខាងត្បូងព្រះនគរ ឱ បុរសនេះមិនគួរនឹងធ្វើបាបកម្ម ជាអំពើគួរដល់កិរិយាកាត់ក្បាល ដែលមានសភាពយ៉ាងនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះមានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភយសញ្ញា (សេចក្តីសម្គាល់ថាគួរខ្លាច) ដ៏ក្លៀវក្លា ក្នុងធម៌ទាំងឡាយ គឺបារាជិកទេ ភយសញ្ញានុ៎ះក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវបារាជិក ក៏នឹងមិនហ៊ានឲ្យត្រូវ ឬត្រូវបារាជិកហើយ ក៏នឹងសម្តែងឲ្យសមគួរតាមធម៌ (សឹកចេញ) ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់លីអង្រៃ ដើរចូលទៅកាន់ទីប្រជុំមហាជន

ឯវំ វទេយ្យ អហំ ភន្តេ ចាបកម្មំ អកាសឹ តាវយ្ហំ មោសល្លំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ ។ តត្រញ្ញតរស្ស ថលដ្ឋស្ស បុរិសស្ស ឯវមស្ស ចាបកំ វត ភោ អយំ បុរិសោ កម្មំ អកាសិ តាវយ្ហំ មោសល្លំ យត្រ ហិ នាម កាឡកំ វត្ថំ បរិធាយ កេសេ បកិរិត្វា មុសលំ ខន្ធេ អារោ-បេត្វា មហាជនកាយំ ឧបសង្កមិត្វា ឯវំ វក្ខតិ អហំ ភន្តេ ចាបកម្មំ អកាសឹ តាវយ្ហំ មោសល្លំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ សោ វតស្សាយំ ឯវរូបំ ចាបកម្មំ ន ករេយ្យ តាវយ្ហំ មោសល្លន្តិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឯវំ តិព្វា ភយសញ្ញា បច្ចុបដ្ឋិតា ហោតិ សង្ឃាទិសេសេសុ ធម្មេសុ តស្សេតំ ចាដិកង្ខំ អនាបន្នោ វា សង្ឃាទិសេសំ ធម្មំ ន អាបជ្ជិស្សតិ អាបន្នោ វា សង្ឃាទិសេសំ ធម្មំ យថាធម្មំ បដិករិស្សតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ កាឡកំ វត្ថំ បរិធាយ

ប្រកាស (សេចក្តីខុសរបស់ខ្លួន) យ៉ាងនេះថា អ្នកដ៏ចម្រើន ខ្ញុំបាន ធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរលីអង្រ្គែ អ្នកមានអាយុ ពេញ ចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ។ ក្នុងទីនោះ មានបុរសមួយនាក់ ឈរនៅក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះបានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរឲ្យលីអង្រ្គែទៅហើយ ហ្ន៎ មើលចុះហ្ន៎ បុរសនេះស្លៀកដណ្តប់សំពត់ខ្មៅរំសាយសក់ លីអង្រ្គែ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស (សេចក្តីខុសរបស់ខ្លួន) យ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរឲ្យលីអង្រ្គែ អ្នកមានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំ នឹងធ្វើអំពើយ៉ាងនោះ ឱ បុរសនេះមិនគួរនឹងធ្វើបាបកម្មដែលគួរតិះដៀល គួរឲ្យលីអង្រ្គែ មានសភាពយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភយសញ្ញា (សេចក្តីសម្គាល់ថាគួរខ្លាច) ដ៏ក្លៀវក្លាយ៉ាងនេះ ក្នុង ធម៌ទាំងឡាយ គឺសង្ឃាទិសេស ភយសញ្ញានោះ ក៏ជាទីសង្ឃឹមបាន ដល់ភិក្ខុនោះថា មិនទាន់ត្រូវសង្ឃាទិសេសាបត្តិទេ ក៏នឹងមិនហ៊ាន ឲ្យត្រូវ ឬត្រូវសង្ឃាទិសេសាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាម ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសស្លៀកដណ្តប់សំពត់ខ្មៅ

កោសេ បកិរិត្វា អស្សបុដំ ខន្ធេ អារោបេត្វា មហាជនកាយំ ឧបសង្កមិត្វា ឯវំ វទេយ្យ អហំ ភន្តេ ចាបកម្មំ អកាសឹ គារយ្ហំ អស្សបុដំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ ។ តត្រញ្ញតរស្ស ថលដ្ឋស្ស បុរិសស្ស ឯវមស្ស ចាបកំ វត ភោ អយំ បុរិសោ កម្មំ អកាសិ គារយ្ហំ អស្សបុដំ យត្រ ហិ នាម កាឡកំ វត្ថំ បរិធាយ កោសេ បកិរិត្វា អស្សបុដំ ខន្ធេ អារោបេត្វា មហាជនកាយំ ឧបសង្កមិត្វា ឯវំ វក្ខតិ អហំ ភន្តេ ចាបកម្មំ អកាសឹ គារយ្ហំ អស្សបុដំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ សោ វតស្សាយំ ឯវរូបំ ចាបកម្មំ ន ករេយ្យ អស្សបុដន្តិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឯវំ តិព្វា ភយសញ្ញា បច្ចុបដ្ឋិតា ហោតិ ចាចិត្តិយេសុ ធម្មេសុ

រំសាយសក់ លីកញ្ចប់ផេះ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស (សេចក្តីខុសរបស់ខ្លួន) យ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញ្ចប់ផេះ អ្នកដ៏មានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនេះ ។ ក្នុងទីនោះមានបុរសមួយនាក់ឈរក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនោះបានធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញ្ចប់ផេះទៅ ហើយហ្ន៎ មើលចុះហ្ន៎ បុរសនេះ ស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ លីកញ្ចប់ផេះ ដើរចូលទៅកាន់ទីប្រជុំមហាជន និយាយស្រែកប្រកាសយ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញ្ចប់ផេះ លោកមានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើអំពើយ៉ាងនោះ ឱ បុរសនោះ មិនគួរធ្វើបាបកម្ម គួរតិះដៀល ជាអំពើគួរឲ្យលីកញ្ចប់ផេះ មានសភាពយ៉ាងនោះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី តាំងភយសញ្ញា (សេចក្តីសម្គាល់ថាគួរខ្លាច) ដ៏ក្លៀវក្លាយ៉ាងនេះ ក្នុងធម៌ទាំងឡាយ គឺបាចិត្តិយ

តស្សេតំ បាដិកង្ខំ អជានន្តោ វា បាចិត្តិយំ ធម្មំ ន អាបជ្ជិស្សតិ អាបន្នោ វា បាចិត្តិយំ ធម្មំ យថាធម្មំ បដិករិស្សតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ កាឡកំ វត្ថំ បរិធាយ កេសេ បកិរិត្វា មហាជនកាយំ ឧបសង្កមិត្វា ឯវំ វទេយ្យ អហំ ភន្តេ បាបកម្មំ អកាសឹ គារយ្ហំ ឧបវជ្ជំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ ។ តត្រញ្ញតរស្ស ថលដ្ឋស្ស បុរិសស្ស ឯវមស្ស បាបកំ វត ភោ អយំ បុរិសោ កម្មំ អកាសិ គារយ្ហំ ឧបវជ្ជំ យត្រ ហិ នាម កាឡកំ វត្ថំ បរិធាយ កេសេ បកិរិត្វា មហាជនកាយំ ឧបសង្កមិត្វា ឯវំ វក្ខតិ អហំ ភន្តេ បាបកម្មំ អកាសឹ គារយ្ហំ ឧបវជ្ជំ យេន មេ អាយស្មន្តោ អត្តមនា ហោន្តិ តំ ករោមីតិ សោ វតស្សាយំ ឯវរូបំ បាបកម្មំ ន ករេយ្យ គារយ្ហំ ឧបវជ្ជន្តិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ឯវំ តិព្វា ភយសញ្ញា

កយសញ្ញានោះ ក៏ជាទីសង្ឃឹមបានដល់ភិក្ខុនោះថា មិនទាន់ត្រូវបាចិត្តិយាបត្តិទេ ក៏នឹងមិនហ៊ានឲ្យត្រូវ ឬត្រូវបាចិត្តិយាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសស្លៀកដណ្តប់សំពត់ខ្មៅ រំសាយសក់ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាស (សេចក្តីខុសរបស់ខ្លួន) យ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម ជាអំពើដែលគួរតិះដៀល គួរស្តីបន្ទោស អ្នកមានអាយុពេញចិត្តឲ្យខ្ញុំធ្វើអំពើយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ។ ក្នុងទីនោះ មានបុរសមួយនាក់ ឈរនៅក្នុងទីខ្ពស់ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុរសនេះបានធ្វើបាបកម្ម ជាអំពើដែលគួរតិះដៀល គួរស្តីបន្ទោសទៅហើយហ្ន៎ មើលចុះហ្ន៎ បុរសនោះស្លៀកដណ្តប់ សំពត់ខ្មៅ រំសាយសក់ ដើរចូលទៅកាន់ទីប្រជុំមហាជន ស្រែកប្រកាសយ៉ាងនេះថា នៃអ្នកដ៏ចម្រើន ខ្ញុំបានធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរស្តីបន្ទោស អ្នកមានអាយុ ពេញចិត្តឲ្យខ្ញុំធ្វើយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ឱ បុរសនេះ មិនគួរនឹងធ្វើបាបកម្ម ជាអំពើគួរតិះដៀល គួរស្តីបន្ទោស មានសភាពយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះ មានឧបមេយ្យ ដូចសហធម្មិកណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី តាំងកយសញ្ញា (សេចក្តីសម្គាល់ថាគួរខ្លាច) ដ៏ក្លៀវក្លាយ៉ាងនេះ

២៤៧



បច្ចុបដ្ឋិតា ហោតិ បាដិទេសនីយេសុ ធម្មេសុ តស្សេតំ បាដិកង្ខំ អនាបន្នោ វា បាដិទេសនីយំ ធម្មំ ន អាបជ្ជិស្សតិ អាបន្នោ វា បាដិទេសនីយំ ធម្មំ យថាធម្មំ បដិការិស្សតិ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ អាបត្តិភយានីតិ ។

[៩៨] សិក្ខានិសំសមិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ បញ្ញុត្តរំ វិមុត្តិសារំ សតាធិបតេយ្យំ ។ កថញ្ច ភិក្ខវេ សិក្ខានិសំសំ ហោតិ ។ ឥធ ភិក្ខវេ មយា សាវកានំ អភិសមាចារិកា សិក្ខា បញ្ញត្តា អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ យថា យថា ភិក្ខវេ មយា សាវកានំ អភិសមាចារិកា សិក្ខា បញ្ញត្តា អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ តថា តថា សោ តស្សា សិក្ខាយ អខណ្ឌការី ហោតិ អច្ឆិទ្ទការី អសពលការី អកម្មាសការី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

ក្នុងធម៌ទាំងឡាយ គឺបាដិទេសនីយ ភយសញ្ញានុ៎ះ ក៏ជាទីសង្ឃឹមបាន ដល់ភិក្ខុនោះថា មិនទាន់ត្រូវបាដិទេសនីយាបត្តិទេ ក៏នឹងមិនហ៊ាន ឲ្យត្រូវ ឬបើត្រូវបាដិទេសនីយាបត្តិហើយ ក៏នឹងសម្តែងឲ្យសមគួរតាម ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ទាំង ៤ នេះ ហៅថា ភ័យកើតព្រោះអាបត្តិ ។

[៩៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈនោះ មានសិក្ខា ជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតី ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានសិក្ខាជាអានិសង្ស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សិក្ខា[១] ជាអភិសមាចារិកា ដែលតថាគតបានបញ្ញត្ត ដល់ពួកសាវ័ក ក្នុងសាសនានេះ ដើម្បីធ្វើពួកជនដែលមិនទាន់ជ្រះថ្លាឲ្យ ជ្រះថ្លាឡើង ពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែកើតសេចក្តី ជ្រះថ្លាឡើង ម្នាលភិក្ខុទាំងឡាយ សិក្ខាជាអភិសមាចារិកា ដែល តថាគតបានបញ្ញត្តដល់ពួកសាវ័ក ដើម្បីធ្វើពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ពួកជនដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹងរឹតតែកើត សេចក្តីជ្រះថ្លាឡើង ដោយប្រការណាៗ សិក្ខាកាមភិក្ខុនោះ ក៏ធ្វើមិន ឲ្យដាច់ ធ្វើមិនឲ្យធ្លុះ ធ្វើមិនឲ្យពពាល ធ្វើមិនឲ្យពព្រុសក្នុងសិក្ខានោះ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ដោយប្រការនោះៗ ។

១ ទំនៀមរបស់ភិក្ខុដែលគួររក្សា ។

បុន ចបរំ ភិក្ខវេ មយា សាវកានំ អាភិសមាចារិកា សិក្ខា បញ្ញត្តា សព្វសោ សម្មាទុក្ខក្ខយាយ យថា យថា ភិក្ខវេ មយា សាវកានំ អាភិសមាចារិកា សិក្ខា បញ្ញត្តា សព្វសោ សម្មាទុក្ខក្ខយាយ តថា តថា សោ តស្សា សិក្ខាយ អខណ្ឌការី ហោតិ អច្ឆិទ្ទការី អសពលការី អកម្មាសការី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឯវំ ខោ ភិក្ខវេ សិក្ខានិសំសំ ហោតិ ។ កថញ្ច ភិក្ខវេ បញ្ញុត្តរំ ហោតិ ។ ឥធ ភិក្ខវេ មយា សាវកានំ ធម្មា ទេសិតា សព្វសោ សម្មាទុក្ខក្ខយាយ យថា យថា ភិក្ខវេ មយា សាវកានំ ធម្មា ទេសិតា សព្វសោ សម្មាទុក្ខក្ខយាយ តថា តថា សព្វេ តេ ធម្មា បញ្ញាយ សមវេក្ខិតា ហោន្តិ ។ ឯវំ ខោ ភិក្ខវេ បញ្ញុត្តរំ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សិក្ខា[១] ជាអាទិព្រហ្មចរិយកា ដែលតថាគត បានបញ្ញត្តដល់ពួកសាវ័ក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ សិក្ខា ជាអាទិព្រហ្មចរិយកា ដែលតថាគតបានបញ្ញត្តដល់ពួកសាវ័ក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ សិក្ខាកាមភិក្ខុនោះ ក៏ធ្វើមិនឲ្យដាច់ ធ្វើមិនឲ្យធ្លុះ ធ្វើមិនឲ្យពពាល ធ្វើមិនឲ្យពព្រុស ក្នុងសិក្ខានោះ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈ មានសិក្ខា ជាអានិសង្ស យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានបញ្ញាជាកំពូល តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតសម្ដែងហើយ ដល់សាវ័កទាំងឡាយ ក្នុងសាសនានេះ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតបានសម្ដែងហើយ ដល់ពួកសាវ័ក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ បញ្ញាកាមភិក្ខុក៏បានឃើញច្បាស់ នូវចតុសច្ចធម៌ទាំងអស់នោះ ដោយប្រាជ្ញា ដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានបញ្ញាជាកំពូលយ៉ាងនេះ ។

---

១ សិក្ខាបទដែលមានក្នុងព្រះបាតិមោក្ខ ដែលជាពុទ្ធអាណា ។

កាថញ្ច ភិក្ខវេ វិមុត្តិសារំ ហោតិ ។ ឥធ ភិក្ខវេ មយា សាវកានំ ធម្មា ទេសិតា សព្វសោ សម្មាទុក្ខក្ខយាយ យថា យថា ភិក្ខវេ មយា សាវកានំ ធម្មា ទេសិតា សព្វសោ សម្មាទុក្ខក្ខយាយ តថា តថា សព្វេ តេ ធម្មា វិមុត្តិយា ផុសិតា ហោន្តិ ។ ឯវំ ខោ ភិក្ខវេ វិមុត្តិសារំ ហោតិ ។ កាថញ្ច ភិក្ខវេ សតាធិបតេយ្យំ ហោតិ ។ ឥតិ អបរិបូរំ វា អភិសមាចារិកំ សិក្ខំ បរិបូរេស្សាមិ បរិបូរំ វា អភិសមាចារិកំ សិក្ខំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ ។ ឥតិ អបរិបូរំ វា អាទិព្រហ្មចរិយកំ សិក្ខំ បរិបូរេស្សាមិ បរិបូរំ វា អាទិព្រហ្មចរិយកំ សិក្ខំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានវិមុត្តិជាខ្លឹម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតសម្ដែងហើយ ដល់ពួកសាវ័កក្នុងសាសនានេះ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ម្នាលភិក្ខុទាំងឡាយ ចតុសច្ចធម៌ ដែលតថាគតសម្ដែងហើយ ដល់ពួកសាវ័ក ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ដោយអាការទាំងពួង ដោយប្រការណាៗ ពួកសាវ័កក៏បានពាល់ត្រូវចតុសច្ចធម៌ទាំងពួងនោះដោយវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានវិមុត្តិជាខ្លឹមយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រហ្មចរិយៈមានសតិជាអធិបតី តើដូចម្ដេច ។ សតិដែលពួកសាវ័កបានតម្កល់ទុកប្រពៃ ឮដ៏ខាងក្នុងថា អាត្មាអញនឹងបំពេញអភិសមាចារិកាសិក្ខា ដែលមិនទាន់បរិបូណ៌នឹងឲ្យបរិបូណ៌ខ្លះ នឹងរក្សាទុកអភិសមាចារិកាសិក្ខា ដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការដូច្នេះ ។ សតិដែលពួកសាវ័កបានតម្កល់ទុកប្រពៃហើយ ឮដ៏ខាងក្នុងថា អាត្មាអញនឹងបំពេញអាទិព្រហ្មចរិយកាសិក្ខា ដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ខ្លះ នឹងរក្សាទុកនូវអាទិព្រហ្មចរិយកាសិក្ខា ដែលបរិបូណ៌ហើយដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការដូច្នេះ។

ឥតិ អសមវេក្ខិតំ វា ធម្មំ តត្ថ តត្ថ បញ្ញាយ សមវេក្ខិស្សាមិ សមវេក្ខិតំ វា ធម្មំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ ។ ឥតិ អផុសិតំ វា ធម្មំ វិមុត្តិយា ផុសិស្សាមិ ផុសិតំ វា ធម្មំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ អជ្ឈត្តំយេវ សតិ សុបដ្ឋិតា ហោតិ ។ ឯវំ ខោ ភិក្ខវេ សតាធិបតេយ្យំ ហោតិ ។ សិក្ខា-និសំសមិទំ ភិក្ខវេ ព្រហ្មចរិយំ វុច្ចតិ បញ្ញុត្តរំ វិមុត្តិសារំ សតាធិបតេយ្យន្តិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[៩៦] ចតស្សោ ឥមា ភិក្ខវេ សេយ្យា ។ កាតមា ចតស្សោ ។ បេតសេយ្យា កាមភោគិសេយ្យា

សតិដែលពួកសាវ័កបានតម្កល់ទុកប្រពៃហើយ ឰដ៏ខាងក្នុងថា អាត្មាអញនឹងធ្វើចតុសច្ចធម៌ ដែលមិនទាន់ឃើញច្បាស់ឲ្យឃើញច្បាស់ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ នឹងរក្សាទុកចតុសច្ចធម៌ ដែលឃើញច្បាស់ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ។ សតិដែលពួកសាវ័កបានតម្កល់ទុកប្រពៃហើយ ឰដ៏ខាងក្នុងថា អាត្មាអញនឹងពាល់ត្រូវនូវចតុសច្ចធម៌ដែលមិនទាន់ប៉ះពាល់ដោយវិមុត្តិខ្លះ នឹងរក្សាទុកនូវចតុសច្ចធម៌ ដែលប៉ះពាល់ហើយ ដោយបញ្ញាក្នុងទីនោះៗ ខ្លះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈមានសតិ ជាអធិបតីយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ព្រហ្មចរិយៈមានសិក្ខា ជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតី ។ ពាក្យណាដែលតថាគតបានពោលហើយ ពាក្យនោះតថាគតពោល ព្រោះអាស្រ័យព្រហ្មចរិយៈនេះ ។

[៩៦] ម្នាលភិក្ខុទាំងឡាយ ដំណេកនេះមាន ៤ ។ ដំណេក ៤ គឺអ្វីខ្លះ ។ គឺដំណេកដូចមនុស្សស្លាប់[១] ១ ដំណេកអ្នកបរិភោគកាម ១

១ ព្រោះស័ព្ទថា បេតៈ ប្រែថា ប្រេតក៏បាន ទើបអដ្ឋកថាអធិប្បាយជា ២ ន័យ បើសំដៅយកប្រេត លោកអធិប្បាយថា ប្រេតនោះជាអ្នកអត់ឃ្លានស្គមរំយើងមានសាច់ឈាមតិច ឆ្អឹងឡើងរគាមដូចមនុស្សឈឺធ្ងន់យូរ មិនអាចដេកផ្អៀងបាន បានតែដេកផ្ងារ ។

២៦១



សីហសេយ្យា តថាគតសេយ្យា ។ កតមា ច ភិក្ខវេ បេតសេយ្យា ។ យេភុយ្យេន ភិក្ខវេ បេតា ឧត្តានា សេន្តិ ។ អយំ វុច្ចតិ ភិក្ខវេ បេតសេយ្យា ។ កតមា ច ភិក្ខវេ កាមភោគិសេយ្យា ។ យេភុយ្យេន ភិក្ខវេ កាមភោគី វាមេន បស្សេន សេន្តិ ។ អយំ វុច្ចតិ ភិក្ខវេ កាមភោគិសេយ្យា ។ កតមា ច ភិក្ខវេ សីហសេយ្យា ។ សីហោ ភិក្ខវេ មិគរាជា ទក្ខិណេន បស្សេន សេយ្យំ កប្បេតិ បាទេន បាទំ អច្ចាធាយ អន្តរសត្ថិម្ហិ នង្គុដ្ឋំ អនុបក្ខិបិត្វា សោ បដិពុជ្ឈិត្វា បុរិមំ កាយំ អព្ភុន្នាមេត្វា បច្ឆិមំ កាយំ អនុវិលោកេតិ ។ សចេ ភិក្ខវេ សីហោ មិគរាជា កិញ្ចិ បស្សតិ កាយស្ស វិក្ខិត្តំ វា វិសដំ វា តេន ភិក្ខវេ សីហោ មិគរាជា អនត្តមនោ ហោតិ សចេ បន ភិក្ខវេ សីហោ មិគរាជា ន កិញ្ចិ បស្សតិ កាយស្ស វិក្ខិត្តំ វា វិសដំ វា តេន ភិក្ខវេ សីហោ មិគរាជា អត្តមនោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីហសេយ្យា ។

ដំណេកសីហៈ ១ ដំណេកព្រះតថាគត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកដូចមនុស្សស្លាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មនុស្សស្លាប់ច្រើនតែដេកផ្ងារ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកមនុស្សស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកអ្នកបរិភោគកាម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគកាម ច្រើនតែដេកផ្អៀងទៅខាងឆ្វេង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកអ្នកបរិភោគកាម ។ ម្នាលភិក្ខុទាំងឡាយ ចុះដំណេកសីហៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ សម្រេចការដេក ដោយខាងៗ ស្តាំ យកជើងតម្រួតលើជើង សិកកន្ទុយក្នុងចន្លោះភ្លៅ សីហមិគរាជនោះ លុះភ្ញាក់ឡើង ងើបកាយខាងមុខគឺងើបក្បាល សំឡឹង មើលកាយខាងក្រោម ។ ម្នាលភិក្ខុទាំងឡាយ បើសីហមិគរាជ ឃើញ សេចក្តីភ្លាំងភ្លាត់ ឬការឃ្លៀងឃ្លាតកាយណាមួយសោត ម្នាលភិក្ខុ ទាំងឡាយ សីហមិគរាជ រមែងតូចចិត្តព្រោះការភ្លាំងភ្លាត់និងឃ្លៀងឃ្លាត នៃកាយនោះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសីហមិគរាជ មិនឃើញ សេចក្តីភ្លាំងភ្លាត់ឬឃ្លៀងឃ្លាតនៃកាយណាមួយទេ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ រមែងត្រេកអរ ដោយការមិនភ្លាំងភ្លាត់និងឃ្លៀងឃ្លាតនៃ កាយនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកសីហៈ ។

កតមា ច ភិក្ខវេ តថាគតសេយ្យា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ តថា-គតសេយ្យា ។ ឥមា ខោ ភិក្ខវេ ចតស្សោ សេយ្យាតិ ។

[៩៧] ចត្តារោម ភិក្ខវេ ថូបារហា ។ កតមេ ចត្តារោ ។ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ថូបារហោ បច្ចេកពុទ្ធោ ថូបារហោ តថាគតស្សាវកោ ថូបារហោ រាជា ចក្កវត្តី ថូបារហោ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ថូបារហាតិ ។

[៩៨] ចត្តារោមេ ភិក្ខវេ ធម្មា បញ្ញាវុឌ្ឍិយា សំវត្តន្តិ ។ កតមេ ចត្តារោ ។ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិ-បត្តិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា បញ្ញាវុឌ្ឍិយា សំវត្តន្តីតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះដំណេកព្រះតថាគត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ នេះដំណេក ៤ ប្រការ ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរបញ្ចុះទុកក្នុងថូបៈនេះមាន ៤ ពួក ។ បុគ្គល ៤ ពួក ដូចម្តេចខ្លះ ។ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ គួរបញ្ចុះក្នុងថូបៈ ១ ព្រះបច្ចេកពុទ្ធ គួរបញ្ចុះក្នុងថូបៈ ១ សាវ័ករបស់ព្រះតថាគត គួរបញ្ចុះក្នុងថូបៈ ១ ស្តេចចក្រពត្តិ គួរបញ្ចុះក្នុងថូបៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ គួរបញ្ចុះទុកក្នុងថូបៈ ។

[៩៨] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ ប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ យកចិត្តទុកដាក់ដោយឧបាយ ១ ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ ប្រការរមែងប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ។

[៩៩] ចត្តារោមេ ភិក្ខវេ ធម្មា មនុស្សភូតស្ស ពហុការា ហោន្តិ ។ កតមេ ចត្តារោ ។ សប្បុរិសសំសេវោ សទ្ធម្មស្សវនំ យោនិសោមនសិការោ ធម្មានុធម្មប្បដិបត្តិ ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មា មនុស្សភូតស្ស ពហុការា ហោន្តីតិ ។

[១០០] ចត្តារោមេ ភិក្ខវេ អនរិយវោហារា ។ កតមេ ចត្តារោ ។ អទិដ្ឋេ ទិដ្ឋវាទិតា អស្សុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អនរិយវោហារាតិ ។

[១០១] ចត្តារោមេ ភិក្ខវេ អរិយវោហារា ។ កតមេ ចត្តារោ ។ អទិដ្ឋេ អទិដ្ឋវាទិតា អស្សុតេ អស្សុតវាទិតា អមុតេ អមុតវាទិតា អវិញ្ញាតេ អវិញ្ញាតវាទិតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អរិយវោហារាតិ ។

បណ្ណាសកាសង្គហិត អាបត្តិភយវគ្គ ទី ៥

[៩៩] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ រមែងមានឧបការៈច្រើនដល់មនុស្ស ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺការសេពគប់សប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការយកចិត្តទុកដាក់ដោយឧបាយ ១ ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយនេះធម៌ ៤ ប្រការ រមែងមានឧបការៈច្រើនដល់មនុស្ស ។

[១០០] ម្នាលភិក្ខុទាំងឡាយ វោហារមិនប្រសើរនេះមាន ៤ យ៉ាង ។ វោហារមិនប្រសើរ ៤ គឺអ្វីខ្លះ ។ គឺមិនឃើញ ពោលថាឃើញ ១ មិនឮ ពោលថាឮ ១ មិនធុំក្លិន ពោលថាធុំក្លិន ១ មិនដឹង ពោលថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះវោហារមិនប្រសើរ ៤ យ៉ាង ។

[១០១] ម្នាលភិក្ខុទាំងឡាយ វោហារប្រសើរនេះមាន ៤ យ៉ាង ។ វោហារប្រសើរ ៤ គឺអ្វីខ្លះ ។ គឺមិនឃើញ ពោលថាមិនឃើញ ១ មិនឮ ពោលថាមិនឮ ១ មិនធុំក្លិន ពោលថាមិនធុំក្លិន ១ មិនដឹង ពោលថាមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវោហារប្រសើរ ៤ យ៉ាង ។

[១០២] ចត្តារោមេ ភិក្ខវេ អនរិយវោហារា ។ កតមេ ចត្តារោ ។ ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អសុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញាតវា-
ទិតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អនរិយវោហារាតិ ។

[១០៣] ចត្តារោមេ ភិក្ខវេ អរិយវោហារា ។ កតមេ ចត្តារោ ។ ទិដ្ឋេ ទិដ្ឋវាទិតា សុតេ សុតវាទិតា មុតេ មុតវាទិតា វិញ្ញាតេ វិញ្ញាតវាទិតា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ អរិយវោហារាតិ ។

អាបត្តិភយវគ្គោ បញ្ចមោ ។

# តស្សុទ្ទានំ

ភេទអាបត្តិ សិក្ខានិសំសោ
សេយ្យា ថូបារហេន ច
បញ្ញាវុឌ្ឍិ ពហុការា ចត្តារោ
វោហារា ឧភយេន វគ្គោតិ ។

[១០២] ម្នាលភិក្ខុទាំងឡាយ វោហារមិនប្រសើរនេះមាន ៤ យ៉ាង ។ វោហារមិនប្រសើរ ៤ គឺអ្វីខ្លះ ។ គឺឃើញ ពោលថាមិនឃើញ ១ ឮ ពោលថាមិនឮ ១ ធុំក្លិន[១] ពោលថាមិនធុំក្លិន ១ ដឹង ពោលថាមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវោហារមិនប្រសើរ ៤ យ៉ាង ។

[១០៣] ម្នាលភិក្ខុទាំងឡាយ វោហារប្រសើរនេះមាន ៤ យ៉ាង ។ វោហារប្រសើរ ៤ គឺអ្វីខ្លះ ។ គឺឃើញ ពោលថាឃើញ ១ ឮ ពោលថា ឮ ១ ធុំក្លិន ពោលថាធុំក្លិន ១ ដឹង ពោលថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាវោហារប្រសើរ ៤ យ៉ាង ។

ចប់ អាបត្តិភយវគ្គ ទី ៥ ។

# ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីភិក្ខុទម្លាយសង្ឃ ៤ យ៉ាង អំពីភ័យ កើតអំពីអាបត្តិ ៤ យ៉ាង អំពីអានិសង្សនៃព្រហ្មចរិយៈ ៤ យ៉ាង មានសិក្ខា ជាអានិសង្សជាដើមអំពីដំណេក ៤ យ៉ាង អំពីថូបារហបុគ្គល ៤ ពួក អំពីហេតុចម្រើនបញ្ញា ៤យ៉ាង អំពីធម៌មានឧបការៈច្រើនដល់មនុស្ស ៤ យ៉ាង អំពីវោហារ ៤ យ៉ាងទាំង ២ ចំណែក ។

១ ធុំក្លិន ក្រេបជញ្ជក់រសពាល់ត្រូវនូវផោដ្ឋព្វៈ ។

# អភិញ្ញាវគ្គោ ឆដ្ឋោ

[១០៤] ចត្តារោមេ ភិក្ខវេ ធម្មា ។ កតមេ ចត្តារោ ។ អត្ថិ ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា អត្ថិ ភិក្ខវេ ធម្មា អភិញ្ញា បហាតព្វា អត្ថិ ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្វា អត្ថិ ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្វា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។ បញ្ចុបាទានក្ខន្ធា ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បហាតព្វា ។ អវិជ្ជា ច ភវតណ្ហា ច ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា អភិញ្ញា បហាតព្វា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្វា ។ សមថោ ច វិបស្សនា ច ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្វា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្វា ។ វិជ្ជា ច វិមុត្តិ ច ឥមេ វុច្ចន្តិ ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្វា ។ ឥមេ ខោ ភិក្ខវេ ចត្តារោ ធម្មាតិ ។

# អភិញ្ញាវគ្គ ទី ៦

[១០៤] ម្នាលភិក្ខុទាំងឡាយ ធម៌នេះមាន ៤ យ៉ាង ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌គួរកំណត់ដឹង ដោយបញ្ញា ក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរលះបង់ ដោយបញ្ញា ក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរចម្រើន ដោយបញ្ញា ក៏មាន ម្នាលភិក្ខុទាំងឡាយ ធម៌គួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរកំណត់ដឹង ដោយបញ្ញា តើដូចម្តេច ។ គឺឧបាទានក្ខន្ធទាំង ៥ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរកំណត់ដឹង ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរលះបង់ ដោយបញ្ញា តើដូចម្តេច ។ គឺអវិជ្ជានិងភវតណ្ហា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរលះបង់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរចម្រើន ដោយបញ្ញា តើដូចម្តេច ។ គឺសមថៈនិងវិបស្សនា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរចម្រើន ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌គួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា តើដូចម្តេច ។ គឺវិជ្ជានិងវិមុត្តិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌គួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៤ យ៉ាង ។

[១០៥] ចតស្សោ ឥមា ភិក្ខវេ អនរិយបរិយេសនា ។ កតមា ចតស្សោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ជរាធម្មោ សមានោ ជរាធម្មំយេវ បរិយេសតិ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មំយេវ បរិយេសតិ អត្តនា មរណធម្មោ សមានោ មរណធម្មំយេវ បរិយេសតិ អត្តនា សង្កិលេសិកធម្មោ សមានោ សង្កិលេសិ-កធម្មំយេវ បរិយេសតិ ។ ឥមា ខោ ភិក្ខវេ ចតស្សោ អនរិយបរិយេសនា ។ ចតស្សោ ឥមា ភិក្ខវេ អរិយបរិយេសនា ។ កតមា ចតស្សោ ។ ឥធ ភិក្ខវេ ឯកច្ចោ អត្តនា ជរាធម្មោ សមានោ ជរាធម្មេ អាទីនវំ វិទិត្វា អជរំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា ព្យាធិធម្មោ សមានោ ព្យាធិធម្មេ អាទីនវំ វិទិត្វា អព្យាធឹ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ អត្តនា មរណធម្មោ សមានោ មរណធម្មេ អាទីនវំ វិទិត្វា អមតំ អនុត្តរំ យោ-គក្ខេមំ និព្វានំ បរិយេសតិ អត្តនា សង្កិលេសិក-ធម្មោ សមានោ សង្កិលេសិកធម្មេ អាទីនវំ វិទិត្វា

[១០៩] ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមិនប្រសើរ នេះមាន ៤ យ៉ាង ។ ការស្វែងរកមិនប្រសើរ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ខ្លួនឯងជាអ្នកមានជរាជាធម្មតា ក៏ស្វែងរកជរាធម៌ថែមទៀត ខ្លួនឯងជាអ្នកមានព្យាធិជាធម្មតា ក៏ស្វែងរកព្យាធិធម៌ថែមទៀត ខ្លួនឯងជាអ្នកមានមរណៈជាធម្មតា ក៏ស្វែងរកមរណធម៌ថែមទៀត ខ្លួនឯងជាអ្នកមានសេចក្តីសៅហ្មងជាធម្មតា ក៏ស្វែងរកសេចក្តីសៅហ្មងថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះជាការស្វែងរកមិនប្រសើរ ៤ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកប្រសើរមាន ៤ យ៉ាង ។ ការស្វែងរកប្រសើរ ៤ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ខ្លួនឯងជាអ្នកមានជរាជាធម្មតា ដឹងច្បាស់នូវទោសក្នុងជរាធម៌ ក៏ស្វែងរកនូវធម៌មិនជរាដ៏ក្សេមចាកយោគៈដ៏ប្រសើរគឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានព្យាធិជាធម្មតា ដឹងច្បាស់នូវទោសក្នុងព្យាធិធម៌ ក៏ស្វែងរកធម៌មិនមានព្យាធិក្សេមចាកយោគៈ ដ៏ប្រសើរគឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានមរណៈជាធម្មតា ដឹងច្បាស់នូវទោសក្នុងមរណធម៌ ក៏ស្វែងរកធម៌មិនស្លាប់ ក្សេមចាកយោគៈ ដ៏ប្រសើរគឺព្រះនិព្វាន ខ្លួនឯងជាអ្នកមានសេចក្តីសៅហ្មងជាធម្មតា ដឹងច្បាស់នូវទោសក្នុងសេចក្តីសៅហ្មង

អសង្កិលិដ្ឋំ អនុត្តរំ យោគក្ខេមំ និព្វានំ បរិយេសតិ ។ ឥមា ខោ ភិក្ខវេ ចតស្សោ អរិយបរិយេសនាតិ ។

[១០៦] ចត្តារិមានិ ភិក្ខវេ សង្គហវត្ថូនិ ។ កតមានិ ចត្តារិ ។ ទានំ បេយ្យវជ្ជំ អត្ថចរិយា សមានត្តតា ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ សង្គហវត្ថូនីតិ ។

[១០៧] អថខោ អាយស្មា មាលុង្ក្យបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មាលុង្ក្យបុត្តោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ ឯត្ថទានិ មាលុង្ក្យបុត្ត កឹ ទហរេ[១] វក្ខាម យត្រ ហិ នាម ត្វំ ជិណ្ណោ វុឌ្ឍោ មហល្លកោ តថាគតស្ស សង្ខិត្តេន ឱវាទំ យាចសីតិ ។

---

១ ឱ. កឹ ទហរេ ភិក្ខូ ។ ម. កឹ នុ ទហរេ ភិក្ខូ ។

ក៏ស្វែងរកធម៌មិនសៅហ្មង ក្សេមចាកយោគៈ ដ៏ប្រសើរគឺព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ នេះការស្វែងរកដ៏ប្រសើរ ៤ យ៉ាង ។

[១០៦] ម្នាលភិក្ខុទាំងឡាយ សង្គហវត្ថុ (វត្ថុជាគ្រឿងសង្គ្រោះ) នេះមាន ៤ យ៉ាង ។ សង្គហវត្ថុ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺការឲ្យ ១ ការពោលពាក្យពីរោះ ១ ការប្រព្រឹត្តជាប្រយោជន៍ ១ ភាពជាអ្នកទុកដាក់ខ្លួនស្មើ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសង្គហវត្ថុ ៤ យ៉ាង ។

[១០៧] គ្រានោះ ព្រះមាលុង្ក្យបុត្រមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះមាលុង្ក្យបុត្រមានអាយុអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ជាធម៌ដែលនាំខ្ញុំព្រះអង្គឲ្យចៀសចេញទៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ព្រោះស្តាប់នូវធម៌របស់ព្រះដ៏មានព្រះភាគ ។ ម្នាលមាលុង្ក្យបុត្រ ក្នុងដំណើរនេះ តថាគតនឹងនិយាយប្រាប់ភិក្ខុកំឡោះ ដូចម្តេចបាន បើខ្លួនអ្នកជាមនុស្សចាស់គ្រាំគ្រាមានវ័យចម្រើន មកសុំនូវឱវាទ ដោយសង្ខេបចំពោះតថាគតដូច្នេះ ។

ទេសេតុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ សុគតោ សង្ខិត្តេន ធម្មំ អប្បេវនាមាហំ ភគវតោ ភាសិតស្ស អត្ថំ ជានេយ្យំ អប្បេវនាមាហំ ភគវតោ ភាសិតស្ស ទាយាទោ អស្សន្តិ ។ ចត្តារោមេ មាលុង្ក្យបុត្ត តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ កតមេ ចត្តារោ ។ ចីវរហេតុ វា មាលុង្ក្យបុត្ត ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ បិណ្ឌបាតហេតុ វា មាលុង្ក្យបុត្ត ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ សេនាសនហេតុ វា មាលុង្ក្យបុត្ត ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឥតិភវាភវហេតុ វា មាលុង្ក្យបុត្ត ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ ឥមេ ខោ មាលុង្ក្យបុត្ត ចត្តារោ តណ្ហុប្បាទា យត្ថ ភិក្ខុនោ តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ។ យតោ ខោ មាលុង្ក្យបុត្ត ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ។

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ធ្វើម្តេចហ្ន៎ ខ្ញុំព្រះអង្គគប្បីដឹងសេចក្តីនៃភាសិតរបស់ព្រះមានព្រះភាគបាន ធ្វើម្តេចហ្ន៎ ខ្ញុំព្រះអង្គគប្បីបានទទួលមត៌កនៃភាសិតរបស់ព្រះដ៏មានព្រះភាគបាន ។ ម្នាលមាលុង្ក្យបុត្រ តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើង ក្នុងវត្ថុណា ការកើតនៃតណ្ហា (ក្នុងវត្ថុនោះ) មាន ៤ ប្រការ ។ តណ្ហា ៤ ប្រការ ដូចម្តេចខ្លះ ។ ម្នាលមាលុង្ក្យបុត្រ តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងព្រោះហេតុចីវរ ១ ម្នាលមាលុង្ក្យបុត្រ តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងព្រោះហេតុបិណ្ឌបាត ១ ម្នាលមាលុង្ក្យបុត្រ តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើងព្រោះហេតុសេនាសនៈ ១ ម្នាលមាលុង្ក្យបុត្រ តណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើង ព្រោះហេតុភពតូចនិងភពធំដូច្នេះ ១ ។ ម្នាលមាលុង្ក្យបុត្រ នេះជាតណ្ហារបស់ភិក្ខុ កាលកើតឡើង រមែងកើតឡើង ក្នុងវត្ថុណា ការកើតនៃតណ្ហា (ក្នុងវត្ថុនោះ) មាន ៤ យ៉ាង ។ ម្នាលមាលុង្ក្យបុត្រ កាលតណ្ហាដែលភិក្ខុបានលះបង់ បានផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាទីកើតនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា ។

អយំ វុច្ចតិ មាលុង្ក្យបុត្ត ភិក្ខុ អច្ឆេជ្ជិ តណ្ហំ វិវដ្តយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។ អថខោ អាយស្មា មាលុង្ក្យបុត្តោ ភគវតា ឥមិនា ឱវាទេន ឱវទិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា មាលុង្ក្យបុត្តោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អភិញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា មាលុង្ក្យបុត្តោ អរហតំ អហោសីតិ ។

ម្នាលមាលុង្ក្យបុត្រ ភិក្ខុនេះហៅថា បានផ្ដាច់តណ្ហា បានរលាស់ចោលសញ្ញោជនៈ ធ្វើនូវទីបំផុតទុក្ខបាន ព្រោះលះមានៈបានដោយប្រពៃ ។ លំដាប់នោះ មាលុង្ក្យបុត្រមានអាយុ បានទទួលពុទ្ធឱវាទនេះហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចចេញទៅ ។ តមក មាលុង្ក្យបុត្រមានអាយុ តែម្នាក់ឯងចេញចាកពួក មិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងកម្ចាត់បង់កិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្រចេញចាកផ្ទះចូលកាន់ផ្នួស ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ មានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចបានធ្វើស្រេចហើយ កិច្ចដទៃដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ មាលុង្ក្យបុត្រមានអាយុ បានជាព្រះអរហន្តមួយអង្គដែរ ។

[១០៨] យានិ កានិចិ ភិក្ខវេ កុលានិ ភោគេសុ មហត្តំ បត្តានិ ន ចិរដ្ឋិតិកានិ ភវន្តិ សព្វានិ តានិ ចតូហិ ឋានេហិ ឯតេសំ វា អញ្ញតរេន ។ កតមេហិ ចតូហិ ។ នដ្ឋំ ន គវេសន្តិ ជិណ្ណំ ន បដិសង្ខរោន្តិ អបរិមិតបានភោជនា ហោន្តិ ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ ។ យានិ កានិចិ ភិក្ខវេ កុលានិ ភោគេសុ មហត្តំ បត្តានិ ន ចិរដ្ឋិតិកានិ ភវន្តិ សព្វានិ តានិ ឥមេហិ ចតូហិ ឋានេហិ ឯតេសំ វា អញ្ញតរេន ។ យានិ កានិចិ ភិក្ខវេ កុលានិ ភោគេសុ មហត្តំ បត្តានិ ចិរដ្ឋិតិកានិ ភវន្តិ សព្វានិ តានិ ចតូហិ ឋានេហិ ឯតេសំ វា អញ្ញតរេន ។ កតមេហិ ចតូហិ ។ នដ្ឋំ គវេសន្តិ ជិណ្ណំ បដិសង្ខរោន្តិ បរិមិតបាន-ភោជនា[១] ហោន្តិ សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ ។ យានិ កានិចិ ភិក្ខវេ កុលានិ

១ ឱ. ម. ឯត្ថន្តរេ បាតិ អត្ថិ ។

[១០៨] ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណាមួយ ដល់នូវភាពស្តុកស្តម្ភ ក្នុងភោគៈទាំងឡាយហើយ មិនឋិតថេរៈនៅបានយូរ ត្រកូលទាំងអស់នោះ សាបសូន្យព្រោះហេតុ ៤ ប្រការ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ហេតុ ៤ ប្រការ គឺអ្វីខ្លះ ។ គឺមិនស្វែងរករបស់ដែលបាត់ទៅ ១ មិនជួសជុលរបស់ដែលចាស់គ្រាំគ្រា ១ មានការផឹកនិងការបរិភោគមិនដឹងប្រមាណ ១ តាំងស្ត្រី ឬ បុរសទ្រុស្តសីលឲ្យជាអធិបតី ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ ដល់នូវភាពស្តុកស្តម្ភ ក្នុងភោគៈទាំងឡាយ ហើយមិនឋិតថេរនៅបានយូរ ត្រកូលទាំងអស់នោះ សាបសូន្យព្រោះហេតុ ៤ ប្រការនេះ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ ដល់នូវភាពស្តុកស្តម្ភ ក្នុងភោគៈទាំងឡាយ ហើយឋិតថេរនៅបានយូរ ត្រកូលទាំងអស់នោះ ចម្រើនព្រោះហេតុ ៤ ប្រការ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។ ហេតុ ៤ ប្រការ គឺអ្វីខ្លះ ។ គឺស្វែងរករបស់ដែលបាត់ទៅ ១ ជួសជុលរបស់ដែលចាស់គ្រាំគ្រា ១ មានការផឹកនិងការបរិភោគដឹងប្រមាណ ១ តាំងស្ត្រី ឬ បុរសមានសីលឲ្យជាអធិបតី ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលណាមួយ

ភោគេសុ មហត្តំ បត្តានិ ចិរដ្ឋិតិកានិ ភវន្តិ សព្វានិ តានិ ឥមេហិ ចតូហិ ឋានេហិ ឯតេសំ វា អញ្ញតរេនាតិ ។

[១០៩] ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។

ដល់នូវភាពស្កុកស្គម្ភ ក្នុងភោគៈទាំងឡាយ ហើយឋិតថេរនៅបានយូរ ត្រកូលទាំងអស់នោះ ចម្រើនព្រោះហេតុ ៤ ប្រការនេះ ឬក៏បណ្តាហេតុទាំងនោះ ហេតុណាមួយ ។

[១០៩] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គ ៤ គួរដល់ព្រះរាជា ជារាជភោគ្គៈរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ អង្គ ៤ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អស្សាជានីយៈដ៏ប្រសើរ របស់ព្រះរាជា ក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកំពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ អស្សាជានីយដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គ ៤ នេះ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលវត្ថុដែលគេបង្អោនចូលមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៤ ប្រការ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកំពស់និងទំហំ ១ ។

កតមញ្ច ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ កតមញ្ច ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហ-បរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ កតមញ្ច ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ កតមញ្ច ភិក្ខវេ ភិក្ខុ អារោហបរិណាហសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ លាភី ហោតិ ចីវរ-បិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ឲ្យកុសលធម៌ទាំងឡាយកើតឡើង ខំព្យាយាមខ្នះខ្នែង មិនលះបង់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបរិបូណ៌ដោយកំពស់និងទំហំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្វាក់លាភចំពោះចីវរ-បិណ្ឌបាតសេនាសនៈនិងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកមានជំងឺ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ អារោហបរិណាហសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១១០] ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខ្យំ គច្ឆតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ វណ្ណ-សម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សា-ជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកំពស់និងទំហំយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

[១១០] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជាប្រកបដោយអង្គ ៤ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ។ អង្គ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ក្នុងលោកនេះ បរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកំពស់និងទំហំ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ព្រះរាជា ប្រកបដោយអង្គទាំង ៤ នេះ ទើបគួរដល់ព្រះរាជា ជារាជភោគ្គៈ រាប់ថាជាអង្គរបស់ព្រះរាជាបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុដ៏ប្រកបដោយធម៌ ៤ ប្រការក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៤ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយល្បឿន ១ បរិបូណ៌ដោយកំពស់និងទំហំ ១ ។

កថញ្ច ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវិរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អារោហបរិណាហសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ លាភី ហោតិ ចីវរបិណ្ឌ-ចាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ឲ្យកុសលធម៌ទាំងឡាយ កើតឡើង ជាអ្នកខំព្យាយាម ខ្នះខ្នែង មិនលះបង់ធុរៈ ក្នុងកុសលទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយល្បឿន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកបរិបូណ៌ដោយកំពស់និងទំហំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ទាក់លាភចំពោះចីវរបិណ្ឌបាតសេនាសនៈនិងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកមានជំងឺ ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ អាហោហាបរិណាហាសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១១១] ចត្តារីមានិ ភិក្ខវេ ពលានិ ។ កតមានិ ចត្តារិ ។ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញា-ពលំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ពលានីតិ ។

[១១២] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ នាលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ ។ កតមេហិ ចតូហិ ។ កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេន ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នាលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុំ ។ កតមេហិ ចតូហិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកំពស់និងទំហំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ ទើបជាអ្នកទទួលនូវទានដែលបុគ្គលនាំមកបូជា ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើរនៃសត្វលោក ។

[១១១] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៤ យ៉ាង ។ កម្លាំង ៤ យ៉ាង គឺអ្វីខ្លះ ។ កម្លាំងគឺវីរិយៈ ១ កម្លាំងគឺសតិ ១ កម្លាំងគឺសមាធិ ១ កម្លាំងគឺបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះកម្លាំង ៤ យ៉ាង ។

[១១២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ មិនគួរសេព សេនាសនៈ ដ៏ស្ងាត់គឺព្រៃតូចព្រៃធំបាន ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។ គឺភិក្ខុប្រកបដោយកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ជាអ្នកអប្បឥតប្រាជ្ញា លលា ឆ្កួតទឹកមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ មិនគួរសេព សេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ទើបគួរសេពសេនាសនៈស្ងាត់ គឺព្រៃតូចព្រៃធំបាន ។ ធម៌ ៤ ប្រការ គឺអ្វីខ្លះ ។

នេក្ខម្មវិតក្កេន អព្យាបាទវិតក្កេន អវិហឹសាវិតក្កេន បញ្ញវា ហោតិ អជឡោ អនេឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវិតុន្តិ ។

[១១៣] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ ចតូហិ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចីកម្មេន សាវជ្ជេន មនោកម្មេន សាវជ្ជាយ ទិដ្ឋិយា ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ

គឺភិក្ខុប្រកបដោយនេក្ខម្មវិតក្កៈ ១ អព្យាបាទវិតក្កៈ ១ អវិហឹសាវិតក្កៈ ១ អ្នកមានប្រាជ្ញា មិនលលា មិនច្លួតទឹកមាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ទើបគួរសេពសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំបាន ។

[១១៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ ជាមនុស្សពាល មិនឈ្លាស ជាអសប្បុរស រមែងបរិហារខ្លួន ដូចដើមឈើដែលគាស់ឫសចោល ផ្ទាប់ពាក់កណ្តាល ជាអ្នកប្រកបដោយទោសផង ដែលពួកវិញ្ញូជនតិះដៀលផង រមែងបាននូវរបស់មិនជាបុណ្យដ៏ច្រើនផង ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ទិដ្ឋិប្រកបដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៤ យ៉ាងនេះ ជាមនុស្សពាលមិនឈ្លាស ជាអសប្បុរស រមែងបរិហារខ្លួនដូចជាដើមឈើដែលគាស់ឫសចោល ផ្ទាប់ពាក់កណ្តាល ជាអ្នកប្រកបដោយទោសផង ដែលពួកវិញ្ញូជនតិះដៀលផង បាននូវរបស់មិនមែនជាបុណ្យដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាង ជាបណ្ឌិត ជាអ្នកឈ្លាសវៃ ជាសប្បុរស រមែងបរិហារខ្លួនដូចដើមឈើដែលមិនបានគាស់ឫសចោល មិនផ្ទាប់ពាក់កណ្តាល ជាអ្នកមិនមានទោសផង

អនន្ធុវត្ថោ  វិញ្ញូនំ  ពហុញ្ច  បុញ្ញំ  បសវតិ  ។  កាតមេហិ ចតូហិ  ។  អនវជ្ជេន  កាយកម្មេន  អនវជ្ជេន  វចីកម្មេន  អនវជ្ជេន  មនោកម្មេន  អនវជ្ជាយ  ទិដ្ឋិយា  ។  ឥមេហិ  ខោ  ភិក្ខវេ  ចតូហិ  ធម្មេហិ  សមន្នាគតោ  បណ្ឌិតោ  ព្យត្តោ  សប្បុរិសោ  អក្ខតំ  អនុបហតំ  អត្តានំ  បរិហរតិ  អនវជ្ជោ  ច  ហោតិ  អនន្ធុវត្ថោ  វិញ្ញូនំ  ពហុញ្ច  បុញ្ញំ  បសវតីតិ  ។

អភិញ្ញាវគ្គោ  ឆដ្ឋោ  ។

## តស្សុទ្ទានំ

អភិញ្ញា  បរិយេសនា
សង្គហោ  មាលុង្ក្យបុត្តោ
អដ្ឋកុលំ  ទ្វេ  អាជញ្ញ-
ពលំ  អរញ្ញកម្មុនាតិ  ។

ដែលពួកវិញ្ញូជនមិនតិះដៀលផង   រមែងបានទូវបុណ្យដ៏ច្រើនផង   ។ ធម៌ ៤ យ៉ាង គឺអ្វីខ្លះ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ទិដ្ឋិមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ យ៉ាងនេះ ជាបណ្ឌិត ជាអ្នកឈ្លាស ជាសប្បុរស រមែងបរិហារខ្លួន ដូចដើមឈើដែលមិនបានគាស់ឫស មិនផាប់ពាក់កណ្ដាល ជាអ្នកមិនមានទោសផង ដែលពួកវិញ្ញូជនមិនតិះដៀលផង   រមែងបានបុណ្យដ៏ច្រើនផង   ។

ចប់  អភិញ្ញាវគ្គ   ទី  ៦  ។

# ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីអភិញ្ញាធម៌ ៤ ប្រការ អំពីការស្វែងរក ៤ ប្រការ អំពីសង្គហៈ ៤ ប្រការ អំពីមាលុង្ក្យបុត្រ អំពីត្រកូលស្ដុកស្ដម្ភនិងមិនស្ដុកស្ដម្ភដោយហេតុ ៤ ប្រការ ២ រឿង អំពីសេះអាជានេយ្យ ប្រកបដោយអង្គ ៤ ជាសេះគួរដល់ព្រះរាជា អំពីពលៈ ៤ ប្រការ អំពីភិក្ខុមិនគួរនៅនឹងគួរនៅក្នុងសេនាសនៈព្រៃបាន និងអំពីកម្មដែលឥតទោសនិងមានទោស ។

# កម្មបថវគ្គោ សត្តមោ

[១១៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ អត្តនា ច បាណាតិបាតី ហោតិ បរញ្ច បាណាតិបាតេ សមាទបេតិ បាណាតិបាតេ ច សមនុញ្ញោ ហោតិ បាណាតិបាតស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ចតូហិ ។ អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ បរញ្ច បាណា-តិបាតា វេរមណិយា សមាទបេតិ បាណាតិបាតា វេរមណិយា ច សមនុញ្ញោ ហោតិ បាណាតិបាតា វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

# កម្មបថវគ្គ ទី ៧

[១១៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺបុគ្គលដែលសម្លាប់សត្វ ដោយខ្លួនឯង ១ ដឹកនាំអ្នកដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ពោលសរសើរការសម្លាប់សត្វ[១] ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺបុគ្គលវៀរចាកការសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំអ្នកដទៃ ក្នុងការវៀរចាកការសម្លាប់សត្វ ១ ពេញចិត្ត ក្នុងការវៀរចាកការសម្លាប់សត្វ ១ ពោលសរសើរការវៀរចាកការសម្លាប់សត្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការនេះ រមែងកើតក្នុងឋានសួគ៌ ដូចគេនាំយកទៅដាក់ ។

---

១ ការរាប់ ៤ៗ នោះឲ្យរាប់ក្នុងមួយបទៗ គឺក្នុងមួយបទៗ ចែកការធ្វើជា ៤ គឺធ្វើខ្លួនឯង ដឹកនាំអ្នកដទៃ ពេញចិត្ត និយាយសរសើរ ។

[១១៥] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ចតូហិ ។ អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អភិជ្ឈាយ ច សមនុញ្ញោ ហោតិ អភិជ្ឈាយ ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ វេរមណិយា សមាទបេតិ អភិជ្ឈាយ វេរមណិយា ច សមនុញ្ញោ ហោតិ អភិជ្ឈាយ វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១១៦] អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ កាមេសុ មិច្ឆាចារេ ច សមនុញ្ញោ ហោតិ កាមេសុ មិច្ឆាចារស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

បណ្ណាសកាសង្គហិត កម្មបថវគ្គ ទី ៧

[១១៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ គឺបុគ្គលជាអ្នកកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃ ក្នុងការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ ពេញចិត្ត ក្នុងការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ ពោលសរសើរការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ ។ អម្បាលនេះ ។ បេ ។ គឺបុគ្គលជាអ្នកវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ដោយខ្លួនឯង ដឹកនាំអ្នកដទៃ ក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ពេញចិត្ត ក្នុងការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ពោលសរសើរការវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ អម្បាលនេះ ។ បេ ។

[១១៦] ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងកាមេសុមិច្ឆាចារ ពេញចិត្ត ក្នុងកាមេសុមិច្ឆាចារ ពោលសរសើរកាមេសុមិច្ឆាចារ ។ អម្បាលនេះ ។ បេ ។

អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ កាមេសុ មិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ កាមេសុ មិច្ឆាចារា វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១១៧] អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសាវាទេ សមាទបេតិ មុសាវាទេ ច សមនុញ្ញោ ហោតិ មុសាវាទស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១១៨] អត្តនា ច បិសុណាវាចោ ហោតិ បរញ្ច បិសុណាយ វាចាយ សមាទបេតិ បិសុណាយ វាចាយ សមនុញ្ញោ ហោតិ បិសុណាយ វាចាយ ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ

ជាអ្នកវៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ពេញចិត្ត ក្នុងការវៀរចាកកាមេសុមិច្ឆាចារ ពោលសរសើរការវៀរចាកកាមេសុមិច្ឆាចារ ។ អម្បាលនេះ ។ បេ ។

[១១៧] ជាអ្នកនិយាយកុហក ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងមុសាវាទ ពេញចិត្ត ក្នុងមុសាវាទ ពោលសរសើរមុសាវាទ ។ អម្បាលនេះ ។ បេ ។ ជាអ្នកវៀរចាកមុសាវាទ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកមុសាវាទ ពេញចិត្ត ក្នុងការវៀរចាកមុសាវាទ ពោលសរសើរការវៀរចាកមុសាវាទ ។ អម្បាលនេះ ។ បេ ។

[១១៨] ជាអ្នកពោលពាក្យញុះញង់ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងបិសុណាវាចា ពេញចិត្ត ក្នុងបិសុណាវាចា ពោលសរសើរបិសុណា-វាចា ។ អម្បាលនេះ ។ បេ ។ ជាអ្នកវៀរចាកបិសុណាវាចា ដោយខ្លួនឯង

បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ បិសុណាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ បិសុណាយ វាចាយ វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១១៩] អត្តនា ច ផរុសវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមាទបេតិ ផរុសាយ វាចាយ ច សមនុញ្ញោ ហោតិ ផរុសាយ វាចាយ ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ ផរុសាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ ផរុសាយ វាចាយ វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១២០] អត្តនា ច សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមាទបេតិ សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ សម្ផប្បលាបស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ

ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកបិសុណាវាចា ពេញចិត្ត ក្នុងការវៀរចាកបិសុណាវាចា ពោលសរសើរការវៀរចាកបិសុណាវាចា ។ អម្បាលនេះ ។ បេ ។

[១១៩] ជាអ្នកនិយាយពាក្យអាក្រក់ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងផរុសវាចា ពេញចិត្ត ក្នុងផរុសវាចា ពោលសរសើរផរុសវាចា ។ អម្បាលនេះ ។ បេ ។ ជាអ្នកវៀរចាកផរុសវាចា ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកផរុសវាចា ពេញចិត្ត ក្នុងការវៀរចាកផរុសវាចា ពោលសរសើរការវៀរចាកផរុសវាចា ។ អម្បាលនេះ ។ បេ ។

[១២០] ជាអ្នកពោលពាក្យឥតប្រយោជន៍ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងសម្ផប្បលាបៈ ពេញចិត្ត ក្នុងសម្ផប្បលាបៈ ពោលសរសើរសម្ផប្បលាបៈ ។ អម្បាលនេះ ។ បេ ។ ជាអ្នកវៀរចាកសម្ផប្បលាបៈ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកសម្ផប្បលាបៈ

សម្ផប្បលាបា វេរមណិយា ច សមាទបេតិ ។ សម្ផប្បលាបា វេរមណិយា ច សមនុញ្ញោ ហោតិ សម្ផប្បលាបា វេរមណិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១២១] អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អភិជ្ឈាយ ច សមនុញ្ញោ ហោតិ អភិជ្ឈាយ ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច អនភិជ្ឈាលុ ហោតិ បរញ្ច អនភិជ្ឈាយ សមាទបេតិ អនភិជ្ឈាយ ច សមនុញ្ញោ ហោតិ អនភិជ្ឈាយ ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

ពេញចិត្ត ក្នុងការវៀរចាកសម្ផប្បលាបៈ ពោលសរសើរការវៀរចាក សម្ផប្បលាបៈ ។ អម្បាលនេះ ។ បេ ។

[១២១] ជាអ្នកមានចិត្តសំឡឹងរំពៃទ្រព្យអ្នកដទៃ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងអភិជ្ឈា ពេញចិត្ត ក្នុងអភិជ្ឈា ពោលសរសើរ អភិជ្ឈា ។ អម្បាលនេះ ។ បេ ។ ជាអ្នកមានចិត្តមិនរំពៃ (ទ្រព្យអ្នកដទៃ) ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងអនភិជ្ឈា ពេញចិត្ត ក្នុងអនភិជ្ឈា ពោលសរសើរអនភិជ្ឈា ។ អម្បាលនេះ ។ បេ ។

[១២២] អត្តនា ច ព្យាបន្នចិត្តោ ហោតិ បរញ្ច ព្យាបាទេ សមាទបេតិ ព្យាបាទេ ច សមនុញ្ញោ ហោតិ ព្យាបាទស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច អព្យាបន្នចិត្តោ ហោតិ បរញ្ច អព្យាបាទេ សមាទបេតិ អព្យាបាទេ ច សមនុញ្ញោ ហោតិ អព្យាបាទស្ស ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។

[១២៣] អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ មិច្ឆាទិដ្ឋិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ។ បេ ។ អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ សម្មាទិដ្ឋិយា ច សមនុញ្ញោ ហោតិ សម្មាទិដ្ឋិយា ច វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

កម្មបថវគ្គោ សត្តមោ ។

[១២២] ជាអ្នកមានចិត្តព្យាបាទ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងព្យាបាទ ពេញចិត្ត ក្នុងព្យាបាទ ពោលសរសើរព្យាបាទ ។ អម្បាលនេះ ។ បេ ។ ជាអ្នកមានចិត្តមិនព្យាបាទ ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងការមិនព្យាបាទ ពេញចិត្ត ក្នុងការមិនព្យាបាទ ពោលសរសើរការមិនព្យាបាទ ។ អម្បាលនេះ ។ បេ ។

[១២៣] ជាអ្នកយល់ខុស ដោយខ្លួនឯង ដឹកនាំបុគ្គលដទៃក្នុងសេចក្តីយល់ខុស ពេញចិត្ត ក្នុងសេចក្តីយល់ខុស ពោលសរសើរសេចក្តីយល់ខុស ។ អម្បាលនេះ ។ បេ ។ ជាអ្នកយល់ត្រូវដោយខ្លួនឯង ដឹកនាំបុគ្គលដទៃ ក្នុងសេចក្តីយល់ត្រូវ ពេញចិត្ត ក្នុងសេចក្តីយល់ត្រូវ ពោលសរសើរសេចក្តីយល់ត្រូវ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៤ នេះ រមែងកើតក្នុងឋានសួគ៌ ដូចគេនាំទៅដាក់ ។

ចប់ កម្មបថវគ្គ ទី ៧ ។

# បណ្ណាសកាសង្គហិតា សុត្តន្តា

[១២៤] រាគស្ស ភិក្ខវេ អភិញ្ញាយ ចត្តារោ ធម្មា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ... ចិត្តេសុ... ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ចត្តារោ ធម្មា ភាវេតព្វាតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ចត្តារោ ធម្មា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ... អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ . . .

# ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក

[១២៤] ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណារឿយៗ នូវកាយក្នុងកាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងល្អ មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ពិចារណារឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ... ពិចារណារឿយៗ នូវចិត្តក្នុងចិត្តទាំងឡាយ... ពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងល្អ មានស្មារតី កម្ចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ដើម្បីលះបង់អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ... ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ឲ្យកើតឡើង...

ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ចត្តារោ ធម្មា ភាវេតព្វាតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ចត្តារោ ធម្មា ភាវេតព្វា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមា-ធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិចិត្តសមាធិវីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ចត្តារោ ធម្មា ភាវេតព្វាតិ ។ រាគស្ស ភិក្ខវេ បរិញ្ញាយ ។ បេ ។ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ចត្តារោ ធម្មា ភាវេតព្វា ។

ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីឲ្យកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើងធំទូលាយ ចម្រើនបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៤ ប្រការតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ វិរិយសមាធិ ចិត្តសមាធិ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះ គួរចម្រើន ដើម្បីកំណត់ដឹងនូវរាគៈ ។ បេ ។ ដើម្បីអស់ទៅ ដើម្បីលះបង់ ដើម្បីក្សយទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់ ។

ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ចត្តារោ ធម្មា ភាវេតព្វាតិ ។

ចតុក្កនិបាតោ និដ្ឋិតោ ។

ធម៌ ៤ ប្រការនេះ គួរចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះបង់ ដើម្បីក្ស័យទៅ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរលត់ ដើម្បីលះបង់ ដើម្បីរលាស់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ (ចងក្រោធទុក) មក្ខៈ (រមិលគុណ) បឡាសៈ (លើកខ្លួនផ្ទឹម) ឥស្សា (ឫស្យា) មច្ឆរិយៈ (កំណាញ់) មាយា (បិទបាំងទោស) សាថេយ្យៈ (អួតអាង) ថម្ភៈ (មុខរឹង) សារម្ភៈ (ប្រណាំងវាស្នា) មានៈ (ប្រកាន់ខ្លួន) អតិមានៈ (មើលងាយគេ) មទៈ (ស្រវឹង) បមាទៈ (ប្រាសចាកសតិ) ។

ចប់ ចតុក្កនិបាត ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស  ចតុក្កនិបាតោ

# ចតុត្ថោ  ភាគោ

# ចតុត្ថបណ្ណាសកោ

## មាតិកា  អង្កេ


| | | |
|---|---|---|
| *ចតុត្ថបណ្ណាសកេ* | *ឥន្ទ្រិយវគ្គោ  បឋមោ* .............................. | *១* |
| | *បដិបទាវគ្គោ  ទុតិយោ*........................... | *១៩* |
| | *សញ្ចេតនិយវគ្គោ  តតិយោ* .................... | *៤១* |
| | *យោធាជីវវគ្គោ  ចតុត្ថោ*......................... | *៧៣* |
| | *មហាវគ្គោ  បញ្ចមោ*............................... | *១០៧* |


## បណ្ណាសកាសង្គហិតា  វគ្គា


| | | |
|---|---|---|
| *បណ្ណាសកាសង្គហិតោ* | *សប្បុរិសវគ្គោ  បឋមោ*........................... | *១៩៨* |
| | *សោភនវគ្គោ  ទុតិយោ*........................... | *២១៧* |
| | *ទុច្ចរិតវគ្គោ  តតិយោ*........................... | *២២៣* |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ចតុក្កនិបាត

# ចតុត្ថភាគ

# ចតុត្ថបណ្ណាសក

## មាតិកា　　　　　　　　　　　　　　លេខទំព័រ


| | | | |
|---|---|---|---|
| *ចតុត្ថបណ្ណាសក* | *ឥន្ទ្រិយវគ្គ ទី ១* | ................................ | *១* |
| | *បដិបទាវគ្គ ទី ២* | ................................ | *១៩* |
| | *សញ្ចេតនិយវគ្គ ទី ៣* | .......................... | *៤១* |
| | *យោធាជីវវគ្គ ទី ៤* | ................................ | *៧៣* |
| | *មហាវគ្គ ទី ៥* | ................................. | *១០៧* |


## បណ្ណាសកាសង្គហិតវគ្គ


| | | | |
|---|---|---|---|
| *បណ្ណាសកាសង្គហិត* | *សប្បុរិសវគ្គ ទី ១* | ................................. | *១៩៨* |
| | *សោភនវគ្គ ទី ២* | ................................. | *២១៧* |
| | *ទុច្ចរិតវគ្គ ទី ៣* | ................................. | *២២៣* |

# មាតិកាបត្តានិ

## មាតិកា អង្កេ


*បណ្ណាសកាសង្គហិតោ កម្មវគ្គោ ចតុត្ថោ* .................................. *២២៩*

*អាបត្តិភយវគ្គោ បញ្ចមោ* ....................... *២៤៩*

*អភិញ្ញាវគ្គោ ឆដ្ឋោ* ................................ *២៦៤*

*កម្មបថវគ្គោ សត្តមោ* ............................ *២៧៨*

*បណ្ណាសកាសង្គហិតា សុត្តន្តា* .................................................... *២៨៤*


---

# សង្ខេបចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


បណ្ណាសកាសង្គហិត កម្មវគ្គ ទី ៤........................................ ២២៩

អាបត្តិភយវគ្គ ទី ៥.............................. ២៤៩

អភិញ្ញាវគ្គ ទី ៦................................. ២៦៤

កម្មបថវគ្គ ទី ៧................................. ២៧៨

ពួកសូត្រដែលមិនសង្គ្រោះដោយបណ្ណាសក................................ ២៨៤

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ
សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក
សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី
សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា
សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ
ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៩៧ ៥១១ ៦៧៨៨
អ៊ីមែល: maha.panna@gmail.com
គេហទំព័រ: http://www.mahapanna.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

# NAME OF SPONSOR
# 助印功德芳名

**Book's Title: KHMER PALI TRIPITAKA VOL.43 ~ VOL.56**
**(SUTTANTA PITAKA)**

**書 名：柬埔寨巴利文大藏經 第四十三冊至第五十六冊（經藏）**

**Book Serial No., 書 號：CA143 ~ CA156**

N.T. Dollars：

**2,000,000：**〔釋心庭、蔡耀裕、蔡慶雲、蔡文裕、李國城、林美惠、朱素心、賴錦瑩、葉明炤、葉王桂花、黃莉庭、黃彩嬉、黃智美、黃寶嬌、黃怡禎、徐淑美、黃婕寧、黃婕米、黃婕棋、黃世熙、碩霖企業有限公司。〕（所有成佛功德法，悉以回向諸群生，願令一切皆清淨，到佛莊嚴之彼岸。）

**40,000：**〔張銀嶽、徐素蓮〕。

**22,800：**道恆法師等三寶弟子。

**20,200：**彌陀佛堂。

**18,200：**道恆法師及石牌彌陀佛堂。

**10,000：**李旭峰。

**7,500：**三寶弟子。

**5,000：**高千惠。

**3,000：**賴榮彬。陳永泰。

**2,800：**張淑美。

**2,600：**往生者楊美伸。

**2,000：**鄭凱文。王嫌。徐源河。〔蔡親仁、蔡孝俊、蔡育娣〕。陳坤煌。魏上傑。

**1,800：**邱曉君。

**1,500：**王安德全家。石美雲。徐孔熾。徐維君。徐維志。

**1,200：**王裕文。

**1,000：**往生者馮俊儒。蔡靜芳。陳碧霞全家。馮志雄。蘇陳梅好全家。李素梅。邱足燕。邱坤遍。邱萬大。洪照榮。馮顯琮。釋映空。徐林阿蕊。張黃月娥。馮詩婷。馮怡蓉。徐纛垚。徐緞。

**900：**林姿君。林泰暉。林泰維。林國忠。徐素謙。

500：[往生者]林桂林。[往生者]徐左村。王韻如。吳美智。林孝銘。張慈燕。梁梨芳。褚瑞國。林敏梅。

300：程明貴。吳振興。黃淑卿。

200：歷代盧氏祖先。歷代徐氏祖先。鄭宇嵩。陳怡蒨。黃氏歷代祖先。法界眾生。吳慶保。歷代張氏祖先。

125：徐玉欣。徐玉杰。郭秋鳳。徐右鎮。

100：釋覺瀚。徐仕賢。林美仙。徐曉帆。蘇聲瑜。林美君。黃兆怡。蕭台重。莊閔如。莊培弘。李俊瑩。莊子德。

378,588：佛陀教育基金會。

**Amount: N.T. Dollars 2,567,388；Print 2,000 sets**

**以上合計：新台幣 2,567,388 元；恭印二千套。**

**Dedication of Merits:**

Wherever the Buddha's teachings have flourished, either in cities or countrysides,
People would gain inconceivable benefits.
The land and people would be enveloped in peace.
The sun and moon will shine clear and bright.
Wind and rain would appear accordingly, and there will be no disasters.
Nations would be prosperous and there would be no use for soldiers or weapons.
People would abide by morality and accord with laws.
They would be courteous and humble, and everyone would be content without injustices.
There would be no thefts or violence.
The strong would not dominate the weak and everyone would get their fair share.

**回向：**天下和順，日月清明，風雨以時，災厲不起，國豐民安，兵戈無用，崇德興仁，務修禮讓，國無盜賊，無有怨枉，強不凌弱，各得其所。法界一切有情，所有六道四生，宿世冤親，現世業債，咸憑法力，悉得解脫。現世者增福延壽，發菩提心，常隨佛學，勤修精進，利濟群生。已故者往生淨土，同出苦輪，共登覺岸，直證阿鞞跋致，圓滿無上菩提。

**附記：**本會接受善信發心印贈經書，其必要之費用，皆經本會審慎評估；若有結餘，均續作本會之印(購)經書及運費使用，為施主廣積陰德。

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.

Homage to Amita Buddha!

**NAMO AMITABHA**
**南無阿彌陀佛**

《東埔寨巴利文大藏經 第四十三冊（經藏）》
〈KHMER PALI TRIPITAKA VOL.43 (SUTTANTA PITAKA)〉


財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website: http://www.budaedu.org


**This book is strictly for free distribution, it is not for sale.**
សម្រាប់ចែកជាធម្មទាន


Printed in Taiwan
2,000 copies; August 2014
CA143 - 12316